ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍៖ វិទ្យាស្ថានស្លឹករឹត
- ទំនាក់ទំនងបដិវត្តន៍ឡាវ-កម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា


លេខ១០៤ ខែសីហា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០៨ ខែសីហា ឆ្នាំ២០០៨

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

### មាតិកា


◆ មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ៖ វិទ្យាស្ថានស្លឹករឹត ....................១

**ផ្នែកឯកសារ**

◆ តើខ្មែរក្រហមទាំងអស់សុទ្ធតែអាក្រក់ឬ? ..........................................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម ....................................៥

◆ លិខិតឆ្លើយតបពីអង្គភាពជនរងគ្រោះ ..........................................១៣

◆ ការពិត ការរៀបរាប់ និងនយោបាយដើម្បីការចងចាំ ........................១៦

◆ ការអភិវឌ្ឍនៅកម្ពុជា ...........................................................២១

◆ ខ្មែរក្រោម និងការកាត់ទោសខ្មែរក្រហម ......................................២៨

**ផ្នែកច្បាប់**

◆ ទីប្រឹក្សាច្បាប់របស់អាល្លឺម៉ង់ខាងកើតចំពោះតុលាការឆ្នាំ១៩៧៩ ..........៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ក្រោយពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ..........................៤១

◆ ទំនាក់ទំនងបដិវត្តន៍ឡាវ-កម្ពុជា ................................................៤៤

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ ការពិតរបស់ខ្ញុំ ...................................................................៥៧




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ : ៥៦៦ អ.ស.ល

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០០៨

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
ជម្រាបជូន
ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**កម្មវត្ថុ :** ករណីស្នើសុំទីតាំងដើម្បីសាងសង់វិទ្យាស្ថានស្រាវជ្រាវអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងដើម្បីសាងសង់ទីស្នាក់ការកណ្ដាលរបស់គណៈវិស្វករកម្ពុជា ។

**យោង :** - លិខិតលេខ ២២/០៨ គស.សវក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨ របស់ស្ថាប័នវិស្វករកម្ពុជា ។
- លិខិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨ ។
- យោងចំណាររបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៨ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍ ជ្រើសយកទីតាំងក្នុងវិទ្យាល័យបឹងត្របែក ផ្នែកខាងក្រោយជាប់និងបណ្ណាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលកំពុងសាងសង់រួច ដើម្បីសាងសង់វិទ្យាស្ថានស្រាវជ្រាវរបស់មជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជា និង ទីស្នាក់ការកណ្ដាលរបស់គណៈវិស្វករកម្ពុជា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

សេង លឹមនៅ

ចម្លងជូន :
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ស្ថាប័នវិស្វករកម្ពុជា
- មជ្ឈមណ្ឌលឯកសារកម្ពុជា ។ "ដើម្បីជ្រាប"
- ឯកសារ-កាលប្បវត្តិ



អ្នកភូមិអានទស្សនាវដ្ដីស្វែងរកការពិត


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នាដៃលេខនេះ ៖** ប្រាក់ កែវតារា, អាឡិច ហ៊ីនតុន, ចន ឆរឆីអារី, ហ្វូវីដ ជីនៃ, ខេលី ហេត្រិដ, រីធី ម៉ារឆីន, ស្វាយ វ៉ាន់ថន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ៖** ជា ដល្លា, ទេស ម៉ារ៉ែម **និពន្ធនាយករង៖** ឆាំង យុ **ជំនួយការនិពន្ធនាយក៖** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វេង Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ៖ វិទ្យាស្ថានស្លឹករឹត

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យមួយនៅកម្ពុជាដែលជំរុញឲ្យមានការចងចាំនិងយុត្តិធម៌ ។ យើងធ្វើការរៀបចំឯកសារស្រាវជ្រាវនិងចែករំលែកនូវប្រវត្តិសាស្ត្ររបបខ្មែរក្រហម ក្នុងគោលបំណងជួយប្រជាជនកម្ពុជាឲ្យជាសះស្បើយពីរបួសអតីតកាល ។ យើងជំរុញឲ្យមានការទទួលខុសត្រូវ ថែមទាំងបង្ហាត់បង្រៀនពីគោលការណ៍ច្បាប់និងយុត្តិធម៌ដើម្បីឲ្យវិធានច្បាប់កាន់តែមានភាពរឹងមាំនិងការពារមិនឲ្យមានការរំលោភបំពានទៅលើសិទ្ធិមនុស្សនៅប្រទេសកម្ពុជាទៅថ្ងៃអនាគត ។

ដើម្បីធានាថា យើងអាចដើរតួនាទីប្រហាក់ប្រហែលទៅថ្ងៃអនាគត បច្ចុប្បន្នយើងកំពុងរៀបចំបង្កើតមជ្ឈមណ្ឌលអចិន្ត្រៃយ៍មួយដែលមានឈ្មោះថាវិទ្យាស្ថានស្លឹករឹត ។ វិទ្យាស្ថាននេះនឹងបម្រើតួនាទីជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ថែមទាំងរួមបញ្ចូលការស្រាវជ្រាវនិងជាស្ថាប័នបណ្តុះបណ្តាល បណ្ណាល័យ សារមន្ទីរ និងមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានថែមទៀតផង ។ ជាងនេះទៅទៀត វិទ្យាស្ថានស្លឹករឹតនឹងជាតំណាងជំហរអចិន្ត្រៃយ៍ប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជា អាស៊ី និង នៅទូទាំងពិភពលោក ។ ឈ្មោះដែលយើងជ្រើសរើសសម្រាប់វិទ្យាស្ថាននេះឆ្លុះបញ្ចាំងពីគោលបំណងសំខាន់របស់យើងនិងកេរ្តិ៍តំណែលរបស់ប្រជាជនកម្ពុជា ។ ស្លឹករឹត គឺជាស្លឹកឈើស្ងួតដែលមេដឹកនាំសាសនាកម្ពុជានិងបញ្ញវន្តបានយកមកប្រើប្រាស់អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ដើម្បីកត់ត្រាប្រវត្តិសាស្ត្រ ចែករំលែកចំណេះដឹង ថែមទាំងការពារវប្បធម៌នៅក្នុងអំឡុងរបបដ៏ព្រៃផ្សៃប៉ុល ពត ។ ស្លឹករឹត ក៏តំណាងឲ្យចំណងប្រវត្តិសាស្ត្រនិងវប្បធម៌របស់ប្រទេសកម្ពុជាជាមួយនឹងប្រទេសជិតខាងដូចដែលអ្នកជំនាញខាងសាសនាបានយកទៅប្រើប្រាស់នៅប្រទេសភូមា ថៃ និង ឥណ្ឌូនេស៊ីជាដើម ។ ***(តទៅទំព័រ២០)***



# តើខ្មែរក្រហមធាំងអស់សុទ្ធតែអាក្រក់ឬ?

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យដែលបានវាយរំលំរបប លន់ នល់ ចេញពីអំណាច ។ បន្ទាប់ពីឡើងកាន់អំណាចភ្លាម ជម្រើសដំបូងនៃរបបនេះ គឺការចាត់តាំងរចនាសម្ព័ន្ធកម្មាភិបាលគ្រប់គ្រងតាមតំបន់ដើម្បីស៊ើបរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងរបស់បក្ស ។ ដូច្នេះការរស់នៅរបស់ប្រជាជនត្រូវស្ថិតនៅក្នុងភាពភ័យខ្លាច និងក្រោមការឃ្លាំមើលពីអង្គការជាប្រចាំ ហើយមួយចំនួនត្រូវទទួលរងការចោទប្រកាន់ទៀតផង ។ អ្នកមានកំហុសទាំងនោះមានវាសនាមិនខុសគ្នាទេ គឺត្រូវទទួលរងការធ្វើពលកម្មជាទម្ងន់ ទារុណ-កម្មនិងការបោសសម្អាតដោយមិនរើសមុខ ដែលនេះត្រូវបានចាត់ទុកថាជារបបដ៏សាហាវឃោរឃៅសម្លាប់ប្រជាជនស្លូតត្រង់ខ្លួនឯងអស់ប្រមាណពីរលាននាក់ ។ ទោះយ៉ាងនេះក្តី ក៏អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួននៅមានទំនាក់ទំនងល្អជាមួយប្រជាជន ។ ប៉ូច ដែលធ្លាប់ធ្វើជាគណៈស្រុកក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានជួយប្រជាជនឲ្យមានសេរីភាព រួចផុតពីការចោទប្រកាន់និងដោះស្រាយអាហារឲ្យប្រជាជនបានហូបគ្រប់គ្រាន់ទៀតផង ។


ប៉ូច

ប៉ូច មានបងប្អូន៤នាក់ មានស្រុកកំណើតនៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ នៅឆ្នាំ១៩៦៥ ប៉ូច បានចូលបួសជាលោកសង្ឃ នៅវត្តតាំងខ្មៅ ដើម្បីរៀនធម៌និងអក្សរសាស្ត្រខ្មែរ ។ រយៈពេលពីរឆ្នាំក្រោយមក ទើប ប៉ូច លាចាកសិក្ខាបទ ហើយត្រូវបានឪពុកម្តាយរៀបចំឲ្យមានប្រពន្ធជាអ្នករស់នៅក្នុងភូមិជាមួយគ្នា ។

**មូលដ្ឋានរំដោះ**

នៅឆ្នាំ១៩៧១ ក្រោយពីព្រឹត្តការអំពាវនាវរបស់សម្តេចសីហនុ ឲ្យរត់ចូលព្រៃម៉ាគីដើម្បីបង្កើតចលនាតស៊ូរំដោះប្រទេសពីរបបលន់ នល់ យុវជន ប៉ូច ក៏បានស្ម័គ្រចិត្តចូលបម្រើទ័ពរណសិរ្សរួបរួមជាតិជាមួយអ្នកភូមិជាច្រើននាក់ទៀត ។ ប៉ូច ត្រូវអង្គការចាត់តាំងឲ្យមើលការខុសត្រូវប្រជាជនធ្វើស្រែចម្ការនៅអង្គភាពឃុំវាលពន់ ។ នៅឆ្នាំ១៩៧៤ ប៉ូច ត្រូវផ្លាស់ទៅអង្គភាពថ្មីមួយទៀត ដែលមានទីតាំងនៅខាងត្បូងផ្លូវជាតិលេខ៤ ស្ថិតនៅក្នុងឃុំកន្ទោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ នៅទីនេះ ប៉ូច មានភារកិច្ចអប់រំអំពីមាគ៌ាបដិវត្តន៍ចំពោះប្រជាជនដែលរត់ចេញពីភ្នំពេញមករស់នៅមូលដ្ឋាន និងដោះស្រាយជីវភាពប្រជាជននៅក្នុងអង្គភាពឃុំទាំងមូលដែលខ្វះខាតស្បៀងអាហារ ដោយទាក់ទងអ្នករស់នៅតាមមាត់ទន្លេដើម្បីទិញពោត អង្ករ ត្រី ព្រមទាំងដឹកនាំកម្លាំងប្រជាជនចុះធ្វើស្រែចម្ការទៀតផង ។ ប៉ូច រៀបរាប់ថាមានថ្ងៃមួយក្មេងស្រីម្នាក់និងនារីម្នាក់ទៀតឈ្មោះ មុំ ជាប្រជាជនរស់នៅតំបន់ខ្មាំង (លន់ នល់) ដែលធ្លាប់រាប់អានគាត់បានដើរសួររកឈ្មោះបងប្អូនចំពេលមានការប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និងកងទ័ពរំដោះ(ខ្មែរក្រហម) ក៏ត្រូវកម្លាំងរំដោះស្រុកកណ្តាលស្ទឹងចាប់ខ្លួនបាននៅខាងត្បូងស្រុកអង្គស្នួល ។ បន្ទាប់មក អង្គការបានចោទអ្នកទាំងពីរថាជាខ្មាំងបង្កប់មកស៊ើបការណ៍នៅមូលដ្ឋានរំដោះដើម្បីរាយការណ៍ឲ្យកងទ័ពលន់ នល់ ។ ដោយសារមើលឃើញថាមានការធ្វើទារុណកម្មនិងវាយដំជាទម្ងន់ ប៉ូច ក៏បានទៅធានាឲ្យមានការដោះលែងនារីទាំងពីរនាក់ឲ្យមានសេរីភាពឡើងវិញ ។

**អង្គការចាត់តាំង**

ក្រោយកងទ័ពរំដោះទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ អង្គការបានចាត់តាំង ប៉ូច ឲ្យធ្វើជាអនុប្រធានស្រុកស្អាង ដើម្បីគ្រប់គ្រងកម្លាំងប្រជាជនធ្វើស្រែចម្ការ ។ នៅឆ្នាំដដែលនោះ ដោយសារប្រពន្ធដើមរបស់ ប៉ូច បាត់បង់ជីវិត អង្គការក៏បានរៀបចំគាត់ឲ្យមានប្រពន្ធឈ្មោះ សល្យ ជាអ្នកស្រុកកណ្តាលស្ទឹងនិងបានកូន១ ។ រយៈពេល៧ខែក្រោយមក អង្គការបានផ្លាស់

ប៉ូច ឲ្យមកគ្រប់គ្រងប្រជាជននៅស្រុកតាំងគោក តំបន់៤២ ភូមិភាគកណ្តាលវិញ ។ ទោះបីជាអង្គការបានកត់ឈ្មោះប្រជាជន១៧មេសា ប្រជាជនជាប់ចោទពីបទលួចដកដំឡូង លួចអង្ករនិងអ្នកទៅធ្វើការមិនទៀងទាត់ពេលវេលាយ៉ាងណាក្តី ក៏ ប៉ូច មិនដែលយកទោសពៃរ៍ប្តឹងរាយការណ៍ទៅថ្នាក់តំបន់ឬមជ្ឈិមដែរ ព្រោះគិតថាអ្នកទាំងអស់នេះជាអ្នកថ្មីមិនដឹងមានសមាសភាពអ្វីខ្លះ ម្យ៉ាងទៀតអាចនាំឲ្យមានការភ័ន្តច្រឡំផង ។ ដូច្នេះហើយទើបការងារដឹកនាំកម្លាំងធ្វើស្រែនៅក្នុងស្រុកតាំងគោកត្រូវធ្លាក់ទៅលើអនុលេខារបស់គាត់គ្រប់គ្រងវិញ ។ ក្រោយមក អង្គការបានណែនាំ ប៉ូច ឲ្យចុះដឹកនាំប្រជាជនធ្វើស្រែ ។ ក្នុងរយៈពេលយ៉ាងខ្លី អង្គភាពរបស់ ប៉ូច បានទទួលផលស្រូវរាប់សែនថាំងសម្រាប់ផ្គត់ផ្គង់ជីវភាពប្រជាជនដែលរស់នៅតាមសហករណ៍ក្នុងស្រុកទាំងមូល ។ ប៉ូច ធ្វើការងារបានល្អនិងមិនសូវតឹងតែងចំពោះប្រជាជនទេ ដោយបានណែនាំកម្មាភិបាលនៅថ្នាក់ក្រោមថា «អង្គការថ្នាក់លើចាត់តាំងឲ្យយើងតាមដានតែអ្នកណាដែលមានសកម្មភាពក្បត់ប្រឆាំងបក្សប៉ុណ្ណោះ មិនមែនឃើញគេខុសហើយដាក់ទោសនោះទេ» ។ ជាក់ស្តែងនៅពេល ប៉ូច ដឹងថាឈ្លបសហករណ៍ឃុំគ្រើលទៅព័ទ្ធចាប់ខ្លួនយុវជននិងយុវនារីក្មេងៗដែលលួចបាយនិងមាន់ រំលងបានមួយថ្ងៃ គាត់បានហៅកងឈ្លបនិងប្រធានសហករណ៍មកជួបដោយនិយាយថា «មិត្តឃ្លានអាចហូបបាន រីឯក្មេងៗដែលឃ្លាន មិត្តទៅយករបស់នោះពីគ្នាហើយគំរាមកំហែងដាក់ទោសទៀត ទៅថ្ងៃមុខមិនត្រូវធ្វើដូច្នេះទេ» ។ លើសពី នេះ ប៉ូច បានប្រជុំប្រាប់ដល់ប្រជាជនថា «មិនមែនយើងជាប្រជាជន១៧មេសាចេះតែមានកំហុសនិងមានរឿងនោះទេ ធ្វើយ៉ាងណាកុំឲ្យតែនិយាយប៉ះពាល់ដល់អង្គការបានហើយ ទោះបីយើងទៅធ្វើការងារឬមិនធ្វើក្តី» ។

## ភារកិច្ចថ្មី

នៅឆ្នាំ១៩៧៧ ប៉ូច ត្រូវអង្គការផ្លាស់ឲ្យមកគ្រប់គ្រងនៅស្រុកបារាយណ៍វិញ ។ ជារៀងរាល់ថ្ងៃ ប៉ូច ត្រូវចុះទៅត្រួតពិនិត្យការដ្ឋានជីកប្រឡាយនៅភូមិកំបើយ ឃុំចុងដូង ដែលមានប្រជាជនរាប់ម៉ឺននាក់លើកទំនប់និងជីកប្រឡាយ ។ ប៉ូច តែងតែអនុគ្រោះដល់ប្រជាជន ដោយបានកំណត់រយៈពេល១០ថ្ងៃ ត្រូវអនុញ្ញាតឲ្យប្រជាជនផ្លាស់វេនគ្នាទៅលេងផ្ទះម្តង ព្រោះការងារធ្វើបានតាមផែនការកំណត់របស់តំបន់និងភូមិភាគហើយ ។ ថ្ងៃមួយខណៈពេលដែល ប៉ូច កំពុងបំពេញការងារនៅការដ្ឋាន អនុលេខារបស់គាត់បានហៅប្រជាជនមកចូលរួមប្រជុំដោយលើកថា «អ្នកណាដែលធ្វើឲ្យបាក់នង្គ័ល រនាស់ រទេះគោ និងអ្នកមិនទៅធ្វើពលកម្ម គឺជាខ្មាំងបំផ្លិចបំផ្លាញអង្គការ» ដែលធ្វើឲ្យប្រជាជនមានការភិតភ័យយ៉ាងខ្លាំង ។ ក្រោយពីទទួលបានដំណឹងនេះ ប៉ូច ក៏បានសម្រួលកុំឲ្យប្រជាជនភ័យខ្លាច ដោយបានហៅមនុស្សប្រមាណ៦០០នាក់ក្នុងឃុំមកពន្យល់ប្រាប់ថា «រឿងខ្វះខាត ដំឡូងបាយដោយសារយើងក្រ ចំណែកនង្គ័លបាក់បណ្តាលមកពីយើងភ្ជួរប៉ះឈើឬថ្ម ដូច្នេះមិនមែនជាទោសកំហុសទេ» ហើយគាត់បន្តថា «មិត្តអាចដាំដំណាំនៅតាមផ្ទះបានដូចជា ពោត ដំឡូង បន្លែ ជាដើម ឬក៏ចិញ្ចឹមមាន់ ទាថែមទៀត សម្រាប់ត្រៀមហូបនៅពេលណាយើងហូបបាយនៅសហករណ៍មិនឆ្អែត» ។ យោបល់នេះធ្វើឲ្យប្រជាជនសប្បាយចិត្ត ហើយខំធ្វើការរហូតទទួលបានផលលើសយកទៅទុកនៅសហករណ៍ ហើយមួយចំនួនទៀតយកមកប្រគល់ឲ្យ ប៉ូច នៅសាលាស្រុក ។ ដោយសារ ប៉ូច ទទួលបានការគោរពរាប់អានពីប្រជាជន ទើបធ្វើឲ្យកម្មាភិបាលស្រុកមួយចំនួនមិនសូវពេញចិត្តនិងទង្វើនេះទេ ហើយក៏រាយការណ៍ទៅតំបន់និងភូមិភាគ ។ ប៉ុន្តែ ប៉ូច ធ្វើការងារបានតាមផែនការបក្ស ដូចនេះអង្គការមិនដែលចោទប្រកាន់គាត់ទេ ហើយក៏មិនបានធ្វើឲ្យប៉ះពាល់ដល់ការងាររបស់គាត់ដែរ ។ នៅពេលស្រង់ប្រវត្តិរូបសមាសភាពគ្រូបង្រៀនម្តងៗ ប៉ូច តែងតែប្រមូលប្រជាជនមកអប់រំបំពាក់គោលជំហរនយោបាយរបស់បក្ស រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ ។ ទោះបីជាប្រជាជនធ្វើឲ្យមានកំហុសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ ប៉ូច មិនដែលចាប់កំហុសឬរាយការណ៍ទៅថ្នាក់លើទេ ។ ជាក់ស្តែងនៅតាមសហករណ៍កើតមានចោរលួចអង្ករ បាយ ដំឡូង សម្ភារៈរបស់អង្គការនិងលួចលាក់ធ្វើទឹកត្នោតជូរទៀត គាត់តែងតែហៅអ្នកទាំងនោះមកណែនាំជានិច្ចថា «កុំឲ្យប្រព្រឹត្តអ៊ីចឹងទៀត ចំណែកអ្នកហូបទឹកត្នោតជូរក៏ហូបចុះ ប៉ុន្តែកុំឲ្យផុំក្លិនលើគេ» ព្រោះបើ

តំបន់ឬភូមិភាគដឹង យើងនាយស្រួលដោះស្រាយថាហូបដើម្បីគ្រាន់តែកែរោគប៉ុណ្ណោះ។ ថ្ងៃមួយពេល ប៉ុច ឃើញប្រជាជនប្រមាណ១០នាក់នៅភូមិអូរស្វស្តី ឃុំបារាយណ៍ កំពុងធ្វើពិធីបង្សុកូលនៅក្នុងផ្ទះឲ្យសាច់ញាតិដែលស្លាប់ ប៉ុច មិនបានស្តីបន្ទោសឲ្យទេ គាត់បែរជាឈប់មុំតូ ហើយប្រាប់ថា «សម័យនេះបងប្អូនដឹងហើយ ប្រយ័ត្នតែធំក្លិនធូបនិងឮដល់ថ្នាក់លើប្រាកដជាអង្គការចោទប្រកាន់មិនខាន»។ បន្ទាប់មក ប៉ុច បន្ថែមថា «ឥឡូវបងប្អូនទាំងអស់គ្នាធ្វើបុណ្យក៏ធ្វើចុះ ប៉ុន្តែសូមបងប្អូនបិទទ្វារធ្វើបុណ្យរួចយកខ្មោចទៅកប់ទៅ»។ ប៉ុន្តែទោះបីជាមានការបន្ធូរបន្ថយមិនដាក់ទោសយ៉ាងនេះក្តី ក៏នៅតែមានអ្នកប្រព្រឹត្តកំហុស៣-៤នាក់ដែលត្រូវរាយការណ៍ទៅអង្គការថ្នាក់លើដែរ។ ពេលប្រជុំរាយការណ៍ពីសកម្មភាពការងារនៅសហករណ៍ ប៉ុច តែងលើកយោបល់ឲ្យមានការបន្ធូរបន្ថយចំពោះការទាក់ទងរវាងបុរសនិងនារី។ មួយឆ្នាំម្តង អង្គការបានកោះហៅកម្មាភិបាលនៅគ្រប់ស្រុក តំបន់ និងភូមិភាគមកប្រជុំនៅភ្នំពេញក្រោមអធិបតីភាពរបស់ នួន ជា ស្តីពីការធ្វើសហករណ៍រួម និងលើកឡើងពីគោល-ការណ៍ណែនាំរបស់មជ្ឈិមថា «ការដឹកនាំប្រៀបបានសរសៃសូត្រឬមងជំពាក់ យើងមិនអាចយកកន្ត្រៃឬកាំបិតទៅកាត់បានទេ ព្រោះអាចនាំឲ្យជំពាក់ថែមទៀត»។ ដូច្នេះ ប៉ុច បានបញ្ជាក់ថា ការអនុវត្តនៅតំបន់ឬភូមិភាគមានលក្ខណៈផ្សេងពីគោលការណ៍ ព្រោះប្រសិនបើយើងចាត់វិធានការដាក់ទោសកំហុសនិងសម្លាប់បែបនេះ អាចធ្វើឲ្យប៉ះពាល់ដល់ក្រុមគ្រួសារសាច់ញាតិដែលមិនមានកំហុសថែមទៀត។

## បញ្ហាថ្នាក់លើ

នៅឆ្នាំ១៩៧៨ ប៉ុច បានចាត់តាំងនិរសារម្នាក់ឲ្យយកអង្ករទៅចែកប្រជាជនដែលខ្វះខាត។ នៅពេលនោះ តំបន់ក៏ចុះមកណែនាំចំនួន៥ដងថា «ម៉េចបានជាមិត្តឯងមិនដកកម្មាភិបាលចាស់ចេញ?» ប៉ុច បានឆ្លើយតបវិញថា «កម្មាភិបាលទាំងអស់ខិតខំធ្វើការដឹកនាំប្រជាជនបានល្អណាស់ ហើយមិនដែលមានសកម្មភាពប្រឆាំងឬថ្ពាំងថ្នាក់ជាមួយអង្គការឡើយ បើមិត្តមិនជឿមិត្តអាចសួរអនុលេខានិងសមាជិកថ្នាក់ក្រោម»។ ដោយសង្កេតឃើញថា ប៉ុច មិនបានផ្លាស់ប្តូរកម្មាភិបាលតាមការណែនាំរបស់តំបន់ អង្គការក៏ចុះមកដកយកអនុលេខាឈ្មោះ ឆន ដែលមានស្រុកកំណើតនៅស្រុកបារាយណ៍ និងឈ្មោះ ដេន ចេញ ដោយគ្រាន់តែប្រាប់ថាផ្លាស់ទៅធ្វើការនៅតំបន់ដែលមាន អឿន ជាអ្នកគ្រប់គ្រងប៉ុណ្ណោះ។

នៅដើមឆ្នាំ១៩៧៩ ប៉ុច នាំក្រុមគ្រួសារនិងបងប្អូនរត់ទៅរស់នៅព្រៃបោះពង ស្រុកបារាយណ៍លើ។ មួយរយៈក្រោយមក ប្រពន្ធរបស់គាត់ឈ្មោះ សល្យ និងកូនទាំង២នាក់បានស្លាប់ជាបន្តបន្ទាប់ដោយសារជំងឺគ្រុនចាញ់។ រស់នៅទីនោះ ប៉ុច ត្រូវបានតែងតាំងឲ្យធ្វើជាគណៈស្រុកបារាយណ៍ មានភារកិច្ចទទួលកម្លាំងតស៊ូមកពីស្រុកនានា។ ដោយសារមានកងទ័ពរងរបួសនិងស្លាប់ដោយជំងឺច្រើន ប៉ុច បានប្រកាសថា «បើបងប្អូនណាទ្រាំនៅតស៊ូបានក៏នៅចុះ ហើយបើទ្រាំមិនបាន ឬមិនហ៊ាននៅសូមត្រឡប់ទៅផ្ទះវិញ»។ នៅឆ្នាំ១៩៨០ ប៉ុច ត្រូវអង្គការប្តូរមកគ្រប់គ្រងកម្លាំងទ័ពប្រចាំខេត្តកំពង់ចាម និងខេត្តកំពង់ធំវិញ។ ក្រោយមក កែ ពក បានចុះមកបញ្ជាទ័ពផ្ទាល់ ដោយតែងតាំង ពេជ្រ ជាង ជាអនុលេខា និង ប៉ុច ធ្វើជាសមាជិកចុះឃោសនាអូសទាញប្រជាជនឲ្យចុះចូលជាមួយខ្មែរក្រហមវិញ។ នៅឆ្នាំ១៩៨៧ ប៉ុច ត្រូវពិការជើងម្ខាងដោយសារជាន់មីននៅពេលប្រយុទ្ធនៅសមរភូមិអូរអង្រ្កង ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។ គាត់ត្រូវអង្គការបញ្ជូនទៅសម្រាកព្យាបាលនៅជំរំអូរត្រាវគ៧។ ក្រោយពីជាសះស្បើយ អង្គការបានចាត់តាំងគាត់ឲ្យមកគ្រប់គ្រងកងទ័ពខ្មែរក្រហមចំនួន៤១៧គ្រួសារ។ ដោយសារតំបន់នេះមានការវាយប្រយុទ្ធគ្នាជាញឹកញាប់ ក្រោយមកកងទ័ពរាជរដ្ឋាភិបាលបានវាយដណ្តើមទីស្នាក់ការរបស់ ប៉ុច បាន។ ពេលនោះ ប៉ុច បានរត់គេចខ្លួនទៅរស់ជាមួយប្រជាជនក្នុងភូមិវិញ។ ដោយសាអំពើល្អរបស់គាត់ដែលបានធ្វើកន្លងមក ទើបអ្នកស្រុកមួយចំនួនបានលួចផ្តល់អង្ករ ត្រីងៀត និងជួយលាក់ប្រវត្តិរូបគាត់ទៀតផង។ រហូតមកដល់សព្វថ្ងៃ នៅតែមានប្រជាជនដែលរស់នៅស្រុកបារាយណ៍ និងស្រុកតាំងគោកតែងតែមកសួរសុខទុកគាត់ជានិច្ចកាល។

**សោម ប៊ុនថន**

# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

***(តពីលេខមុន)***

◆ *ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា បញ្ហាក្នុងការបង្កើតសាលាក្តីខ្មែរក្រហម កំពុងធ្វើឲ្យគាត់ឈឺក្បាល ហើយព្រមានថាវានឹងមិនមានសាលាក្តីនេះទេ ប្រសិនបើសហគមន៍អន្តរជាតិមិនចំណាយលើចំណែកថវិការបស់រដ្ឋាភិបាលសម្រាប់សាលាក្តី ។*

◆ *ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិប្រកាសថា លោកស្រី មីសែល លី (**Michelle Lee**) របស់ប្រទេសចិននឹងសម្របសម្រួលជំនួយរបស់អង្គការសហប្រជាជាតិចំពោះសាលាក្តីខ្មែរក្រហម ។ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៥ លោកស្រីនឹងបម្រើការជាអនុប្រធានការិយាល័យរដ្ឋបាលតំណាងអន្តរជាតិ ។ លោកស្រីបានចូលរួមការងារអង្គការសហប្រជាជាតិនៅឆ្នាំ១៩៧៤ ហើយថ្មីៗនេះ លោកស្រីទទួលខុសត្រូវសេវាគាំទ្រកិច្ចការរដ្ឋបាលសម្រាប់តុលាការប្រល័យពូជសាសន៍សម្រាប់ប្រទេសរ៉្វាន់ដាក្នុងតំបន់អារូសា (**Arusha**) ប្រទេសតង់ហ្សានីតាំងពីខែកក្កដា ឆ្នាំ២០០៣ ។ ពីមុនគាត់ជាប្រធានផ្នែករដ្ឋបាលនៅក្នុងគណៈកម្មការសង្គម និងសេដ្ឋកិច្ចតំបន់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិនៅទីក្រុងបាងកកពីខែកុម្ភៈ ឆ្នាំ២០០១ដល់ខែកក្កដា ឆ្នាំ២០០៣ ។*

◆ *ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្វាគមន៍ចំពោះការតែងតាំង លោកស្រី មីសែល លី ជាអ្នកសម្របសម្រួលដោយអង្គការសហប្រជាជាតិសម្រាប់ការខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិនិងកម្ពុជាក្នុងការបង្កើតសាលាក្តីមួយកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ សម្តេច ហ៊ុន សែន បានប្រាប់អ្នកយកការណ៍ថា យើងស្វាគមន៍ចំពោះជំហានណាមួយដែលធ្វើឡើងដោយអង្គការសហប្រជាជាតិ ។ យើងក៏ស្វាគមន៍ចំពោះការតែងតាំងបុគ្គលិកណាមួយរបស់អង្គការសហប្រជាជាតិដែរ ។ លោកបន្ថែមថា អង្គការសហប្រជាជាតិមានបទបញ្ញត្តិរបស់ខ្លួន គឺថានរណាម្នាក់ដែលបម្រើការងារក្នុងអង្គការនេះត្រូវតែបម្រើផលប្រយោជន៍របស់អង្គការសហប្រជាជាតិ ។*

◆ *ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ ប្រធានាធិបតីប្រទេសបារាំង ហ្សាក់ ស៊ីរ៉ាក់ ជួបជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីពិភាក្សាគ្នាស្តីពីសហប្រតិបត្តិការនិងការខិតខំប្រឹងប្រែងទ្វេភាគីក្នុងការយកមេដឹកនាំនៃរបបខ្មែរក្រហមប្រល័យពូជសាសន៍ដែលនៅរស់ទៅកាត់ទោស ។*

◆ *ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ ឯកអគ្គរដ្ឋទូតថ្មីរបស់អាមេរិកប្រចាំនៅកម្ពុជានិយាយថា វាជាពេលវេលាដែលត្រូវនាំអតីតមេដឹកនាំខ្មែរក្រហមទៅកាត់ទោសហើយ ។ លោកមានប្រសាសន៍ទៀតថា «វាប្រាកដជាសាលាក្តីពិតប្រាកដមួយហើយ ប្រសិនបើសាលាក្តីធានាថាមានស្តង់ដារអន្តរជាតិ រដ្ឋាភិបាលអាមេរិកនឹងគាំទ្ររឿងនេះ ។ អ្វីដែលយើងត្រូវការនោះគឺការកាត់ក្តីពិតប្រាកដ មិនមែនជាការក្លែងបន្លំទេ» ។*

◆ *ថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ឥណ្ឌានឹងផ្តល់វិភាគទានចំនួន១លានដុល្លារ មកឲ្យកម្ពុជាសម្រាប់ជាថវិកាដល់តុលាការខ្មែរក្រហម ។*

◆ *ថ្ងៃ២៥ ខែតុលា ឆ្នាំ២០០៥ អតីតមេបញ្ជាការខ្មែរក្រហម ឈូក រិន ដែលរត់គេចខ្លួនត្រូវបានចាប់ខ្លួននៅជិតព្រំដែនថៃក្នុងខេត្តឧត្តរមានជ័យ ។ ការចាប់ខ្លួននេះធ្វើឡើងតាមសំណូមពររបស់ប្រធានាធិបតី ហ្សាក់ ស៊ីរ៉ាក់ ក្នុងអំឡុងជំនួបជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី២១ ខែកញ្ញា នៅទីក្រុងប៉ារីស ។ ឈូក រិន បានគេចខ្លួនតាំងពីខែកុម្ភៈ នៅពេលតុលាការកំពូលបានបដិសេធបណ្តឹងចុងក្រោយរបស់គាត់ប្រឆាំងនឹងទោសជាប់គុកមួយជីវិត ដែលចេញសាលក្រមក្នុងឆ្នាំ២០០២ ដោយសារគាត់ជាឃាតករសម្លាប់អ្នកទេសចរបីនាក់មកពីប្រទេសអូស្ត្រាលី អង់គ្លេស និងបារាំងដែលត្រូវចាប់ជាចំណាប់ខ្មាំងបន្ទាប់ពីការវាយឆ្មក់រទេះភ្លើងមួយ ហើយក្រោយមកបានសម្លាប់ពួកគេនៅលើភ្នំវល្លិ៍ក្នុងខេត្តកំពត ឆ្នាំ១៩៩៤ ។*

◆ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៥ ព្រះមហាក្សត្រសម្តេច នរោត្តម សីហមុនី ឡាយព្រះហស្តលេខាព្រះរាជក្រឹត្យតែងតាំង ឯកឧត្តម ស៊ាន វិសុទ្ធ ជាប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងតែងតាំងលោកស្រី មីសែល លី ជាអនុប្រធាន ដែលជាតំណែងមួយត្រូវបានតែងតាំងនៅថ្ងៃទី១៤ ខែតុលា ដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

◆ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៥ អតីតព្រះមហាក្សត្រសម្តេចនរោត្តម សីហនុ ចោទប្រកាន់លោក រីឆាដ និចសុន អតីតប្រធានាធិបតីអាមេរិក និងហិនរី ឃីស៊ីងជឺ (Henry Kissinger) ដែលពេលនោះជារដ្ឋមន្ត្រីការបរទេសបម្រើផលប្រយោជន៍ខ្មែរក្រហមក្នុងពេលធ្វើសកម្មភាពយោធានៅកម្ពុជា ។ ឯកសារដែលចេញផ្សាយនៅសប្តាហ៍មុននៅអាមេរិក បានរៀបរាប់លម្អិតពីការបោកប្រាស់របស់ និចសុនក្នុងអំឡុងសង្គ្រាមសម្ងាត់របស់អាមេរិកនៅកម្ពុជានៅដើមទសវត្សរ៍៧០ នៅពេលដែលអាមេរិកធ្វើការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់មកលើប្រទេសនេះ ។ សម្តេច នរោត្តម សីហនុ ទ្រង់បានចារលើគេហទំព័រនៃសារព័ត៌មានមួយដែលចេញផ្សាយតាមវេបសាយរបស់ព្រះអង្គថា «ដោយប្រើប្រាស់អ្នកនិយមលន់ នល់ និង សិរិមតៈ ដើម្បីលុបបំបាត់សង្គមរាស្ត្រនិយម និងនរោត្តម សីហនុ នៅទីបំផុត និចសុន, ឃីស៊ីងជឺ បម្រើផលប្រយោជន៍ខ្មែរក្រហម ប៉ុល ពត និងរបបកុម្មុយនីស្ត ប៉ុល ពត ។

**◆ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិ ដំណើរការទៅមុខជាមួយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់កម្ពុជា**

«ថ្ងៃទី២៣ វិច្ឆិកា ២០០៥ ការប្រឹងប្រែងរបស់អង្គការសហប្រជាជាតិជួយកម្ពុជាក្នុងការបង្កើតតុលាការចម្រុះពិសេសមួយដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ពីបទសម្លាប់ជនស៊ីវិលរាប់សែននាក់នៅអំឡុងទសវត្សរ៍៧០ កំពុងតែមានដំណើរការទៅមុខខណៈពេលអគ្គលេខាធិការកូហ្វី អាណាន់ តែងតាំងបុគ្គលិកសម្រាប់សាលាក្តី» ។

អ្នកនាំពាក្យ ស្តេហ្វានី ឌុហ្សារិច (Stephane Dujarric ) បានប្រាប់ពីកម្មវិធីព័ត៌មានសង្ខេបថ្ងៃត្រង់ប្រចាំថ្ងៃថា «បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីនឹងត្រូវសម្ភាសន៍នៅដើមខែធ្នូសម្រាប់តំណែងចៅក្រមអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ» ។

«អង្គការសហប្រជាជាតិនិងកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីទីតាំងដើម្បីបង្កើតអគារសាលាដំបូង និងតុលាការកំពូលស្របតាមប្រព័ន្ធច្បាប់កម្ពុជាដើម្បីកាត់ទោសអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋកម្ម និងបទរំលោភបំពានធ្ងន់ធ្ងរលើច្បាប់កម្ពុជានិងអន្តរជាតិរវាងពីថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩» ។

«តុលាការនឹងមានចៅក្រមកម្ពុជានិងអន្តរជាតិធ្វើការជាមួយគ្នា ។ យោងតាមកិច្ចព្រមព្រៀងដែលសង្កត់ធ្ងន់លើអព្យាក្រឹតភាព និងឯករាជ្យរបស់គណៈវិនិច្ឆ័យ ការសម្រេចចិត្តក្នុងអង្គជំនុំជម្រះទាំងពីរគួរតែធ្វើឡើងតាមមតិភាគច្រើន៤នាក់នៅសាលាដំបូងនិងមតិភាគច្រើន៥នាក់នៅតុលាការកំពូល ។

## ចៅក្រមអន្តរជាតិ

«កិច្ចព្រមព្រៀងក្នុងមាត្រា៣ចែងថា អង្គជំនុំជម្រះសាលាដំបូងរួមមានចៅក្រមកម្ពុជា៣រូប និងចៅក្រមអន្តរជាតិពីររូប ហើយអង្គជំនុំជម្រះតុលាការកំពូលមានចៅក្រមកម្ពុជា៤រូប និងចៅក្រមអន្តរជាតិ៣រូប» ។

«ស្របតាមមាត្រា៣ កថាខណ្ឌ៥ នៃកិច្ចព្រមព្រៀង ចៅក្រមអន្តរជាតិ៥ នាក់នេះត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីនៃបេក្ខជនដែលបញ្ជូនមកពីអគ្គលេខាធិការ» ។

«អ្នកដែលត្រូវបានជ្រើសរើសជាចៅក្រមអន្តរជាតិអាចត្រូវបានតែងតាំងប្រសិនបើមានកន្លែងទំនេរ ។ ចៅក្រមអាចនឹងត្រូវតែងតាំងដើម្បីបម្រើការជាចៅក្រមក្នុងរឿងក្តីពិសេសៗ ស្របតាមមាត្រា៣ កថាខណ្ឌទី៨នៃកិច្ចព្រមព្រៀង» ។

«តំណាងឲ្យអគ្គលេខាធិការ អ្នកប្រឹក្សាផ្នែកច្បាប់បានធ្វើបញ្ជីសម្រាំងបុគ្គលដែលអគ្គលេខាធិការអាចនឹងតែងតាំងជាចៅក្រមអន្តរជាតិ ឬជាចៅក្រមនៃអង្គបុរេជំនុំជម្រះ ៖

◆ ស៊ីវ៉ាល ខាតរីត្យ (Silvia Cartwright) ចៅហ្វាយ

ក្រុងប្រទេសនូវែលសេឡង់ ។

◆ រ៉ូវ៉ាន ដូនីង (Rowan Downing) សមាជិកនៃអ្នកប្រឹក្សាផ្នែកច្បាប់ ។

◆ ខ្លូឌី ហ្វិន (Claudia Fenz) អតីតចៅក្រមអន្តរជាតិជនជាតិអូស្ត្រីននៅឯបេសកកម្មរបស់អង្គការសហប្រជាជាតិក្នុងតំបន់កូសូវ៉ូ ។

◆ ចាន់ដ្រា ចាយ៉ាស៊ីងហ៊្គីល (Chandra Javasinghe)

◆ ម៉ាទីន ខារ៉ូបគីន (Martin Karopkin) ចៅក្រមតុលាការឧក្រិដ្ឋកម្មក្រុងញូវយ៉ក ជាចៅក្រមស្តីទីនៃតុលាការកំពូលក្រុងញូវយ៉ក ។

◆ អាកនីសខា ខ្លូណូវិខា មីឡាត (Agnieszka Klonowiecka-Milart) ចៅក្រមអន្តរជាតិជនជាតិប៉ូឡូញនៅឯបេសកកម្មអង្គការសហប្រជាជាតិក្នុងតំបន់កូសូវ៉ូ ។

◆ ជីន ម៉ាក ឡាវឺចនី (Jean-Marc Lavergne)

◆ ហ្វ្រិដ ម៉ាកអិលរៀ (Fred McElrea) ចៅក្រមតុលាការស្រុកអកលែន (Auckland District) ប្រទេសនូវែលសេឡង់ ។

◆ អាឌែល អ៊ីប្រាហ៊ីម ម៉ាកិដ (Adel Ibrahim Maged) ចៅក្រមជនជាតិអេហ្ស៊ីប តុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងអធិបតេយ្យជាតិ ។

◆ ម៉ូតូ ណូហ្គូឈី (Motoo Noguchi)

◆ រ៉ូបឺត ស្ពៀរ (Robert Spear)

«អ្នកដែលពាក់ព័ន្ធត្រូវបានអញ្ជើញទៅសម្ភាសន៍នៅទីក្រុងញូវយ៉កនៅខែធ្នូ ឆ្នាំ២០០៥» ។

## សហព្រះរាជអាជ្ញាអន្តរជាតិ

«កិច្ចព្រមព្រៀងចែងនៅក្នុងមាត្រា៦ មានព្រះរាជអាជ្ញាកម្ពុជាម្នាក់និងព្រះរាជអាជ្ញាអន្តរជាតិម្នាក់ ដែលបម្រើការងារជាសហព្រះរាជអាជ្ញា» ។

«ស្របតាមមាត្រា៦ កថាខណ្ឌទី៥ សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ចេញពីបញ្ជីឈ្មោះបេក្ខជនពីរដែលប្រគល់ឲ្យដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ» ។

«បេក្ខជនដទៃទៀតនឹងត្រូវតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងដើម្បីបំពេញមុខតំណែងជាសហព្រះរាជអាជ្ញានៅពេលមានតម្រូវការ ។

«តំណាងឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិនិងជាទីប្រឹក្សាផ្នែកច្បាប់បានបង្កើតបញ្ជីឈ្មោះសម្រាំងនៃបេក្ខជនដែលអគ្គលេខាធិការអាចនឹងតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិ ៖

◆ Maria BENEDETTI

◆ Charles CARUSO

◆ Paul COFFEY

◆ Dermot GROOME

◆ Robert PETIT

◆ Jude ROMANO

«អ្នកមានឈ្មោះត្រូវបានអញ្ជើញទៅសម្ភាសន៍នៅទីក្រុងញូវយ៉កនៅខែធ្នូ ឆ្នាំ២០០៥» ។

## សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

«កិច្ចព្រមព្រៀងក្នុងមាត្រា៥ ចែងពីចៅក្រមស៊ើបអង្កេតខ្មែរម្នាក់និងចៅក្រមស៊ើបអង្កេតអន្តរជាតិម្នាក់ដែលបម្រើការងារជាសហចៅក្រមស៊ើបអង្កេត» ។

«ស្របតាមមាត្រា៥ កថាខណ្ឌទី៥ សហចៅក្រមស៊ើបអង្កេតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ចេញពីបញ្ជីបេក្ខជនពីរដែលផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ» ។

«តំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិនិងជាប្រឹក្សាផ្នែកច្បាប់បានបង្កើតបញ្ជីឈ្មោះសម្រាំងនៃបេក្ខជនដែលនឹងអាចតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ៖

◆ Abdulkadir KAYA

◆ Agnieszka KLONOWIECKA-MILART

◆ Marcel LEMONDE

«អ្នកមានឈ្មោះត្រូវបានអញ្ជើញទៅសម្ភាសន៍នៅទីក្រុងញូវយ៉កនៅខែធ្នូ ឆ្នាំ២០០៥» ។

## ចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះ

«កិច្ចព្រមព្រៀងចែងក្នុងមាត្រា៧ អង្គបុរេជំនុំជម្រះមានចៅក្រមបីរូបត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅ

ក្រុមកម្ពុជានិងចៅក្រម២រូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមការស្នើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ» ។

«អង្គបុរេជំនុំជម្រះត្រូវកោះប្រជុំចៅក្រមរបស់ខ្លួន នៅពេលមានការសម្រេចផ្ទុយគ្នារវាងសហព្រះរាជអាជ្ញាឬរវាងសហចៅក្រមស៊ើបអង្កេត» ។

«តំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិនិងជាទីប្រឹក្សាផ្នែកច្បាប់បានបង្កើតបញ្ជីឈ្មោះសម្រាំងដែលនឹងអាចតែងតាំងជាចៅក្រមអន្តរជាតិ ឬជាចៅក្រមនៃអង្គបុរេជំនុំជម្រះ

◆ *Silvia CARTWRIGHT*

◆ *Rowan DOWNING*

◆ *Claudia FENZ*

◆ *Candra JAYASINGHE*

◆ *Martin KAROPKIN*

◆ *Agnieszka KLONOWIECKA-MILART*

◆ *Jean-Marc LAVERGNE*

◆ *Fred McELREA*

◆ *Adel Ibrahim MAGED*

◆ *Motoo NOGUCHI*

◆ *Michael PROULX:* អតីតចៅក្រមសាលាឧទ្ធរណ៍ *Quebec* នៅប្រទេសកាណាដា ។

◆ *Phillip RAPOZA:* ចៅក្រមសាលាឧទ្ធរណ៍នៅរដ្ឋម៉ាស្សាឈូសេតសហរដ្ឋអាមេរិកនិងជាអតីតចៅក្រមអន្តរជាតិនៅទីម័រខាងកើត ។

◆ *Robert SPEAR*

«អ្នកមានឈ្មោះត្រូវបានអញ្ជើញទៅសម្ភាសន៍នៅទីក្រុងញូវយ៉កនៅខែធ្នូ ឆ្នាំ២០០៥» ។

◆ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ លេខាធិការដ្ឋាននៃក្រុមការងារសាលាក្តីខ្មែរក្រហមចេញផ្សាយសេចក្តីប្រកាសព័ត៌មានដែលថា ព្រះមហាក្សត្រសម្តេចនរោត្តម សីហមុនី បានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងឯកឧត្តម ស៊ាន វិសុទ្ធ ជាប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញនិងតែងតាំងអ្នកស្រី មីសែល លី (*Michelle Lee*) ជាអនុប្រធានដែលត្រូវបានជ្រើសតាំងនៅថ្ងៃទី១៨ ខែតុលា ដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ ទាក់ទងនឹងបញ្ហាថវិកា រដ្ឋាភិបាលនៅខ្វះទឹកប្រាក់ចំនួន១០,៨លានដុល្លារ ហើយកំពុងអំពាវនាវទៅរដ្ឋាភិបាលដទៃទៀតជួយបំពេញបន្ថែមការខ្វះខាតនេះ ។

◆ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៥ ប្រាក់វិភាគទានសរុបសម្រាប់ភាគីអង្គការសហប្រជាជាតិនៃថវិកាអង្គជំនុំជម្រះវិសាមញ្ញកើនឡើងដោយមានការសន្យាថ្មីៗនេះពីប្រទេសអាមីឡៀរ (១ពាន់ដុល្លារ) ណាមីប៊ី (៥រយដុល្លារ) និងប្រទេសអៀរឡង់ (៣សែនដុល្លារ) ។

◆ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៥ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ ស្នើទៅរដ្ឋាភិបាលកម្ពុជាឲ្យចរចាជាមួយរដ្ឋាភិបាលបារាំងដើម្បីសុំខ្សែភាពយន្តខ្នាត៣៥មីលីម៉ែត្រឲ្យមកប្រទេសកម្ពុជា ព្រោះខ្សែភាពយន្តនេះអាចនឹងប្រើជាភស្តុតាងនៅក្នុងតុលាការខ្មែរក្រហម ។ ខ្សែភាពយន្តនេះត្រូវបានដឹងថាបានបញ្ជូនទៅប្រទេសបារាំងដើម្បីជួសជុលឡើងវិញនៅឆ្នាំ១៩៩៨ ។ គាត់មានប្រសាសន៍ថា គាត់បានចរចាជាមួយមន្ត្រីបារាំងជាច្រើនរូបដើម្បីសុំខ្សែភាពយន្តមកវិញ ប៉ុន្តែខាងភាគីបារាំងឆ្លើយតបថាវាជាបញ្ហាបុគ្គល ។

អ្នកស្រី មីសែល លី តំណាងអង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហមបានមកបំពេញបេសកកម្មនៅក្រុងភ្នំពេញរយៈពេលពីរសប្តាហ៍ពីថ្ងៃទី៦-១៦ ខែធ្នូ ដែលបង្ហាញឲ្យឃើញពីដំណាក់កាលឆ្ពោះទៅរកសាលាក្តីពិតប្រាកដមួយ ។

◆ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៥ អ្នកស្រី មីសែល លី នៅក្នុងសេចក្តីថ្លែងការណ៍រួមជាមួយប្រធានការិយាល័យរដ្ឋបាលសម្រាប់សាលាក្តីខ្មែរក្រហមនិយាយថា ឧបសគ្គចម្បងដែលនៅសល់គឺទាក់ទងនឹងបញ្ហាថវិកា ។ អ្នកស្រីបានសរសេរនៅក្នុងសេចក្តីថ្លែងការណ៍ថា «នៅពេលបច្ចុប្បន្នទឹកប្រាក់៤៣លានដុល្លារនៃថវិកាភាគីអង្គការសហប្រជាជាតិជិតគ្រប់ហើយ ប៉ុន្តែភាគីកម្ពុជានៅខ្វះ១០,៨លានដុល្លារ» ។ គាត់បន្ថែមទៀតថា រដ្ឋាភិបាលកម្ពុជាកំពុងអំពាវនាវដើម្បីសុំជំនួយជាបន្ទាន់ចំពោះថវិការដែលនៅខ្វះនេះ ។

◆ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៥ រដ្ឋាភិបាលប្រទេសអូស្ត្រាលី

ប្រកាសផ្តល់ប្រាក់៤៨.៣០៦ដុល្លារអូស្ត្រាលី ដល់លេខាធិការដ្ឋានក្រុមការងារដើម្បីរៀបចំវេទិកាផ្សព្វផ្សាយតាមមូលដ្ឋានក្នុងទីរួមខេត្តនៅទូទាំងប្រទេស ។ ប្រាក់ជំនួយដែលត្រូវបានផ្តល់នេះគឺជាចំណែកនៃគម្រោងកិច្ចការសិទ្ធិមនុស្សឆ្នាំ២០០៥-០៦ ហើយជាប្រាក់ជំនួយបន្ថែមលើទឹកប្រាក់ចំនួន១៩.៩៦០ដុល្លារអាមេរិកដែលផ្តល់ឲ្យនៅខែតុលា តាមរយៈស្ថាប័នសិទ្ធិមនុស្សរបស់ស្ថានទូតអូស្ត្រាលី និងមូលនិធិគ្រប់គ្រងសម្រាប់ការបោះពុម្ពនិងចែកផ្សាយទៅថ្នាក់រៀននីមួយៗនៅក្នុងប្រទេសកម្ពុជា អំពីសៀវភៅព័ត៌មាន «ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម» ដែលបោះពុម្ពនៅឆ្នាំ២០០៤ ដោយទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ (*AusAID*) ។

◆ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៥អ្នកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាលសម្រាប់សាលាក្តីខ្មែរក្រហមនិងក្រុមការងារបានមកទស្សនាមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងវាយតម្លៃប្រភពឯកសារនិងសម្ភារៈបរិក្ខារសម្រាប់ដំណើរការសាលាក្តីដែលរំពឹងថានឹងចាប់ផ្តើមឡើងនៅពេលឆាប់ៗនេះ ។

អ្នកស្រី មីសែល លី ដឹកនាំបេសកកម្មអង្គការសហប្រជាជាតិដំបូងនៅកម្ពុជា ពីថ្ងៃទី៦ដល់១៦ ខែធ្នូ ឆ្នាំ២០០៥ ដែលមានសមាជិក៧រូប រួមមានប្រធានផ្នែកសន្តិសុខ បច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនង ថវិកានិងហិរញ្ញវត្ថុ និងផ្នែកសេវាកម្មទូទៅ ព្រមទាំងមន្ត្រីមកពីអង្គការសហប្រជាជាតិដែលមានទីស្នាក់ការនៅទីក្រុងញូវយ៉ក *Anne-Marie Ibanez* មកពីនាយកដ្ឋានកិច្ចការនយោបាយជាអ្នកនាំពាក្យឲ្យក្រុមបេសកម្មនិង *David Hutchinson* មកពីការិយាល័យកិច្ចការច្បាប់ ។

រយៈពេល៨ឆ្នាំបន្ទាប់ពីស្ថិតនៅក្រៅប្រទេស ភាពយន្តខ្លាតវែងដែលរៀបរាប់ពីព្រឹត្តិការណ៍ប្រទេសកម្ពុជានៅទសវត្សរ៍៦០, ៧០ និង ៨០ នឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញក្នុងពេលឆាប់ៗនេះ ។ ក្រុមហ៊ុនទូរទស្សន៍បារាំងដែលបានចុះកិច្ចសន្យាជាមួយក្រសួងវប្បធម៌ប្រទេសកម្ពុជានៅឆ្នាំ១៩៩៨ ដើម្បីថតចម្លងឡើងវិញបានប្រគល់ភាពយន្តខ្លាតវែងនេះទៅឲ្យផលិតករកម្ពុជានិងលោក ប៊្លូ ប៉ាន់ ជាច្រើនសប្តាហ៍មកហើយ ។ ក្រុមហ៊ុននេះបាននិយាយថា ក្រសួងវប្បធម៌បានផ្តល់សិទ្ធិឲ្យគេរក្សាភាពយន្តនេះមួយច្បាប់នៅមជ្ឈមណ្ឌលសោតទស្សន៍ ។

◆ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥ អង្គការសហប្រជាជាតិកំពុងរិះរកវិធីដើម្បីកាត់បន្ថយការប្រើប្រាស់លុយទៅលើគម្រោងចំណាយរបស់សាលាក្តីខ្មែរក្រហម ។ បញ្ហាគឺនៅត្រង់ថា ស្ថាប័នពិភពលោកមួយនេះអាចប្រើប្រាស់លុយទាំងអស់នេះប្លុយ៉ាងណា ។ អ្នកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាលនៃអង្គការសហប្រជាជាតិបាននិយាយថា ទឹកប្រាក់សរុបប្រមាណ ៦,៩លានដុល្លារ (៥,៧លានអឺរ៉ូ) គឺប្រាក់ដែលប្រមូលពីការបរិច្ចាគដែលប្រទេសផ្សេងៗសម្រាប់បេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅកម្ពុជាក្នុងដើមទសវត្សរ៍៩០ ។

◆ នៅថ្ងៃ១៦ ខែធ្នូ ឆ្នាំ២០០៥ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ បានសរសេរលិខិតមួយច្បាប់ទៅកាសែតបាងកកប៉ុស្តិ៍ប្រាប់ពីចំណុចមួយចំនួនដែលរដ្ឋាភិបាលកម្ពុជាអាចធ្វើដើម្បីឲ្យឧបសគ្គក្នុងការរកថវិកាសម្រាប់សាលាក្តីខ្មែរក្រហមអាចដោះស្រាយបាន ។ ចំណុចទាំងនោះរួមមាន ទី១) យល់ព្រមឲ្យប្រទេសជប៉ុនចំណាយលើប្រាក់ដែលខ្វះខាត ទី២) អំពាវនាវតាមសារព័ត៌មានដោយធ្វើសំណូមពរនិងស្នើជាផ្លូវការឲ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយទាំងក្នុងស្រុកនិងអន្តរជាតិ ប្រសិនបើរដ្ឋាភិបាលចង់ឲ្យប្រជាជនខ្មែរផ្តល់មូលនិធិ និងទី៣) ស្វែងរកប្រភពថវិកាដោយខ្លួនឯងសម្រាប់សាលាក្តីនេះ ។ គាត់បានបន្ថែមថា ប្រទេសផ្តល់ជំនួយអាចពិចារណាការបរិច្ចាគមួយឆ្នាំម្តងៗក៏បាន ប្រសិនបើប្រទេសទាំងនោះខ្វាចខាតបង់ថវិកា ។

◆ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា ទាហាននៅទីបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទក្នុងខេត្តកណ្តាលនឹងចាកចេញក្នុងពេលឆាប់ៗ ដូច្នេះ តុលាការខ្មែរក្រហមអាចនឹងចាប់ផ្តើមការងារនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៥នេះ ។ លោកបន្ថែមទៀតថា «ថវិកាមិនមែនជាបញ្ហាសម្រាប់ការកាត់ទោសទេ ហើយរដ្ឋាភិបាលនឹងប្រើប្រាស់ប្រាក់មាននៅក្នុងដៃសម្រាប់ដំណើរការ ហើយនឹងស្វែងរកមូលនិធិបន្ថែម» ។

◆ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ នាយកសារមន្ទីរអំពើប្រល័យពូជសាសន៍ទួលស្លែង ជ័យ សុភារ៉ា បំភ្លឺពាក្យចចាមអារ៉ាម

ទាក់ទងនឹងការលក់សារមន្ទីរនេះ ។ លោកនិយាយថា ក្រុមហ៊ុនកូរ៉េខាងត្បូងបានស្នើទៅរដ្ឋាភិបាលនៅពាក់កណ្តាលទសវត្សរ៍៩០ដែរ ប៉ុន្តែរដ្ឋាភិបាលបានបដិសេធ ចាប់ពីពេលនោះមកមិនមានការពិភាក្សាទាក់ទងនឹងការលក់សារមន្ទីរនេះទៀតទេ ។

◆ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥ គណៈកម្មាធិការសហគមន៍អឺរ៉ុបសន្យាផ្តល់ប្រាក់១,២លានដុល្លារ ដើម្បីជួយចំណាយលើចំណែកថវិការបស់រដ្ឋាភិបាលសម្រាប់សាលាក្តីខ្មែរក្រហម ។

◆ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលសំណូមពរជាផ្លូវការដំបូងពីបណ្ឌិត ស៊ីវ ហេងឌី តំណាងឲ្យជំនួយការរបស់អង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហមស្តីពីវិធីដែលគាត់អាចទទួលបានឯកសារសង្ខេប និងឯកសារបកប្រែដែលមានស្រាប់ ។

◆ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៦ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្រទេសស៊ុយអែត ថូម៉ាស់ បូដស្ត្រំ មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ។ ទស្សនកិច្ចនេះនឹងពិភាក្សាអំពីគម្រោងអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ ការប្រឆាំងនឹងអំពើឧក្រិដ្ឋកម្មនិងសិទ្ធិមនុស្ស ។ ការខិតខំប្រឹងប្រែងដើម្បីបញ្ឈប់អំពើជួញដូរមនុស្សនិងគម្រោងសម្រាប់តុលាការខ្មែរក្រហមដែលប្រទេសស៊ុយអែតកំពុងតែផ្តល់វិភាគទាននឹងត្រូវយកមកពិភាក្សាផងដែរ ។

◆ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៦ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាអមដំណើរលោកអគ្គរដ្ឋទូត ចូសេប មូសូមេលី ទៅទស្សនាអគារអង្គជំនុំជម្រះដែលនឹងត្រូវយកអតីតមេដឹកនាំខ្មែរក្រហមមកកាត់ទោស ព្រមទាំងពិនិត្យទៅលើសន្តិសុខនិងគម្រោងសាងសង់របស់ក្រុមការងាររដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ។

◆ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ គ្រីស្តូហ្វឺ ហ៊ីល ជំនួយការក្រសួងការបរទេសអាមេរិកទទួលបន្ទុកកិច្ចការប៉ាស៊ីហ្វិកនិងអាស៊ីខាងកើត បានមកទស្សនាសារមន្ទីរទួលស្លែងជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

◆ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ប្រទេសថៃផ្តល់ជំនួយ ២៥.០០០ដុល្លារដល់សាលាក្តីខ្មែរក្រហម ។

◆ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ មួយផ្នែកនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទនៅកំបូល ត្រូវបានប្រគល់ឲ្យក្រុមការងាររាជរដ្ឋាភិបាលសម្រាប់ការកាត់ក្តីខ្មែរក្រហម ។ អគារពីរនិងបរិវេណជុំវិញត្រូវបានសន្យាឲ្យប្រើជាកន្លែងធ្វើការងារនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ជុំវិញករណីច្បាប់និងយុត្តាធិការ ដំណាក់កាលបញ្ចប់នៃការជ្រើសតាំងចៅក្រម សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិកំពុងតែចាប់ផ្តើម ហើយយើងរំពឹងទុកថានឹងប្រកាសឈ្មោះអ្នកទាំងនោះក្នុងពេលឆាប់ៗនេះ ។ ការរៀបចំផ្សេងទៀតដូចជា ឯកសារច្បាប់ជាង១០០ទំព័រនឹងបកប្រែជាភាសាផ្លូវការនៅក្នុងអង្គជំនុំជម្រះ (ដោយមានជំនួយការមកពីរដ្ឋាភិបាលន័រវេស) និងសម្រាប់វិធីផ្សព្វផ្សាយតាមមូលដ្ឋាន (ទទួលមូលនិធិពីរដ្ឋាភិបាលប្រទេសអូស្ត្រាលី) ។

◆ នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៦ អ្នកស្រី មីសែល លី តំណាងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការសាលាក្តីខ្មែរក្រហមបានមកដល់ប្រទេសកម្ពុជា ដើម្បីរៀបចំបុគ្គលិកសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

◆ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៦ លោក រាជ សម្បត្តិ ជាគ្រូបង្រៀនផ្នែកសារព័ត៌មានត្រូវបានតែងតាំងជាមន្ត្រីសារព័ត៌មានសម្រាប់សាលាក្តីខ្មែរក្រហមដែលនឹងត្រូវបង្កើតឡើង ។ គាត់ធ្វើជាអ្នកឆ្លើយឆ្លងព័ត៌មានឲ្យកាសែតបារាំង Agence France Press អស់រយៈពេល១២ឆ្នាំ ហើយបច្ចុប្បន្នធ្វើការក្រៅម៉ោងឲ្យកាសែតញូយ៉កថែម និងជាគ្រូបង្រៀនផ្នែកប្រព័ន្ធផ្សព្វផ្សាយនិងទូរគមនាគមន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ គាត់ទទួលសញ្ញាប័ត្រផ្នែកសារព័ត៌មានពីសាកលវិទ្យាល័យកាលីហ្វញ៉ា និងបរិញ្ញាប័ត្រផ្នែកសាកវប្បកម្ម (ដាំដុះ) នៅហ្វូលតុន ប្រទេសឥណ្ឌា និងសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសារព័ត៌មានពីសាកលវិទ្យាល័យកូឡុំបៀទីក្រុងញូវយ៉ក ។

◆ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៦ លោក នួន ជា បងធំទីពីរបន្ទាប់ពី ប៉ុល ពត នៃរបបកម្ពុជាប្រជាធិបតេយ្យ បានបំភ្លឺពាក្យចចាមអារ៉ាមស្តីពីការស្លាប់របស់គាត់ដែលផ្សព្វផ្សាយនៅពេញប្រទេសនៅយប់ថ្ងៃអង្គារនេះ ។ គាត់បាននិយាយថា «ខ្ញុំមិន

ស្លាប់ទេ» ។

◆ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៦ ប្រធានរដ្ឋបាលនៃសាលាក្តីខ្មែរក្រហមថ្លែងថា ចៅក្រមនិងព្រះរាជអាជ្ញាត្រូវបានរំពឹងថានឹងចូលកាន់តំណែងនៅពាក់កណ្តាលដើមឆ្នាំនេះ ហើយសាលាក្តីដែលគេរង់ចាំដ៏យូរនោះគួរតែចាប់ផ្តើមនៅឆ្នាំ២០០៧ ។

អ្នកស្រី មីសែល លី អនុប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញ មានយោបល់លើបញ្ហាថវិកាថា ត្រឹមថ្ងៃទី១៥ ខែកុម្ភៈ បុគ្គលិកសាលាក្តីនឹងដឹងថាតើប្រទេសផ្តល់ជំនួយដល់កម្ពុជាទាំង២៩បានយល់ព្រមផ្ទេរមូលនិធិរួមនៅសល់ពីសម័យអ៊ុនតាក់ដែលមានទឹកប្រាក់សរុប៦,៩លានដុល្លារ ដើម្បីដោះស្រាយកង្វះថវិការបស់កម្ពុជាដែរឬយ៉ាងណា ។

លោក ស៊ាន វិសុទ្ធ ប្រកាសថា អគ្គនាយករងនគរបាលជាតិលោក ម៉ៅ ចាន់ដារ៉ា ត្រូវបានតែងតាំងជាប្រធានសន្តិសុខនៃសាលាក្តី ។

◆ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៦ យោងតាមអ្នកនាំពាក្យសាលាក្តី លោក រាជ សម្បត្តិ ប្រធានរដ្ឋបាលខាងកម្ពុជា និងអង្គការសហប្រជាជាតិនៃសាលាក្តីខ្មែរក្រហមនៅរង់ចាំទទួលការយល់ព្រមពី២៧ប្រទេសដើម្បីផ្ទេរប្រាក់៦,៩លានដុល្លារពីមូលនិធិរួមនៅសល់ពីសម័យអ៊ុនតាក់ដើម្បីយកទៅចំណាយសម្រាប់ការកាត់ក្តី ។ គាត់បានបន្ថែមថា «យើងបានអះអាងថា ចក្រភពអង់គ្លេសនិងជប៉ុនបានយល់ព្រមលើការផ្ទេរនេះ» ។ «យើងមានសុទិដ្ឋិនិយមថា វានឹងមិនមានបញ្ហា ហើយការកាត់ក្តីនឹងដំណើរការទៅមុខតាមកាលកំណត់» ។

◆ នៅថ្ងៃទី២៥-២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ប្រជាជនបួនរយប៉ែតសិបនាក់មកពីទូទាំងប្រទេសរួមមាន ដូនជី ចាមមូស្លីម សិស្ស និស្សិតនិងអ្នកស្រាវជ្រាវដែលខ្លះអាចត្រូវបានសុំឲ្យធ្វើជាសាក្សីនៅសាលាក្តី បានចំណាយពេល២ថ្ងៃមកទស្សនាទីកន្លែងធ្វើទារុណកម្មរបស់ខ្មែរក្រហម (គុកទួលស្លែងនិងជើងឯក) និងទីតាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសួរសំណួរអំពីតុលាការដែលត្រូវបានបង្កើតដើម្បីស្វែងរកយុត្តិធម៌ឲ្យជនរងគ្រោះ ។ ទស្សនកិច្ចនេះត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**◆ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ ជំនួយការអង្គការសហប្រជាជាតិទៅកាន់ការកាត់ទោសខ្មែរក្រហម**

អគ្គលេខាធិការបានសរសេរលិខិតចុះថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ ផ្ញើទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយប្រគល់នូវឈ្មោះអ្នកដែលត្រូវគេជ្រើសរើសសម្រាប់ចៅក្រមអន្តរជាតិ សហចៅក្រមអន្តរជាតិ និងចៅក្រមអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ។

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០៣ចែងថា នៅតុលាការដំបូងត្រូវមានចៅក្រមកម្ពុជា៣រូប និងចៅក្រមអន្តរជាតិ២រូប ហើយតុលាការកំពូលត្រូវមានចៅក្រមកម្ពុជា៤រូប និងចៅក្រមអន្តរជាតិ៣រូប ។ កិច្ចព្រមព្រៀងនេះបង្ហាញថា ចៅក្រមអន្តរជាតិ៥រូបត្រូវបានតែងតាំងឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីឈ្មោះបេក្ខជន៧រូបដែលផ្ញើដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

*ចៅក្រមអន្តរជាតិៈ*

◆ អ្នកស្រី *Silvia Cartwright* (នូវែលសេឡង់)

◆ អ្នកស្រី *Claudia Fenz* (អូស្ត្រាលី)

◆ លោក *Chandra Nihal Jayasinghe* (ស្រីលង្កា)

◆ លោក *Martin Karopkin* (សហរដ្ឋអាមេរិក)

◆ អ្នកស្រី *Agnieszka Klonowiecka-Milart* (ប៉ូឡូញ)

◆ លោក *Jean-Marc Laverge* (បារាំង)

◆ លោក *Motoo Noguchi* (ជប៉ុន)

កិច្ចព្រមព្រៀងនោះក៏ចែងដែរថា ចៅក្រមស៊ើបអង្កេតកម្ពុជាម្នាក់និងចៅក្រមស៊ើបអង្កេតអន្តរជាតិម្នាក់ ធ្វើជាសហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីនៃបេក្ខជនពីរនាក់ដែលប្រគល់ដោយអគ្គលេខាធិការ ។ បេក្ខជនដទៃទៀតត្រូវតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ។

អគ្គលេខាធិការបានប្រគល់លិខិតតែងតាំងសម្រាប់តំណែង

*សហចៅក្រមស៊ើបអង្កេតអន្តរជាតិៈ*

*លោក Marcel Lemonde (បារាំង)*

*អគ្គលេខាធិការសន្យាប្រគល់បញ្ជីឈ្មោះបេក្ខជនបន្ថែមទៀតសម្រាប់តំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅពេលក្រោយ ។*

*កិច្ចព្រមព្រៀងបានចែងថា ព្រះរាជអាជ្ញាកម្ពុជាម្នាក់និងព្រះរាជអាជ្ញាអន្តរជាតិម្នាក់ធ្វើជាសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីឈ្មោះបេក្ខជន២រូបដែលប្រគល់ដោយអគ្គលេខាធិការ ។ បេក្ខជនដទៃទៀតត្រូវតែងតាំងជាសហព្រះរាជអាជ្ញាបម្រុង ។*

*អគ្គលេខាធិការបានផ្ញើបញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងសហព្រះរាជអាជ្ញាៈ*

*លោក Paul Coffey (សហរដ្ឋអាមេរិក)*

*លោក Robert Petit (កាណាដា)*

*ចុងក្រោយ កិច្ចព្រមព្រៀងចែងពីចៅក្រម៥រូបនៃអង្គបុរេជំនុំជម្រះដែល៣រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមការជ្រើសរើសរបស់អគ្គលេខាធិការ ។ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ អគ្គលេខាធិការបានប្រគល់បញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងសហចៅក្រមនៃអង្គបុរេជំនុំជម្រះៈ*

- *លោក Rowan Downing (អូស្ត្រាលី)*
- *អ្នកស្រី Katinka Lahuis (ហូឡង់)*

*អគ្គលេខាធិការបានសំណូមពរឲ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជូនបញ្ជីបេក្ខជនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ។ នៅមិនទាន់មានការបញ្ជាក់ថាតើនៅពេលណាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងប្រកាសថានរណានឹងត្រូវតែងតាំងក្នុងចំណោមបេក្ខជនទាំងនោះទេ ។*

- *នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងបង្កើតមូលដ្ឋានច្បាប់សម្រាប់ការរៀបចំផ្នែករដ្ឋបាលនិងប្រតិបត្តិការរបស់អង្គជំនុំជម្រះដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដ៏ឃោរឃៅ ដូចជាការសម្លាប់រង្គាលអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ ។ តាមរបាយការណ៍របស់លោក Stephane Dujarric កិច្ចព្រមព្រៀងមួយដែលចុះនៅថ្ងៃនេះគឺទាក់ទិននឹងការចាត់ចែងបន្ថែមលើសម្ភារៈ ទីកន្លែង និងសេវាកម្មដែលរដ្ឋាភិបាលកម្ពុជានឹងផ្តល់ ។ កិច្ចព្រមព្រៀងមួយផ្សេងទៀតគឺទាក់ទងនឹងការរៀបចំសុវត្ថិភាពនិងសន្តិសុខ ។*

- *នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ អ្នកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាលតុលាការពិសេសដើម្បីយកមេដឹកនាំខ្មែរក្រហមដែលនៅរស់មកកាត់ទោស បានធ្វើទស្សនកិច្ចនៅសារមន្ទីរអំពើប្រល័យពូជសាសន៍ទួលស្លែង ដែលពីមុនជាគុក ស-២១ ទស្សនាកិច្ចនេះគឺជាលើកទីមួយតាំងពីគាត់បានមកដល់ប្រទេសកម្ពុជារយៈពេលជាង១ខែ ។ បន្ទាប់ពីមើលឃើញការបង្ហាញរូបថតស-ខ្មៅរបស់ជនរងគ្រោះ និងលលាដ៏ក្បាលជាច្រើន លោកស្រីនិយាយថា «វាគួរឲ្យភ័យខ្លាចណាស់» ។*

- *នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ ប្រជាជនជាង៣០០ នាក់ដែលភាគច្រើនជាសមាជិកគ្រួសាររបស់អតីតខ្មែរក្រហមបានបួសជាព្រះសង្ឃនៅប៉ៃលិន ។ ញឹម សុធន ប្រធានសមាគមនិស្សិតកម្ពុជាដែលឧបត្ថម្ភគាំទ្រកម្មវិធីបណ្តុះបណ្តាលមួយបានឲ្យដឹងថា ក្នុងខណៈពេលដែលកំពុងបង្រៀនធម៌ព្រះពុទ្ធនិងសីលធម៌ លោកនេនទាំងនេះក៏បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការការពារនៃការប្រើប្រាស់ថ្នាំញៀននិងអំពើហិង្សាក្នុងស្រុករយៈពេល១១ថ្ងៃដែរ ។* **(នៅមានត)** **សោម ប៊ុនថន**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ឡើងវិញនៅលើគេហទំព័ររបស់ខ្លួននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ។*

*អ្នកទាំងអស់គ្នាអាចស្តាប់ ថតចម្លង និងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។*

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# លិខិតឆ្លើយតបពីអង្គភាពជនរងគ្រោះ

ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាបានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែរក្រហម ។ ពេលនោះ មេដឹកនាំខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងទៅទីជនបទ បង្ខំឲ្យប្រជាជនធ្វើការស្ទើរតែគ្មានពេលសម្រាក ផ្តល់អាហារហូបមិនគ្រប់គ្រាន់ បំបិទសិទ្ធិសេរីភាពក្នុងការនិយាយស្តីនិងជួបជុំគ្រួសារ មិនមានមន្ទីរពេទ្យនិងថ្នាំព្យាបាលពេលឈឺថ្កាត់ ចាប់ប្រជាជនយកទៅឃុំឃាំង ធ្វើទារុណកម្ម ឬសម្លាប់ចោលប្រសិនបើហ៊ានប្រព្រឹត្តល្មើសប្រឆាំងនឹងបទបញ្ជារបស់អង្គការ ។ នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាក្រោមជំនួយពីកងទ័ពវៀតណាម បានវាយកម្ទេចកងទ័ពខ្មែរក្រហមឲ្យរត់ភៀសខ្លួនទៅតំបន់ព្រៃភ្នំតាមបណ្តោយព្រំប្រទល់ខ្មែរ-ថៃ ។ នៅឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពរវាងភាគីខ្មែរក្រហមនិងរដ្ឋាភិបាលកម្ពុជានៅទីក្រុងប៉ារីសត្រូវបានបង្កើតឡើងដែលនាំឲ្យមានការរៀបចំការបោះឆ្នោតជាតិមួយនៅឆ្នាំ១៩៩៣ ។ បន្ទាប់មក កងទ័ពខ្មែរក្រហមដែលនៅសេសសល់មួយចំនួនក៏បានចូលធ្វើសមាហរណកម្មជាបន្តបន្ទាប់ជាមួយរដ្ឋាភិបាលកម្ពុជា ។

ក្រោមការដឹកនាំនៃរដ្ឋាភិបាលដែលកើតឡើងពីការបោះឆ្នោតជាសកល បានធ្វើឲ្យប្រទេសជាតិកាន់តែមានការរីកចម្រើន តែក៏មិនបានបំភ្លេចការស្វែងរកយុត្តិធម៌ពេញលេញមួយជូនប្រជាជនកម្ពុជាដែរ ។ រហូតពាក់កណ្តាលឆ្នាំ២០០៦ រាជរដ្ឋាភិបាលយើងជាមួយអង្គការសហប្រជាជាតិក៏បានបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំនួន៥រូបរួមមាន ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, នួន ជា និងឌុច ។ អង្គជំនុំជម្រះនេះបានអនុញ្ញាតឲ្យជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានសិទ្ធិចូលរួមដាក់ពាក្យបណ្តឹងដើម្បីស្វែងរកយុត្តិធម៌ ។

គិតត្រឹមខែកក្កដា នៅឆ្នាំ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានទៅជួបប្រជាជននៅតាមខេត្តនិងជួយពួកគាត់ក្នុងការដាក់បណ្តឹងទៅតុលាការខ្មែរក្រហមបានចំនួន១.២២៨នាក់ ។

ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងទៅតុលាការ គឺតម្រូវឲ្យរៀបរាប់អំពីព្រឹត្តិការណ៍ដែលគាត់បានឆ្លងកាត់និងជួបប្រទះ ។ ក្នុងខណៈពេលកំពុងបំពេញពាក្យបណ្តឹងនេះ ជនរងគ្រោះទាំងអស់មានចិត្តរីករាយក្នុងការផ្តល់ព័ត៌មាននិងបទពិសោធន៍នៅក្នុងសម័យខ្មែរក្រហម តែទន្ទឹមនឹងនោះក៏មានជនរងគ្រោះមួយចំនួនមិនអាចទប់ចិត្តបានរហូតបង្ហូរទឹកភ្នែកទៀតផង ។ នេះបញ្ជាក់ថា ការឈឺចាប់នៅមាននៅឡើយទោះជាពេលវេលាបានកន្លងផុតទៅអស់រយៈពេលពាទសវត្សរ៍ហើយក៏ដោយ ។ ដូច្នេះ តើយើងគួរធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ?


សកម្មភាពរបស់អ្នកភូមិកំពុងបំពេញពាក្យបណ្តឹងនៅខេត្តកំពង់ធំ

សព្វថ្ងៃមានប្រជាជនមួយចំនួនដែលមានជីវភាពរស់នៅសមរម្យដូចជាមីង គង់ ជាអាជីវកររស់នៅសង្កាត់បឹងកេងកង២ ខណ្ឌចំការមន ក្រុងភ្នំពេញ បានសួរថា «តើតុលាការនឹងយកអ្វីមកសងសម្រាប់ការខូចខាតនិងការឈឺចាប់របស់ប្រជាជនខ្មែរដែលទទួលរងគ្រោះនៅក្នុងរបបនោះ?» ។

ប៉ុន្តែ អ្នកមីងក៏មិនបដិសេធចុះសម្តែងការមិនពេញចិត្ត ចំពោះអ្វីដែលរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិកំពុងធ្វើដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នោះដែរ ។ ខ្ញុំគិតថា មីង គង់ គ្រាន់តែចង់ដឹងពីសំណងប៉ុណ្ណោះ ទោះជាតុលាការមិនទាន់សន្យាថានឹងសងជាសំណងណាមួយក៏ដោយ ។ ម្យ៉ាងមកពីប្រជាជនយើងមិនទាន់យល់ច្បាស់អំពីអត្ថន័យនៃពាក្យ «យុត្តិធម៌» ដែលនឹងត្រូវផ្តល់ឲ្យដោយតុលាការកូនកាត់មួយនេះ ។ បើតាមវចនានុក្រមសម្តេចសង្ឃជួនណាត យុត្តិធម៌មានន័យថា «សេចក្តីទៀងត្រង់ ការប្រព្រឹត្តត្រឹមត្រូវតាមច្បាប់គឺការវិនិច្ឆ័យដោយសុចរិត» ។ ទោះជាបែបនេះក្តី ពាក្យយុត្តិធម៌មានន័យជ្រាលជ្រៅជាងនេះទៀត គឺក្នុងសង្គមមួយដែលមានយុត្តិធម៌ ជាសង្គមដែលគ្មានជម្លោះ គ្មានការគៀបសង្កត់ គ្មានការកេងប្រវ័ញ្ច ជាពិសេសជាសង្គមមួយដែលមានសន្តិភាព មនុស្សចេះយោគយល់គ្នានិងចេះអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក ។ ដោយសារប្រទេសកម្ពុជាធ្លាប់មានវិបត្តិសង្គមអស់រយៈពេលជាច្រើនឆ្នាំ និងមានការបែកបាក់សាមគ្គី ទើបបង្កឲ្យមានអំពើពុករលួយនិងអំពើអយុត្តិធម៌ ។ ចំណែកការដឹកនាំរបស់បនប៉ុល ពត, អៀង សារី, និង ខៀវ សំផន បានកាប់សម្លាប់ប្រជាជនខ្លួនឯងអស់ជិត២លាននាក់ដោយសារមនោគមន៍វិជ្ជាជ្រុលនិយម ។ សព្វថ្ងៃនេះយើងដឹងថា មានកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមមួយចំនួនកំពុងរស់នៅជាមួយជនរងគ្រោះយ៉ាងសុខសាន្តដងដែរ ។ ចំណុចនេះជាករណីដែលយើងគួរតែដោះស្រាយឲ្យបានសមស្របដើម្បីធ្វើឲ្យប្រជាជនយើងអាចរស់នៅក្នុងប្រទេសមួយ សង្គមមួយដែលមានសន្តិភាពទាំងផ្លូវកាយនិងផ្លូវចិត្ត ។ យើងបានសួរទៅកាន់ប្រជាជនមួយចំនួនថាតើជនរងគ្រោះទាំងអស់គ្នាមានគំនិតយ៉ាងណាដែរចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហម?

អ្នកខ្លះបាននិយាយថា ទាល់តែនាំយកមេដឹកនាំទាំងអស់ទៅកាត់ទោសទើបគ្រប់គ្រាន់ ខ្លះទៀតទាល់តែមានជាសំណង់ដូចជាសាលាបុណ្យ សាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ និងមួយចំនួនទៀតចង់ឲ្យតុលាការកាត់ទោសត្រឹមត្រូវ គ្មានការប្រកាន់បក្សពួកនិងគ្មានអំពើពុករលួយ ។

រិន ជាប្រជាពលរដ្ឋរស់នៅខេត្តស្វាយរៀងនិងជាជនរងគ្រោះម្នាក់ក្នុងចំណោមប្រជាជនខ្មែរជាច្រើនលាននាក់បានមានប្រសាសន៍ថា ក្រៅពីការបង្ខំឲ្យធ្វើការ ការបង្អត់អាហារ ការធ្វើទារុណកម្ម គាត់បានបាត់បង់បងប្អូនមួយចំនួនទៀត ជាពិសេសបងស្រីច្បងរបស់គាត់ដែលជាបង្គោលក្នុងគ្រួសារ ។ ម្យ៉ាងដោយសារតែមានការពន្យារពេលយូរក្នុងការបើកសវនាការដើម្បីជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម គាត់ខ្លាចតែពួកនោះ (មេដឹកនាំខ្មែរក្រហមទាំង៥នាក់) ស្លាប់មុនពេលតុលាការកាត់ក្តី ហើយគាត់ខ្លួនឯងក៏មិនដឹងថាអាចនៅមើលតុលាការកាត់ក្តីបានឬក៏អត់ព្រោះតែគាត់មានជំងឺជាប់ខ្លួន ។ រិន បានបន្ថែមថា «ប្រសិនបើគាត់បានឃើញតុលាការផ្តល់យុត្តិធម៌ដល់រូបគាត់និងប្រជាជនខ្មែរទាំងអស់ប្រហែលជាជំងឺរបស់គាត់បានជាសះស្បើយនិងធ្វើឲ្យគាត់បានស្ងប់ចិត្ត» ។ ដូច្នេះ ចម្លើយទាំងអស់នេះ ខ្ញុំយល់ថា រិន ចង់ឃើញតុលាការមានយុត្តិធម៌ពិតប្រាកដដែលរូបគាត់និងប្រជាជនខ្មែរបានកំពុងរង់ចាំអស់រយៈពេលច្រើនឆ្នាំមកហើយ ។

ដោយឡែក ប្រជាជនមួយចំនួនទៀតដែលចូលរួមដាក់ពាក្យបណ្តឹងតែងតែរំពឹងថាតុលាការនេះនឹងផ្តល់យុត្តិធម៌ ពីព្រោះមានការចូលរួមពីអង្គការសហប្រជាជាតិ ។ ស៊ីន ខ រស់នៅប្រាំងចំរេះ ហាក់ដូចជាមានការភ្ញាក់ផ្អើលក្រោយពេលទទួលបានលិខិតឆ្លើយតប ។ ក្រុមការងារបានប្រាប់ទៅគាត់ថា «នេះជាលិខិតឆ្លើយតបពីតុលាការចំពោះការចូលរួមផ្តល់ព័ត៌មានទាក់ទងនឹងរបបខ្មែរក្រហមតាមរយៈការបំពេញពាក្យបណ្តឹងរបស់មីង ហើយព័ត៌មានទាំងអស់នេះមានសារសំខាន់បំផុតសម្រាប់តុលាការ ជាពិសេសមានតម្លៃខាងផ្នែកប្រវត្តិសាស្ត្រ ។ មិនត្រឹមតែមីង ខ ម្នាក់ទេដែលខ្ញុំបានជួបនិងជូនលិខិតថ្លែងអំណរគុណពីតុលាការ គឺនៅមាន ចាន់ ដែ រស់នៅទួលសង្កែ, ស សំអៀន, ម៉ៅ វណ្ណី និង ខាន់ ថាវី រស់នៅភ្នំពេញថ្មី ។ អ្នកទាំងអស់បាននិយាយថា «យើងស្មានតែតុលាការមិនចាប់អារម្មណ៍ទៅលើរឿងរ៉ាវទុក្ខលំបាកដែលយើងបានរៀបរាប់នោះទេ ពីព្រោះមិនដែលទទួលបានការឆ្លើយតបណាមួយមកវិញសោះ» ។ ជាងនេះទៅទៀត ក្រោយពេលដឹងថា តុលាការបានផ្តល់លិខិតឆ្លើយតបនេះធ្វើឲ្យគាត់សប្បាយចិត្តយ៉ាងខ្លាំងព្រោះតុលាការយកចិត្តទុកដាក់លើរឿងរ៉ាវដែលបានកើតឡើង

នៅក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។

ដែ បានមានប្រសាសន៍ថា «ខ្ញុំរីករាយណាស់ដែលទទួលបានលិខិតពីខាងតុលាការដែលនេះបញ្ជាក់ថាពាក្យបណ្តឹងរបស់ខ្ញុំមិនត្រូវបានតុលាការយកទៅទុកចោលទេ» ។ ដែ បានបន្ថែមទៀតថា ទោះបីជាគ្មានសំណងជាលុយ ប៉ុន្តែឲ្យតែមានការយកចិត្តទុកដាក់ពីតុលាការនិងអង្គភាពជនរងគ្រោះគឺជាការគ្រប់គ្រាន់ហើយ ព្រោះថាយ៉ាងហោចណាស់រឿងដែលកើតឡើងមកលើគាត់តាំងពី៣០ឆ្នាំមុនត្រូវបានតុលាការដឹងឮដែរ ហើយឥឡូវនេះគាត់រីករាយខ្លាំងណាស់ ។

យើងសង្កេតឃើញថាមានមូលហេតុខ្លះដែលធ្វើឲ្យការឆ្លើយតបពីអង្គភាពជនរងគ្រោះមានភាពយឺតយ៉ាវ ព្រោះតាមរយៈការចូលរួមប្រជុំជាមួយអង្គភាពជនរងគ្រោះបានឲ្យដឹងថា «ដោយសារអង្គភាពជនរងគ្រោះមិនទាន់មានថវិកាគ្រប់គ្រាន់ដើម្បីជួលបុគ្គលិកសម្រាប់ធ្វើកិច្ចការនេះទើបមានការយឺតយ៉ាវក្នុងការឆ្លើយតបទៅជនរងគ្រោះ» ។ ប៉ុន្តែពេលនេះអង្គភាពជនរងគ្រោះកំពុងឆ្លើយតបទៅជនរងគ្រោះជាបន្តបន្ទាប់ហើយ ។ នេះជាការលើកទឹកចិត្តដល់ជនរងគ្រោះទាំងអស់ដែលបានដាក់ពាក្យបណ្តឹង ហើយក៏ជាជោគជ័យដ៏ធំមួយទៀតរបស់ជនរងគ្រោះបន្ទាប់ពីការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផងដែរ ។

យ៉ាងណាមិញ ទោះជាមានការមមាញឹកក្នុងមុខរបររកស៊ីចិញ្ចឹមជីវិតយ៉ាងណាក្តី ក៏ប្រជាជនកម្ពុជានៅតែមានពេលវេលាដើម្បីចែករំលែកនូវព័ត៌មានជូនដល់តុលាការដើម្បីទុកជាប្រវត្តិសាស្ត្រដ៏សំខាន់មួយសម្រាប់ឲ្យក្មេងជំនាន់ក្រោយបានដឹងដែរ ។ ប្រជាជនខ្មែរទាំងអស់គិតថាមានតែតុលាការខ្មែរក្រហមនេះហើយដែលអាចរកយុត្តិធម៌ជូនគាត់និងធ្វើឲ្យស្ងប់ចិត្តបាន ។ ដូច្នេះ ទោះជាគាត់ត្រូវចំណាយពេលដើម្បីរង់ចាំយូរបន្តិចក៏ដោយ ក៏គាត់រីករាយដែរព្រោះតែបានទទួលការឆ្លើយតបពីតុលាការនិងអង្គភាពជនរងគ្រោះ ហើយជាពិសេសប្រជាជនទាំងអស់នៅតែអាចចូលរួមជាមួយតុលាការដើម្បីទទួលបានយុត្តិធម៌ក្នុងពេលដ៏ខ្លីខាងមុខ ។

**ប្រាក់ កែវតារា**



អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត

# ការពិត ការរៀបរាប់ និងនយោបាយដើម្បីការចងចាំ បន្ទាប់ពីអំពើប្រល័យពូជសាសន៍

**(តចប់)**

*លលាដ៍ក្បាលទាំងនោះបានក្លាយជានិមិត្តរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ កន្លែងរំឭកវិញ្ញាណក្ខន្ធនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកដែលបានបើកសម្ពោធនៅឆ្នាំ១៩៨០ និងមានកន្លែងរំឭកវិញ្ញាណក្ខន្ធដទៃទៀតនៅទូទាំងប្រទេស រួមមានទីតាំងវាលពិឃាដនៅវត្តភ្នំប្រុសដែលត្រូវបានសាងសង់ឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៨៣ ។ លលាដ៍ក្បាលទាំងនោះជាតឹកតាងដែលបានភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍ជាផ្លូវការស្តីពីការស្លាប់ ការបំផ្លិចបំផ្លាញ អំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងគ្រោះថ្នាក់នៃការវិលត្រឡប់មកវិញនៃបន ប៉ុល ពត អៀង សារី ។ រូបថតនៅទួលស្លែងក៏បង្ហាញនូវគោលបំណងស្រដៀងគ្នានេះដែរ ពីព្រោះថាជនជាតិកម្ពុជាបានដឹងយ៉ាងច្បាស់ពីជោគវាសនានៃរូបគំនូរប្រជាជនដែលតាំងបង្ហាញនេះធ្វើឲ្យពួកគាត់នឹកឃើញឡើងវិញពីការឈឺចាប់និងការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទួលស្លែងនិងបូជនីយដ្ឋានជាច្រើនទៀតក៏ជាភ័ស្តុតាងនៃអំពើឧក្រិដ្ឋកម្មដែលបន ប៉ុល ពត បានប្រព្រឹត្តមកលើប្រជាជនស្លូតត្រង់ដែរ ។*

*ជាមួយនឹងមាគ៌ានយោបាយនេះ ការខ្វះខាតទស្សនវិស័យគឺប្រៀបបាននឹងលលាដ៍ក្បាលចង់រុំភ្នែក ។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្សារភ្ជាប់ទៅនឹងការបាត់បង់ការចងចាំនិងវិចារណញ្ញាណ ។ អ្នកនៅរស់ជាច្រើនបានរំឭកពីរបបកម្ពុជាប្រជាធិបតេយ្យថាជាពេលមួយដែលប្រជាជនត្រូវផ្លាស់ប្តូរទម្លាប់របស់ខ្លួនដូចជាការនិយាយស្តីនិងការរស់នៅប្រចាំថ្ងៃជាដើម ។ ប្រជាជនជាច្រើនបានខ្សឹបដាក់គ្នាថា «ដាំដើមគ» មានន័យថាមិននិយាយស្តី ។ មាគ៌ានយោបាយដែលខ្វះខាតទស្សនវិស័យគ្រប់គ្រងបានបណ្តាលឲ្យប្រជាជនជាច្រើនបាត់បង់សិទ្ធិសេរីភាពនិងកម្មសិទ្ធិផ្ទាល់ខ្លួន ។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានភ្ជាប់ទៅនឹងការស្លាប់និងលលាដ៍ក្បាលចង់រុំភ្នែកដ៏ច្រើនសន្ធឹកសន្ធាប់ តាមរយៈការរៀបរាប់ពីប្រវត្តិអ្នកបាត់ខ្លួននិងការនិទានអំពីខ្មែរក្រហមស៊ីថ្លើមជនរងគ្រោះ ការប្រើអំណាចក្នុងសង្គមដែលមនុស្សគិតថាវាជាអំពើព្រៃផ្សៃ ។ ជាការពិតណាស់ របបកម្ពុជាប្រជាធិបតេយ្យផ្សារភ្ជាប់ទៅនឹងការស្លាប់និងបំបាត់ការចងចាំ ។*

*ខណៈដែលជនរងគ្រោះមើលមិនឃើញ ខ្មែរក្រហមបានអះអាងថា គេមើលឃើញទាំងអស់ ។ របបកម្ពុជាប្រជាធិបតេយ្យមានវិធីសាស្ត្រជាច្រើនដើម្បីស៊ើបការណ៍ ដូចជាដាក់បណ្តាញសម្ងាត់សម្រាប់តាមដានរាល់ទង្វើនិងការនិយាយស្តីរបស់ប្រជាជនជាដើម ។ នៅក្នុងអត្ថបទនយោបាយ របបនេះត្រូវបានចាត់ទុកថា «មើលឃើញសព្វគ្រប់» និង «ដឹងពីអនាគត» ដែលប្រជាជនហៅថា «អង្គការភ្នែកម្នាស់» ។ តាមរយៈទស្សនវិស័យនេះ បានកាត់ផ្តាច់ចេញពីការឃោសនានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលលើកឡើងពីការបំភិតបំភ័យ ការចុះខ្សោយ និងភាពល្ងង់ខ្លៅបែរបបកម្ពុជាប្រជាធិបតេយ្យ ។*

*ទីតាំងនិងរូបភាពចំពីមុខ រួមជាមួយឧបករណ៍ដទៃទៀតគឺជាជាការស្វែងរកការពិតនិងការចងចាំ ដូចជា ថ្ងៃទី៧ ខែមករា «ថ្ងៃរំដោះ» និង ថ្ងៃទី២០ ខែឧសភា «ទិវាចងកំហឹង» ។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានឧបត្ថម្ភក្នុងការបោះពុម្ពនិងថតខ្សែភាពយន្តស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ និងការកាត់ទោសកំបាំងមុខ ប៉ុល ពត និងអៀង សារី ដោយតុលាការប្រជាជននៅឆ្នាំ១៩៧៩ ដែរ ។*

## រឿងនិទានដែលមិនចុះសម្រុងគ្នា

*ទោះបីមានរឿងនិទានដ៏លើសលប់និងមានស្ថាប័នជាច្រើននៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានលើកឡើងពីរបបកម្ពុជាប្រជាធិបតេយ្យក្តី ក៏ប៉ុន្តែអំណះអំណាងទាំងនោះវាមិនទាន់បានប្រមូលផ្តុំនៅឡើយទេ ។ ផ្ទុយទៅវិញ វាបានប្រឈមនឹង*

បញ្ហាទាំងខាងក្នុងនិងខាងក្រៅ ដោយសារការបកស្រាយផ្ទុយគ្នានិងកម្រិតយល់ដឹងរបស់ប្រជាជន ។ ជាក់ស្តែង ការឃោសនាលើឆាកអន្តរជាតិស្តីពីមិត្តភាពកម្ពុជា-វៀតណាម ដែលឧទាហរណ៍នេះមិនអាចឲ្យ ឆ្លាត ឈប់ស្អប់ជនជាតិវៀតណាមបានទេ ព្រោះវាជាអារម្មណ៍ដែលប្រជាជនខ្មែរមួយចំនួនគិតថា វៀតណាមមើលងាយខ្មែរនិងមានបំណងចង់បានទឹកដីខ្មែរតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ននេះ ។ គាត់បានប្រាប់ខ្ញុំម្តងហើយម្តងទៀតថា «ខ្ញុំមិនអាចនិយាយបានថាខ្ញុំស្អប់វៀតណាមប៉ុណ្ណោះទេ» និងបានបន្ថែមការរិះគន់អំពីចរិតពុតត្បុតរបស់ជនជាតិវៀតណាមទៀតផង ។ ប្រទេសវៀតណាមគឺជាចំណាប់អារម្មណ៍សម្រាប់ជនជាតិខ្មែររស់នៅបរទេសដែលបានចាត់ទុករបបសាធារណរដ្ឋប្រជាមានិតកម្ពុជាថាជាខែលនៃការគ្រប់គ្រងរបស់វៀតណាម ហើយកម្ពុជាត្រូវតែរំដោះខ្លួនពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានសម្ព័ន្ធភាពជាមួយសត្រូវវៀតណាមនេះ ។ រឿងនិទានទាំងនេះពាក់ព័ន្ធទៅនឹងការធ្វើប្រជាភិថុតិរបស់ខ្មែរក្រហមដែលមានបំណងកសាងកម្លាំងរបស់ខ្លួនឡើងវិញ ដោយបានរិះគន់ចំណងមិត្តភាពរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជានិងវៀតណាមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនកម្ពុជានិងប្រឌិតភ័ស្តុតាងផ្សេងៗដូចជា គុកទួលស្លែង និងជើងឯកជាដើម ។ គួរឲ្យសោកស្តាយ ជំហរប្រឆាំងនឹងវៀតណាមនេះត្រូវស្ថិតក្នុងដៃប្រទេសចិន ថៃ សហរដ្ឋអាមេរិក និងប្រទេសមហាអំណាចបស្ចិមប្រទេសដទៃទៀតដែលចាត់ទុកប្រទេសកម្ពុជាជាមូលដ្ឋាននៃជម្លោះសង្គ្រាមត្រជាក់ពិភពលោក ។ ប្រទេសទាំងនេះមិនគ្រាន់តែគាំទ្រខ្មែរក្រហមប៉ុណ្ណោះទេ ថែមទាំងអនុញ្ញាតឲ្យមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យមានកៅអីនៅអង្គការសហប្រជាជាតិនិងមិនអើពើការអំពាវនាវសុំឲ្យមានតុលាការអន្តរជាតិសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហមទៀតផង ។

ផ្ទុយមកវិញ ខ្មែរក្រហមបានប្រើភាពស្របច្បាប់ថ្មីនេះដើម្បីថ្លែងពីអតីតកាលរបស់ខ្លួន ។ អតីតមេដឹកនាំខ្មែរក្រហមបានធ្វើសុន្ទរកថាទៅកាន់អ្នកស្តាប់អន្តរជាតិដោយមិនត្រឹមតែបដិសេធថាខ្លួនមិនបានប្រព្រឹត្តអំពើឃោរឃៅទេ ប៉ុន្តែថែមទាំងចោទប្រកាន់វៀតណាមថាជាអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៀត ។ ភ័ស្តុតាងរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានខ្មែរក្រហមបដិសេធថាជាការប្រឌិត ។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ វិទ្យុបានផ្សាយថា ទាក់ទងនឹងគ្រោងឆ្អឹងនៅទួលស្លែង វាជាក់ស្តែងណាស់ថាជាផ្នែកមួយនៃសង្គ្រាមចិត្តសាស្ត្រដែលប្រព្រឹត្តដោយវៀតណាមប្រឆាំងនឹងកម្ពុជា ។ ប្រទេសកុម្មុយនីស្តវៀតណាមបានប្រមែប្រមូលលលាដ៍ក្បាលនិងឆ្អឹងពីទីវាលកប់សាកសពនៅវៀតណាមខាងជើងនិងខាងត្បូងដឹកតាមរថយន្តមកកម្ពុជានិងដាក់តាំងបង្ហាញនៅទួលស្លែងដើម្បីធ្វើជាយុទ្ធនាការឃោសនាផ្នែកចិត្តសាស្ត្រសម្រាប់បិទបាំងពីអំពើឃោរឃៅនិងការទន្ទ្រានកាន់កាប់ប្រទេសកម្ពុជា ។

ទំនាក់ទំនងជិតស្និទ្ធរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាមជាឧបករណ៍ឃោសនាដ៏មានឥទ្ធិពលសម្រាប់ឲ្យខ្មែរក្រហមជ្រើសរើសទ័ពឡើងវិញ ។ ខ្មែរក្រហមទទួលបានការគាំទ្រពីសមាជិកអាណិកជនខ្មែរនៅបរទេសនិងខ្មែរនៅបរទេសក្រោយរបបខ្មែរក្រហមដែលបានអះអាងពីអត្តសញ្ញាណ និងភាពស្របច្បាប់ដើម្បីធ្វើការប្រឆាំងនឹងវត្តមានរបស់វៀតណាមនៅកម្ពុជា ។

ដោយមានអនុសញ្ញាសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ រូបរាងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងប្រទេសកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន និងការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ គណបក្សនេះត្រូវបានរិះគន់យ៉ាងខ្លាំងអំពីចំណងមិត្តភាពជាមួយវៀតណាមពីក្រុមបក្សប្រឆាំងដទៃទៀតនិងប្រជាជនខ្មែរនៅបរទេស ។ ផ្ទុយទៅវិញ គណបក្សប្រជាជនកម្ពុជាបន្តអះអាងពីភាពត្រឹមត្រូវរបស់ខ្លួនស្តីពីការរំដោះនិងបន្តការការពារប្រជាជនពីការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម (បន្ទាប់ពីពួកគេធ្លាក់ពីអំណាច) ។ ជម្លោះទាំងនេះជារឿយៗបានកើតឡើងចំពោះទីតាំងដែលពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែង មានការពិភាក្សាស្តីពីការកប់ចំណែកឆ្អឹងដែលសេសសល់នៅជើងឯក (គណបក្សប្រជាជនអះអាងថា ភ័ស្តុតាងគួរតែរក្សាទុក តែសម្តេច សីហនុ ចង់ជំរុញឲ្យមានការផ្សះផ្សា និងថាព្រលឹងនៃអ្នកស្លាប់គួរតែបានស្ងប់ស្ងាត់) និងផែនទីលលាដ៍ក្បាលនៅទួលស្លែង (ត្រូវបានគេយកចេញកាលពីឆ្នាំ២០០៣) ។ សេចក្តីថ្លែង

ការណ៍ពីការផ្សះផ្សាថ្មីបានលេចឡើងព្រមគ្នាជាមួយនឹងដំណើរការសន្តិភាពដែលនាំទៅរកការផ្លាស់ប្តូរដ៏សំខាន់មួយ ។ ឧទាហរណ៍ការរៀបរាប់ពីរបបកម្ពុជាប្រជាធិបតេយ្យលែងមាននៅក្នុងកម្មវិធីបង្រៀនរបស់សាលាហើយ ។ ព្រមជាមួយគ្នានេះ គេមិនសូវចាប់អារម្មណ៍ពីសេចក្តីថ្លែងការណ៍អំពីសិទ្ធិមនុស្សទេ ដោយសារគេផ្អែកលើទស្សនៈព្រះពុទ្ធសាសនា ទោះបីជាសេចក្តីថ្លែងនេះត្រូវបានបញ្ចូលក្នុងកតិកាសន្តិភាពទីក្រុងប៉ារីស និងរដ្ឋធម្មនុញ្ញថ្មីដែលគាំទ្រដោយអ៊ុនតាក់ក៏ដោយ ។

## ការយល់ឃើញតាមទស្សនៈព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាបានដើរតួយ៉ាងសំខាន់ក្នុងដំណើរការផ្សះផ្សា ។ នៅពេលដែលសាសនាត្រូវបានប្រតិបត្តិឡើងវិញ ប្រជាជនកម្ពុជាទូទាំងប្រទេសចាប់ផ្តើមកសាងព្រះវិហារនិងរៀបចំពិធីបុណ្យសាសនាផ្សេងៗ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាចាត់ទុកព្រះពុទ្ធសាសនាជាស្ថាប័នមួយដែលគេអាចផ្សព្វផ្សាយគោលនយោបាយគណបក្ស ហើយការបំផ្លិចបំផ្លាញដោយខ្មែរក្រហមជានិមិត្តរូបនៃបទល្មើសរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ទោះជាយ៉ាងនេះក្តី ព្រះពុទ្ធសាសនាក៏បានផ្តល់នូវទស្សនៈស្តីពីព្រឹត្តិការណ៍ដែលបានកើតឡើងតាមរយៈកម្មផល បុណ្យបាប ដែលមនុស្សបានប្រព្រឹត្ត ។ វាក៏បានបង្ហាញពីមធ្យោបាយដោះស្រាយរឿងអតីតកាលតាមរយៈការធ្វើសមាធិនិងការអធ្យាស្រ័យផងដែរ ។

ដូច្នេះ ពេលនិយាយដល់អ្នកភូមិម្នាក់ដែលបាននាំ ស្រួន ទៅសម្លាប់ ឆ្លាត ដែលជាពុទ្ធសាសនិកបាននិយាយថា ខ្ញុំនៅគិតដល់ការសងសឹក ប៉ុន្តែខ្ញុំមិនដឹងបញ្ឈប់គំនិតនេះតាមរបៀបណាទេ ។ យើងមិនគួរមានគំនិតបែបនេះទេ ពុំនោះបញ្ហានឹងរីកកាន់តែធំនិងបន្តយូរទៅមុខទៀត ។ យើងគួរធ្វើជាមនុស្សដែលចេះគិតនិងប្រព្រឹត្តតាមធម៌ព្រះពុទ្ធ ។ មនុស្សដែលចង់សងសឹកនិងបន្តភាពសោកសៅដល់សង្គមគឺជាជន្លួវសង្គម ។ តែខ្ញុំនៅតែគិតដល់ការសងសឹកចំពោះអ្នកសម្លាប់បងប្រុសខ្ញុំដែលបានកត់ឈ្មោះគាត់បញ្ជូនឡើងរថយន្តយកទៅសម្លាប់ ហើយអ្នកទាំងនោះសុទ្ធតែនៅរស់ក្នុងភូមិខ្ញុំនេះតែម្តង ។ សព្វថ្ងៃ ខ្ញុំនៅតែចង់សងសឹក ខ្ញុំនៅតែតាមដានខ្មែរក្រហម ។ ប៉ុន្តែខ្ញុំមិនដឹងធ្វើម៉េច ព្រោះរដ្ឋាភិបាលក៏ហាមឃាត់រឿងនេះដែរ ។

ដើម្បីស្វែងយល់ការរៀបរាប់របស់ ឆ្លាត ក៏ដូចជាការឆ្លើយតបរបស់គាត់ចំពោះអំពើហិង្សាក្នុងអតីតកាល យើងត្រូវវិភាគវោហារសព្ទរបស់គាត់ ។

ទស្សនៈព្រះពុទ្ធសាសនាទាក់ទងយ៉ាងសំខាន់ទៅនឹងការឆ្លើយតបទាំងនេះ ។ ដូច្នេះ ជួនកាលប្រជាជនខ្មែរនិយាយថា ជនល្មើសខ្មែរក្រហមនឹងទទួលកម្មផលរបស់គេ ។ ប្រជាជននិយាយថា "ធ្វើល្អបានផលល្អ ធ្វើអាក្រក់បានផលអាក្រក់" ។ ទស្សនៈព្រះពុទ្ធសាសនាពន្យល់ថា ហិង្សាមានប្រភពមកពីអវិជ្ជានិងតណ្ហា ។ ប្រសិនបើអំពើហិង្សាកើតឡើងជាក់ស្តែង នោះផលវិបាកក៏កើតឡើងរយៈពេលយូរដែរ ។ ម្យ៉ាងវិញទៀត អំពើហិង្សាអាចនាំឲ្យអ្នកដទៃចង់សងសឹកនឹងអ្នក ហើយការធ្វើបាបអ្នកដទៃចាត់ទុកជាបាបកម្មដែលនាំឲ្យបាត់បង់បុណ្យកុសលនៅជាតិក្រោយ ។

លើសពីនេះ ការជាប់ជំពាក់ទៅនឹងហិង្សានិងកំហឹងធ្វើឲ្យបាត់បង់ភាពស្ងប់ខាងផ្លូវចិត្តរបស់ប្រជាជនកម្ពុជា រួមទាំងទំនាក់ទំនងសង្គមនិងផ្លូវកាយ ។ អារម្មណ៍ខឹងសម្បាដែលបង្កើតជាការរំខានដល់ភាពស្ងប់ទាំងផ្លូវកាយនិងផ្លូវចិត្តគឺជាសញ្ញារំខានដែលធ្វើឲ្យមនុស្សមានអារម្មណ៍ឈឺចាប់ មិនស្រួលខ្លួន វិលមុខ ឬក្តៅខ្លួន ។ កម្តៅនៃកំហឹងទៅលើសម្ពាធផ្លូវអារម្មណ៍ដែលកំពុងគិតត្រូវបានរំខាននោះ ជំរុញឲ្យចិត្តមនុស្សធ្វើសកម្មភាព ។ ការឡើងកម្តៅនិងកំហឹងបង្ហាញពីសភាពមិនស្ងប់ដែលជាប់ទាក់ទងនឹងអតីតកាលដែលវាមិនគ្រាន់តែជាការរំខានក្នុងចិត្តទេ តែវាថែមទាំងជាសញ្ញានៃការឈឺចាប់ក្នុងសង្គមដែលបង្កប់អត្ថន័យនយោបាយនិងសីលធម៌ទៀតផង ។

ក្រៅពីការចែងពីឫសគល់នៃហិង្សានិងផលវិបាក ព្រះពុទ្ធសាសនាបានប្រាប់ពីមធ្យោបាយកម្ចាត់ចោលទង្វើបែបនេះតាមរយៈមជ្ឈិមប្បដិបទា (ការប្រតិបត្តិតាមផ្លូវកណ្តាល) ។ ក្នុងផ្លូវពុទ្ធចក្រ ប្រជាជនខ្មែរត្រូវជំរុញឲ្យប្រតិបត្តិសីល៥ដែលសីលទីមួយគឺការវៀរចាកការសម្លាប់ ។ ព្រះសង្ឃទេសនាថា យើងត្រូវរៀនគ្រប់គ្រងនិងបំបាត់កំហឹងរបស់ខ្លួនដែលកើតចេញពីអវិជ្ជានិងតណ្ហា ហើយវានាំទៅរកហិង្សានិងការឈឺចាប់ ។ ក្នុងទ្រឹស្តីព្រះពុទ្ធសាសនា វិធីដោះស្រាយកំហឹងគឺត្រូវស្គាល់ប្រភពរបស់វាឲ្យបានច្បាស់លាស់និងត្រូវបំបាត់ចោលកំហឹងដែលបានកើតឡើង ហើយ

អ្វីៗនៅក្នុងលោកនេះមិនឋិតថេរទេ ។ អ្នកដែលនៅតែប្រព្រឹត្តដោយអវិជ្ជានឹងទទួលការឈឺចាប់ពីទង្វើរបស់ខ្លួន ដូចជាស្រមោលអន្ទោលតាមប្រាណ ហើយនឹងទទួលរងការឈឺចាប់គ្រប់ជាតិ ។

បើព្រះពុទ្ធសាសនាចែងពីយុត្តិធម៌សម្រាប់ជនរងគ្រោះ វាក៏បញ្ជាក់ដែរថា ការឈឺចាប់អ្នកទាំងនោះគឺជាផលនៃអំពើអាក្រក់នៅក្នុងអតីតកាល ។ អ្នកខ្លះយល់ថា អ្វីដែលបានកើតឡើងគឺត្រូវតាមព្រះពុទ្ធទំនាយ ។ អ្នកទាំងនោះបានទស្សន៍ទាយពីរយៈពេលដែលសត្រូវបុរណ្ណៈក្រីក្រនៃសង្គមខ្មែរឡើងកាន់អំណាចដែលផ្លាស់ប្តូរសណ្តាប់ធ្នាប់សង្គមឲ្យក្លាយទៅជាល្មើសលើព្រះពុទ្ធសាសនា ទុរភិក្ស និងការស្លាប់ ។ ពាក្យស្លោករបបកម្ពុជាប្រជាធិបតេយ្យមួយដែលទាក់ទងនឹងការមិននិយាយស្តី «ដាំដើមគ» ដែលទំនងជាដកស្រង់ចេញពីការទស្សន៍ទាយរបស់អ្នកនិពន្ធ ពិន យ៉ាថៃ ដែលពន្យល់ថា ព្រះពុទ្ធមានអាយុកាលជាង១៩សតវត្សរ៍បានទស្សន៍ទាយថា ប្រទេសនេះនឹងត្រូវផ្លាស់ប្តូរទាំងស្រុង ផ្ទះអត់មានមនុស្សនៅ ផ្លូវអត់មានមនុស្សដើរ មនុស្សអវិជ្ជាប្រឆាំងនឹងអ្នកចេះដឹង ទមិឡនឹងកាន់អំណាចផ្តាច់ការសម្លាប់បព្វជិត ។ ប៉ុន្តែប្រជាជននឹងត្រូវបានជួយសង្គ្រោះប្រសិនបើគាត់ដាំដើមគ ដែលមានន័យថាមិនចេះនិយាយស្តី ។ ប្រស្នានេះប្រែថា មានតែអ្នកដែលគថ្លង់ទេដែលអាចរួចផុតពីសេចក្តីស្លាប់នៅអំឡុងសម័យកាលកលិយុគនេះ ។ ធ្វើគ ធ្វើថ្លង់ ។ ឥឡូវខ្ញុំដឹងថាវាជាមធ្យោបាយសង្គ្រោះជីវិត ។ ធ្វើពុតជាគថ្លង់ កុំនិយាយអ្វីទាំងអស់ កុំស្តាប់អ្វីទាំងអស់ កុំយល់អ្វីទាំងអស់ ។

ក្នុងផ្លូវអាណាចក្រ ទំនាយនេះបានធ្វើឲ្យខ្មែរមានទស្សនៈពីរគឺភាពបរិសុទ្ធ និងភាពពិសពុល ដែលមានភាពផ្ទុយគ្នារវាងព្រះពុទ្ធនិងមារ ធម៌និងអធម៌ សណ្តាប់ធ្នាប់និងភាពចលាចល ការស្រុះស្រួលនិងការបែកបាក់ ។

ដើម្បីស្វែងយល់ពីនយោបាយចងចាំក្នុងប្រទេសកម្ពុជាឲ្យកាន់តែច្បាស់ យើងមិនត្រឹមតែសម្លឹងមើលរចនាសម្ព័ន្ធពិភាក្សាថ្នាក់ជាតិប៉ុណ្ណោះទេ តែក៏ត្រូវមើលទៅលើការពិភាក្សាថ្នាក់សហគមន៍និងថ្នាក់ក្រោមៗផងដែរ ។ ក្នុងឧទាហរណ៍ជាច្រើនយើងឃើញមានភាពដូចគ្នា ។ ប៉ុន្តែវាក៏មានចំណុចខុសគ្នាសំខាន់ៗដែរ ដូចជាការពិភាក្សារបស់អ្នកកាន់ព្រះពុទ្ធសាសនានៅតាមសហគមន៍ក្នុងអំឡុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាជាដើម ។

ការលេចចេញម្តងទៀតនេះគឺដោយសារព្យុហយាត្រាសន្តិភាព មហាឃោសនន្ទា នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ដែលអះអាងពីការរស់ឡើងវិញនៃព្រះសង្ឃ និងព្រះធម៌ (តាមរយៈការដាំកូនឈើនិងការប្រមូលផ្តុំធ្វើធម្មយាត្រា) ដែលមានសារសំខាន់សម្រាប់បោសសម្អាតឧបទ្រពចង្រៃនៅក្នុងប្រទេសកម្ពុជានិងការបំបាត់ចោលកំហឹង (ដោយការបាចទឹកមន្តរំដោះគ្រោះ) និងការចង់បានសន្តិភាព គឺជានិមិត្តរូបនៃធម្មយាត្រាដែលឆ្លងកាត់គ្រប់តំបន់ក្នុងប្រទេសកម្ពុជា រួមទាំងតំបន់សង្គ្រាម បច្ចុប្បន្ននិងអតីតកាល ។

ពេលថ្មីៗនេះ ការពិភាក្សាតាមរយៈអ្នកកាន់ព្រះពុទ្ធសាសនាមានភាពមិនចុះសម្រុងជាមួយនឹងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សជាសាកលដែលផ្សារភ្ជាប់ទៅនឹងវិធីនៃការចងចាំពីអតីតកាលមួយគឺការផ្តួចផ្តើមបង្កើតឲ្យមានសាលាក្តី ។ ខណៈដែលព្រះពុទ្ធសាសនាលើកកម្ពស់ការយល់ដឹងពីអតីតកាលដែលជាឧឡារិករណ៍សម្រាប់ការបង្កើតសាលាក្តី វាក៏អះអាងពីសារសំខាន់នៃការបំភ្លេចអតីតកាល បំបាត់កំហឹង និងការពាក់ព័ន្ធទាំងឡាយដែរ ។ ផ្អែកលើអ្វីដែលបានលើកឡើង គោលគំនិតទាំងនេះផ្ទុយពីការអះអាងដែលថាសាលាក្តីនឹងជំរុញឲ្យប្រជាជនខ្មែរទទួលបានយុត្តិធម៌ ឲ្យគេអាចព្យាបាលជំងឺផ្លូវចិត្តនិងដើម្បីពង្រឹងការអនុវត្តច្បាប់នៅកម្ពុជា ។ សេចក្តីថ្លែងការណ៍ទាំងនេះ គឺផ្សារភ្ជាប់ទៅនឹងគំរូរបស់តុលាការបស្ចិមប្រទេសតាមគោលគំនិតនៃការអត់ឱនរបស់គ្រិស្តសាសនានិងដំណើរការផ្លូវចិត្តជាសកល ។

## នយោបាយនៃការចងចាំក្នុងពេលបច្ចុប្បន្ន

រឿងនេះត្រូវបានសរសេរឡើងនៅពេលបច្ចុប្បន្ន ដោយសារប្រទេសកម្ពុជាបន្តដោះស្រាយភាពសាំញ៉ាំនៃអតីតកាលនៅពេលដែលសាលាក្តីមួយចាប់ផ្តើម ។ នៅត្រង់ចំណុចនៃប្រវត្តិសាស្ត្រកម្ពុជា តើនេះជាវិធីសមស្របដើម្បីដោះស្រាយបញ្ហាអតីតកាលដែរឬទេ? តើសាលាក្តីគួរតែបន្ថែមកិច្ចការស្វែងរកយុត្តិធម៌និងការចងចាំ ដូចជាគណៈកម្មការស្វែងរកការពិត ឬការដោះស្រាយតាមរយៈពិធីធ្វើបុណ្យតាមបែបព្រះពុទ្ធសាសនាដែរឬទេ? ឬ តើប្រជាជនគួរតែបំបាត់កំហឹងរបស់គេ បំភ្លេចអតីតកាលនិងគិតពីអនាគតឬទេ?

នៅពេលខ្ញុំគិតដល់សំណួរមួយនេះ ខ្ញុំចង់ដឹងថាមនុស្សដូច ឆ្វាត អាចនឹងឆ្លើយតបយ៉ាងដូចម្តេច ។ ខ្ញុំមិនអាចសួរគាត់សោះ ។ ពេលចុងក្រោយដែលខ្ញុំបានជួបគាត់នៅរដូវប្រាំង ឆ្នាំ២០០៣ គាត់មានរូបរាងស្គម ហើយឈឺជាញឹកញាប់ ។ គាត់បានពន្យល់ដោយស្នាមញញឹមថា គាត់មានមេរោគក្នុងខ្លួនដែលប្រតិកម្មនឹងថ្នាំដោយក្តាប់ដៃដើម្បីបង្ហាញពីរបៀបដែលមេរោគធ្វើទុករាល់ពេលគាត់លេបថ្នាំម្តងៗ ។ យើងបានជជែកគ្នាពីអតីតកាលមុនពេលគាត់ហូបបាយល្ងាចជាមួយមិត្តភក្តិម្នាក់ទៀត និងកូនប្រុសរបស់គាត់ ។ ច្រើនខែកន្លងមក ខ្ញុំបានទទួលដំណឹងពីមិត្តភក្តិរបស់គាត់ប្រាប់ថា ឆ្វាត សម្រាកនៅមន្ទីរពេទ្យរង់ចាំសេចក្តីស្លាប់ប៉ុណ្ណោះ ។ គាត់មានផ្ទុកមេរោគអេដស៍ ប៉ុន្មានថ្ងៃក្រោយមកក៏ស្លាប់ ។

ខ្ញុំគិតថា ឆ្វាត ចង់បានសាលាក្តីមួយ ទោះបីជាខ្ញុំដឹងហើយថាគាត់ព្រួយបារម្ភពីអំពើពុករលួយនៃប្រព័ន្ធតុលាការកម្ពុជា ការលោភលន់ពុតរបស់សហគមន៍អន្តរជាតិនិងការដែលមិនអាចទៅជួបជាមួយកម្មាភិបាលដែលបានបញ្ជូនបងប្រុសគាត់ទៅសម្លាប់នៅវត្តភ្នំប្រុស ។ ខ្ញុំស្រមៃដល់ចម្លើយដែលគាត់ឆ្លើយក្នុងទីងងឹត មុខបាំងដោយផ្សែងបារី ហើយភ្លើងបារីដែលកំពុងឆេះប្រៀបដូចការចងចាំរបស់គាត់ដែលក្រោយមកក្លាយជាផេះផង ។ **អាឡិច ហ៊ីនតុន**

***(តមកពីទំព័រទី១)***

នៅទូទាំងអាស៊ី ស្លឹករឹតតំណាងឲ្យសោភ័ណភាពនៃចំណេះដឹងនិងអំណាចនៃការរក្សាមនុស្សនៅសម័យគ្រោះថ្នាក់ ។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ដីមួយកន្លែងដល់វិទ្យាស្ថានយើងនៅភ្នំពេញ ហើយថែមទាំងផ្តល់សិទ្ធិឲ្យយើងធ្វើការបណ្តុះបណ្តាលផ្នែកអប់រំនៅថ្ងៃអនាគត ។ បច្ចុប្បន្ន យើងកំពុងធ្វើការជាមួយស្ថាបត្យករក្នុងស្រុកជាន់ខ្ពស់និងអន្តរជាតិ ដើម្បីរៀបចំកសាងវិទ្យាស្ថាននិងចាប់ផ្តើមយុទ្ធនាការសាងសង់និងប្រតិបត្តិការនៅក្នុងវិទ្យាស្ថានស្លឹករឹត ។

**ទស្សនៈវិស័យសម្រាប់វិទ្យាស្ថានស្លឹករឹត**

ចាប់តាំងពីឆ្នាំ១៩៩៥ យើងមានកិត្តិនាមជាអ្នកដឹកនាំអន្តរ-ជាតិដើម្បីស្វែងរកការចងចាំនិងយុត្តិធម៌ ។ បេសកកម្មរបស់យើងមានបំណងធ្វើការជាមួយអនាគតជាជាងអតីតកាល ។ វិទ្យាស្ថានស្លឹករឹតបង្កើតឡើងក្នុងគោលបំណងប្រហាក់ប្រហែលគ្នា ។

◆ សារមន្ទីរ ៖ វិទ្យាស្ថាននឹងរក្សាការចងចាំអ្នកជាទីស្រឡាញ់ដែលបានបាត់បង់ជីវិត ជំរុញឲ្យមានការផ្សះផ្សា និងការអភ័យទោស ព្រមទាំងបង្ហាញពីឥទ្ធិពលនៃវប្បធម៌ខ្មែរក្នុងការរក្សានិងជម្នះអ្វីដែលនៅសេសសល់ដ៏ខ្មៅងងឹតពីរបបខ្មែរក្រហម ។

◆ មជ្ឈមណ្ឌលស្រាវជ្រាវ ៖ ក្នុងនាមជាបណ្ណាល័យសិល្បៈវានឹងបន្តការងាររបស់ក្រុង រៀបចំ វិភាគនិងរក្សាព័ត៌មានអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងរយៈពេលផ្សេងទៀតដែលប្រជាជនធ្លាប់រងការឈឺចាប់ដ៏ធ្ងន់ធ្ងរ ។ ការស្រាវជ្រាវរបស់បញ្ញវន្តនៅវិទ្យាស្ថាននឹងជំរុញឲ្យមានការទទួលខុសត្រូវ ព្រមទាំងឲ្យមានការយល់ដឹងយ៉ាងជ្រាលជ្រៅអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា និងព្រឹត្តិការណ៍នៅកន្លែងផ្សេងទៀតដែលកើតឡើងដោយជម្លោះនិងសោកនាដកម្ម ។

◆ វិទ្យាស្ថានអប់រំ ៖ វិទ្យាស្ថាននេះនឹងបណ្តុះបណ្តាលប្រជាជនកម្ពុជានិងភ្ញៀវអន្តរជាតិអំពីមេរៀននៃអតីតកាល និងគោលការណ៍នៃច្បាប់ និងសិទ្ធិមនុស្សដើម្បីជំរុញឲ្យមានអនាគតដ៏ល្អមួយ ។

◆ មជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មាន ៖ វិទ្យាស្ថាននឹងផ្សព្វផ្សាយចំណេះដឹងដ៏ទូលំទូលាយនិងជំរុញឲ្យមានភាពរឹងមាំនិងការពិភាក្សារបស់ប្រជាជនកម្ពុជានិងអ្នកដទៃទៀតអំពីតម្រូវការសម្រាប់សង្គម ។

ការសិក្សាគឺជាចំណុចសំខាន់ដែលភ្ជាប់គោលគំនិតរបស់យើង ។ ទោះបីជាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងត្រូវបញ្ចប់ក៏ដោយ ក៏ការស្រាវជ្រាវនិងការបង្រៀននៅតែបន្តប្រសិនបើមិនទាន់មានអ្នកយល់ដឹងច្បាស់ពីសោកនាដកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនកម្ពុជានឹងទទួលស្គាល់ការផ្សះផ្សានិងបទពិសោធន៍ដែលខ្លួនធ្លាប់ឆ្លងកាត់ជាមួយនឹងប្រវត្តិសាស្ត្រ ។ តាមរយៈការយល់ដឹងពីមូលហេតុនិងផលវិបាកនៃអំពើប្រល័យពូជសាសន៍ធ្វើឲ្យប្រជាជនកម្ពុជាអាចទប់ស្កាត់មិនឲ្យមានការរំលោភបំពានស្រដៀងគ្នានេះកើតឡើងម្តងទៀត ថែមទាំងអាចពង្រឹងការអនុវត្តឲ្យកាន់តែប្រសើរឡើង ។ វិទ្យាស្ថានស្លឹករឹតនឹងដើរតួនាទីសំខាន់នៅក្នុងដំណើរការផ្សះផ្សានិងអភិវឌ្ឍសង្គមឲ្យកាន់តែរីកចម្រើន ។

**ឆាំង យុ**

# ការអភិវឌ្ឍនៅកម្ពុជា

## *សុន្ទរកថារបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំរំឭកខួបរបស់បក្ស*

*សុន្ទរកថារបស់លោក ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងកិច្ចប្រជុំនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ក្នុងក្រុងភ្នំពេញ ដើម្បីរំឭកខួបលើកទីពីរនៃជ័យជម្នះថ្ងៃទី១៧ ខែមេសា និងកំណើតនៃកម្ពុជាប្រជាធិបតេយ្យ ។*

ខ្ញុំសូមអនុញ្ញាតសម្តែងនូវការគោរពដ៏ជ្រាលជ្រៅបំផុតចំពោះសមមិត្តទាំងអស់ដែលមានវត្តមាននៅទីនេះ ថ្ងៃនេះក្នុងកិច្ចប្រជុំដើម្បីប្រារព្ធពិធីជាមួយប្រជាជនយើងនៅទូទាំងប្រទេសនូវខួបលើកទីពីរនៃមហាជ័យជម្នះថ្ងៃទី១៧ ខែមេសា ថ្ងៃកំណើតកម្ពុជាប្រជាធិបតេយ្យរបស់យើងនិងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ ។

ឱកាសទាំងបីនេះធ្វើឲ្យយើងនឹកឃើញនូវមហាវីរភាពរបស់កម្មករ កសិករ និងកងទ័ពបដិវត្តន៍របស់យើង ។ ក្នុងឱកាសនេះយើងសូមគោរពវិញ្ញាណក្ខន្ធដោយស្មារតីមុតមាំនិងមនោសញ្ចេតនាបដិវត្តន៍ដ៏ជ្រាលជ្រៅចំពោះកម្មករ កសិករ កងទ័ពប្រដាប់អាវុធយុទ្ធមិត្តប្រុស-ស្រី និងកម្មាភិបាលដែលបានលះបង់គ្រប់បែបយ៉ាងក្នុងការតស៊ូដ៏តឹងតែង ស្មុគស្មាញ សាំញ៉ាំ និងលំបាក រហូតដល់ប្រទេសទទួលបានសេរីភាពពេញលេញនិងពិតប្រាកដ ដែលធ្វើឲ្យវណ្ណៈកម្មករ កសិករឥឡូវនេះក្លាយជាម្ចាស់នៃប្រទេស និងគ្រប់គ្រងជោគវាសនារបស់ខ្លួន ។

គ្រប់ពេល និងពិសេសនៅឱកាសនេះ យើងតែងតែសួរខ្លួនឯងថាតើយើងមានអ្វីដើម្បីសងគុណវីរជននិងកងទ័ពប្រដាប់អាវុធយុទ្ធមិត្តប្រុស-ស្រី និងកម្មាភិបាលដែលបានលះបង់ជីវិតដោយសេចក្តីក្លាហានសម្រាប់បុព្វហេតុរំដោះជាតិនិងប្រជាជន ។ ដើម្បីតបស្នងគុណដល់វីរបុរសរបស់យើង យើងទាំងអស់គ្នាសូមសច្ចាដោយមុតមាំថានឹងចងចាំនូវចលនាតស៊ូរបស់ប្រជាជននិងកងទ័ពយើង ដើម្បីឲ្យប្រជាជនយើងប្រកាន់យកនូវប្រពៃណីដែលបានបន្សល់ទុកដោយវីរជនរបស់យើងនៅក្នុងការប្រយុទ្ធយ៉ាងប្តូរផ្តាច់ពីអតីតកាលនាពេលថ្មីៗនេះ ។ យើងសន្យាបន្តគ្រប់ការងារបដិវត្តន៍របស់វីរជនដោយខ្សះខ្សែងព្យាយាមដើម្បីរួមចំណែកជាមួយប្រជាជន យើងទូទាំងប្រទេសការពារជាតិ កម្មករ កសិករ ផលប្រយោជន៍បដិវត្តន៍ និងខិតខំកសាងកម្ពុជាប្រជាធិបតេយ្យឲ្យអស់ពីសមត្ថភាព ។ យើងសច្ចាបំពេញការងារនេះដោយស្មារតីទទួលខុសត្រូវ និងការប្រឹងប្រែងដ៏ខ្លាំងក្លាដើម្បីសម្រេចការងារឲ្យបានជោគជ័យ ។


ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ក្នុងចុងឆ្នាំ១៩៧៧)


ខៀវ សំផន ក្នុងឆ្នាំ២០០៧

តំណក់ឈាមរបស់ប្រជាជននិងកងទ័ពបដិវត្តន៍យើងប្រាកដជាជំរុញឲ្យយើងទាំងអស់គ្នាពង្រឹងនិងអភិវឌ្ឍជំហរបដិវត្តន៍របស់យើង ដោយកែប្រែឲ្យទៅជាកម្លាំងកាន់តែខ្លាំងក្នុងការបំពេញកាតព្វកិច្ចបដិវត្តន៍ក្នុងពេលបច្ចុប្បន្ន ។ ឥឡូវនេះបន្ទាប់ពីកម្ចាត់ពួកចក្រពត្តិនិយមអាមេរិកនិងអាយ៉ងរបស់វាចេញពីប្រទេសយើង កម្មករ កសិករ និងទាហានបដិវត្តន៍របស់យើងបានក្លាយជាចៅហ្វាយនាយនៃប្រទេស ។ អំឡុងពីរឆ្នាំចុងក្រោយ ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិង

ច្បាស់លាស់នៃអង្គការបដិវត្តន៍របស់យើង កម្មករ កសិករនិងទាហានបដិវត្តន៍របស់យើងបានទទួលស្នាដៃធំធេងជាច្រើនដទៃទៀត ជាពិសេសស្នាដៃដែលបញ្ជាក់ពីសមត្ថភាពយ៉ាងច្បាស់លាស់ទាំងវិស័យការពារជាតិនិងរដ្ឋបាល និងវិស័យកសាងជាតិ ដោយផ្អែកលើគោលការណ៍ឯករាជ្យនិងម្ចាស់ការលើខ្លួនឯង ។

ជ័យជម្នះអំឡុងពីរឆ្នាំចុងក្រោយនេះ គឺដោយសារកងទ័ពដែលមានតួនាទីដ៏សំខាន់និងក្លៀវក្លាបានតស៊ូជម្នះខបសត្រូវរាប់ពាន់ដំពូក ។ ក្នុងវិស័យការពារប្រទេសកម្ពុជាប្រជាធិបតេយ្យ ដោយផ្តោតទៅលើកម្មករ កសិករ និងថែរក្សាសមិទ្ធផលបដិវត្តន៍កម្ពុជាកន្លងមក យើងអាចធ្វើបានទាំងស្រុងដោយប្រើប្រាស់ចំណេះវិជ្ជានិងមិនមានភាពស្មុគស្មាញ ព្រមទាំងការព្រួយបារម្ភ ព្រោះថាមានការសហការពីសហជីពកម្មករ កសិករ និងមូលដ្ឋានផ្សេងៗទៀត ។ កងទ័ពយើងមិនអនុញ្ញាតឲ្យសត្រូវចូលឈ្លានពានដែនដីគោកនិងដែនទឹកបានឡើយ ហើយក៏មិនឲ្យសត្រូវបំផ្លាញបដិវត្តន៍កម្ពុជាដែរទោះពីខាងក្រៅឬខាងក្នុង ។

យើងមិនត្រឹមតែទទួលជោគជ័យលើការការពាររបបកម្ពុជាប្រជាធិបតេយ្យ និង កម្មករ កសិករប៉ុណ្ណោះទេ យើងថែមទាំងអាចការពារអ្វីៗដែលជាកម្មសិទ្ធរបស់យើង និងបង្កើតលក្ខណ្ឌកាន់តែល្អប្រសើរនិងគួរឲ្យទុកចិត្តសម្រាប់កិច្ចការពារនាពេលអនាគត ស្ថានភាពការពារជាតិកំពុងរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។ ជាពិសេសស្ថានភាពនៅឆ្នាំ១៩៧៧ គឺល្អប្រសើរខ្លាំងជាងស្ថានភាពឆ្នាំ១៩៧៦ ដូច្នេះយើងអាចពង្រឹងនិងពង្រីកការងារកម្មករ កសិកររបស់យើង ។

ភ្លាមៗបន្ទាប់ពីរំដោះប្រទេស នៅពេលយើងបានជួបការលំបាកដោយសារយើងទើបងើបពីសង្គ្រាមចក្រពត្តិអាមេរិកដ៏ខ្ទេចខ្ទាំ សត្រូវមិនបានបង្កបញ្ហាធ្ងន់ធ្ងរទេ ។ ពេលនេះសត្រូវមិនអាចធ្វើអ្វីយើងបានទេ ។ នេះជាជំនឿដ៏មុតមាំរបស់យើងដោយមានភ័ស្តុតាងច្បាស់លាស់និងជាក់ស្តែង ។ ទោះជាយ៉ាងនេះក្តីយើងត្រូវបន្តកិច្ចការពាររបបកម្ពុជាប្រជាធិបតេយ្យ ការពារកម្មករ កសិកររបស់យើង និងថែរក្សាសមិទ្ធផលបដិវត្តន៍កម្ពុជាដោយកម្ចាត់សត្រូវគ្រប់ទិសទី ការពារមិនឲ្យខ្មាំងចូលឈ្លានពានជ្រៀតជ្រែកឬធ្វើវិទ្ធង្សនាបានឡើយ ។ យើងត្រូវកម្ចាត់សត្រូវខាងក្នុង យើងជាម្ចាស់នៃស្ថានការណ៍ ដោយដើរតាមគោលនយោបាយក្នុងប្រទេស បរទេស និងគោលនយោបាយកងទ័ពនៃអង្គការបដិវត្តន៍ ។ អ្វីៗត្រូវធ្វើដោយមានរបៀបនិងហ្មត់ចត់ ។ យើងមិនត្រូវភ្លេចភ្លាំងនិងធ្វេសប្រហែសដោយសារជ័យជម្នះពីអតីតកាលនោះទេ ។ ផ្ទុយទៅវិញ យើងត្រូវពង្រឹងខ្លួន បន្ថែមការប្រុងប្រយ័ត្ន រក្សាស្មារតីបដិវត្តន៍ និងបន្តវាយបំផ្លាញសត្រូវគ្រប់ទិសទីនិងគ្រប់ពេលវេលា ។

ក្នុងវិស័យកសាងជាតិ យើងក៏ទទួលបានជោគជ័យសំខាន់ៗផងដែរនៅអំឡុងពីរឆ្នាំចុងក្រោយនេះ ។ បន្ទាប់ពីយើងងើបពីសង្គ្រាម យើងមានតែដៃទទេ និងអត់អាហារ សម្ភារៈនិងគោក្របី ។ យើងជួបការលំបាកយ៉ាងខ្លាំង ។ ប៉ុន្តែ យើងបានស្តារសេដ្ឋកិច្ចនិងកសាងប្រទេសឡើងវិញដោយឯករាជ្យនិងម្ចាស់ការលើខ្លួនឯង ។

នេះជាមេរៀននិងបទពិសោធន៍ដ៏អស្ចារ្យ ។ នៅឆ្នាំ១៩៧៦ យើងអាចដោះស្រាយបញ្ហានិងសម្រេចផែនការផលិតកម្ម ។ ជាលទ្ធផល យើងប្រមូលបានទិន្នផលខ្ពស់សម្រាប់ឆ្នាំ១៩៧៧ ។ ឥឡូវនេះ រដ្ឋយើងអាចចែកអាហារគ្រប់គ្រាន់ដល់ប្រជាជន ។ យើងថែមទាំងសល់សម្រាប់នាំចេញទៅក្រៅប្រទេសទៀតផង ។ ដូច្នេះ រឿងនេះគួរតែកត់ត្រាក្នុងប្រវត្តិសាស្ត្រ ។ យើងអាចទទួលជ័យជម្នះបាន ដោយសារយើងដើរតាមជំហរនៃការម្ចាស់ការឯករាជ្យ ស្មារតីស្នេហាជាតិខ្ពស់និងស្មារតីបដិវត្តន៍ខ្ពស់ ។

ឥឡូវយើងពិចារណាពីលទ្ធផលនៃការអនុវត្តផែនការឆ្នាំ១៩៧៧ របស់អង្គការបដិវត្តន៍ក្នុងរយៈពេលបីខែដំបូង ។ យើងឃើញថា លទ្ធផលលើសពីឆ្នាំ១៩៧៦ទៅទៀត ។ ប្រជាជនយើងកាន់តែពេញចិត្តនិងពោរពេញដោយការតស៊ូដើម្បីកសាងជាតិ ។ ដំបូង កម្មករ កសិករយើងសប្បាយចិត្តកាន់តែខ្លាំងជាមួយនឹងការគ្រប់គ្រងថ្មី ។ កសិករក្រីក្រ និងកសិករកណ្តាលថ្នាក់ក្រោមសប្បាយរីករាយ ហើយកសិករកណ្តាលក៏សប្បាយរីករាយដូចគ្នាដែរ ។ ក្រៅពីនេះ ប្រជាជនដទៃដែលមកពីភ្នំពេញជាអ្នកស្នេហាជាតិដែរនោះ ឃើញកាន់តែច្បាស់ពីការគ្រប់គ្រងនេះ គឺត្រឹមត្រូវជាតិនិយមនិងឯករាជ្យ ។ ប្រជាជនកាន់តែដឹងច្បាស់ថា ការដើរតាមគោលនយោបាយឯករាជ្យគឺមិនងាយស្រួលទេ និងដឹងទៀតថា

មាគ៌ានេះមិនងាយសម្រេច ហើយយើងដឹងពីផលពិបាក ប៉ុន្តែវាជាមាគ៌ាដ៏ថ្លៃថ្នូរ ។ ដូច្នេះប្រជាជនកាន់តែមានការប្តេជ្ញាចិត្តខ្ពស់ ។

សម្រាប់ហេតុផលនេះ ការផ្លាស់ប្តូរដ៏ខ្លាំងបានកើតឡើងក្នុងសង្គមជាតិយើង ។ ជាមួយនេះ កងកម្លាំងយើងកំពុងកើនឡើង យើងមានអាហារគ្រប់គ្រាន់ សុខភាពប្រជាជនល្អប្រសើរជាងមុន មានថ្នាំសង្កូវច្រើនជាងមុន គោក្របីធំជាងកាលពីឆ្នាំ១៩៧៦ ឧបករណ៍សម្ភារៈផ្សេងៗល្អ និងសម្បូរបែបជាងកាលពីឆ្នាំ១៩៧៦ ។ ទន្ទឹមនឹងនេះ យើងកាន់តែមានបទពិសោធន៍ យើងអាចរៀបចំកងកម្លាំងល្អប្រសើរ កម្មករយើងមានវិន័យជាងមុន ការងារបានល្អប្រសើរតាមរយៈការផ្លាស់វេន មានកាលវិភាគ ហើយមានពេលសម្រាកដើម្បីឲ្យកម្មករបំប៉នកម្លាំងឡើងវិញ ។

ដូច្នេះ ការប្រឹងប្រែងកសាងប្រទេសក្នុងឆ្នាំ១៩៧៧ គឺខ្លាំងក្លាជាងឆ្នាំ១៩៧៦ ។ ក្រុមបង្កបង្កើនផលយើងខ្លះបានសម្រេចផែនការឆ្នាំ១៩៧៧រួចហើយ ដូចជាក្រុមបង្កបង្កើនផលអំបិលជាដើម ។ ក្រុមនេះសម្រេចផែនការឆ្នាំ១៩៧៧ បាន១៦០ភាគរយ ។ ដូច្នេះឥឡូវនេះយើងមានអំបិលគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការប្រជាជនយើង ។ អំបិលជាផលិតផលយុទ្ធសាស្ត្រដែលធ្លាប់បង្កការលំបាកដល់យើង ។ ឥឡូវយើងអាចដោះស្រាយការលំបាកនេះបាន ។ នេះជាជោគជ័យដ៏ធំធេងមួយទៀតដែលយើងទទួលបាន ។

ក្រុមចម្រើនមួយក្រុមទៀត គឺក្រុមបង្កបង្កើនផលកៅស៊ូ ។ ក្រុមនេះសម្រេចផែនការត្រីមាសបាន១០០ភាគរយ ។ កៅស៊ូគឺជាផលិតផលសំខាន់មួយសម្រាប់នាំចេញ ។ វាជាផលិតផលបង្កើនចំណូលទីពីរបន្ទាប់ពីស្រូវដើម្បីផ្គត់ផ្គង់កម្លាំងកសាងជាតិ ។ ដូច្នេះ ការសម្រេចដ៏មានប្រសិទ្ធភាពនៃផែនការឆ្នាំ១៩៧៧របស់អង្គការបដិវត្តន៍គួរតែចាត់ទុកជាជោគជ័យដ៏ធំធេងមួយទៀតសម្រាប់យើង ។

លើសពីនេះ នៅគ្រប់ការដ្ឋានសាងសង់ទំនប់ អាងស្តុកទឹក និងប្រឡាយ ក្រុមការងារជាច្រើនបានបញ្ចប់ផែនការឆ្នាំ១៩៧៧រួចហើយ ហើយកំពុងជួយក្រុមការងារដទៃដើម្បីបំពេញការងារលើវិស័យផ្សេងទៀត ។ យើងអាចមើលឃើញក្រុមចម្រើនផលទាំងនេះនៅគ្រប់តំបន់និងស្រុក ។ មកដល់ពេលនេះ ការដ្ឋានជាច្រើនបានសម្រេចការងារបាន៦០ទៅ៧០ភាគរយហើយ ។ នៅកម្រិតនេះ គម្រោងជីកប្រឡាយនឹងបញ្ចប់១០០ភាគរយត្រឹមចុងខែមេសា ។ ការដ្ឋាននៅទូទាំងប្រទេស ទាំងអស់នឹងសម្រេចផែនការនៅត្រឹមចុងខែឧសភា ឆ្នាំ១៩៧៧ ។ គម្រោងទាំងនេះរួមមានទំនប់សម្រាប់ស្រោចស្រពវាលស្រែពេញមួយឆ្នាំ និងអាងស្តុកទឹកស្ទឹងព្រែកត្នោត ជីនិត និងស្ទឹងដទៃទៀត ។ ជាងនេះទៅទៀត យើងកំពុងសង់អាងស្តុកទឹកធំៗដែលអាចស្តុកទឹកបានរាប់រយលានម៉ែត្រគូប និងអាងស្តុកតូចៗ និងមធ្យមដែលអាចស្តុកទឹក២០លានម៉ែត្រគូប និង១០លានម៉ែត្រគូប ដែលរំពឹងទុក ។ នៅពេលជាមួយគ្នានេះដែរ យើងកំពុងសាងសង់ស្ថានីយបូមទឹកជាច្រើនកន្លែងទៀត ។

ដូច្នេះ យើងមើលឃើញថា ជនបទកំពុងផ្លាស់ប្តូរយ៉ាងខ្លាំង ។ ការដ្ឋានអាងស្តុកទឹក ប្រឡាយ ឬទំនប់នីមួយៗមានកម្មករមួយម៉ឺន ឬពីរម៉ឺន ឬរហូតដល់បីម៉ឺននាក់ ។ ដោយសារហេតុផលនេះ ការងាររីកចម្រើនយ៉ាងលឿន ។ នៅជនបទ នៅខែមីនា និងខែមេសា ធ្លាប់ស្ងួតហួតហែង ។ ប៉ុន្តែ ឥឡូវស្រូវប្រាំងរាប់ពាន់ហិចតាដុះនៅកន្លែងជាច្រើន ទឹកហូរដោរជន់ ទេសភាពស្រស់បំព្រង រុក្ខជាតិស្រស់បំព្រង ជីវិតស្រស់ថ្លា ហើយប្រជាជនញញឹមស្រស់ស្រាយ ។

តើភាពជោគជ័យទាំងនេះកើតឡើងដោយសារគ្រឿងម៉ាស៊ីនឬ? ទេ យើងមិនមានគ្រឿងម៉ាស៊ីនទេ ។ យើងធ្វើអ្វីសព្វបែបយ៉ាងដោយពឹងផ្អែកជាសំខាន់ទៅលើកម្លាំងប្រជាជន ។ យើងម្ចាស់ការទាំងស្រុងលើខ្លួនឯង ។ នេះបង្ហាញពីវីរភាពដ៏ខ្លាំងលើសលប់របស់ប្រជាជនយើង ។ វាក៏បង្ហាញកម្លាំងដ៏អស្ចារ្យរបស់ប្រជាជនយើងដែរ ។ យើងអាចធ្វើអ្វីគ្រប់យ៉ាងទោះជាយើងមានតែដៃទទេក៏ដោយ ។ កងទ័ពមានកម្លាំងខ្លាំងក្លានៅពេលធ្វើសង្គ្រាមប្រឆាំងពួកចក្រពត្តិឈ្លានពានអាមេរិក ហើយនឹងមានកម្លាំងជំរុញខ្លាំងក្លាដើម្បីកសាងប្រទេស ។

ចលនាប្រមូលជីក៏កំពុងរីកលូតលាស់ខ្លាំងណាស់ដែរ ។ មានជីល្បាប់ ជីលាមកសត្វ ជីបន្លែ និងជីដទៃទៀត ។ សារធាតុបន្ថែមទៅលើជីត្រូវបានប្រមូលមកពីគ្រប់ផ្នែក ។ យើងមិនបានចំណាយ សូម្បីតែមួយសេនសម្រាប់ការនាំចូលជី ។ ជាមធ្យម ជីបីគោនត្រូវ

បាចលើដីដាំផងមួយហិចតា ។ នៅតំបន់ដទៃត្រូវដាក់ជីបន្ថែមទៀត ។

គោនិងក្របីគឺជាមិត្តរួមអាវុធជិតស្និទ្ធដាំងគេក្នុងយុទ្ធនាការកសាងជាតិរបស់យើង ។ ឆ្នាំនេះគោយើងមានសុខភាពល្អ ហើយធាត់ ព្រោះយើងបានចាត់ចែងកម្លាំងថែរក្សាវាបានល្អជាងឆ្នាំមុន ។ កងកម្លាំងនេះដើររកស្មៅធ្វើក្រោល និងរកខសដុត (ដេញមូសពេលយប់) ។ បើគោយើងខិតខំធ្វើការ យើងអាចកសាងប្រទេសបានឆាប់រហ័សព្រោះយើងមិនបានប្រើគ្រឿងម៉ាស៊ីនដើម្បីបំពេញការងារទេ ។ យើងពឹងផ្អែកលើកម្លាំងគោ ក្របី និងជីហរឯករាជ្យ និងម្ចាស់ការលើខ្លួនឯង ។ ក្រោយមក ពេលដែលយើងមានលុយច្រើន យើងនឹងទិញម៉ាស៊ីនជាបណ្តើរ ដើម្បីជួយដល់កងកម្លាំងរបស់យើង ។ ទន្ទឹមនឹងនេះ យើងនឹងព្យាយាមផលិតឧបករណ៍និងម៉ាស៊ីនដោយខ្លួនយើង ។ យើងនឹងចាប់ផ្តើមពីដៃទទេ រហូតដល់មានអ្វីមួយពីតិចតួចទៅច្រើននិងពីតូចទៅធំ ។ នេះគឺជាគោលការណ៍កសាងជាតិនៃអង្គការបដិវត្តន៍ដែលពឹងផ្អែកលើខ្លួនឯង ។ វិស័យផលិតថ្នាំសម្លាប់សត្វល្អិតក៏ទទួលការរីកចម្រើនខ្លាំងដែរ ។

តើមានការផ្លាស់ប្តូរអ្វីខ្លះចំពោះជីវភាពរស់នៅរបស់ប្រជាជនយើង? លក្ខណរស់នៅរបស់ប្រជាជនយើងពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្លាំងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីព្យាយាមបង្រួបបង្រួម និងពង្រីកការងារកម្មករកសិករ និងកម្លាំងកសាងជាតិរបស់យើង ។ ប្រទេសយើងមានប្រជាជនតិចដែលចាំបាច់ឲ្យយើងត្រូវពង្រឹងនិងពង្រីកចំនួនប្រជាជន ការពារកម្លាំងដែលមានស្រាប់ ចិញ្ចឹមបីបាច់កម្លាំងដែលមានស្រាប់និងពង្រីកកម្លាំងថ្មី ។ នេះជាគោលនយោបាយដឹកនាំដោយអង្គការបដិវត្តន៍ ។ ដូច្នេះយើងត្រូវអភិវឌ្ឍប្រជាជនយើង ។ យើងចែកអង្ករបីកំប៉ុង ពីរកំប៉ុងកន្លះ ពីរកំប៉ុងតូចគ្រប់គ្រាន់រៀងរាល់ថ្ងៃ ។ ជាងនេះទៀត យើងមានបន្លែម ។ កាលពីមុន តើកសិករក្រីក្រនិងកសិករកណ្តាលថ្នាក់ទាបហូបអាហារឆ្ងាញ់ប៉ុន្មានដងក្នុងមួយខែ? កម្រណាស់ ។ ប្រជាជនអាចហូបតែផ្លែត្របែកនិងផ្លែឈើដទៃ ។ ជាមធ្យម ប្រជាជនឥឡូវនេះហូបបន្អែមបីដងក្នុងមួយខែដែលគ្រប់គ្រាន់សម្រាប់ថែរក្សាសុខភាពនិងធ្វើឲ្យគាត់ធាត់ ។ តើសុខភាពប្រជាជនយើងនៅពេលបច្ចុប្បន្ននេះយ៉ាងដូចម្តេចហើយ? ជាទូទៅ សុខភាពអ្នកទាំងអស់គឺល្អទាំងយុទ្ធជននៅភូមិភាគរំដោះនិងអ្នកចំណូលថ្មី ។ យើងមិនអាចដឹងថា នរណាជាកសិករជនទាន់ចាស់ហើយនរណាជាអ្នកចំណូលថ្មីទេ ។ ជំងឺគ្រុនចាញ់ក៏មិនសូវរាតត្បាតដូចឆ្នាំមុនដែរ ។ម្យ៉ាងដោយសាររបបអាហារគ្រប់គ្រាន់ កម្មករសម្រាកបានគ្រប់គ្រាន់ ហើយថ្នាំសង្កូវក៏មានច្រើនដែរ ។ ម្យ៉ាងទៀត គឺយើងបានអនុវត្តន៍កម្មវិធីប្រឆាំងជំងឺគ្រុនចាញ់ជាច្រើន ។ ដោយសារហេតុផលនេះ ការប្រមូលទិន្នផលឆ្នាំនេះកម្លាំងការងារស្ទើរតែគ្រប់គ្នាបានចូលរួម ។ យើងអាចប្រមូលទិន្នផលបានយ៉ាងឆាប់រហ័សដែលខុសពីឆ្នាំមុន ។

មន្ទីរពេទ្យ ៈ គ្រប់សហករណ៍ទាំងអស់មានមន្ទីរពេទ្យនិងបន្ទប់ពិសោធន៍សម្រាប់ផ្សំថ្នាំផ្ទាល់ខ្លួន ។ បន្ទប់ពិសោធន៍ទាំងនេះមាននៅគ្រប់សហករណ៍ ស្រុក តំបន់ ភូមិភាគ និងនៅទីក្រុងភ្នំពេញ ។ បន្ទប់ពិសោធន៍ឱសថមានគ្រប់ទីកន្លែង ហើយបើទោះបីជាវាស្ថិតនៅអគារចាស់ដដែល យើងក៏ត្រៀមខ្លួនរួចហើយដើម្បីពង្រីកនិងធ្វើឲ្យទំនើប ។ ជាងនេះទៀត នៅទីក្រុងភ្នំពេញសមមិត្តរបស់យើងកំពុងសិក្សាបច្ចេកទេសវេជ្ជសាស្ត្រកាន់តែបានទូលំទូលាយ ។ យើងមានពេទ្យឆ្អឹង ពេទ្យវះកាត់ ទន្តពេទ្យ ចក្ខុពេទ្យ និងអ្នកជំនាញត្រចៀក ច្រមុះ និងបំពង់ក ។ ដូច្នេះ ពីមួយឆ្នាំទៅមួយឆ្នាំយើងទទួលបានអ្នកជំនាញវេជ្ជសាស្ត្រកាន់តែច្រើនដើម្បីបម្រើប្រជាជនយើងឲ្យកាន់តែមានប្រសិទ្ធភាព ។

សម្លៀកបំពាក់ៈ យើងមិនទាន់ស្ថិតនៅដំណាក់កាលលេងម៉ូត ឬស្លៀកពាក់ស្អាតបាតទេ ប៉ុន្តែយើងមានសម្លៀកបំពាក់គ្រប់គ្រាន់ ។ ដូច្នេះយើងអាចនិយាយថា លក្ខណរស់នៅរបស់កសិករក្រីក្រ និងកសិករថ្នាក់កណ្តាល និងថ្នាក់ក្រោមរីកចម្រើនជាងមុន ។

ទាក់ទងនឹងលំនៅឋាន យើងបានចាប់ផ្តើមសាងសង់ផ្ទះតាមផែនការ ។ ស្រុកនិងតំបន់នីមួយៗមានគម្រោងសាងសង់ផ្ទះរៀងខ្លួនដើម្បីផ្តល់ជម្រកដល់ប្រជាជន ។ ចំនួនផ្ទះដែលត្រូវសាងសង់ប្រចាំឆ្នាំអាស្រ័យលើសម្ភារៈជាក់ស្តែងនៅតាមតំបន់នីមួយៗ ។ នៅទីកន្លែងខ្លះគេសង់ផ្ទះស្អាតៗ ហើយចែកដល់គ្រួសារប្រជាជន ។ សហករណ៍ថ្មីរបស់យើងកំពុងលេចរូបរាងជាបណ្តើរៗហើយ ។

ខាងវិស័យវប្បធម៌ ៈ តើមានការសិក្សារៀនសូត្រនៅ

ប្រទេសយើងទេ? ជាការពិតណាស់ មាន ប៉ុន្តែការអប់រំជាសំខាន់ធ្វើឡើងក្នុងក្របខណ្ឌរបស់សហជីពកម្មករនៅតាមរោងចក្រផ្សេងៗ ក្នុងក្របខ័ណ្ឌរបស់សហករណ៍កសិករ និងក្នុងក្របខ័ណ្ឌរបស់កងទ័ពបដិវត្តន៍នីមួយៗ ។

គោលដៅរបស់យើងគឺបំបាត់អនក្ខរភាពទាំងមនុស្សចាស់ និងកូនក្មេង ជាពិសេសក្មេងៗត្រូវតែរៀនសូត្រ ។ វាជាការចាំបាច់សម្រាប់កម្មករ កសិករយើងចេះអាននិងគណនា ។ នេះគឺជាកាតព្វកិច្ច ព្រោះវាជាការចាំបាច់សម្រាប់ពួកគាត់ក្នុងការរៀនអំពីនយោបាយនិងបច្ចេកវិទ្យា ដើម្បីពង្រឹងនិងអភិវឌ្ឍសមត្ថភាពនយោបាយនិងបច្ចេកវិទ្យានាពេលអនាគតដែលជាចំណែកមួយនៃការការពារនិងកសាងប្រទេស ដើម្បីធ្វើឲ្យប្រទេសរឹងមាំនិងខ្លាំងក្លាគ្រប់ពេលវេលា ។ ដោយសារហេតុផលនេះ យើងបានបោះពុម្ពសៀវភៅអក្ខរកម្ម និងលេខនព្វន្តជាបន្តបន្ទាប់ ។ ជាទូទៅការសិក្សាធ្វើឡើងជាចម្បងនៅក្នុងរោងចក្រនិងសហករណ៍ ។ វិធីសាស្ត្រអប់រំនេះធ្វើឲ្យសិស្សមានភាពជិតស្និទ្ធនឹងការងារនិងភាពជាក់ស្តែង ។ គោលនយោបាយអប់រំ អក្ខរកម្ម និងវប្បធម៌របស់អង្គការបដិវត្តន៍មានគោលបំណងបញ្ចូលនូវអក្សរសាស្ត្រនិងវប្បធម៌ជាមួយនឹងគំនិតការងារ ការបង្កបង្កើនផល ជាតិនិយម ការការពារជាតិ និងការកសាងជាតិ ។

នៅក្នុងរបបចាស់ តើក្មេងៗសិស្សសាលា និស្សិតដឹងពីវិទ្យាសាស្ត្រធម្មជាតិនៃជនបទស្រុកស្រែរបស់យើងដែរឬទេ? តើអ្នកទាំងអស់អាចដឹងថាស្រូវស្រាលខុសពីស្រូវធ្ងន់យ៉ាងដូចម្តេច? តើអ្នកទាំងអស់ដឹងថា គេសាបនិងស្ទូងស្រូវនៅពេលណា ឬនៅកន្លែងណាដែរឬទេ? មិនបានដឹងទេ ។ ដូច្នេះ យើងអាចនិយាយថាអ្នកទាំងអស់ឃ្លាតឆ្ងាយពីការពិត ។ ជាលទ្ធផល ពួកគេមិនអាចធ្វើអ្វីជាប្រយោជន៍ពិតប្រាកដទេ ។ ពួកគេពឹងផ្អែកទាំងស្រុងលើបរទេស ដោយរំពឹងឧបករណ៍បរទេសនិងអ្នកជំនាញបរទេសដើម្បីធ្វើការឲ្យ អ្វីសព្វបែបយ៉ាងត្រូវធ្វើតាមសៀវភៅបរទេស និងស្តង់ដារបរទេស ។ ដូច្នេះ វាគ្មានប្រយោជន៍សោះ និងមិនអាចបម្រើតម្រូវការរបស់ប្រជាជន ឬជួយកសាងជាតិរបស់យើងបានទេ ។

ផ្ទុយទៅវិញ ក្មេងៗនៅជនបទតែងតែមានចំណេះដឹងដែលមានប្រយោជន៍ ។ ក្មេងៗដឹងថា គោមួយណាសាំង ហើយគោមួយណាកាច ។ ក្មេងៗអាចជិះក្របីពីចំហៀងណាមួយក៏បាន ។ ក្មេងៗជាអ្នកឃ្វាលគោក្របី ។ ក្មេងៗអាចគ្រប់គ្រងធម្មជាតិបាន ។ ក្មេងៗស្គាល់ពូជស្រូវដូចស្គាល់ហោប៉ៅអាវពួកគេអ៊ីចឹង ។ ក្មេងៗដឹងថាស្រូវណាស្រាល ស្រូវណាធ្ងន់ ស្រូវណាទុំក្នុងរយៈពេលប៉ុន្មានជាដើម ។ ក្មេងៗចេះសាបព្រោះនិងស្ទូងសំណាប ។ ក្មេងៗដឹងថា វាលស្រែណាខ្ពស់ វាលស្រែណាទាប ។ ក្មេងៗពិតជាដឹងនិងយល់ ។ រឿងនេះទើបគេហៅថាវិទ្យាសាស្ត្រធម្មជាតិ ព្រោះចំណេះដឹងនេះទាក់ទងនឹងភាពជាក់ស្តែងរបស់ប្រទេសយើងជាមួយនឹងគំនិតជាតិនិយម ការបង្កបង្កើនផល ការកសាងជាតិ និងការការពារជាតិ ។

ក្មេងៗយើងមិនលេងឡានជ័រ ទូកជ័រ ឬកាំភ្លើងជ័រដែលនាំចូលដោយតម្លៃថ្លៃទេ ។ ក្មេងៗយើងសប្បាយចិត្តនឹងដេញចាបមិនឲ្យស៊ីដំណាំ ថែរក្សាគោក្របី ប្រមូលជីធម្មជាតិ និងជួយកសាងទំនប់ និងលើកភ្លឺស្រែ ជីកអាងស្តុកទឹក និងប្រឡាយ ។ ក្មេងៗបានអភិវឌ្ឍជាច្រើន ។ ក្មេងៗមានវិន័យល្អ ភ្ញាក់រឭក មានជំនាញក្លាហាន ប៉ុន្តែមិនក្អេងក្អាងឬកោងកាចទេ ។ ក្មេងៗស្រឡាញ់ការងារនិងផលិតកម្ម ។ ក្មេងៗស្រឡាញ់គោក្របី វាលស្រែ ចម្ការ ភ្លឺស្រែ ប្រឡាយធារាសាស្ត្រ ភូមិកំណើត ប្រទេស និងប្រជាជន ។ ក្មេងៗគោរពប្រជាជននិងនៅជិតពួកគាត់ ។ ក្មេងៗត្រូវបានបណ្តុះបណ្តាលការងារហត្ថកម្មនិងការងារស្រែចម្ការ ។ នេះជាមូលហេតុដែលយើងកោតសរសើរក្មេងៗ ។

រឿងដូចគ្នានេះកំពុងកើតឡើងនៅទីក្រុង ។ គោលបំណងរបស់យើងគឺធ្វើឲ្យការសិក្សានៅជិតស្និទ្ធនឹងការងារបង្កបង្កើនផល ។ ការសិក្សាបច្ចេកវិទ្យាក៏វិវត្តតាមបែបដែនដូចគ្នាដែរ ។ នោះគឺថា យើងរៀនជំនាញបច្ចេកទេសនិងអនុវត្តពេលយើងកំពុងធ្វើការ ។ បច្ចេកទេសជីកប្រឡាយនិងអាងស្តុកទឹកក៏ត្រូវរៀនសូត្រតាមរបៀបនេះដែរ ក៏ដូចនឹងការសាងសង់រោងចក្រនិងជំនាញជួសជុល ។ អាងស្តុកទឹក ប្រឡាយជាច្រើនដែលយើងបានសាងសង់នេះអាចនឹងចំណាយពេលច្រើនឆ្នាំ ប្រសិនណាយើងរង់ចាំអ្នកជំនាញកសិកម្មសម័យមុនមកសាងសង់ឲ្យយើង ។ នៅសម័យនោះ វាមានអ្នកជំនាញជនជាតិជប៉ុន បារាំង អង់គ្លេសក្នុងវិស័យ

នេះ ។ បើសិនណាយើងរង់ចាំវិញនោះ យើងនៅតែគ្មានទឹកសម្រាប់ដាំស្រូវនិងគ្មានស្រូវដើម្បីកសាងជាតិរាប់ឆ្នាំនោះទេ ។

យើងអាចមើលមកទំនប់ព្រែកត្នោត ។ យើងបានពុំពីគម្រោងជាយូរមកហើយ ប៉ុន្តែគ្មានអ្វីកើតឡើងទេ ។ កាលពីឆ្នាំមុនយើងចំណាយពេលតែមួយខែដើម្បីស្តុកទឹកស្ទឹងព្រែកត្នោតដែលឥឡូវនេះប្រើសម្រាប់ដាំស្រូវក្នុងស្រុកបី ។ នៅឆ្នាំ១៩៧៦ ទិន្នផលនៅកំពង់ស្ពឺខាងត្បូងល្អជាងពីមុន ។ ប្រជាជនក្នុងតំបន់នេះមានស្រូវហូបគ្រប់គ្រាន់ ហើយថែមទាំងអាចផ្គត់ផ្គង់ស្រូវដែលនៅសល់ទៅឲ្យរដ្ឋជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ខេត្តកំពង់ស្ពឺ ។

ដូច្នេះ គោលបំណងរបស់យើងគឺបម្រើចលនាកសាងជាតិនិងរៀនជំនាញបច្ចេកទេសនៅពេលជាមួយគ្នា ។ មិនថាទំនប់ឬអាងស្តុកទឹកដែលយើងបានសាងសង់នោះចំណាយពេល៩ ឬ១០ឆ្នាំ វាមិនមែនជាបញ្ហាទេ ។ ក្នុងរយៈពេល៩ ឬ១០ឆ្នាំទៅមុខយើងនឹងរីកចម្រើនកាន់តែច្រើន និងកាន់តែមានបទពិសោធន៍ជាងពេលឥឡូវនេះ ហើយយើងនឹងចាប់ជំនាញបច្ចេកទេសជាច្រើនជាងពេលឥឡូវនេះ ។

ហេតុដូច្នេះ ជាមួយការរៀនសូត្របែបនេះ យើងអាចបម្រើក្នុងវិស័យដូចជាទាហាន កសិកម្ម និងឧស្សាហកម្ម ។ ពីមុននៅភ្នំពេញ តើអ្នកធ្លាប់ឃើញជនជាតិខ្មែរណាកាន់ម៉ាស៊ីនក្រឡឹង? កម្រណាស់ ។ គ្មានជនជាតិខ្មែរណាកាន់ការងារដែលពាក់ព័ន្ធគ្រឿងម៉ាស៊ីនទេ មានតែបរទេសទេជាយន្តការី ។ ឥឡូវមានក្មេងជនជាតិខ្មែរយើងនៅគ្រប់ទីកន្លែង ។ ក្មេងៗអាចធ្វើការងារនេះបាន ។ យើងពេញចិត្តនឹងទំនោរថ្មីនេះ ។ ដូច្នេះ នេះជាដំណាក់កាលទីមួយក្នុងការកសាងបច្ចេកទេសនៃប្រទេសយើង ។ ស្ថិតក្រោមការដឹកនាំនៃអង្គការបដិវត្តន៍ វណ្ណៈកម្មករ កសិកររបស់យើងបានចាប់មានជំនាញបច្ចេកទេស បន្ទាប់ពីអង្គការបានគ្រប់គ្រងខាងអំណាចនយោបាយ ។

តើនឹងមានការរីកចម្រើនអ្វីនៅពីរឆ្នាំខាងមុខនេះ? គោលដៅរបស់យើងគឺផ្លាស់ប្តូររោងជាង គ្រឿងម៉ាស៊ីន រោងជាងជួសជុលនិងរោងជាងផលិតគ្រឿងបន្លាស់ទៅជារោងចក្រ ។ ឥឡូវនេះគ្រប់រោងជាងទាំងនៅទីក្រុងភ្នំពេញនិងក្នុងតំបន់កំពុងកែប្រែជាបណ្តើរៗតាមទិសដៅខាងលើ ។ បែបផែននៃការអភិវឌ្ឍដូចគ្នានេះកំពុងកើតឡើងក្នុងវិស័យដទៃទៀត ។

ជាធម្មតា យើងរៀនច្បាស់លាស់និងធ្វើការច្បាស់លាស់ ។ យើងចេះវិទ្យាសាស្ត្រពេទ្យមូលដ្ឋានជាជំហានៗ ។ យើងកំពុងរៀនវិទ្យាសាស្ត្រនេះបានកាន់តែទូលំទូលាយ ។ តាមរបៀបនេះយើងរំពឹងដល់អនាគតដ៏ត្រចះត្រចង់ ។ នាពេលអនាគត យើងនឹងអភិវឌ្ឍកាន់តែលឿន មិនត្រឹមតែវិស័យមួយចំនួនតូចនោះទេ ។ យើងនឹងអភិវឌ្ឍយ៉ាងឆាប់រហ័សលើគ្រប់វិស័យទូទាំងប្រទេស ។

ក្នុងវិស័យដឹកជញ្ជូនតាមទន្លេ យើងគ្មានដែកសម្រាប់សង់កប៉ាល់ទេ ។ យើងប្រើឈើជំនួសវិញ ។ ការសាងសង់កប៉ាល់មាននៅទាំងទីក្រុងភ្នំពេញនិងនៅទីជនបទ ។

កាលពីមុន យើងទិញអ្វីៗស្ទើរគ្រប់បែបយ៉ាងពីប្រទេសដទៃ ។ ឥឡូវយើងកំពុងផលិតអ្វីៗដោយខ្លួនឯង ។ បើលទ្ធផលមិនទាន់ធ្វើឲ្យពេញចិត្ត យើងអាចលួងលោមខ្លួនឯងថា យើងកំពុងព្យាយាមអភិវឌ្ឍបន្តិចម្តងៗ ។

ទាំងអស់នេះបង្កើតជាជំហរសេដ្ឋកិច្ចឯករាជ្យ ។ កំពង់ផែយើងនៅមានប្រសិទ្ធភាព នៅរក្សាបានល្អ និងដំណើរការរលូនជាងកាលពីមុន ។ វាមានប្រសិទ្ធភាពមិនចាញ់ពីកំពង់ផែធំៗលើពិភពលោកទេ ។ ក្រុមហ៊ុនដឹកជញ្ជូនបរទេសដែលចតនៅកំពង់ផែបានសរសើរយើង ។ នេះបង្ហាញថា ជំនាញបច្ចេកទេសមិនមែនជាកត្តាកំណត់ ។ ការពិត កត្តាកំណត់គឺជំហរនយោបាយនិងមនោគមន៍វិជ្ជានៃក្រុមកម្មករកំពង់ផែ ។ ជំហរថ្លៃថ្នូរ មនោគមន៍វិជ្ជាបដិវត្តន៍រឹងមាំ ស្មារតីទទួលខុសត្រូវខ្ពស់ គំនិតស្នេហាជាតិឧត្តមខ្ពង់ខ្ពស់ ហើយការប្តេជ្ញាចិត្តការពារកិត្តិយសជាតិពិតប្រាកដ ។ ទាំងអស់នេះអាចទូទាត់លើសពីជំនាញបច្ចេកទេសដែលយើងគ្មាន ។

សមរភូមិ អង្គភាព និងសមរភូមិមុខនៃការបង្កបង្កើនផលទូទាំងប្រទេសអនុវត្តន៍តាមបែបផែននេះ ។ ដូច្នេះ យើងមើលឃើញយ៉ាងច្បាស់ថា បន្ទាប់ពីការសាកល្បងពីរឆ្នាំចុងក្រោយ វប្បធម៌យើងកំពុងរីកលូតលាស់ ចំណេះដឹងបច្ចេកទេសកំពុងរីកចម្រើនយ៉ាងខ្លាំង ហើយសេដ្ឋកិច្ចក៏កំពុងអភិវឌ្ឍន៍ដែរ ។ នេះគឺជាស្ថានភាពជាក់ស្តែងនៃការជំរុញការកសាងជាតិ ។ ការរីកចម្រើនកំពុងត្រូវបានអនុវត្តតាមគោលការណ៍ម្ចាស់ការខ្លួនឯង ។

កម្មករ កសិករ យុទ្ធមិត្តប្រុសស្រី និងកម្មាភិបាលមានសេចក្តីក្លាហានខ្លាំងណាស់ ។ ទាំងអស់គ្នាមានសេចក្តីក្លាហានក្នុងសង្គ្រាម និងតាំងពីសម័យរំដោះមក ។ ទាំងអស់គ្នាបានការពារប្រទេស និងកសាងប្រទេសបានយ៉ាងល្អផ្អែកលើជំហរឯករាជ្យ និងម្ចាស់ការលើខ្លួនឯង ។

នៅលើឆាកអន្តរជាតិ យើងក៏ទទួលជោគជ័យសំខាន់ៗដែរ ។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ។ ប្រជាជនបដិវត្តន៍លើពិភពលោក ប្រជាជនតតិយលោកដែលតាមទារសេរីភាពជាតិ និងប្រជាជន មិត្តភក្តិជិតឆ្ងាយដែលស្រឡាញ់ឯករាជ្យ សន្តិភាព និងយុត្តិធម៌ ហើយមហាគ្រួសារនៃប្រជាជាតិដែលចូលបក្សសម្ព័ន្ធកាន់តែពេញចិត្តនិងគាំទ្រជំហរឯករាជ្យ និងម្ចាស់ការលើខ្លួនឯងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ដោយសារហេតុនេះ យើងអាចនិយាយបានថា យើងទាំងអស់គ្នាបានបំពេញការងារបដិវត្តន៍បានល្អដោយមានវីរបុរស និងកងទ័ពប្រដាប់អាវុធយើងគាំទ្រ ។

យើងគួរតែមានមោទនភាពនៃជ័យជម្នះអតីតកាលរបស់យើង ប៉ុន្តែយើងមិនគួរខ្ជិលច្រអូស ធុសប្រហែស និងភ្លេចភ្លាំងដោយសារជោគជ័យទាំងនោះទេ ។ ផ្ទុយទៅវិញ យើងត្រូវបន្ទាបខ្លួន ភ្ញាក់រឭក ប្រុងប្រយ័ត្ន ហើយគោរព និងអនុវត្តតាមគ្រប់គោលនយោបាយអង្គការបដិវត្តន៍ឲ្យកាន់តែរឹងមាំ ។ បើយើងអាចធ្វើកិច្ចការដោយម៉ឺងម៉ាត់ យើងនឹងពង្រឹង និងពង្រីកជ័យជម្នះរបស់យើងបន្ថែមទៀត ។

យើងត្រូវប្រកាន់ភ្ជាប់ស្មារតីប្រុងប្រយ័ត្នគ្រប់ពេលវេលាប្រឆាំងនឹងសត្រូវពីគ្រប់ទិសទី ទាំងក្នុងនិងក្រៅប្រទេស ដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ ការពារកម្មករ កសិករ និងថែរក្សាសមិទ្ធផលបដិវត្តន៍យើងដោយម៉ឺងម៉ាត់និងថិតថេរជានិរន្តរ៍ ។ យើងត្រូវបន្តការតស៊ូផ្អែកលើគោលការណ៍ឯករាជ្យនិងម្ចាស់ការលើខ្លួនឯង ហើយអនុវត្តផែនការឆ្នាំ១៩៧៧របស់អង្គការបដិវត្តន៍ឲ្យបាន១០០ភាគរយ ឬលើសពីនេះ ។ យើងត្រូវបំពេញ និងធ្វើឲ្យលើសផែនការបង្កបង្កើនផលទាំងក្នុងក្របខណ្ឌនៃផែនការរួមឆ្នាំ១៩៧៧ និងក្នុងក្របខណ្ឌសមរភូមិ សមរភូមិមុខ ឬមូលដ្ឋានបង្កបង្កើនផល ។

ក្រុមបង្កបង្កើនផលដែលកំពុងរីកចម្រើនគួរតស៊ូឲ្យកាន់តែខ្លាំង ដើម្បីបំពេញផែនការឲ្យអស់ពីសមត្ថភាព ។ ក្រុមដទៃទៀតគួរអនុវត្តតាមក្រុមដែលរីកចម្រើនទាំងនោះ ដើម្បីសម្រេចបានទាំងស្រុងនូវផែនការឆ្នាំ១៩៧៧ជាការរួមចំណែកជាមួយកសិករសហករណ៍យើងក្នុងការសម្រេចផែនការដាំស្រូវឆ្នាំ១៩៧៧ ។

ខ្ញុំចង់ធ្វើសេចក្តីសន្និដ្ឋានលើរបាយការណ៍នេះក្នុងឱកាសខួបលើកទីពីរនៃជ័យជម្នះថ្ងៃទី១៧ ខែមេសា និងខួបលើកទីពីរនៃកំណើតកម្ពុជាប្រជាធិបតេយ្យនៅពេលនេះ ។ តែមុននឹងសន្និដ្ឋានខ្ញុំចង់ជូនពរបវរគ្រប់ប្រការដល់សមមិត្តទាំងអស់ដែលមានវត្តមាននៅទីនេះ ហើយតាមរយៈអ្នកទាំងអស់គ្នា ខ្ញុំសូមផ្ញើនូវការរាប់អាននិងជូនពរដល់សមមិត្តរបស់យើង យុទ្ធមិត្តប្រុសស្រី និងកម្មាភិបាលទូទាំងប្រទេស ជូនពរអ្នកទាំងអស់គ្នាមានសុខភាពល្អ និងជោគជ័យលើកិច្ចការការពារជាតិ ការពារកម្មករ កសិករ និងថែរក្សាសមិទ្ធផលនៃបដិវត្តន៍កម្ពុជា ហើយជោគជ័យលើការប្រឹងប្រែងដើម្បីកសាងកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងពេលជាមួយគ្នានេះ ខ្ញុំសូមសម្តែងការជូនពរបវរដល់អ្នកទាំងអស់គ្នាក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិ ។

ខួបលើកទីពីរនៃមហាជ័យជម្នះថ្ងៃទី១៧ ខែមេសា និងកំណើតកម្ពុជាប្រជាធិបតេយ្យស្ថិតនៅយូរអង្វែង ។

**ឯកសារលេខ D២៩០១៥**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ខ្មែរក្រោមនិងការកាត់ទោសខ្មែរក្រហម

អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ជនជាតិភាគតិចកម្ពុជាដែលស្គាល់ថាជាខ្មែរក្រោមបានមករស់នៅលើដីវាលទំនាបដ៏មានជីជាតិនៅជុំវិញដែនដីសណ្តទន្លេមេគង្គ ។ ដំបូង ខ្មែរក្រោមបានចូលមករស់នៅតំបន់មួយនាទិសអាគ្នេយ៍អាណាចក្រខ្មែរ ហើយរៀនចេះដឹងភាសានិងវប្បធម៌ខ្មែរយ៉ាងស្ទាត់ជំនាញ ។ បន្ទាប់ពីការធ្វើអាណានិគមរបស់ជនជាតិវៀតណាមជាច្រើនសតវត្សរ៍ បានធ្វើឲ្យខ្មែរក្រោមចូលមករស់នៅភាគខាងត្បូងប្រទេសវៀតណាម ។ នៅពេលដែលមានភាពតានតឹងកើតឡើងរវាងកម្ពុជានិងវៀតណាម ខ្មែរក្រោមតែងតែឈរនៅចំណុចកណ្តាលនៃភាពតានតឹងទាំងនោះជានិច្ច ។ ដោយសារអត្តសញ្ញាណខ្មែរក្រោមជាកូនកាត់ ធ្វើឲ្យពួកគេមិនអាចប្រកាន់ជំហរនៅខាងរដ្ឋាភិបាលណាមួយដើម្បីជាផលប្រយោជន៍របស់ខ្លួនឡើយ ប៉ុន្តែ «ភាពស្មោះត្រង់ទៅលើរដ្ឋាភិបាលទាំងពីរ» ធ្វើឲ្យខ្មែរក្រោមក្លាយទៅជាគោលដៅនៃការរំលោភបំពាន ។ តើស្ថានភាពរស់នៅរបស់ខ្មែរក្រោមមានសភាពលំបាកជាងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? នៅក្នុងអត្ថបទនេះ ខ្ញុំនឹងរៀបរាប់ដោយសង្ខេបអំពីស្ថានភាពលំបាករបស់ខ្មែរក្រោមនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ព្រមទាំងចោទសួរទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថាតើអំពើឃោរឃៅរបស់ខ្មែរក្រហមទៅលើខ្មែរក្រោមមានលក្ខណៈខុសប្លែកពីការរំលោភបំពានលើប្រជាជនកម្ពុជាផ្សេងទៀតយ៉ាងណា?

## ប្រវត្តិសាស្ត្រ

ប្រវត្តិសាស្ត្ររបស់ខ្មែរក្រោមមានសភាពស្មុគស្មាញ ។ រហូតមកដល់សតវត្សរ៍ទី១៨ តំបន់ដីសណ្តភាគច្រើននៅតែជារបស់ខ្មែរ ប៉ុន្តែអំណាចរបស់វៀតណាមនៅតំបន់នោះមានការកើនឡើងជាលំដាប់ ។ នៅចុងសតវត្សរ៍ទី១៩ នៅពេលដែលរដ្ឋាភិបាលបារាំងបញ្ចូលតំបន់ដីសណ្តទន្លេមេគង្គឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណានិគមកូសាំងស៊ីន ភាគច្រើននៃជនជាតិវៀតណាមនិងពាណិជ្ជករចិនភាគតិចបានចូលមករស់នៅនិងរកស៊ីជាមួយខ្មែរក្រោមក្នុងតំបន់ចម្រុះជាតិសាសន៍នេះដែរ ។ ទោះបី



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងបង្ហាញប្រវត្តិរូបអតីតកម្មាភិបាលខ្មែរក្រហមដល់ក្រុមគ្រួសារជនរងគ្រោះ

ជាមានជនជាតិភាគតិចខ្មែរក្រោមជាង១លាននាក់រស់នៅទីនោះក៏ដោយ ក៏ពួកគេបានក្លាយទៅជាក្រុមជនជាតិភាគតិចតូចមួយនៅសម័យដែលវៀតណាមខាងត្បូងទទួលឯករាជ្យនៅដើមទសវត្សរ៍៥០ដែរ ។ ទាំងប្រជាជនកម្ពុជានិងខ្មែរក្រោមនៅតែហៅតំបន់ដែនដីសណ្តនោះថាកម្ពុជាក្រោម (ខ្មែរក្រោម) ដែលធ្វើឲ្យឈ្មោះនេះក្លាយទៅជាឈ្មោះប្រវត្តិសាស្ត្ររហូតមក ។

ក្នុងអំឡុងសង្គ្រាមវៀតណាម រដ្ឋាភិបាលអាមេរិកាំងបានហ្វឹកហ្វឺនខ្មែរក្រោមជាច្រើននាក់ឲ្យធ្វើទាហានដើម្បីតស៊ូប្រយុទ្ធប្រឆាំងនឹងយៀកកុង ។ ទាហានខ្មែរក្រោមទាំងនោះហៅខ្លួនឯងថាទាហាន «កន្សែងស» បន្ទាប់មកបានបង្កើតជាសម្ព័ន្ធតស៊ូខ្មែរកម្ពុជាក្រោម ដែលអង្គការនេះមានគោលដៅទាមទារដែនដីសណ្តទន្លេមេគង្គទៅឲ្យជនជាតិភាគតិចកម្ពុជាវិញ ។ នៅពេលជាមួយគ្នានោះ សឺង ង៉ុកថាញ់ ដែលជាខ្មែរក្រោមមួយរូបបានព្យាយាមធ្វើឲ្យចលនាខ្មែរសេរីប្រសើរឡើងវិញដើម្បីធ្វើជាខែលទម្លាក់សម្តេចសីហនុ ពីតំណែង និងកម្ចាត់ជនកុម្មុយនីស្តចេញពីកម្ពុជា ។ ខ្មែរសេរីបានរើសយកទាហានល្អបរបស់ខ្លួនជាច្រើនចេញពីប្រជាជនខ្មែរក្រោម ។ បន្ទាប់ពីលោកសេនាប្រមុខ លន់ នល់ ធ្វើប្រហារដណ្តើមអំណាចនៅខែមីនា ឆ្នាំ១៩៧០ សឺង ង៉ុកថាញ់ ក៏បានក្លាយជារដ្ឋមន្ត្រីខុទ្ទកាល័យនិងបានបញ្ចូលទាហានខ្មែរសេរីជាច្រើនក្នុងជួរកងទ័ពរដ្ឋាភិបាលនៅអំឡុងសម័យសង្គ្រាមស៊ីវិលក្នុងស្រុក ។

មិនមែនខ្មែរក្រោមទាំងអស់សុទ្ធតែចងសម្ព័ន្ធជាមួយអាមេរិកាំងនិងក្រុមស្តាំនិយមក្នុងស្រុកទេ ។ តាមការពិត មានចលនាមេដឹកនាំខ្មែរក្រហមពីររូបគឺ អៀង សារី និង សុន សេន ក៏ជាខ្មែរក្រោមដែរ ។ ទោះបីបែបនេះក្តី បន្ទាប់ពីខ្មែរក្រហមនិងពួកកុម្មុយនីស្តវៀតណាមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ តួនាទីរបស់ខ្មែរសេរី និងការតស៊ូរបស់ខ្មែរកម្ពុជាក្រោមនៅក្នុងប្រទេសទាំងពីរនេះបានធ្វើឲ្យខ្មែរក្រោមរស់នៅក្នុងស្ថានភាពកាន់តែលំបាកថែមទៀត ។

## ខ្មែរក្រោមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ទាំងមេដឹកនាំខ្មែរក្រហមនិងវៀតណាមមិនបានជឿទុកចិត្តលើសហគមន៍ខ្មែរក្រោមទេ ហើយគិតថា ពីដំបូងសហគមន៍ខ្មែរក្រោមមានជាប់ពាក់ព័ន្ធជាមួយចលនាដែលប្រឆាំងទៅនឹងរបបថ្មីទាំងពីរ ។ កងទ័ពវៀតណាមនៅតែបន្តជម្លោះជាមួយល្អបខ្មែរកម្ពុជាក្រោម ហើយចាត់ទុកប្រជាជនខ្មែរក្រោមថាជាប្រភពសំខាន់នៃចលនាបំបែកខ្លួនដែលអាចប្រឆាំងនឹងទស្សនៈជាតិនិយមរបស់វៀតណាម ។ ចំណែកនៅប្រទេសកម្ពុជា អ្នកបដិវត្តន៍ជ្រុលនិយមខ្មែរក្រហមនៅតែចងចាំអំពីសង្គ្រាមដែលកងទ័ពខ្មែរសេរីបានវាយប្រឆាំងនឹងខ្លួន ។ ខ្មែរក្រហមគិតថា ខ្មែរក្រោមមិនមានភាពស្មោះត្រង់ និងជឿថាអត្តសញ្ញាណនយោបាយនិងវប្បធម៌របស់ខ្មែរក្រោមអាចបង្កឲ្យមានភាពស្មុគស្មាញដល់ការបង្កើតរដ្ឋកម្ពុជាថ្មី ។ មេដឹកនាំប្រទេសទាំងពីរសុទ្ធតែភ័យខ្លាចថា ខ្មែរក្រោមអាចជាខ្សែបណ្តាញរបស់ «ចក្រពត្តិអាមេរិក» ដែលធ្លាប់កាន់កាប់នៅតំបន់ឥណ្ឌូចិន ។

នៅពេលជនជាតិខ្មែរក្រោមស្ថិតនៅចំណុចកណ្តាលនៃទំនាក់ទំនងដ៏ប្រេះស្រាំរវាងវៀតណាមនិងកម្ពុជា វាធ្វើឲ្យបញ្ហាមួយចំនួនកាន់តែអាក្រក់ថែមទៀត ។ ទោះបីជាធ្លាប់មានទំនាក់ទំនងល្អជាមួយគ្នាជាច្រើនឆ្នាំនៅអំឡុងសម័យសង្គ្រាមវៀតណាមក៏ដោយ ក៏មេដឹកនាំនៅភ្នំពេញនិងហាណូយបានបន្សល់ទុកនូវសេចក្តីរបាអាននឹងគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ។ ភ្លាមៗបន្ទាប់ពីបរាជ័យរបស់ទីក្រុងព្រៃនគរ ជម្លោះនៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរក៏បានផ្ទុះឡើង ។ ជម្លោះអំពីកោះនៅក្នុងឈូងសមុទ្រថៃបានបង្កឲ្យមានជម្លោះលើព្រំដែនគោក ដែលបញ្ហាទាំងនេះបានជាប់ពាក់ព័ន្ធទៅនឹងសញ្ជាតិនិងអត្តសញ្ញាណជាតិផងដែរ ។ កម្ពុជាក្រោមគឺជាបញ្ហាសំខាន់ក្នុងគំនិតរបស់ខ្មែរក្រហមពីព្រោះពួកគេតំណាងឲ្យ «ខេត្តដែលបាត់បង់» និងរំឭកដល់ភាពអាម៉ាស់នៃប្រវត្តិសាស្ត្រដែលប្រជាជនកម្ពុជាជួបប្រទះនៅពេលមានការវាតទីរបស់វៀតណាមនិងសៀម ។ ដូចដែលបានកត់សម្គាល់ខាងលើមានប្រភពជាច្រើនផ្សេងទៀតដែលនាំឲ្យមានរបប ប៉ុល ពត កើតឡើង ។ ដោយខ្មែរក្រោមមានលទ្ធភាពចូលរួមជាមួយសង្គមកម្ពុជាដូចច្នេះវៀតណាមគិតថា ខ្មែរក្រោមគឺជាភ្នាក់ងារដ៏ល្អសម្រាប់ធ្វើជារនុកក្នុង ។

## គោលដៅទៅលើខ្មែរក្រោម

បញ្ញវន្តមួយចំនួនបានផ្តោតទៅលើស្ថានភាពរស់នៅយ៉ាងលំបាករបស់ប្រជាជនខ្មែរក្រោមនៅក្នុងអំឡុងរបបកម្ពុជាប្រជា

ធិបតេយ្យ ។ ប៉ែន យៀរនិន ជាអ្នកដែលបានធ្វើសម្ភាសន៍និង ស្រាវជ្រាវនៅប្រទេសកម្ពុជាបន្ទាប់ពីរបប ប៉ុល ពត ទើបតែដួលរលំទៅ ។ លោក យៀរនិន បានធ្វើការស្រាវជ្រាវលម្អិតទៅលើវិធីសាស្រ្តដែលរបបនេះធ្វើបាបទៅលើក្រុមជនជាតិភាគតិចផ្សេងៗគ្នា និងប្រជាជនខ្មែរផ្សេងទៀតដែលត្រូវបានសង្ស័យថាមិនស្មោះត្រង់នឹងបដិវត្តន៍ ។ ការរកឃើញរបស់គាត់បង្ហាញឲ្យឃើញច្បាស់ថាខ្មែរក្រោមត្រូវបានធ្វើបាបដោយផ្ទាល់ ។

នៅក្នុងអត្ថបទប្រវត្តិសាស្រ្ត លោក យៀរនិន បានរៀបរាប់ពីព្រឹត្តិការណ៍នៅឆ្នាំ១៩៧៦ ពេលដែលកងទ័ពវៀតណាមបានដឹកនាំអ្នកតស៊ូប្រយុទ្ធខ្មែរកម្ពុជាក្រោម៦៨នាក់ ចូលមកប្រទេសកម្ពុជា ហើយឈ្លបខ្មែរក្រោមបានស្នើទៅកម្មាភិបាលខ្មែរក្រហមក្នុងស្រុកដើម្បីសុំជួបគណៈប្រធានរដ្ឋ លោក ខៀវ សំផន ព្រមទាំងសុំភ្ជាប់មិត្តភាពជាមួយកម្ពុជាប្រជាធិបតេយ្យដើម្បីប្រឆាំងនឹងវៀតណាម ។ ការស្នើនេះត្រូវបានបដិសេធចោល ហើយមេដឹកនាំម្នាក់នោះត្រូវបានចាប់បញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងដោយទទួលរងការធ្វើទារុណកម្មនិងសម្លាប់នៅទីនោះ ។ ៦៧នាក់ផ្សេងទៀតក៏ត្រូវយកទៅបាញ់ចោលដែរ ។ ទោះបីជាមានសញ្ជាតិដូចគ្នាក្តី ក៏កងទ័ពកម្ពុជាប្រជាធិបតេយ្យបានចាត់ទុកខ្មែរក្រោមថាជាហានិភ័យដល់នយោបាយរបស់ខ្លួន ព្រោះពួកគេធ្លាប់មានទំនាក់ទំនងជាមួយវៀតណាមនិងពួកចក្រពត្តិអាមេរិកាំង ។ ការស្រាវជ្រាវរបស់លោក យៀរនិន បង្ហាញឲ្យឃើញថា ទាហានខ្មែរកម្ពុជាក្រោមអាចត្រូវបានចាត់ទុកជាចារបុរសរបស់អាមេរិកឬជាជនក្បត់ ដោយយោងទៅតាមទម្លាប់ផឹកទឹកដោះគោ (ភេសជ្ជៈរបស់ពួកចក្រពត្តិ) និង ទុកសក់វែង ។ ព្រឹត្តិការណ៍នេះមិនទាន់មានលក្ខណៈពិសេសនៅឡើយទេ លោក យៀរនិន ក៏បាននិយាយពីការសម្លាប់ខ្មែរក្រោមនៅស្រុកចំនួនពីរនៅភូមិភាគនិរតី គឺស្រុកព្រៃកប្បាសនិងស្រុកបាទីនៅឆ្នាំ ១៩៧៥-១៩៧៦ ។

នៅពេលនោះស្ថានភាពរស់នៅរបស់ខ្មែរក្រោមកាន់តែអាក្រក់ឡើង ។ រហូតមកដល់ឆ្នាំ១៩៧៧ ប្រជាជនកម្ពុជាជាច្រើននាក់នៅ «ភូមិភាគបូព៌ា» នៃរបបកម្ពុជាប្រជាធិបតេយ្យបានរត់ទៅប្រទេសវៀតណាមចូលរួមជាមួយនឹងចលនាតស៊ូប្រឆាំង ប៉ុល ពត ។ ភាពសង្ស័យជាច្រើននៅភ្នំពេញកាន់តែកើនឡើង ហើយមានការសម្លាប់ភ្នាក់ងាររវៀតណាមយ៉ាងច្រើន ។ ខ្មែរក្រោមដែលរស់នៅប្រទេសកម្ពុជាស្ថិតក្នុងចំណោមជនសង្ស័យដំបូងគេ ។ ការកាត់ទោសប្រជាជនមួយក្រុមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានកើនឡើងបន្ទាប់ពីអ្នកទោសខ្មែរក្រោមមួយចំនួននៅគុកទួលស្លែងព្រមសារភាពថាជាជនបង្កប់របស់វៀតណាម ប៉ុន្តែតាមការពិតការសារភាពនេះគ្រាន់តែដើម្បីចៀសវាងពីការធ្វើទារុណកម្មប៉ុណ្ណោះ ។ ការធ្វើបាបស្រដៀងគ្នានេះក៏កើតឡើងនៅគុកក្រាំងតាចាន់ ខេត្តតាកែវ ដែលនៅជិតព្រំដែនវៀតណាមដែរ ។ ឯកសារជាច្រើនដែលយកមកពីគុកខេត្តបញ្ជាក់ថា ខ្មែរក្រោមត្រូវបានសង្ស័យថាជាជនបង្កប់និងជាអ្នកធ្វើសកម្មភាព «ប្រឆាំងបដិវត្តន៍» ។ ឯកសារនោះបង្ហាញថា អ្នកទោសភាគច្រើននៅគុកក្រាំងតាចាន់គឺជាខ្មែរក្រោម ។

នៅឆ្នាំ១៩៧៧ ភ្លាមៗបន្ទាប់ពីមេដឹកនាំមជ្ឈិមនៅភ្នំពេញចោទប្រកាន់ប្រធានខេត្តថាក្បត់ជាតិ មានការរំលោភបំពានដ៏ព្រៃផ្សៃទៅលើខ្មែរក្រោមនៅស្រុកបាកាន ខេត្តពោធិ៍សាត់ ។ តាមរយៈការធ្វើសម្ភាសន៍ គឹម កែវកន្និដ្ឋា បានស្រាវជ្រាវរកឃើញថា នៅឃុំរំលេច កម្មាភិបាលខ្មែរក្រហមបានចងក្រងប្រវត្តិរូបប្រជាជនដែលធ្វើការនៅសហករណ៍នោះដើម្បីរកខ្មែរក្រោមព្រមទាំងបំបែកពួកគេពីសហគមន៍ដើម្បីធ្វើការតាមដាន ។ គាត់បង្ហាញថា កម្មាភិបាលម្នាក់ហៅខ្លួនឯងថាអង្គការ (ជាទូទៅសម្រាប់ហៅមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ) បានបញ្ជូនអ្នកភូមិខ្មែរក្រោមនៅជិតឃុំខ្នារទទឹងទៅកន្លែងផ្សេង ។ បន្ទាប់មក គាត់ចងក្រងឯកសារនៃការសម្លាប់និងការបាត់ខ្លួនរបស់ខ្មែរក្រោម ដោយកំណត់សម្គាល់ថា ប្រជាជនកម្ពុជាផ្សេងទៀតត្រូវទទួលការបន្ធូរបន្ថយទោស ។ ការសម្ភាសជាមួយអ្នកនៅរស់ពីរបបខ្មែរក្រហមជាច្រើនរបស់នាងបានឲ្យដឹងថា ខ្មែរក្រោមគឺជាគោលដៅសម្លាប់ព្រោះពួកគេមានទំនាក់ទំនងជាមួយនឹងវៀតណាម ។ ការស្រាវជ្រាវរបស់ យៀរនិន បង្ហាញថា ខ្មែរក្រោមពី៥០០ទៅ៧០០នាក់ត្រូវបានសម្លាប់និងកប់នៅក្នុងរណ្តៅរួម ។

## គោលនយោបាយរបស់ខ្មែរក្រហម

ការសម្លាប់និងការវាយប្រហារទាំងនេះកើតឡើងនៅពេល

 

មានយុទ្ធនាការរំដោះកម្ពុជាក្រោមរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ តាមការផ្សាយវិទ្យុនៅខែឧសភា ឆ្នាំ១៩៧៨ បានឲ្យដឹងថា ប៉ុល ពត ព្យាយាមប្រមូលផ្តុំកងទ័ពនិងប្រជាជនដើម្បីតស៊ូប្រឆាំងនឹងវៀតណាមរំដោះជាតិនិងពូជសាសន៍ ។ ប៉ុល ពត បានបញ្ជាឲ្យកងទ័ពខ្មែរក្រហមម្នាក់ៗត្រូវសម្លាប់ «ជនជាតិវៀតណាម ៣០នាក់» ព្រោះប្រជាជនកម្ពុជាមានចំនួនតិច ព្រមទាំងជំរុញឲ្យប្រជាជនធម្មតាប្រឆាំងនឹងវៀតណាម «ដើម្បីការពារបូរណភាពដែនដីនិងពូជសាសន៍កម្ពុជា» ។ ប៉ុល ពត បានចោទប្រកាន់វៀតណាមថាមានគម្រោងលេបយកប្រទេសកម្ពុជា ពីព្រោះពីដំបូងវៀតណាមបានវាយកទីក្រុង «ព្រៃនគរ» បន្ទាប់មកនឹងវាយប្រហារមកលើភ្នំពេញទៀត ។ ដូច្នេះគាត់បានសំណូមពរថាខ្មែរក្រោមគឺជាផ្នែកមួយនៃពូជសាសន៍កម្ពុជាដែលពួកយើងត្រូវរំដោះពីការគ្រប់គ្រងរបស់វៀតណាម ។ នៅឆ្នាំ១៩៧៧ កងទ័ពកម្ពុជាប្រជាធិបតេយ្យបានប្រមូលផ្តុំអ្នកបះបោរនៅវៀតណាមខាងត្បូងនិងញុះញង់ឲ្យប្រជាជនងើបឡើងប្រឆាំងនឹងរដ្ឋាភិបាលនៅទីក្រុងហាណូយ ។

ការវាយដណ្តើមយកកម្ពុជាក្រោមមកវិញដែលបានគ្រោងទុកជាមុន បានក្លាយទៅជាគោលនយោបាយកម្ពុជាប្រជាធិបតេយ្យដែលប្រជាជនជឿទុកចិត្តទាំងស្រុង ។ ជាឧទាហរណ៍ វិន័យសន្តិបាលទាំង១០នៅគុកទួលស្លែងរួមមាន «កុំយកលេសកម្ពុជាក្រោមបាំងមុខមាត់ក្បត់របស់អាឯងឲ្យសោះ» ឃ្លាគួរឲ្យអស់សំណើចនេះបង្ហាញថា យ៉ាងហោចណាស់មានអ្នកទោសខ្លះសារភាពថាគាំទ្រ «ការរំដោះ» កម្ពុជាក្រោមដើម្បីបង្ហាញភាពស្មោះត្រង់ទៅកាន់អ្នកសួរចម្លើយ ។

ដូចដែលបានបង្ហាញខាងលើ មានខ្មែរក្រហមមួយក្រុមបានត្រួតពិនិត្យទៅលើយន្តការនយោបាយក្នុងស្រុកដែលបញ្ជូនជនសង្ស័យខ្មែរក្រោមជាច្រើនទៅដាក់គុកឬទៅសម្លាប់ ។ កន្និដ្ឋាបង្ហាញថាមាន «ការជួបប្រជុំអប់រំនយោបាយ» នៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ នៅឯពហុកីឡដ្ឋានអូឡាំពិចទីក្រុងភ្នំពេញ ដែលនៅក្នុងការប្រជុំនោះ ប៉ុល ពត ធ្វើជាគណៈអធិបតីនិងមានការចូលរួមពីខ្មែរក្រោមមួយក្រុម ។ ប៉ុល ពត ប្រាប់ខ្មែរក្រោមទាំងនោះថាគាត់នឹង «ទុក» តែអ្នកដែលយល់ព្រមដើរតាមមាគ៌ារបស់អង្គការប៉ុណ្ណោះ ។ ប៉ុន្តែនៅក្នុងបទសម្ភាសន៍ យៀវនិន បង្ហាញថា មកត្រឹមឆ្នាំ១៩៧៨ កម្ពុជាប្រជាធិបតេយ្យមានគោលនយោបាយដើម្បីធ្វើការ «ស៊ើបអង្កេត» ទៅលើជនជាតិវៀតណាមនិងប្រជាជនខ្មែរក្រោម បន្ទាប់មកសម្លាប់អ្នកទាំងនោះចោល ។ លោក យៀវនិន ក៏បានសម្ភាសន៍ខ្មែរក្រោមមួយចំនួនដែលត្រូវបានកងទ័ពកម្ពុជាប្រជាធិបតេយ្យចាប់ខ្លួនពីទឹកដីវៀតណាមយកមកឲ្យធ្វើការធ្ងន់នៅប្រទេសកម្ពុជាដែរ ។ អ្នកផ្តល់បទសម្ភាសន៍ម្នាក់និយាយថា គាត់និងអ្នកដទៃទៀតបដិសេធថាមិនចេះវៀតណាម ពីព្រោះប្រសិនបើទទួលស្គាល់ថាចេះនិយាយភាសាវៀតណាម គាត់ទាំងអស់គ្នាច្បាស់ជាត្រូវស្លាប់មិនខាន ។

## ដំណោះស្រាយរឿងបទឧក្រិដ្ឋប្រឆាំងនឹងខ្មែរក្រោម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សហគមន៍ខ្មែរក្រោមបានទទួលរងនូវការធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំងពីសំណាក់ខ្មែរក្រហម ។ ក្នុងសវនាការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រឹមតែប្រាំនាក់បានឈានចូលមកដល់ហើយ ព្រះរាជអាជ្ញានិងចៅក្រមបានប្រឈមមុខនឹងសំណួរសំខាន់មួយថាតើគួរតែចាត់ទុកការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងខ្មែរក្រោមខុសពីការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងជនរងគ្រោះដទៃទៀតដែរឬទេ?

## បទបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ

ជាយូរមកហើយ ច្បាប់អន្តរជាតិបានបញ្ចូលបទបញ្ញត្តិច្បាប់ដែលបង្កើតឡើងដើម្បីការពារក្រុមជនភាគតិចដែលងាយរងគ្រោះ ។ អនុសញ្ញាទាក់ទងនឹងអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ដែលបានព្រាងឡើងក្រោយរបបណាហ្ស៊ីបន្តិច បានដាក់ការប្រកាន់ពូជសាសន៍ សាសនា ជាតិសាសន៍និងក្រុមជនជាតិភាគតិចឲ្យនៅក្រៅច្បាប់ ។ បទល្មើស «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ក៏បានការពារសមាជិកក្នុងក្រុមដែលទទួលរងនូវការធ្វើទុក្ខបុកម្នេញជាបន្តបន្ទាប់ក្នុងប្រវត្តិសាស្ត្រដែរ ។ ត្រូវបានអនុវត្តនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិនៅនូរ៉ែមប៊ឺក បទល្មើស «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ក៏បានហាមឃាត់នូវការរីករាលដាលឬការវាយប្រហារជាប្រព័ន្ធប្រឆាំងនឹងពលរដ្ឋស្លូតត្រង់ ការប្រកាន់ពូជសាសន៍ ជនជាតិភាគតិច និងសកម្មជននយោបាយដែរ ។

ការរិះគន់ជាបន្តបន្ទាប់បានគូសបញ្ជាក់ថា និយមន័យនេះ

 

គឺមានលក្ខណៈមិនសូវទូលំទូលាយទេ ព្រោះច្បាប់នោះមិនបាន បញ្ចូលក្រុមជនរងគ្រោះក្នុងការការពារ ហើយក្រោយមកច្បាប់ នោះក៏ចាប់ផ្តើមមានការផ្លាស់ប្តូរ ។ អ្វីដែលគួរកត់សម្គាល់បំផុត នោះ បទបញ្ញត្តិក្រុងរ៉ូមឆ្នាំ១៩៩៨បានពង្រីកនិយមន័យខក្រិដ្ឋ កម្មប្រឆាំងមនុស្សជាតិដើម្បីបញ្ចូលការធ្វើទុក្ខបុកម្នេញប្រឆាំង នឹងពលរដ្ឋដែលមិនមែនជាជនប្រដាប់អាវុធស្ថិតនៅក្រោមការ ការពារ ។ ប៉ុន្តែ ច្បាប់របស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការ កម្ពុជាបានប្រើប្រាស់នូវនិយមន័យដែលបានបង្កើតឡើងលើក ដំបូង ហើយមានហេតុផលច្បាប់ត្រឹមត្រូវក្នុងការយកនិយមន័យ ចាស់នេះមកប្រើប្រាស់ ។ របបខ្មែរក្រហមបានប្រព្រឹត្តខុសក្នុង ទសវត្សរ៍៧០ ហើយគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ចែងថា ជនម្នាក់អាចត្រូវបានកាត់ទោសពីបទខក្រិដ្ឋកម្ម នៅពេលជននោះ ពិតជាបានប្រព្រឹត្តបទខក្រិដ្ឋមែន ។ អ្នកច្បាប់និងអ្នកប្រាជ្ញអន្តរ ជាតិភាគច្រើនយល់ស្របទាំងអស់គ្នាថា ក្នុងចុងទសវត្សរ៍៧០ ជនជាប់ចោទម្នាក់អាចទទួលរងនូវការចោទប្រកាន់ពីបទខក្រិដ្ឋកម្ម និងប្រល័យពូជសាសន៍បាន លុះត្រាណាជននោះបានប្រព្រឹត្តបទ ល្មើសជាក់លាក់ប្រឆាំងនឹងក្រុមមួយឬច្រើនដែលទទួលបាននូវការ ការពារ ។

មកដល់បច្ចុប្បន្ននេះ អតីតមេដឹកនាំខ្មែរក្រហមចំនួនប្រាំ នាក់ដូចជា នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ និង ឌុច ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ពីបទខក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិ ។ មិនមានជនណាម្នាក់ខាងលើត្រូវបានចោទប្រកាន់ពីបទ ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងខ្មែរក្រោមឡើយ ។ ប្រសិនបើមានការចោទប្រកាន់បែបនេះមែន នោះចំណោទបញ្ហា ដែលទាក់ទងនឹងយុត្តិសាស្ត្រនៃការដាក់បន្ទុកលើការធ្វើទុកបុក ម្នេញទៅលើខ្មែរក្រោមនឹងកាន់តែមានមានសារសំខាន់ថែមទៀត ព្រោះច្បាប់របស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជាប្រឆាំងនឹងអំពើ ប្រល័យពូជសាសន៍មិនបានការពារក្រុមអ្នកនយោបាយទេ ។ តើ ជនត្រូវចោទបានសម្លឹងមើលខ្មែរក្រោមជាក្រុមមួយដែលត្រូវតែ មើលឲ្យបានដិតដល់ដោយសារតែហេតុផលនយោបាយដូចបញ្ហា វន្តដទៃទៀត ឬប្រជាជនថ្មីដែលខ្មែរក្រហមបានជម្លៀសពីទីក្រុង ឬក៏ជនត្រូវចោទបានសម្លឹងមើលខ្មែរក្រោមជាក្រុមជនជាតិភាគ តិចមួយឬក៏ផ្នែកមួយនៃជនជាតិវៀតណាមដែលត្រូវតែបំផ្លាញ ចោល? ។ អតីតមេដឹកនាំខ្មែរក្រហមអាចជាប់ចោទពីបទខក្រិដ្ឋ ប្រឆាំងមនុស្សជាតិ ប៉ុន្តែទើបតែក្រោយមកទេទើបនាំទៅរកការ ជាប់ចោទពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

## ការចាត់ថ្នាក់ខ្មែរក្រោម

ច្បាប់ដែលប្រើក្នុងអង្គជំនុំជម្រះក្នុងតុលាការកម្ពុជាមិនបាន កំណត់និយមមន័យអំពីការប្រកាន់ពូជសាសន៍ សាសនា ជនជាតិ ភាគតិច សញ្ជាតិ និងក្រុមនយោបាយទេ ។ ប៉ុន្តែប្រសិនបើការ អនុវត្តច្បាប់អន្តរជាតិកាលពីអតីតកាលត្រូវបានយកមកធ្វើជាគំរូ នោះអង្គជំនុំជម្រះប្រាកដជាទទួលស្គាល់សាសនា សញ្ជាតិ និង ក្រុមនយោបាយរបស់ខ្មែរក្រោម ។ ជាឧទាហរណ៍ ខ្មែរក្រោមត្រូវ បានវាយប្រហារដោយខ្មែរក្រហមដោយសារតែធ្លាប់មានទំនាក់ ទំនងជាមួយរបប លន់ នល់ នេះអាចចាត់ទុកថាជាផ្នែកមួយនៃ ក្រុមនយោបាយដែលទទួលបានការការពារ ។ ស្រដៀងគ្នានេះ ដែរ ប្រសិនបើខ្មែរក្រោមត្រូវបានធ្វើបាបក្នុងនាមជាព្រះសង្ឃ ពុទ្ធសាសនា នេះអាចនឹងចាត់ទុកថាជាការរំលោភលើសាសនា ដែលទទួលបាននូវការការពារ ។

ជារួម ខ្មែរក្រោមជាក្រុមមួយរបស់ជនជាតិពីរក្រុម ។ ទីមួយ អ្នកដែលមានសញ្ជាតិវៀតណាមអាចចាត់ទុកជាផ្នែកមួយ នៃក្រុមជនជាតិវៀតណាម ។ ដើម្បីបញ្ចូលខ្មែរក្រោមទៅក្នុង ក្រុមជនជាតិវៀតណាមដែលទទួលបានការការពារ ចៅក្រមត្រូវ តែសន្និដ្ឋានលើភ័ស្តុតាងដែលចុងចោទបានចាត់ទុកខ្មែរក្រោមជា ជនជាតិវៀតណាម ហើយបានធ្វើទុក្ខបុកម្នេញអ្នកទាំងនោះ ។ ខ្មែរក្រោមដែលមានសញ្ជាតិកម្ពុជាមិនត្រូវបានចាត់ទុកជាក្រុម ដែលទទួលបានការការពារទេ ។ អ្នកស្រាវជ្រាវខ្លះបានបញ្ជាក់ថា គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យគឺអនុវត្តនូវអំពើ «ប្រល័យពូជសាសន៍ខ្លួនឯង» ដែលក្នុងនោះខ្មែរក្រហមបានព្យា យាមបំផ្លាញចោល «ជាផ្នែក» នូវក្រុមជនជាតិខ្មែរ ។ អំណះ អំណាងនេះអាចទទួលយកបាន ប៉ុន្តែមិនទំនងត្រង់ថា ព្រះរាជអាជ្ញា របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចបញ្ជាក់ថា មេដឹកនាំខ្មែរក្រហមមានទិសដៅចំពោះពលរដ្ឋកម្ពុជាពីបទអំពើ ប្រល័យពូជសាសន៍និងបទខក្រិដ្ឋប្រឆាំងមនុស្សជាតិលើទឹកដី

កំណើតរបស់ខ្លួន ។

ខ្មែរក្រោមដែលជាក្រុមជនជាតិភាគតិចមួយគឺជាបញ្ហាដ៏លំបាកនៅក្នុងច្បាប់អន្តរជាតិ «ក្រុមជនជាតិភាគតិច» ជាធម្មតាសំដៅទៅលើក្រុមជនជាតិមួយដែលមានលក្ខណៈវប្បធម៌និងប្រវត្តិសាស្ត្រខុសពីគេដូចជាភាសា សាសនា និងប្រវត្តិសាស្ត្រ ។ ភាពខុសគ្នារវាងខ្មែរក្រោម និងប្រជាជនកម្ពុជាដទៃទៀតមានដូចជាការបញ្ចេញសំឡេង ទំនៀមទម្លាប់ប្រពៃណី និងការស្លៀកពាក់ជាដើម ។ ភាពផ្សេងគ្នារវាងវប្បធម៌និងប្រវត្តិសាស្ត្ររបស់ខ្មែរក្រោមនិងប្រជាជនកម្ពុជា អាចធ្វើឲ្យកម្មាភិបាលខ្មែរក្រហមកត់សម្គាល់បាន ប៉ុន្តែខ្មែរក្រោមមិនអាចបង្កើតជាក្រុមដែលទទួលបានការការពារទេ ។

ព្រះរាជអាជ្ញាអាចនឹងត្រូវបង្ហាញភ័ស្តុតាងថា ចុងចោទនៃរបបកម្ពុជាប្រជាធិតេយ្យបានចាត់ទុកខ្មែរក្រោមគឺជាក្រុមជនជាតិភាគតិច ទើបខ្មែរក្រហមធ្វើដូច្នេះ ។ កិច្ចការនេះអាចមានការលំបាក ។

## ហេតុអ្វីក៏ខ្មែរក្រោមត្រូវបានបោសសម្អាត?

ពិតណាស់ បើខ្មែរក្រោមគឺជាក្រុមមនុស្សដែលទទួលបានការការពារ នោះមិនមានន័យថាខ្មែរក្រោមទាំងនោះគឺជាជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏សំខាន់នោះទេ ។ ដើម្បីកាត់សេចក្តីឲ្យមានទោសពីបទប្រល័យពូជសាសន៍ លុះត្រាតែជនជាប់ចោទបានប៉ុនប៉ងបំផ្លាញទាំងស្រុងនិងដោយផ្អែកទៅលើក្រុមដែលត្រូវទទួលបានការការពារ ។ ដើម្បីកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជនល្មើសត្រូវតែបានប្រព្រឹត្តបទល្មើសដោយការធ្វើទុក្ខបុកម្នេញ និងជាប្រព័ន្ធចំពោះក្រុមមនុស្សដែលទទួលការការពារក្នុងតំបន់នៅលើទឹកដីដែលជាលំនៅឋានរបស់ជននោះ ។

ភ័ស្តុតាងជាប្រវត្តិសាស្ត្របានបង្ហាញយ៉ាងច្បាស់ថា របបកម្ពុជាប្រជាធិបតេយ្យយ៉ាងហោចណាស់បានបោសសម្អាតខ្មែរក្រោមដោយឈរលើមូលដ្ឋានថាមានការពាក់ពន្ធ័ជាមួយវៀតណាម ។ មានការងាយស្រួលនឹងបង្ហាញថា មេដឹកនាំខ្មែរក្រហមបានចាត់ទុកជនជាតិវៀតណាមជាសត្រូវស្លូពូជ ជាពិសេសនៅក្នុងដំណាក់កាលក្រោយមកនៃរបបខ្មែរក្រហម ។ ដូចលោកយៀវនិន, អាឡិច ហ៊ិនតុន និងអ្នកស្រាវជ្រាវដទៃទៀតបានបង្ហាញផងដែរ ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ សេចក្តីថ្លែងការណ៍តាមវិទ្យុនិងការបោះពុម្ពផ្សាយគឺពោរពេញទៅដោយពាក្យពេចន៍សំដៅទៅលើសត្រូវយួន ហើយជារឿយៗបានបន្ទុះបន្ទាប់ទៅលើអ្នកប្រឆាំងក្នុងស្រុកថាជាពួកក្បាលយួនខ្លួនខ្មែរ ។

ចម្ងល់ទាក់ទងផ្លូវច្បាប់ដែលពិបាកយល់ជាងគេនោះគឺថាហេតុអ្វីបានជាខ្មែរក្រោមជាទិសដៅនៃការកាប់សម្លាប់ ។ តើខ្មែរក្រោមជាទិសដៅដោយសម្អាងទៅលើអ្វីដែលហៅថានយោបាយអយុត្តិធម៌ ដោយសារតែអត្តសញ្ញាណជាជនជាតិភាគតិច ឬមានសញ្ជាតិជាជនជាតិវៀតណាមឬ? ក្នុងករណីដែលថា ខ្មែរក្រោមត្រូវបានចោទប្រកាន់ពីបទធ្វើចារកិច្ចឲ្យវៀតណាម អង្គជំនុំជម្រះវិសាមញ្ញមានភាពយុត្តិធម៌ត្រឹមត្រូវនិងចោទប្រកាន់មេដឹកនាំខ្មែរក្រហមថាបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅលើក្រុមមនុស្សដែលទទួលនូវការការពារ ។ ប៉ុន្តែករណីខ្លះទៀត ខ្មែរក្រហមមិនបានចាត់ទុកខ្មែរក្រោមឲ្យស្មើភាពគ្នាដោយសារតែមានការពាក់ព័ន្ធផ្នែកនយោបាយជាមួយវៀតណាម របប លន់ នល់ និងសហរដ្ឋអាមេរិក ។ យោងតាមករណីទាំងនោះ ខ្មែរក្រោមមើលទៅមិនទំនងជាទិសដៅក្នុងការសម្លាប់ជាងជនជាតិខ្មែរផ្សេងទៀត ដែលជាជនរងគ្រោះនៃមនោគមន៍វិជ្ជាដែលរងគ្រោះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ។

## ហេតុអ្វីបានជារឿងក្តីខ្មែរក្រោមបានកើតឡើង?

គេអាចនឹងសួរថាហេតុអ្វីបានជាវាមានសារសំខាន់ក្នុងការផ្តោតទៅលើការរំលោភបំពានប្រឆាំងនឹងខ្មែរក្រោម ដោយដឹងថាក្រុមមនុស្សដទៃទៀតជាច្រើនក៏ត្រូវទទួលរងនូវការឈឺចាប់ដែលមិនអាចពណ៌នាបាននៅក្នុងរបបខ្មែរក្រហមដែរ ។ រឿងក្តីខ្មែរក្រោមត្រូវបានគេធ្វើការត្រួតពិនិត្យដោយសម្អាងលើហេតុផលចំនួនពីរគឺៈ

## ការយល់ដឹងពីអំពើប្រល័យពូជសាសន៍

ជាបឋម តួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញគឺជាផ្នែកមួយក្នុងការស្វែងរកយុត្តិធម៌និងផ្តល់នូវការវិនិច្ឆ័យផ្នែកច្បាប់យ៉ាងច្បាស់លាស់ ហើយថែមទាំងជួយប្រជាជនខ្មែរក្នុងការបង្កើនការយល់ដឹងអំពីរបបនេះ ។ សំណួរផ្នែកច្បាប់ដែលទាក់ទងនឹងគោល

បំណងរបស់ខ្មែរក្រហម គឺជាមូលដ្ឋានគ្រឹះពិតប្រាកដនៃអំពើព្រៃផ្សៃរបស់ខ្មែរក្រហម ។ អស់រយៈពេលជាច្រើនឆ្នាំ បញ្ញវន្តជាច្រើនកំពុងជាប់រវល់ធ្វើការពិភាក្សាយ៉ាងខ្លាំងក្លាពីអំពើឃោរឃៅរបស់ខ្មែរក្រហមថាតើគោលនយោបាយរបស់ខ្មែរក្រហមប៉ះពាល់ដល់ការរើសអើងជាតិសាសន៍និងជាតិពន្ធដល់កម្រិតណា? តើមនោគមន៍វិជ្ជារបស់កុម្មុយនីស្តឬអំណាចនយោបាយមានការទទួលខុសត្រូវដល់កម្រិតណា?

ការពិភាក្សាស្តីពីគោលបំណងនៃការសម្លាប់របស់ពួកខ្មែរក្រហម គឺមានសារសំខាន់ចំពោះប្រវត្តិសាស្ត្រយ៉ាងខ្លាំង ។ បើសិនជាយើងផ្តោតពីគោលបំណងនៃការរំលោភបំពានរបស់ខ្មែរក្រហមទៅលើអំពើប្រល័យពូជសាសន៍និងជាតិនិយម នោះយើងនឹងឃើញយ៉ាងច្បាស់ពីទំនាក់ទំនងនៃរបប ប៉ុល ពត ជាមួយនឹងលទ្ធិហ្វាស៊ីសនិយមនិងរបបដែលប្រកាន់នយោបាយជ្រុលនិយម ។ ប្រសិនបើយើងសង្កត់ធ្ងន់ទៅលើមនោគមន៍វិជ្ជានៃការសម្លាប់ នោះយើងនឹងមើលឃើញពីជំហររបស់លទ្ធិម៉ៅនិងស្តាលីននៅក្នុងគោលនយោបាយរបស់ខ្មែរក្រហម ។ បញ្ញវន្តភាគច្រើនបានពិភាក្សាសេចក្តីអត្ថាធិប្បាយចុងក្រោយ និងជាការពិតណាស់ដែលមានភស្តុតាងជាច្រើនគាំទ្រការផ្តល់អត្ថិភាពនេះទៅឲ្យគោលនយោបាយភេរវកម្មកម្ពុជាប្រជាធិបតេយ្យ ។ ការសម្លាប់រង្គាលរបស់ខ្មែរក្រហមគឺត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរបបកុម្មុយនីស្ត ។ អ្នកនយោបាយតែងតែពិពណ៌នានូវទង្វើទាំងអស់នេះថាជាការខំប្រឹងប្រែងក្នុងកិច្ចការពារ «បដិវត្តន៍» ប្រឆាំងទៅនឹង «សត្រូវ» និង «អ្នកបះបោរ» ជាច្រើន ដែលរួមគំនិតក្បត់ជាមួយនឹងសត្រូវបរទេសនិងចក្រពត្តិនិយម ។ ក្នុងករណីភាគច្រើនបំផុត អ្នកត្រូវគេឃុំខ្លួននៅក្នុងគុក ដូចជាគុកទួលស្លែងគឺត្រូវបានចោទប្រកាន់ពីបទចារកម្មនិងធ្វើវិទ្ធង្សនា ដែលទាំងនេះគឺបង្កប់នូវគោលបំណងនយោបាយដើម្បីចង់ធ្វើបាបពួកគេ ។ ទោះបីមានការកំណត់ពូជសាសន៍សាសនា ឬក៏ក្រុមជាតិនិយមដែលត្រូវបានជ្រើសរើសមកធ្វើបាបនោះ ភាគច្រើននៃបទល្មើសទាំងនោះតែងតែលើកឡើងពីបញ្ហានយោបាយឬក៏ទាក់ទងនឹងកិច្ចប្រឹងប្រែងពង្រឹងអំណាចរបស់ខ្មែរក្រហមដើម្បីតាមដានឬកម្ទេចចោលសត្រូវនយោបាយ ។

ភស្តុតាងមួយចំនួនបានគាំទ្រទៅលើគំនិតដែលថា កម្មាភិបាលខ្មែរក្រហមគ្រប់ជាន់ថ្នាក់ត្រូវបានដឹកនាំតាមរបៀបផ្សេងៗគ្នាតាមរយៈកំហឹងពូជសាសន៍ដ៏រឹងរូសមិនអាចកែបាន ជាពិសេសទៅលើជនជាតិវៀតណាម ។ យ៉ាងណាមិញ ការបែងចែកពូជសាសន៍ និង គោលនយោបាយគឺវាពិបាកណាស់ ។ ការបង្កាប់បញ្ជារបស់ «បដិវត្តន៍» គឺប្រហែលជាអនុញ្ញាតឲ្យកម្មាភិបាលខ្មែរក្រហមធ្វើសកម្មភាពទៅលើសត្រូវជាតិសាសន៍ និងពូជសាសន៍របស់ខ្លួន ។ គោលបំណងនៃការបែងចែកពូជសាសន៍ និងនយោបាយក៏ក្លាយជាភាពស្មុគស្មាញមួយនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្មែរក្រហមផងដែរ ។ ក្នុងអំឡុងពេលនោះ ការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យគឺចាប់ផ្តើមផ្តោតទៅលើទំហំទំនាស់ជាតិសាសន៍និងពូជសាសន៍ជាមួយជនជាតិវៀតណាម ។ តើទាំងនេះជាអ្វីដែលរបបនេះចង់បង្ហាញពីរូបភាពប្រល័យពូជសាសន៍ពិតប្រាកដឬ? ឬក៏គ្រាន់តែជាការប៉ុនប៉ងក្នុងការពង្រឹងកម្លាំងឡោមព័ទ្ធប្រជាជនកម្ពុជា និងបង្វែរការចាប់អារម្មណ៍ពីបរាជ័យនិងភាពឃោរឃៅនៃរបបនយោបាយក្នុងស្រុករបស់ខ្មែរក្រហម?

តួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនដើម្បីដោះស្រាយការពិភាក្សារបស់បញ្ញវន្តអំពីរូបភាពដើមនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ។ នីតិវិធីនេះនឹងផ្តោតទៅលើចុងចោទម្នាក់ៗ ។ ដោយជ្រើសរើសការអនុវត្តរបៀបណាមកធ្វើការកាត់ទោស ការបើកសវនាការជាសាធារណៈ ការតវ៉ា និងការប្រកាសសវនាការ មន្ត្រីតុលាការអាចរួមចំណែកយ៉ាងមានន័យបំផុតចំពោះការពិភាក្សាដ៏សំខាន់នេះ ។ ក្នុងស្មារតីនោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងក្លាយជាផ្នែកមួយយ៉ាងសំខាន់ក្នុងការរៀបចំជារូបរាងនូវការយល់ដឹងជាសាធារណៈពីសម័យកាលខ្មែរក្រហម ។

## ការថ្លែងអំពីទស្សនៈនៃយុត្តិធម៌

ហេតុផលទីពីរចំពោះសំណួរថាតើហេតុអ្វីបានជាករណីខ្មែរក្រោមមានសារសំខាន់ជាមួយនឹងទស្សនៈនៃយុត្តិធម៌ ។ ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើន រួមបញ្ចូលទាំងខ្មែរក្រោមខ្លះផងបានទទួលនូវបទពិសោធន៍ដែលកម្របានជួបប្រទះ ។ មានន័យថាជាបទពិសោធន៍ឈឺចាប់ដែលគ្មាននរណាធ្លាប់បានជួបប្រទះ ។ ជនរងគ្រោះជាច្រើនជឿថា ពួកគេបានទទួលរងនូវ

«អំពើប្រល័យពូជសាសន៍» ជាផ្នែក ព្រោះពាក្យនេះត្រូវបានយកមកប្រើប្រាស់យ៉ាងច្រើនចំពោះករណីដែលជាប់ពាក់ព័ន្ធជាមួយនឹងបទឧក្រិដ្ឋកម្មដ៏ធំក្នុងប្រវត្តិសាស្ត្រ ។ អ្នកដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យខ្លះយល់ថាខ្លួនត្រូវបានបោកប្រាស់និងកេងបន្លំ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានបញ្ចូលពួកគាត់ជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។ ករណីរបស់ខ្មែរក្រោមអាចថា ជាករណីចម្រូងចម្រាសមួយពីព្រោះក្រុមនេះមានទីតាំងនៅជិតព្រំដែន ដែលអាចជាទិសដៅក្នុងគោលបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ និយាយឲ្យចំទៅ គ្មានក្រុមណាមួយទទួលរងគ្រោះខ្លាំងជាងក្រុមណាមួយទេ ។ ការអប់រំដល់សាធារណជនត្រូវធ្វើចាំបាច់ឬក្នុងការជម្រះមន្ទិលអំពីអ្វីដែលមិនបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ដែលមិនបានធ្វើឲ្យការឈឺចាប់របស់ជនរងគ្រោះបានរសាយក្នុងចិត្ត ។ ទោះយ៉ាងណាក៏ដោយ ក៏ពាក្យថា «អំពើប្រល័យពូជសាសន៍» នឹងធ្វើឲ្យការចងចាំក្នុងចិត្តរបស់ជនរងគ្រោះនៅតែមានរហូតដល់ថ្ងៃអនាគតមួយដែលមិនអាចកំណត់ពេលវេលាបាន ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានកាតព្វកិច្ចនាំយកយុត្តិធម៌ជូនជនរងគ្រោះ ប៉ុន្តែក៏មានកាតព្វកិច្ចដូចគ្នាដែរក្នុងការធ្វើឲ្យមន្ត្រីតុលាការផ្សេងទៀតមានទំនុកចិត្តក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈនិងគួរឲ្យជឿជាក់បាន ។ អត្ថបទនេះមិនបានព្យាយាមពន្យល់ថាតើខ្មែរក្រោមទទួលរងនូវការធ្វើទុក្ខបុកម្នេញដែលត្រូវនឹងនិយមន័យរបស់ពាក្យប្រល័យពូជសាសន៍ ឬថាតើខ្មែរក្រោមគឺជាជនរងគ្រោះនៃការរំលោភបំពានសិទ្ធមនុស្សដែរនោះទេ ។ តុលាការអាចវិនិច្ឆ័យទោសបានដោយយោងទៅលើភស្តុតាងដែលមានស្រាប់ ។ ឥឡូវនេះជនត្រូវចោទត្រូវបានយកមកប្រឈមមុខនឹងផ្លូវច្បាប់ហើយ ។ ក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងផ្តល់នូវភាពយុត្តិធម៌ដ៏ស័ក្តិសមជាទីបំផុតនិងជួយផ្តល់នូវវិភាគទានក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីអំពើព្រៃផ្សៃរបស់ខ្មែរក្រហម ។ **ចន ឆរធីអារី**



ព្រះសង្ឃខ្មែរក្រោម

# ទីប្រឹក្សាច្បាប់របស់អាល្លឺម៉ង់ខាងកើត ចំពោះតុលាការឆ្នាំ១៩៧៩

## សេចក្តីផ្តើម

កាលពីឆ្នាំ២០០០ សាកលវិទ្យាល័យដេនស៊ីវ៉ានីញ៉ា បានបោះពុម្ពសៀវភៅមួយក្បាលទាក់ទងទៅនឹងសាលាក្តីឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុល ពត និង អៀង សារី ។ សៀវភៅនោះមានចំណងជើងថា អំពើប្រល័យពូជសាសន៍នៅកម្ពុជាៈ ឯកសារស្តីពីការកាត់ទោស ប៉ុល ពត និង អៀង សារី ដែលនិពន្ធដោយ ឌីណៃគី, ហោវើដ, ចន ឃ្វីលី, និង ខេណេត រ៉ូប៊ីនសុន ។ នេះជាសៀវភៅលើកទីមួយដែលបានបរិយាយអំពីតុលាការដែលមានឈ្មោះជាផ្លូវការថា តុលាការប្រជាជនបដិវត្តន៍កម្ពុជា បោះពុម្ពឡើងដើម្បីផ្សព្វផ្សាយដល់សាធារណជនទូទៅ ។ បន្ថែមទៅលើឯកសារជាង ៥៥០ទំព័រទាក់ទងនឹងតុលាការ ក៏មានការបោះពុម្ពផ្សាយអត្ថបទខ្លីៗបន្ថែមទៀតជាច្រើនផងដែររួមបញ្ចូលទាំងអត្ថបទមួយរបស់ខ្ញុំមានចំណងជើងថា «ការឆ្លុះបញ្ចាំងពីនរវិទូច្បាប់ម្នាក់» ។ នៅក្នុងអត្ថបទនេះខ្ញុំបានសន្និដ្ឋានថា «វាមានការកត់សម្គាល់ថា ប្រទេសអាល្លឺម៉ង់ខាងកើតមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំពិព័រណ៌អំពីការធ្វើទារុណកម្ម និងការសម្លាប់ដែលមាននៅបន្ទប់សួរចម្លើយរបស់ខ្មែរក្រហមដែលរក្សាទុកនៅទួលស្លែង ។ មានការបង្ហាញច្បាស់ថា សេចក្តីណែនាំដែលប្រើប្រាស់ក្នុងតុលាការត្រូវបានយកមកពីបុកអាល្លឺម៉ង់ខាងកើតក្នុងការកាត់ទោស ប៉ុល ពត និង អៀង សារី ។

បើតាមការស្មាន សំណើនោះមិនពិបាកយល់ទេ ។ យ៉ាងណាក៏ដោយ កាលពីឆ្នាំ២០០៧ ខ្ញុំមានការពេញចិត្តដែលបានសម្ភាសន៍ជាមួយនឹងលោក ហ៊ើ ខាឡូស ហុស្ត ដែលជាអ្នកតំណាងឲ្យការិយាល័យអគ្គព្រះរាជអាជ្ញានៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ (អតីតអាល្លឺម៉ង់ខាងកើត) ។ លោក ហុស្ត ត្រូវបានបញ្ជូនទៅប្រទេសកម្ពុជាកាលពីខែកក្កដា ឆ្នាំ១៩៧៩ ដើម្បីធ្វើជាទីប្រឹក្សារដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលទើបតែនឹងបង្កើតថ្មី ជាពិសេសផ្តល់ប្រឹក្សាលើករណី ប៉ុល ពត និង អៀង សារី ។ ការសន្ទនារវាងខ្ញុំជាមួយលោក ហុស្ត គឺជាលើកទីមួយដែលចាប់តាំងពីឆ្នាំ១៩៧៩មកមិនដែលមានការសម្ភាសណាមានលក្ខណៈពេញលេញបែបនេះទេ ។

## បទសម្ភាសន៍

ព្រិលកំពុងតែធ្លាក់ដែលអាចមើលឃើញនៅខាងក្រៅនារសៀលថ្ងៃសៅរ៍មួយកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ខ្ញុំបានអង្គុយជជែកអស់រយៈពេលជាងពីរម៉ោងជាមួយលោក ហុស្ត នៅក្នុងភោជនីយដ្ឋានដ៏ប្រណីតមួយឈ្មោះហ្គាស្តូស ប៊ុ កាហ្វេលីប៊ីក នៅជាយក្រុងហ្វ្រេគ្គតណាវ ដោយចំណាយពេលធ្វើដំណើររយៈពេល២០នាទីពីស្តាដប៊ីនអតីតប៊ែរឡាំងខាងកើត ។ ទោះបីជាដៃគូសន្ទនារបស់ខ្ញុំមានអាយុ៨៥ឆ្នាំ ហើយក៏ដោយ ក៏គាត់មិនមានការភ្លេចភ្លាំងឬខ្វះឆន្ទៈនិយាយលម្អិតអំពីរឿងតុលាការក្នុងតួនាទីការងាររបស់គាត់ធ្វើការនៅទីក្រុងភ្នំពេញកាលពី៣០ឆ្នាំមុនដែរ ។ លើសពីនេះ ដើម្បីបន្ថែមលើការសន្ទនាដ៏មានតម្លៃនេះ លោក ហុស្ត បានផ្តល់នូវឯកសារជាច្រើនដែលបង្ហាញយ៉ាងច្បាស់ទៅកាន់ក្រុមប្រឹក្សាតុលាការនិងសហការីកម្ពុជាដទៃទៀតអំពីរូបថតដែលគាត់បានថតក្នុងរយៈពេល៣សប្តាហ៍នៃការស្នាក់នៅរបស់គាត់ក្នុងទីក្រុងភ្នំពេញ ។

មានការចងចាំយ៉ាងច្បាស់នូវដំណើរការកាត់ទោសរបស់តុលាការឆ្នាំ១៩៧៩ ។ ក្នុងខែមករា ឆ្នាំ១៩៧៩ ដោយមានការគាំទ្រពីកងទ័ពវៀតណាមដែលមានបទពិសោធន៍និងអតីតកម្មាភិបាលដែលបានផ្តាច់ខ្លួនពីខ្មែរក្រហម បានរួមគ្នាបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដើម្បីប្រឆាំងនឹងរដ្ឋាភិបាលខ្មែរក្រហមដែលកំពុងតែកាន់អំណាចនៅទីក្រុងភ្នំពេញ ។ ក្នុងរយៈពេលប្រហែលតែ៣សប្តាហ៍ប៉ុណ្ណោះ រដ្ឋាភិបាលព្រៃផ្សៃដែលដឹកនាំ

ដោយ ប៉ុល ពត បានបោះបង់ចោលទីក្រុងភ្នំពេញ ហើយរត់ទៅកាន់តំបន់ភ្នំភូមិភាគខាងឦសាននៃប្រទេសកម្ពុជាដែលជាកន្លែងក្រុមខ្មែរក្រហមធ្លាប់ធ្វើសង្គ្រាម និងធ្វើជាចោរព្រៃអស់រយៈពេល ២ទសវត្សរ៍ ។ ខ្មែរក្រហមបានធ្វើខ្លួនជាសត្រូវចេសរឹងរូសអស់រយៈពេលយ៉ាងយូរ ដែលដំបូងជាសត្រូវរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាគាំទ្រដោយវៀតណាម និងក្រោយមកជាសត្រូវរបស់រដ្ឋកម្ពុជាដែលគាំទ្រដោយអង្គការសហប្រជាជាតិ ហើយទីបញ្ចប់ជាសត្រូវរបស់ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ បន្ទាប់ពីរដ្ឋាភិបាលខ្មែរក្រហមបានចាកចេញពីទីក្រុងភ្នំពេញ បញ្ហាប្រឈមមុខនឹងរបបថ្មីដែលទើបតែកើតឡើងនោះបានលេចចេញជាបញ្ហា ដូចជារដ្ឋាភិបាលខិតខំរកវិធីដើម្បីទាក់ទាញសេចក្តីទុកចិត្តពីប្រជាជនកម្ពុជានិងពីសហគមន៍អន្តរជាតិ ។ ទំព័រថ្មីនៃប្រវត្តិសាស្ត្រកម្ពុជានឹងចាប់ផ្តើមនាពេលឆាប់ៗខាងមុខនេះ ខណៈពេលដែលប្រទេសស្ថិតក្នុងការពិចារណារបស់សហគមន៍អន្តរជាតិថាតើគួរត្រូវទទួលស្គាល់ជាសមាជិករបស់អង្គការសហប្រជាជាតិឬយ៉ាងណា ។

## មូលហេតុដែលនាំឲ្យមានការចាត់តាំង

ទោះបីជាបច្ចុប្បន្ននេះមានការលំបាកក្នុងការអះអាងទាក់ទងទៅនឹងមូលហេតុដែលនាំឲ្យលោក ហុស្ត ត្រូវបានចាត់តាំងទៅធ្វើការនៅប្រទេសកម្ពុជាយ៉ាងណាក៏ដោយ យ៉ាងហោចណាស់យើងអាចសន្និដ្ឋានបានថា គឺហេតុផលអាចបណ្តាលមកពីការពាក់ព័ន្ធនឹងករណីលោក ហានស៍ គ្លុបកេ ។ លោក គ្លុបកេ កើតក្នុងឆ្នាំ១៨៩៨ ។ នៅឆ្នាំ១៩៦៣ លោកក្លាយជាមេធាវី និងបានឡើងកាន់តំណែងជាទីប្រឹក្សាសន្តិសុខជាតិទទួលបន្ទុកជាអ្នកតំណាងឲ្យមូលនិធិ ខុនរ៉ាដ អាដឺណៅអេ នៅប្រទេសអាល្លឺម៉ង់ខាងលិច ។ កាលពី៣ទសវត្សរ៍មុន ក្នុងនាមជាព្រះរាជអាជ្ញានៅរដ្ឋធានីព្រូសរបស់ប្រទេសអាល្លឺម៉ង់ លោក គ្លុបកេ បានសរសេរបទអធិប្បាយដ៏ល្អមួយក្នុងឆ្នាំ១៩៣៦ អំពីច្បាប់បន្សុទ្ធកម្មពូជសាសន៍របស់ណាហ្ស៊ី (ច្បាប់នូរ៉េមបឺកដ៏អាក្រក់) ។ បើតាម អ៊ីហ្គោ មូលើ ការវិភាគរបស់គ្លុបកេនៃច្បាប់ពូជសាសន៍គឺថាមានលក្ខណៈប្រកាន់ពូជសាសន៍ជាទីបំផុត ។ (យុត្តិធម៌របស់អ៊ីត្លែរៈ តុលាការនៃរបបណាហ្ស៊ី១៩៣៣-១៩៤៥ បោះពុម្ពនៅរោងពុម្ពនៃសាកលវិទ្យាល័យហាវើដក្នុងទីក្រុងខេមប្រីជ ឆ្នាំ១៩៩១ ទំព័រ១០០) ។ លទ្ធផលដែលទទួលបានគឺការកាត់ទោសជាលក្ខណៈបុគ្គល ។ ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ចំពោះមេដឹកនាំណាហ្ស៊ីដ៏ឃោរឃៅ ដោយបានអះអាងថា ទោះបីការពិតមិនសមស្របទៅនឹងផ្លូវច្បាប់ក៏ដោយ ប៉ុន្តែបញ្ហានេះគួរតែត្រូវបានបរិយាយយ៉ាងទូលំទូលាយ «ដើម្បីការពារនូវកិត្តិយសជនជាតិអាល្លឺម៉ង់ ជាពិសេសកិត្តិយសទាក់ទងទៅនឹងការរំលោភផ្លូវភេទដែលមានឈាមជ័រជាពលរដ្ឋអាល្លឺម៉ង់» ។ ដូចករណីរបស់ ប៉ុល ពត និង អៀង សារី ដែរ លោក គ្លុបកេ លើកពីសិទ្ធផ្ទាល់ខ្លួនក្នុងតុលាការ ហើយសវនាការរបស់គាត់នៅអាល្លឺម៉ង់ខាងកើតត្រូវបានធ្វើឡើងដោយកំបាំងមុខ ។ ទ្រឹស្តីនៃការកាត់ទោសក្នុងឆ្នាំ១៩៣៦ គឺបានបញ្ជាក់នៅក្នុងការអធិប្បាយពីអំពើពុករលួយនៃច្បាប់បន្សុទ្ធកម្មពូជសាសន៍ ហើយលោក គ្លុបកេ ក៏បានផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់អំពើប្រល័យពូជសាសន៍ដែលបានកើតឡើងក្រោយៗមកទៀតផងដែរ ។

ក្នុងពេលបច្ចុប្បន្ន លោក គ្លុបកេ បានប្រកាសថា គាត់មានការសប្បាយចិត្តដែលបានទទួលនូវការតែងតាំងឲ្យទៅបំពេញភារកិច្ចនៅទីក្រុងភ្នំពេញ និងបានទទួលស្គាល់កិច្ចការដ៏មានសារសំខាន់នេះដែលសម្រេចបាននូវយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ហើយវាជាជំហានមួយឆ្ពោះទៅរកការដោះស្រាយនូវរឿងអតីតកាលដែលបានជួបប្រទះដូចករណីលោក គ្លុបកេ ដែរ ។

មានសំបុត្រអញ្ជើញផ្ញើមក «សមមិត្ត ខាឡូស ហុស្ត» ជាច្រើនលើកដើម្បីទៅចូលរួមក្នុងព្រឹត្តិការណ៍ដែលត្រូវបានរៀបចំឡើងដោយលោក កែវ ចិន្តា ជារដ្ឋមន្ត្រីក្រសួងឃោសនាការវប្ប-ធម៌និងព័ត៌មាន ដែលប្រារព្ធធ្វើនៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៩ ដែលក្នុងនោះរួមមានលិខិតអញ្ជើញឲ្យទៅចូលរួមការសម្តែងសិល្បៈនៅសាលសន្និសីទចតុមុខផង ដែលក្រោយមកទីតាំងនេះត្រូវបានប្រើប្រាស់ជាសាលាក្តីខ្មែរក្រហម ។ មួយថ្ងៃក្រោយមកក៏មានការអញ្ជើញឲ្យទៅចូលរួមបរិភោគអាហារពេលល្ងាចជាឯកជនមួយនៅឯក្រសួងការបរទេស ។ ក្នុងពេលនោះ លោក កែវ ចិន្តា ក៏ជាប្រធានចៅក្រមនៃតុលាការប្រជាជនបដិវត្តន៍កម្ពុជាផងដែរ ។

## ក្រឹត្យ

កិច្ចប្រឹងប្រែងរបស់លោក ហូស្ត ទាក់ទងទៅនឹងដំណើរការតុលាការគឺផ្អែកទៅលើឯកសារសំខាន់ៗពីរ ហើយឯកសារទាំងនោះលោក ហូស្ត បានផ្តល់ជូនក្នុងអំឡុងពេលពិភាក្សាគ្នា ។ ឯកសារទីមួយគឺជាក្រឹត្យរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ កថាខណ្ឌខាងមុខរបស់តុលាការបានបកស្រាយថាមាន «ភ័ស្តុតាងនិងព័ត៌មាននៃអំពើឧក្រិដ្ឋកម្មដ៏យង់ឃ្នងជាទីបំផុតប្រឆាំងនឹងប្រជាជនចាប់តាំងពីថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥» ។ លើសពីនេះទៅទៀត ភ័ស្តុតាងនេះត្រូវបានចាត់ទុកថា «ជាសំណើមួយជូនចំពោះក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាដើម្បីនាំទៅរកយុត្តិធម៌និងនាំយកអ្នកដែលទទួលខុសត្រូវចំពោះទង្វើដែលបានប្រព្រឹត្តដោយអនុលោមតាមកម្រិតនៃកំហុសរបស់បុគ្គលម្នាក់ៗ» ។ ការងារសម្រាប់ដំណើរការតុលាការត្រូវបានធ្វើឡើងដោយជោគជ័យ ។

កថាខណ្ឌទាំង១៣ដែលមានចែងនៅក្នុងក្រឹត្យបានពន្យល់អំពីសមាសភាពរបស់តុលាការនិងទម្រង់ច្បាប់ ។ ការទទួលខុសក្នុងការអនុវត្តការងារច្បាប់នេះគឺជាភារកិច្ចរបស់ប្រធានតុលាការប្រជាជន (កថាខណ្ឌទី២) ។ ឧបាសក ឧបាសិកាចំនួន៨-១០នាក់គួរត្រូវបានជ្រើសរើសមកចូលរួមស្តាប់សវនាការ (កថាខណ្ឌទី៣) ។ កថាខណ្ឌទី៤និង៦ បានតម្រូវឲ្យមានការចាត់តាំងប្រធានព្រះរាជអាជ្ញានិងក្រុមប្រឹក្សាមេធាវី ។ (កថាខណ្ឌទី៩និងទី១០ក) អនុញ្ញាតឲ្យមានការប្រកាសអំពីជនត្រូវចោទនិងផ្តល់អំណាចដល់តុលាការដើម្បីដំណើរការក្តីទោះជាជនត្រូវចោទអវត្តមានក៏ដោយ និងរួមទាំងសិទ្ធិក្នុងការកាត់ទោសប្រហារជីវិត ។ ជនត្រូវចោទអាចនាំខ្លួនមកប្រឈមមុខនឹងតុលាការ ទោះជាជននោះចុះចាញ់ឬត្រូវចាប់ខ្លួនក៏ដោយ ។ ជនត្រូវចោទអាចមានសិទ្ធិនិងទាមទារការកាត់ក្តីថ្មីមួយទៀត (កថាខណ្ឌទី១០ង) ។ ការផ្តល់ជូនឲ្យមានការកាត់ទោសលើកក្រោយនេះ គឺអាចធ្វើឡើងបាននៅពេលណាដែលការកាត់ទោសកំបាំងមុខត្រូវបានអនុញ្ញាត ហើយជនត្រូវចោទអវត្តមានពីការកាត់ទោស ។

### «គោលបំណងនិងកិច្ចការរបស់ភាគីចុងចោទ»

ក្រឹត្យដែលបានរៀបរាប់ខាងលើបានបង្ហាញពីការបរិច្ចាគយ៉ាងសំខាន់របស់លោក ហូស្ត ក្នុងតួនាទីរបស់គាត់ជាទីប្រឹក្សាតុលាការ ។ មុខងារនេះត្រូវបានរៀបរាប់នៅក្នុងឯកសារទីពីរ «គោលបំណងនិងកិច្ចការរបស់ភាគីចុងចោទ» ។ ឯកសារនេះមានបួនទំព័រនិងចែកចេញជាពីផ្នែក ។ ផ្នែកទីមួយៈ គឺជាអនុសញ្ញាដែលពិពណ៌នាអំពីយុទ្ធសាស្ត្រនិងបច្ចេកទេសនៃមេធាវីរបស់ជនត្រូវចោទដែលពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរបំផុត ។ ផ្នែកទីពីរៈ សំដៅទៅលើ «គោលដៅនិងកិច្ចការ» ពាក់ព័ន្ធនឹងការផ្តល់ដំបូន្មានដែលឆ្លុះបញ្ចាំងពីភាពបន្ទាន់នៃសង្គ្រាមត្រជាក់ដូចបានស្គាល់ជាទូទៅតាមរយៈទស្សនៈនៃប៉ុកសូវៀត ។ ឯកសារទាំងពីរត្រូវបានរកឃើញក្នុងសេចក្តីថ្លែងការណ៍នៃការបើកជំនុំជម្រះថាៈ តុលាការនេះគួរតែមាន «ភ័ស្តុតាងដែលមិនអាចប្រកែកបាននៅមុនពេលបើកសវនាការជាសាធារណៈ» ១) ការកាត់ក្តីប្រកបដោយភាពយុត្តិធម៌សម្រាប់ជនត្រូវចោទ និង២) បនល្ងានពានចិនប៉ះកាំងជាបរិវារនិងជាអ្នកការពារជនត្រូវចោទ ។

បើទោះជាអត្ថបទរបស់លោក ហូស្ត សំដៅទៅលើ «គោលដៅនិងកិច្ចការរបស់ភាគីចុងចោទ» ក៏ដោយ ក៏មានភ័ស្តុតាងបញ្ជាក់ថាទីប្រឹក្សាអាល្លឺម៉ង់ខាងកើតនឹងៈ ក) ចូលបម្រើជាស្មៀនសម្រាប់សាលាក្តីទាំងមូល និង ខ) ផ្តល់នូវការណែនាំចំពោះសំណួរទាក់ទងនយោបាយដែលបានចោទសួរនៅពេលដំណើរការក្តី ព្រោះវាបានកើតឡើងម្តងហើយកាលពីករណីរបស់លោក ក្លុបប្លេ កាលពី១៧ឆ្នាំមុន ។ ក្នុងករណីខ្លះទៀត គោលបំណងដែលបានរៀបរាប់ហាក់ដូចជាមិនមានលក្ខណៈសមហេតុសមផល ប៉ុន្តែប្រហែលជាវាគ្មានភាពប្រសើរជាងករណីដែលបានកើតឡើងពីមុននោះទេ ព្រោះតុលាការនេះគឺផ្តោតទៅលើយុត្តិធម៌ជាបុគ្គលជាជាងយុត្តិធម៌សម្រាប់ប្រជាជនរាប់លាននាក់ដែលបានស្លាប់នៅក្នុងសម័យកាលនៃជម្លោះអស់រយៈពេល២ទសវត្សរ៍មកហើយ ។ ព្រឹត្តិការណ៍ដ៏ខ្មៅងងឹតនោះបានជាប់ពាក់ព័ន្ធទៅនឹងប្រទេសមហាអំណាចលើពិភពលោក ការបះបោរនិងសង្គ្រាមស៊ីវិល (ដែលអូសបន្លាយអស់រយៈពេល៥ឆ្នាំក្នុងការទម្លាក់គ្រាប់បែករបស់អាមេរិក) ការឈ្លានពាន ការរំដោះ និងជម្លោះប្រដាប់អាវុធដែលមិនបានដោះស្រាយ ។

### ការផ្តល់អនុសាសន៍របស់អាល្លឺម៉ង់ខាងកើត

គោលបំណងទាក់ទងការងារតុលាការចំពោះសាធារណជន

នៅក្រៅប្រទេសគឺកាន់តែងាយស្រួលយល់ជុំវិញអនុសាសន៍ដែលបានផ្តល់ឲ្យដោយលោក ហ្វស្ត ។ កថាខណ្ឌទី១.១) តម្រូវឲ្យ «ផ្ញើលិខិតអញ្ជើញមួយច្បាប់ទៅកាន់កាកបាទក្រហមអន្តរជាតិនៅទីក្រុងហ្សឺណែវ» ខណៈដែលកថាខណ្ឌទី១.២) សុំឲ្យមានការ «ឆ្លើយតបនិងមានលិខិតអញ្ជើញទៅអគ្គលេខាធិការនៃសមាគមមេធាវីប្រជាធិបតេយ្យអន្តរជាតិឈ្មោះ ចូ ណដម៉ែន ដែលមានទីស្នាក់ការនៅទីក្រុងប្រ៊ុចសែល» ។ នៅក្នុងសំបុត្រនេះមានបញ្ជាក់ពី «គោលបំណងនិងកិច្ចការ» ដែលសង្កត់ធ្ងន់ទៅលើពេលវេលាពិសេសការណែនាំចំពោះទីភ្នាក់ងាររបស់អគ្គឯកឧត្តមរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមធ្លាប់សម្របសម្រួលក្នុងការងារចាត់តាំងទីប្រឹក្សាមេធាវីបន្ថែមទៅលើមេធាវីមួយចំនួនដែលបានចាត់តាំងមកពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ចំពោះអនុសាសន៍ទាក់ទងទៅនឹងការអះអាងនៃក្រុមប្រឹក្សាមេធាវីបានចោទសួរពីភាពលម្អៀងរបស់តុលាការនិងការខ្វះខាតយុត្តាធិការ ។ ទីមួយ តុលាការបង្កើតឡើងទាំងស្រុងដោយជនរងគ្រោះឬក៏ក្រុមគ្រួសាររបស់ជនរងគ្រោះ ហើយដោយសារការជាប់ពាក់ព័ន្ធដូច្នេះ គឺមិនអាចជៀសវាងភាពលម្អៀងបានទេ ។ ទីពីរ តុលាការមិនអាចចោទសួរ ប៉ុល ពត និង អៀង សារី តាមផ្លូវច្បាប់បានទេ ពីព្រោះ «ពួកគេនៅតែមានឥទ្ធិពលនៅក្នុងទឹកដីកម្ពុជា» ។ ដោយយោងតាមការស្នើ អនុស្សរណៈទាំងនេះបានបញ្ចូលក្នុងច្បាប់របស់ខ្លួនទោះជាមានការប្រឆាំងជំទាស់ចំពោះការកាត់ទោសក៏ដោយ ។ ជាពិសេស តាមរយៈគោលការណ៍របស់អង្គការសហប្រជាជាតិដែលតំណាងឲ្យ «បូរណភាពទឹកដី» សាធារណរដ្ឋប្រជាមានិតកម្ពុជាបានកាន់កាប់ «សិទ្ធិកាត់ទោសបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងនៅក្នុងដែនដីនោះ» ។ ជាងនេះទៅទៀត «ការបរាជ័យនៃរដ្ឋ» ដែលមិនបានកាត់ទោសអាចក្លាយទៅជារដ្ឋហិង្សាហើយ «អ្នកទទួលខុសត្រូវនៃអំពើហិង្សាទាំងនេះគឺរដ្ឋទី៣» ។ នេះជាការឆ្លុះបញ្ចាំងពីការយល់ដឹងរបស់អ្នកនិពន្ធចំពោះ «ភារកិច្ចកាត់ទោស» របស់រដ្ឋដែលស្ថិតនៅក្រោមអនុសញ្ញារបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៨ ស្តីអំពីការបង្ការនិងការផ្តន្ទាទោសបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

នៅខណៈដែលនោះមន្ត្រីតុលាការចាត់វិធានការចំពោះចុងចោទដែលអវត្តមាន អនុស្សរណៈនេះបានផ្តល់ការអះអាងដែលអាចប្រើបានទាំងសងខាងដោយការកាត់ទោសក៏ដូចជាការការពារក្តី ។ តាំងពីពេលដែលចុងចោទរត់គេចបានជ្រើសរើស «ការមិនបង្ហាញខ្លួននិងការការពារខ្លួនគាត់» កាលៈទេសៈគឺខុសប្លែកពីអ្នកទាំងនោះក្នុងករណី «ជនត្រូវចោទម្នាក់មិនមានលទ្ធភាពប្រឈមមុខចំពោះកាត់ទោស» ជនត្រូវចោទខ្លួនគាត់ «ទទួលខុសត្រូវលើភាពខូចខាតដែលបណ្តាលមកពីការអវត្តមានរបស់គាត់» ។ នៅក្នុងករណីខ្លះ «ប្រសិនបើគាត់បង្ហាញខ្លួន» ឬត្រូវបានចាប់ខ្លួននៅក្រោមបទបញ្ញត្តិដែលមានចែងនៅក្នុងក្រឹត្យ គាត់មានសិទ្ធិប្តឹងតាមនីតិវិធីថ្មីមួយទៀត» ។

បន្ទាប់មក «គោលបំណងនិងកិច្ចការ» នៃអនុស្សរណៈក៏បាននាំទៅរកជំនាញអន្តរជាតិ សមត្ថភាពនៃឯកសារសួរចម្លើយដែលត្រឹមត្រូវតាមច្បាប់ នៅខណៈពេលដែលមានការនិយាយបញ្ចិតបញ្ចៀងទៅលើភាពគ្មានប្រយោជន៍នៃសាក្សីនៅអំឡុងពេលកាត់ក្តីនៅឆ្នាំ១៩៦៦ ប្រឆាំងនឹងអធិការបតីនៃសាធារណរដ្ឋសហពន្ធ័អាល្លឺម៉ង់ ពីបទឧក្រិដ្ឋកម្មសម័យណាហ្ស៊ី ។

នៅក្នុងឥរិយាបថដែលអាចយល់បានក្នុងកម្រិតខ្ពស់ អនុស្សរណៈបានជំរុញឲ្យមានការការពារចំពោះការកោះហៅ «ជនត្រូវចោទពីរដ្ឋទីបី ដែលជននោះរស់នៅភ្នំពេញ ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងអាចឆ្លើយបដិសេធនឹងការកាត់ទោសបាន ជាពិសេសពីសាធារណរដ្ឋប្រជាមានិតចិន» ។ កម្រិតដែលជនជាតិចិនអាចឆ្លើយតបទៅនឹងការកោះហៅឲ្យចូលខ្លួនទាំងនេះ គឺគ្មាន ។

ចំណុចដដែលប្រហែលជាបាននិយាយអំពីជំពូកចុងក្រោយនៅក្នុង «គោលបំណងនិងកិច្ចការ» ដែលមានបំណងថា «ចាប់តាំងពីបទឧក្រិដ្ឋដ៏ឃោរឃៅដែលបានប្រព្រឹត្តគឺមិនសមហេតុសមផលសម្រាប់មនុស្សម្នាក់ដែលមានសតិធម្មតា» ចុងចោទជាច្រើនមាន «ជំងឺសតិអារម្មណ៍» ឬ «បាត់បង់ការចងចាំ» ខណៈដែលរឿងក្តីរបស់គេដែលរកឃើញគឺមិនមានកំហុស ។ តាមរយៈការណែនាំសាក្សីត្រូវបានអញ្ជើញ ជាពិសេស «សាក្សីជាជនជាតិចិនដែលអាចត្រូវបានសាកសួរដោយអ្នកជំនាញឯកទេសចិត្តសាស្ត្រអន្តរជាតិដើម្បីដោះស្រាយរាល់សំណួរទាំងឡាយ» ។ ទោះជាយ៉ាងណា

ក៏ដោយ អ្នកបង្កើតអនុស្សរណៈនេះបានចេញសេចក្តីអះអាងយ៉ាងប្រញាប់ថា ការប្តឹងតវ៉ាបែបនេះគួរតែត្រូវបានប្រានចោលនៅខណៈដែលពួកគេកំពុងធ្វើតាមសង្គ្រាមលោកលើកទីពីរ ។ ខណៈដែលវាត្រូវបដិសេធចោលជាមួយណាហ្ស៊ីដែល «វាមានគោលបំណងបង្ហាញពីការសម្លាប់និងការកម្ទេចជនជាតិជ្វីហ្វ និងពួកទាសករមួយភាគធំ ក៏ដូចជាជនកុម្មុយនីស្តមួយចំនួនផងដែរ» ដោយសារតែមានវិបត្តិនយោបាយនៅពេលនោះ ដូច្នេះការប្តឹងទាមទារបែបនេះគួរតែត្រូវបដិសេធចោលចំពោះការសម្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងប្រទេសកម្ពុជា ។ សម្តីប្រកបដោយវោហាររបស់គាត់មានៈ

*ក្នុងនាមប្រជាជនដែលស្លាប់រាប់លាននាក់ អ្នកនៅរស់ពីរបបខ្មែរក្រហមក៏ដូចជាប្រជាជនទាំងអស់យល់ឃើញថា បណ្តឹងទាមទារនិងទ្រឹស្តីនេះគួរតែត្រូវបានប្រានចោល ពីព្រោះជនរងគ្រោះមិនមានសិទ្ធិប្រកែកតវ៉ានឹងសិទ្ធិរស់រានមានជីវិតទេ ។*

**លទ្ធផល**

នៅចុងបញ្ចប់នៃការកាត់ទោសនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ ទាំង ប៉ុល ពត និង អៀង សារី ត្រូវបានផ្តន្ទាទោស និងកាត់ទោសប្រហារជីវិត ។ វាជាការពិបាកក្នុងការនិយាយឲ្យបានប្រាកដប្រជាដែលក្រុមប្រឹក្សាមេធាវី ហ្វស្ត មានឥទ្ធិពលទៅលើការប្តឹង ។ ការចូលរួមរបស់គាត់ប្រហែលជាមានសារសំខាន់ដើម្បីបង្ហាញសាមគ្គីភាពរវាងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ដូចជាការផ្តល់នូវភាពលម្អៀងខាងផ្នែកច្បាប់រវាងរបបខ្មែរក្រហមនិងរបបណាហ្ស៊ីដែរ ។ ម្យ៉ាងវិញទៀត ការជជែកវែកញែកភាគច្រើនរបស់លោក ហប ស្ទីវិន ជាទីប្រឹក្សាការពារក្តីអាមេរិក ត្រូវបានបង្ហាញនៅក្នុងការរៀបរាប់របស់លោក ហ្វស្ត ពី «គោលបំណងនិងកិច្ចការការពារ» ។ ជាពិសេស លោក ស្ទីវិន បានជំរុញឲ្យមានទម្រង់បែបបទដើម្បីរកឲ្យឃើញកំហុសចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តដោយចុងចោទចំពោះអ្នកដទៃ «អ្នកដឹកនាំសង្គមដែលមិនស្មោះត្រង់នៃហ្វាស៊ីសចិន» ។ ប្រាកដណាស់ សញ្ញាណនេះគឺមិនមែនជាច្បាប់ដើមចំពោះលោក ហ្វស្ត ទេ ។ យ៉ាងណាក៏ដោយ ចំណុចសំខាន់នៅក្នុងជម្លោះដែលបានកើតឡើងក្នុងនាមជាចុងចោទគឺជាចំណុចមួយដែលគួរឲ្យកត់សម្គាល់ ។

**សេចក្តីសន្និដ្ឋាន**

ចំណុចផ្សេងទៀតដែលខ្ញុំបានរៀបរាប់នៅក្នុងសំណុំរឿងឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញគឺៈ «ចលនាសិទ្ធិមនុស្សអន្តរជាតិ» ។ សរុប ទោះបីជាមានការបង្ហាញពីគោលបំណងនិងការខិតខំប្រឹងប្រែងដើម្បីឈានទៅដល់ការបង្ហាញដល់សាធារណជនឲ្យមានលក្ខណៈទូលំទូលាយ ឧទាហរណ៍ តាមការអញ្ជើញរបស់កាកកបាទក្រហមអន្តរជាតិនៅទីក្រុងហ្សឺណែវ គោលនយោបាយសង្គ្រាមត្រជាក់នៅតែមានតួនាទីបញ្ចៀសឥទ្ធិពលនយោបាយក្រៅប្រទេស ។ ដូច្នេះ ទោះបីជាឯកសារដែលប្រមូលបាននៅឆ្នាំ១៩៧៩ ត្រូវបានរៀបចំយ៉ាងយកចិត្តទុកដាក់ និងទាន់ពេលវេលាក៏ដោយ វាហាក់ដូចជាមិនត្រូវបានគេយកចិត្តទុកដាក់ (ហើយកាន់តែអាក្រក់ជាងនេះទៅទៀតខ្មែរក្រហមនៅតែបន្តវាយប្រហារដោយប្រដាប់អាវុធនិងត្រូវបានទទួលស្គាល់ជាផ្លូវការទូតដោយសហរដ្ឋអាមេរិកនិងប្រទេសដទៃទៀតអស់រយៈពេលជាយូរមកហើយ បន្ទាប់ពីការភ័យខ្លាចនិងព្រំដែននៃការគ្រប់គ្រងរបស់ខ្លួនត្រូវបានគេយល់យ៉ាងច្បាស់) ។ ជាងនេះទៅទៀត រឿងដែលកាន់តែធ្ងន់ធ្ងរ ប្រជាជនជាច្រើនបានរកឃើញកំហុសដោយពឹងទៅលើនីតិវិធីច្បាប់និងមិនខ្វល់ពីតម្លៃដែលទទួលបាន ទោះបីជាវាមានឧបសគ្គច្រើនក៏ដោយ ។ ដូចនេះការប៉ះទង្គិចដោយចេតនាចំពោះការកាត់ក្តីឆ្នាំ១៩៧៩ ជាពិសេសនៅខាងក្រៅប្រទេសកម្ពុជានៅតែមានភាពចាំបាច់ ។

បច្ចុប្បន្ននេះ លោក កាឡូស ហ្វស្ត ធ្វើការយ៉ាងជិតស្និទ្ធជាមួយហេតុការណ៍ដែលបានកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខណៈដែលមានការចោទកាន់ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដែលនៅរស់ដើម្បីឆ្ពោះទៅរកការវិនិច្ឆ័យប្រកបដោយយុត្តិធម៌ ។ ទោះបីជាលោកគ្រូរបស់គាត់ចូលនិវត្តន៍និងរស់នៅឆ្ងាយពីសង្គមក៏ដោយ ប៉ុន្តែសព្វថ្ងៃនេះ លោក ហ្វស្ត នៅតែធ្វើជាអនុប្រធានតំណាងឲ្យសហគមន៍មេធាវីអន្តរជាតិប្រឆាំងនឹងអាវុធនុយក្លេអ៊ែរដែល គឺជាអង្គការដែលមានយុទ្ធសាស្ត្រប្រឆាំងនឹងគ្រាប់បែកអាតូមិច ជីវសាស្ត្រ និងអាវុធគីមី ។

**ហ្វូវីដ ជីវែន**

# ក្រោយពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អ្នកនយោបាយ អ្នកជំនាញច្បាប់ បញ្ញវន្ត និងប្រជាជនគ្រប់រូបដែលបានឆ្លងកាត់សម័យខ្មែរក្រហម តែងតែឮដដែលៗពីបំណងប្រាថ្នាចង់បាន «ការផ្សះផ្សា» នៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញអាចជាជំហានមួយនៅក្នុងដំណើរការផ្សះផ្សានេះក៏ដោយ ក៏សាលាក្តីដ៏ប្រសើរបំផុតនៅក្នុងពិភពលោកនេះមិនអាចសម្របសម្រួលសង្គមមួយបានទេ ។ បើទោះជាលទ្ធផលនៃដំណើរការកាត់ក្តីនៅក្នុងអង្គជំនុំជម្រះទៅជាយ៉ាងណាក៏ដោយ ក៏ប្រទេសកម្ពុជានិងប្រជាជនកម្ពុជានៅតែដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនដដែល ។ ដំណើរការដែលបុគ្គលម្នាក់ឬសង្គមទាំងមូលដឹងពីអតីតកាល គឺមានន័យថាជា «ការផ្សះផ្សា» ហើយ ។

### តើអ្វីជាការផ្សះផ្សា?

ខណៈដែលបញ្ញវន្តនិងអ្នកជំនាញច្បាប់ជាច្រើនបានសរសេរយ៉ាងច្រើនលើសលប់អំពីការផ្សះផ្សា ប៉ុន្តែមិនមាននិយមន័យនៃពាក្យផ្សះផ្សាត្រូវបានទទួលស្គាល់ទូលំទូលាយនៅឡើយទេ ។ ជាងនេះទៅទៀត បុគ្គលម្នាក់ៗហាក់ដូចជាកំណត់និយមន័យនៃពាក្យ «ផ្សះផ្សា» នេះខុសៗគ្នា ដោយយោងទៅតាមកត្តាអ្វីដែលសំខាន់ជាងគេបំផុតចំពោះបុគ្គលនោះ ។ ដូចដែលបញ្ញវន្តម្នាក់បានគូសបញ្ជាក់ថា «ការផ្សះផ្សា» គឺជា «តំបន់ពណ៌ប្រផេះដិតជាប់ពីមុនមក ដែលរឿងតិចតួចណាស់មានលក្ខណៈច្បាស់លាស់ ហើយការឆ្លើយតបរបស់បុគ្គលម្នាក់អាស្រ័យទៅតាមបុព្វសិទ្ធិរបស់អ្នកនោះ» ។

បញ្ញវន្តខ្លះបានដោះស្រាយភាពមិនច្បាស់នេះតាមរយៈការកំណត់និយមន័យនៃពាក្យផ្សះផ្សា ថាជាដំណើរការមួយជាជាងគោលដៅ ។ យោងទៅតាមទស្សនៈនេះ ការផ្សះផ្សាគឺ «ជាការដោះស្រាយជាមួយអតីតកាលក្នុងរបៀបមួយដែលនាំឲ្យមានការផ្លាស់ប្តូរឥរិយាបថអំពីអ្នកផ្សេង ខ្លួនយើង និងទំនាក់ទំនងរវាង «ភាគីជម្លោះ» ។ អ្នកឯកទេសខាងការផ្សះផ្សាផ្សេងទៀតបានគូសបញ្ជាក់ថា ទោះជាមានភាពខុសគ្នាក្នុងការកំណត់និយមន័យក៏ដោយ ក៏ខ្លឹមសារមួយចំនួនបានលេចឡើងយ៉ាងស្របគ្នាដែរ ។ ឧទាហរណ៍ គ្រេច អេនឹសុន បានបញ្ជាក់ថា «ដំណើរការនៃការព្យាបាលជំងឺប៉ះទង្គិចផ្លូវចិត្ត» មានសារសំខាន់ចំពោះការពិភាក្សាអំពីការផ្សះផ្សានេះ ។



ជនជាតិភាគតិចទទួលអំណោយ

នៅពេលដែលប្រជាជនកម្ពុជាសួរដើម្បីកំណត់និយមន័យពាក្យផ្សះផ្សា គំនិតដូចៗគ្នាក៏បានលេចឡើង ។ ប្រការនេះមានភាពច្បាស់លាស់ ខណៈពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្ទាបស្ទង់មតិថាតើអ្នកចូលរួមពិពណ៌នាថា «ការផ្សះផ្សា» មានន័យយ៉ាងដូចម្តេច ។ បើទោះជាអ្នកចូលរួមមានគំនិតខុសប្លែកគ្នាយ៉ាងច្រើនអំពីការផ្សះផ្សាក៏ដោយ

ក៏ខ្លឹមសារដូចជា «ការចងចាំ» និង «យុត្តិធម៌» បានលើកឡើងដដែលៗ ។ លើសពីនេះទៀត ប្រជាជនកម្ពុជាភាគច្រើនបំផុតបានចាត់ទុកគោលដៅនៃការផ្សះផ្សាថាជា «គោលដៅតែមួយគត់នាំឲ្យប្រទេសជាតិមានការរួបរួមវិបុលភាព និងអភិវឌ្ឍន៍» និងសង្គមមួយ «ដែលគ្មានអំពើហិង្សានិងជម្លោះ» និងសង្គមមួយដែល «រស់នៅក្រោមវិធាននៃច្បាប់» ។

អ្នកឆ្លើយសំណួរស្ទាបស្ទង់មតិនិងបញ្ញវន្តមិនយល់ស្របគ្នាទេថាតើ «ការផ្សះផ្សា» ជាបញ្ហាសង្គម ជាបញ្ហាបុគ្គល ឬជាបញ្ហាទាំងពីរ ។ បន្ថែមពីនេះទៀត អ្នកឆ្លើយសំណួរស្ទាបស្ទង់មតិបានបញ្ជាក់ថា ការផ្សះផ្សានេះទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងពីប្រជាពលរដ្ឋកម្ពុជាម្នាក់ៗនិងរដ្ឋាភិបាល ។ ដូច្នេះហើយ ការស្ទាបស្ទង់មតិបានបង្ហាញថា យ៉ាងហោចណាស់អ្នកចូលរួមចាត់ទុកការផ្សះផ្សាស្ថិតនៅលើកម្រិតបួនប្រភេទផ្សេងៗគ្នា បុគ្គលរវាងបុគ្គល នៅក្នុងសហគមន៍ និងទូទាំងប្រទេស ។ លីនតុន អ្នកនិពន្ធនៅក្នុងការស្ទាបស្ទង់មតិបានស្នើឡើងថា លទ្ធផលបានបង្ហាញឲ្យឃើញថា កាផ្សះផ្សាមិនមែនត្រង់ៗតែម្តងទេ ប៉ុន្តែវាជាដំណើរការមានច្រើនដំណាក់ដែលគ្របដណ្តប់ទាំង «បុគ្គល អន្តរបុគ្គល ទំនាក់ទំនងសហគមន៍និងប្រទេសជាតិ ព្រមទាំងចងភ្ជាប់ទៅក្នុងទស្សនៈសមាហរណកម្ម រាងកាយ នយោបាយ សេដ្ឋកិច្ច-សង្គម និងវប្បធម៌» ។

ប្រហែលជាដោយសារតែមានការលំបាកក្នុងការកំណត់និយមន័យ បញ្ញវន្ត និងបុគ្គលខ្លះចោទសួរអំពីទស្សនៈបែបនេះ ដោយនិយាយថាតើវាចាំបាច់ឬអាចទៅរួចដែរទេ ។ បុគ្គលទាំងនេះបានចោទសួរថាតើ «ការដោះស្រាយជាមួយអតីតកាល» ផ្តល់ផលប្រយោជន៍ពិតប្រាកដ ឬថាតើផលប្រយោជន៍មានតម្លៃស្មើនឹង «ការលែងខ្វាយខ្វល់» ហើយ «គម្លាតឆ្ងាយខាងចិត្តសាស្ត្រ» អាចនឹងទទួលបានវិញទេ ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនកម្ពុជាភាគច្រើនបំផុតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្ទាបស្ទង់មតិជឿថា ទម្រង់នៃការផ្សះផ្សាខ្លះៗគឺចាំបាច់ដើម្បីបញ្ចប់អតីតកាលនិងកសាងសង្គមដ៏ប្រសើរជាងមុននាពេលអនាគត ។

## ការផ្សះផ្សានិងអង្គជំនុំជម្រះវិសាមញ្ញ

ទោះបីជាគោលបំណងរបស់អង្គជំនុំជម្រះវិសាមញ្ញមិនសំដៅទៅរកការផ្សះផ្សាតែមួយគត់ក៏ដោយ ក៏អង្គជំនុំជម្រះនៅតែមានប្រយោជន៍ខ្លាំងនៅក្នុងដំណើរការផ្សះផ្សានៅប្រទេសកម្ពុជា ។ ប្រជាជនកម្ពុជាភាគច្រើនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាស្ទាបស្ទង់មតិបានបញ្ជាក់ថា «យុត្តិធម៌» មានសារសំខាន់ដើម្បីសម្រេចបាននូវការផ្សះផ្សា ។ ដំណើការកាត់សេចក្តីបទឧក្រិដ្ឋកម្មនៅអង្គជំនុំជម្រះវិសាមញ្ញ ជាមធ្យោបាយមួយដើម្បីស្វែងរកយុត្តិធម៌ឲ្យជនរងគ្រោះនៃរបបខ្មែរក្រហម ។ ការដែលបានឃើញការកាត់ទោសជនជាប់ចោទនិងស្តាប់ពុភស្តុតាងនានានៅចំពោះមុខសាលាក្តីអាចជួយជនរងគ្រោះខ្លះដោះស្រាយជំងឺប៉ះទង្គិចផ្លូវចិត្តកាលពីជំនាន់ខ្មែរក្រហមបាន ។ ជនរងគ្រោះដែលចង់ចូលរួមយ៉ាងក្លៀវក្លានៅក្នុងដំណើការកាត់ក្តីក៏អាចត្រូវបានជ្រើសរើសឲ្យធ្វើជាភាគីដើមបណ្តឹងរដ្ឋប្បវេណីដែរ ។ ចំណែកអ្នកផ្សេងៗទៀតអាចត្រូវកោះហៅឲ្យមកធ្វើជាសាក្សី ហើយមានឱកាសផ្តល់សក្ខីភាព ។


បុគលិក្តមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងពន្យល់អំពីដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅកាន់អ្នកភូមិក្នុងខេត្តកំពត

ច្បាប់អង្គជំនុំជម្រះក៏អនុញ្ញាតឲ្យសាលាក្តីផ្តល់ «សំណងជានិមិត្តរូប

និងជារួម» ដល់ជនរងគ្រោះ ដែលរាប់បញ្ចូលទាំងស្តូបសាធារណៈ ឬទិវានៃការចងចាំ ។ «ការចងចាំ» ជាខ្លឹមសារទីពីរ ដែលលើកឡើងដដែល ៗ ដោយអ្នកឆ្លើយសំណួរស្ទាបស្ទង់មតិ និងបូជនីយដ្ឋានសាធារណៈ ។ ទាំងអស់នេះជាផ្នែកមួយនៃដំណើរការផ្សះផ្សា ដើម្បីធានាថា សង្គមមិនបំភ្លេចអំពើឃោរឃៅកាលពីអតីតកាលបានទេ ។

## ការផ្សះផ្សានៅកម្ពុជា

ប្រទេសកម្ពុជាបានជ្រើសរើសយកការកាត់សេចក្តីលើបទឧក្រិដ្ឋកម្មរបស់បុគ្គលជាផ្នែកមួយនៃដំណើរការផ្សះផ្សា ។ ប៉ុន្តែប្រទេសផ្សេងៗទៀតដែលជួបប្រទះអំពើហិង្សាខាងនយោបាយធ្ងន់ធ្ងរដែរ បានលះបង់ចោលការកាត់សេចក្តីបែបនេះ ដោយជ្រើសរើសយកការធ្វើកិច្ចការនានាសំដៅទៅរកការផ្សះផ្សាតាមរយៈវិធីផ្សេងៗគ្នា ។ ប្រទេសមួយចំនួនដូចជា ប្រទេសអាហ្វ្រិកខាងត្បូងបានបង្កើតគណៈកម្មការស្វែងរកការពិត ។ គណៈកម្មការទាំងនេះមិនមែនជាតុលាការទេ ប៉ុន្តែជាវេទិកាដែលស្វែងរកការប្រមែប្រមូលនិងផ្សព្វផ្សាយព័ត៌មានពីសម័យកាលនៃអំពើហិង្សានយោបាយ ។

មុនពេលអង្គជំនុំជម្រះត្រូវបានបង្កើតឡើង អ្នកជំនាញច្បាប់និងអ្នកនយោបាយបានស្នើឲ្យបង្កើតគណៈកម្មការផ្សះផ្សាជំនួសឲ្យការកាត់សេចក្តីបទឧក្រិដ្ឋកម្មបុគ្គល ។ ខណៈដែលប្រទេសកម្ពុជានិងសហគមន៍អន្តរជាតិបានសម្រេចចុងក្រោយថា ការកាត់សេចក្តីបទឧក្រិដ្ឋកម្មសមស្របជាងនោះ កិច្ចខិតខំប្រឹងប្រែងដទៃទៀតត្រូវបានធ្វើឡើងដើម្បីផ្តល់មធ្យោបាយបន្ថែមដល់ការផ្សះផ្សា ។ ការពិត ដំណើរការនៃការផ្សះផ្សានៅប្រទេសកម្ពុជាបានចាប់ផ្តើមតាំងពីឆ្នាំ១៩៧៩មកម្ល៉េះ តាំងពីមុនលទ្ធភាពក្នុងការបង្កើតសាលាក្តីដូចជាអង្គជំនុំជម្រះវិសាមញ្ញនេះទៅទៀត ។

នៅក្នុងឆ្នាំ១៩៧៩ មេដឹកនាំខ្មែរក្រហមមួយចំនួនត្រូវបានកាត់ទោសហើយកាត់ឲ្យជាប់ទោសដោយកំបាំងមុខ ។ ខណៈពេលដែលសហគមន៍អន្តរជាតិបានថ្កោលទោសការកាត់សេចក្តីនេះ គឺដោយសារការកាត់សេចក្តីនេះមិនគោរពទៅតាមបទដ្ឋានអន្តរជាតិនិងមិនបម្រើជាវេទិកាផ្សព្វផ្សាយព័ត៌មានពីសម័យខ្មែរក្រហម ព្រមទាំងបង្ហាញពីការថ្កោលទោសជាសាធារណៈពីអំពើឃោរឃៅដែលបានប្រព្រឹត្តនៅក្នុងសម័យនោះដែរ ។

ក្រោយការកាត់សេចក្តីឆ្នាំ១៩៧៩ រដ្ឋាភិបាលបានបង្កើតគណៈកម្មការស្រាវជ្រាវមួយ ដើម្បីស៊ើបអង្កេតបទឧក្រិដ្ឋកម្មសម័យខ្មែរក្រហម ។ គណៈកម្មការនេះសហការជាមួយប្រធានភូមិនិងចៅហ្វាយស្រុកដែលចងក្រងបញ្ជីអ្នកដែលត្រូវបានសម្លាប់ និងទ្រព្យសម្បត្តិដែលត្រូវបានបំផ្លិចបំផ្លាញ ។ បញ្ជីទាំងនេះត្រូវបានស្គាល់ថាជា «ញត្តិរណសិរ្ស» ។ ក្រៅពីញត្តិទាំងនេះ កាលពីច្រើនឆ្នាំមុន រដ្ឋាភិបាលបានបង្កើតទិវាចងចាំនិងបូជនីយដ្ឋានជាច្រើន ដូចជានៅជើងឯកជាដើម ។

អង្គការក្រៅរដ្ឋាភិបាលក៏ដើរតួនាទីដ៏សំខាន់នៅក្នុងដំណើរការផ្សះផ្សានេះដែរ ។ អង្គការដូចជាមជ្ឈមណ្ឌលអភិវឌ្ឍសង្គមបានបើកវេទិកាជាច្រើននៅតាមបណ្តាខេត្តដើម្បីផ្តល់ឲ្យជនរងគ្រោះនូវឱកាសចែករំលែករឿងរ៉ាវរបស់ខ្លួន ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីសាលាក្តីខ្មែរក្រហម ។ ទស្សនាវដ្តី «ស្វែងរកការពិត» ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពផ្សាយបានសរសេរបទវិចារណកថា ព័ត៌មានផ្នែកច្បាប់និងព័ត៌មានទូទៅអំពីខ្មែរក្រហម ។ បន្ថែមពីនេះទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឱកាសឲ្យសាធារណជនទទួលបានឯកសារនិងព័ត៌មានដែលប្រមែប្រមូលបានអស់រយៈពេលជាង១០ឆ្នាំមកហើយ ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់រដ្ឋាភិបាលក៏ដោយ ក៏អង្គជំនុំជម្រះនិងអង្គការក្រៅរដ្ឋាភិបាល អត្ថន័យនិងផ្លូវឆ្ពោះទៅកាន់ការផ្សះផ្សាត្រូវបានជិតជាប់ជាមួយបុគ្គលម្នាក់ៗដែរ ។ មនុស្សម្នាក់ៗត្រូវតែសម្រេចដោយខ្លួនឯងថាអ្វីទៅដែលនាំឲ្យមានការផ្សះផ្សា តើការផ្សះផ្សាអាចសម្រេចទៅបានតាមវិធីណាខ្លះ ឬក៏ថាតើការផ្សះផ្សាអាចសម្រេចបានដែរឬទេ ។ ប្រសិនបើមានខ្លឹមសារនៃការពិភាក្សាជាប្រចាំនិងការព្យាយាមកំណត់និយមន័យនៃពាក្យផ្សះផ្សា នោះមានន័យថាការផ្សះផ្សាជាដំណើការមួយ តែមិនមែនជាគោលដៅមួយនោះទេ ។ ប្រទេសនីមួយៗដែលជួបប្រទះនូវអំពើហិង្សានិងអំពើឃោរឃៅធ្ងន់ធ្ងរត្រូវតែរិះរកមធ្យោបាយស្តារឡើងវិញដោយខ្លួនឯង ចំណែកបុគ្គលម្នាក់ៗដែលឆ្លងកាត់សម័យកាលនោះនិងក្មេងៗក៏ត្រូវធ្វើដូចគ្នាអ៊ីចឹងដែរ ។ **ខេលី ហោឡិង**

# ទំនាក់ទំនងបដិវត្តន៍ឡាវ-កម្ពុជា

នៅថ្ងៃចុងក្រោយរបស់ ប៉ុល ពត ដែលស្ថិតក្រោមការឃុំឃាំងនៅក្នុងផ្ទះនៅអន្លង់វែង គាត់បានធ្វើឲ្យមានចំណាប់អារម្មណ៍មួយចំពោះជនកុម្មុយនីស្តដែលមិនសូវល្បីម្នាក់ឈ្មោះ តា យ៉ា ដោយបានចោទប្រកាន់ឈ្មោះ នៃ សារ៉ាន់ ហៅ យ៉ា នេះថាជាជនបះបោរនៃកងកម្លាំងក្បត់ដែលនាំទៅរកភាពអន្តរាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អស់រយៈពេលពីរបីឆ្នាំចុងក្រោយនេះ ខ្ញុំបានស្រាវជ្រាវរកខ្សែបណ្តាញទាក់ទងរវាងចលនាបដិវត្តន៍ខ្មែរ និងឡាវ ។ ខ្ញុំបានសង្កេតលើទំនាក់ទំនងរវាងចលនានៅក្នុងប្រទេសឡាវខាងត្បូង កម្ពុជាប៉ែកខាងជើងនិងប៉ែកឦសាននៃប្រទេសថៃ ។ ការផ្តោតសំខាន់របស់ខ្ញុំគឺទៅលើទំនាក់ទំនងរវាងចលនាប៉ាថេតឡាវនិងខ្មែរក្រហម ។ ប៉ុន្តែ ដែនកំណត់នៃការសិក្សានេះបានឈានទៅដល់តំបន់ឦសាន ដោយសារតែចលនាបដិវត្តន៍ទាំងពីរនេះបានតស៊ូប្រឆាំងនឹងឥទ្ធិពលទៅលើកុលសម្ព័ន្ធឡាវនិងកុម្មុយនីស្តកម្ពុជានៃភូមិភាគឦសានប្រទេសថៃ ជាពិសេសសាខាអ៊ីសានតៃនៃបក្សកុម្មុយនីស្តថៃ ។ ការស្រាវជ្រាវរបស់ខ្ញុំផ្តោតទៅលើភាគខាងត្បូងនៃចលនាប៉ាថេតឡាវ ទំនាក់ទំនងបដិវត្តន៍រវាងអ៊ីសានតៃ-ឡាវ ការសិក្សាពីប្រវត្តិខេត្ត ទំនាក់ទំនងតំបន់ចំណុះប្រព័ន្ធទំនាក់ទំនងរវាងមេនិងកូនចៅ និងទំនាក់ទំនងនៃកងកម្លាំងប្រឆាំងនឹងវៀតណាមនៅតាមព្រំដែនឡាវខ្មែរ ពាណិជ្ជកម្មនិងការធ្វើអន្តោប្រវេសន៍ឆ្លងកាត់ព្រំដែន និងដើមកំណើតដ៏អាថ៌កំបាំងនៃប្រពន្ធ័កុម្មុយនីស្តក្នុងខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ឧត្តរមានជ័យ បន្ទាយមានជ័យ និងព្រះវិហារ ។

អត្ថបទនេះដកស្រង់ចេញពីការស្រាវជ្រាវនិក្ខេបបទរបស់ខ្ញុំដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទំនាក់ទំនងនៃបដិវត្តន៍ឡាវ-កម្ពុជានៅសតវត្សរ៍ទី២០ ។ អត្ថបទនេះប្រើប្រាស់ឯកសារជាភាសាឡាវ ខ្មែរ វៀតណាម ថៃ និងអង់គ្លេស នៅក្នុងបណ្ណសារដ្ឋាន ព្រមទាំងប្រវត្តិសាស្ត្រផ្ទាល់មាត់ដែលកត់ត្រាពីខេត្តនៅភាគខាងត្បូងនៃប្រទេសឡាវនិងភាគខាងជើងនៃប្រទេសកម្ពុជា ។ ខ្ញុំបានទៅមើលអន្លង់វែងចំនួនបីដងដើម្បីធ្វើសម្ភាសជាមួយអតីតយុទ្ធជនខ្មែរក្រហមដែលមានដើមកំណើតពីភាគឦសាននៃប្រទេសកម្ពុជា ។ ភាគច្រើននៃអ្នកទាំងនោះគឺជាខ្មែរលើ (ខ្មែរដែលរស់នៅតាមតំបន់ភ្នំមានអម្បូរភាសាអូស្ត្រូអាស៊ីយ៉ាទិច) ឬជាជនជាតិភាគតិចឡាវ ហើយខ្លះទៀតជាជនជាតិភាគតិចខ្មែរដែលផ្លាស់ទៅរស់នៅភាគឦសានប្រទេសកម្ពុជាដើម្បីធ្វើជាកងការពារសន្តិសុខនៅព្រំដែនបន្ទាប់ពីឆ្នាំ១៩៧៥ ។ ខ្ញុំមានចំណាប់អារម្មណ៍ថាខ្មែរក្រហមមិនបានធ្វើបាបជនជាតិភាគតិចឡាវខ្លាំងទេ ។ នៅសម័យនោះ ខ្មែរក្រហមមិនមានជំហរប្រឆាំងនឹងជនជាតិភាគតិចឡាវដែលរស់នៅភាគឦសាននៃប្រទេសកម្ពុជាឡើយ ។ តាមការពិតមានការធ្វើទុក្ខបុកម្នេញនិងសម្លាប់ជនជាតិភាគតិចឡាវ ប៉ុន្តែចំណុចដែលគួរឲ្យចាប់អារម្មណ៍នោះ គឺជនជាតិភាគតិចឡាវខ្លះមានមុខតំណែងដ៏មានឥទ្ធិពលក្នុងជួររដ្ឋាភិបាលខ្មែរក្រហមនិងក្នុងអំឡុងពេលនៃការកាន់កាប់របស់វៀតណាមដែរ ។ លើសពីនេះទៅទៀត អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺប្រពន្ធ កូន និងកូនចៅរបស់កម្មាភិបាលដែលបានសម្លាប់ប្រជាជនដ៏ច្រើនមកពីខេត្តនៅភាគខាងជើងនិងភាគឦសាននៅរស់រានមានជីវិតនៅឡើយ ។

ឧទាហរណ៍មួយ គឺគណៈស្រុកវ៉ឺនសៃឈ្មោះ តា កាត ដែលជាជនជាតិភាគតិចខ្មែរត្រូវបានបោសសម្អាត បន្ទាប់ពីបងប្អូនរបស់គាត់ ឈ្មោះ ឃាង ស៊ីមហ៊ិន (ហៅ តា ប៊ិត) ជាប្រធានតំបន់១០៤ (ស្ទឹងត្រែង) ត្រូវបានចាប់ខ្លួនដោយកងសន្តិសុខនៅមន្ទីរស-២១ ពីបទរួមគំនិតជាមួយឡាវ នៅពេលដែលស្ថានភាពរវាងវៀតណាមនិងកម្ពុជាកាន់តែតានតឹងឡើងនៅឆ្នាំ១៩៧៨ ។ ផ្ទុយទៅវិញ ប្រពន្ធរបស់គាត់ដែលជាជនជាតិភាគតិចឡាវនៅរស់រានមានជីវិត ហើយសព្វថ្ងៃរស់នៅភាគខាងលិចប្រទេសកម្ពុជាទៀត ។ តាប៊ិត និង តាកាត មិនទាន់ត្រូវបានចាប់ខ្លួននៅពេលមានការធ្វើបន្សុទ្ធកម្មទេ ពីព្រោះអ្នកទាំងពីរនេះមានសម្ព័ន្ធភាពជាមួយ «បងធំ» ហើយជាកូនកាត់ខ្មែរចិនអាចជាជនជាតិចិនផង ។ តា ប៊ិត

ធ្លាប់មានទំនាក់ទំនងជាមួយ ប៉ាថេតឡាវដែលជាប្រធានស្រុកខួង នៅភាគខាងត្បូងប្រទេសឡាវឈ្មោះ បូនយ៉ុង វង្សសាវ៉ាត ។ បូនយ៉ុង ចងចាំពីទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយខ្មែរក្រហមរហូតដល់ឆ្នាំ១៩៧៦ នៅពេលដែលគាត់ត្រូវបានបញ្ជូនទៅសិក្សាវគ្គបណ្តុះបណ្តាលនយោបាយនៅប្រទេសវៀតណាម ។ តាមសំណេរដែលសរសេរដោយ ដេវីដ ឆេនល័រ និង បែ៊ន ឃៀរនិន បានឲ្យដឹងថា អង្គការថ្នាក់លើមានបំណងកម្ចាត់សាច់ញាតិនិងអ្នកដែលមានទំនាក់ទំនងជាមួយខ្មាំង ប៉ុន្តែអ្វីដែលធ្លាប់អះអាងនេះ វាមិនពិតទាំងអស់នោះទេ ។ ករណីដែលគួរឲ្យចាប់អារម្មណ៍មួយទៀតគឺករណី តា ឡាំង ដែលជាចៅហ្វាយខេត្តមណ្ឌលគិរី (ហៅតំបន់ ១០៥) ធ្លាប់ធ្វើការងារជាមួយអតីតជនក្បត់ឈ្មោះ តាយ៉ា និងមានសម្ព័ន្ធភាពនឹងគ្នាតាមរយៈអាពាហ៍ពិពាហ៍កូនចៅ ។ នៅក្នុងបទសម្ភាសចុងក្រោយជាមួយ ណេត ថាយ័រ ប៉ុល ពតបានអះអាងថា យ៉ា ជាជនក្បត់មួយរូបដែលបានចូលដៃចូលជើងជាមួយវៀតណាមដើម្បីប្រឆាំងនឹងអង្គការ ។

នៅសតវត្សរ៍ទី២០ ចលនាបដិវត្តន៍ឥណ្ឌូចិនបានអះអាងពីសម្ព័ន្ធភាពដ៏រឹងមាំរបស់ខ្លួន ។ ប៉ុន្តែ ឥទ្ធិពលរបស់ ប៉ុល ពត ក្នុងចលនាបដិវត្តន៍កម្ពុជានៅចុងទសវត្សរ៍៦០ បង្កឲ្យមានការបែកបាក់សម្ព័ន្ធភាពបងប្អូននៅឥណ្ឌូចិននៅចុងទសវត្សរ៍៧០ ។ ចាប់តាំងពីទសវត្សរ៍៨០ មានការសិក្សាផ្សេងៗគ្នាអំពីទំនាក់ទំនងរវាងវៀតណាមនិងកម្ពុជា ព្រមទាំងទំនាក់ទំនងរវាងឡាវនិងវៀតណាម ។ ប៉ុន្តែមិនមានការសិក្សាលម្អិតទៅលើទំនាក់ទំនងចលនាបដិវត្តន៍រវាងកម្ពុជានិងឡាវទេ ។ ហេតុផលសំខាន់គឺថាការតស៊ូបដិវត្តន៍របស់ក្រុមទាំងពីរនេះត្រូវបានបណ្តុះបណ្តាលនិងអភិវឌ្ឍដោយជនកម្មុយនីស្តវៀតណាមដោយឡែកពីគ្នា ។ ដំបូងឡើយ វៀតណាមខាងជើងគ្រប់គ្រងឡាវ រីឯវៀតណាមខាងត្បូងគ្រប់គ្រងកម្ពុជា ។ យ៉ាងណាមិញ មានតំបន់ជាប់គ្នាពីរតាមបណ្តោយព្រំដែនកម្ពុជា-ឡាវ ដែលគ្រប់គ្រងដោយកម្មាភិបាលវៀតណាមនៅវៀតណាមកណ្តាលនិងថៃ ដែលអ្នកបដិវត្តន៍ឥណ្ឌូចិនភៀសខ្លួនទៅរស់នៅ ដើម្បីគេចពីការតាមចាប់របស់ទាហានបារាំងក្នុងគោលបំណងចូលរួមជាមួយថៃសេរីនិងសាខាបក្សកម្មុយនីស្តឥណ្ឌូចិននៅបរទេស ។

តា យ៉ា គឺជាឈ្មោះបដិវត្តន៍ចុងក្រោយរបស់ជនកម្មុយនីស្តកម្ពុជា នៃ សាវ៉ាន់ ។ នៃ សាវ៉ាន់ គឺជាកូនខ្មែរកាត់ចិន មានដើមកំណើតមកពីខេត្តស្វាយរៀង ដែលជាកន្លែងគាត់បានចូលរួមបក្សកុម្មុយនីស្តកម្ពុជា ជាមួយ សោ ភឹម (ក្រោយមកជាលេខាភូមិភាគបូព៌) កែវ មុនី និងកែវ មាស នៅចុងទសវត្សរ៍៤០ ។ នៅពេលមានសង្គ្រាមឥណ្ឌូចិនលើកទីមួយ គាត់ធ្វើការជាមួយកម្មាភិបាលកម្ពុជានិងវៀតណាម ដូចជា ទូ សាមុត, ង៉ូ ថាត់សឺន (ហៅ សឺន ស៊ីចាន់) ង្វៀង ថាញ់ សឺន, នង សារួន, ឆាយ សារ៉េត, សក្យវង្ស និង ហុង ហ៊ី នៅភាគខាងកើត ដែលលាតសន្ធឹងពី



កិច្ចប្រជុំរណសិរ្សបង្រួបបង្រួមឡាវ-កម្ពុជា និងវៀតណាម ក្នុងឆ្នាំ១៩៥០
(ក្នុងរូបថតនេះមាន នូ ហាក់, ស៊ីសាណា, ខាំតៃ និងស៊ុក ដែលឈរបាំងដោយ ស៊ីសាណា)

គាយនិញដល់ក្រចេះ ។ នៃ សារ៉ាន់ ទទួលការបណ្តុះបណ្តាលនៅខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាមអំឡុងពេលសង្គ្រាមឥណ្ឌូចិនលើកទីមួយ ហើយទទួលមុខងារជាអ្នកនាំសារតំបន់ឦសានរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរដែលគ្រប់គ្រងដោយ ឌិម សេដា និងអនុប្រធានឈ្មោះ យ៉ាកន ។

ជាយូរណាស់មកហើយយើងជឿថា ជនកុម្មុយនីស្តកម្ពុជាមិនទាន់មានសាខាបក្សពិតប្រាកដនៅភូមិភាគឦសានទេ រហូតការមកដល់របស់ អៀង សារី និង សុន សេន នៅដើមទសវត្សរ៍ ៦០ ប៉ុន្តែតំបន់នេះមានសកម្មភាពតាំងពីចុងទសវត្សរ៍៤០មកម្ល៉េះដែលដឹកនាំដោយ ឌិម សេដា ។ ឌិម សេដា គឺជាលេខាតំបន់ដំបូងគេរបស់បក្សកុម្មុយនីស្តកម្ពុជា បន្ទាប់មកបក្សប្រជាជនបដិវត្តន៍ខ្មែរនៅភាគឦសាននៃប្រទេសកម្ពុជា ។ ឈ្មោះពិតរបស់គាត់គឺ សៀង គឹមសេង ជាជនជាតិភាគតិច ។ គ្មានអ្នកណាដឹងថាហេតុអ្វីបានជាគេហៅគាត់ថា សេដា នោះទេ ដែលឈ្មោះនេះជាឈ្មោះរុក្ខជាតិខ្មែរ ។ សេដា ក៏អាចជាឈ្មោះឡាវដែលហៅថា ស៊ីដា ហើយក៏ជាឈ្មោះមនុស្សស្រីដែរ ។ បច្ចុប្បន្ននេះមានឃុំមួយនៅស្រុកលំផាត់ឈ្មោះ សេដា ដែរ ។ ឈ្មោះ ឌិម សេដា នៅប្រទេសកម្ពុជាមិនដឹងជាមានដើមកំណើតមកពីណាទេ យើងគ្រាន់តែដឹងថាបារាំងបានដាក់គាត់ឲ្យចូលជាទាហានអាណានិគម ហើយបន្ទាប់មកត្រូវបានគេដាក់គុកនៅញ៉ាត្រាងប្រទេសវៀតណាម ។ ដោយមានការកាន់កាប់របស់ជប៉ុននៅឥណ្ឌូចិន ឌិម សេដា ត្រូវបានដោះលែង ហើយបន្ទាប់មកគាត់ត្រូវបានបញ្ជូនទៅចូលរួមចលនាបដិវត្តន៍វៀតណាម ។ គាត់ត្រូវបានបណ្តុះបណ្តាលដោយកម្មាភិបាលនៅលៀនឃូវី ដែលនៅតំបន់ជាប់គ្នារវាងភាគខាងជើងប្រទេសកម្ពុជានិងភាគខាងត្បូងប្រទេសឡាវក្នុងខ្ពង់រាបភាគកណ្តាលនៃប្រទេសវៀតណាម បន្ទាប់មកគាត់ត្រូវបានចោទប្រកាន់ថាមានបង្កើតកងទ័ពបដិវត្តន៍នៅកម្ពុជា ។ ឌិម សេដា រត់ទៅរស់នៅសៀមប៉ាង បច្ចុប្បន្នខេត្តស្ទឹងត្រែង និងវ៉ឺនសៃ បច្ចុប្បន្នខេត្តរតនគិរី ។ ទីលំនៅរបស់គាត់គឺនៅចាន់ទូកដែលបច្ចុប្បន្នគឺជាភូមិដាច់ស្រយាលតូចមួយនៅជិតភាគខាងលិចឧទ្យានជាតិវីរជ័យ ។ បន្ទាប់មក ឌិម សេដា រៀបការជាមួយនារីជនជាតិឡាវម្នាក់ ហើយរៀននិយាយភាសាឡាវយ៉ាងស្ទាត់ជំនាញ ។ គាត់ក៏ចេះនិយាយភាសាវៀតណាមល្អដែរ ។

ចំណុចគួរឲ្យចាប់អារម្មណ៍គឺ សាខាបក្សប្រជាជនបដិវត្តន៍ខ្មែរនៅភាគឦសានត្រូវបានគ្រប់គ្រងដោយជនជាតិភាគតិចឡាវ ។ នេះមិនជាការភ្ញាក់ផ្អើលទេ ពីព្រោះមានជនជាតិឡាវជាច្រើនស្ថិតនៅក្នុងចំណោមប្រជាជនក្នុងស្រុក ។ គណៈកម្មការមូលដ្ឋានរួមមានសមាជិក៥នាក់ ឌិម សេដា, យ៉ា កន, ចាន់ ដេង, ចាន់ នុកែវ និងអ្នកស្រី ហួត ។ យ៉ា កន (អ៊ុច ខាំកន) គឺជាជនជាតិភាគតិចមកពីភូមិក្រគរ ខេត្តក្រចេះ ។ គាត់មកពីគ្រួសារអ្នកមាន ហើយបន្ទាប់មកត្រូវបានបណ្តុះបណ្តាលធ្វើជាមន្ត្រីអាណានិគម ។ យ៉ា កន ដំបូងឡើយទៅខេត្តរតនគិរី (ក្រោយមកជាផ្នែកមួយនៃខេត្តស្ទឹងត្រែង) ដើម្បីធ្វើជាមន្ត្រី និងទទួលខុសត្រូវស្រុកលំផាត់និងវ៉ឺនសៃ ។ ដោយគាត់ស្រឡាញ់នារីជនជាតិឡាវម្នាក់ឈ្មោះ ចៅណាងអ៊ុំដន គាត់ក៏បានរៀបការជាមួយនាង ។ ចៅ ណាងអ៊ុំដន គឺជាចៅស្រីរបស់ ចៅ យ៉ាថាម ដែលជាព្រះអង្គម្ចាស់ឡាវមកពីចម្ប៉ាសាក់ ហើយទ្រង់ក៏ជាអ្នករកឃើញវ៉ឺនសៃនៅចុងសតវត្សរ៍ទី១៩ដែរ ។ នៅពេលនោះ វ៉ឺនសៃ ស្ថិតនៅក្នុងចំណុះឬក្រោមអំណាចព្រះរាជាណាចក្រចម្ប៉ាសាក់នៅភាគខាងត្បូងប្រទេសឡាវ ហើយក៏ជាកន្លែងផ្លាស់ប្តូរវប្បធម៌និងសេដ្ឋកិច្ចដ៏សំខាន់រវាងតំបន់ពីរដែរ ។ ចៅ យ៉ាថាម គឺជាអភិបាលស្រុកមូឡាពូមុកដែលជាតំបន់គ្របដណ្តប់លើភាគខាងជើងរតនគិរីនៅជំនាន់អាណានិគមបារាំង ។ ឈ្មោះមូឡាពូមុក ក្លាយមកពីមូឡាប៉ាមុក ដែលជាស្រុកឆ្ងាយមួយនៅភាគខាងត្បូងប៉ែកខាងលិចនៃខេត្តចម្ប៉ាសាក់ដែលប្រជាជនឡាវភាគច្រើនតាំងទីលំនៅ ។ ដោយ អ៊ុច ខាំកន បានរៀបការនៅផ្ទះអភិជននៅវ៉ឺនសៃ គាត់ត្រូវបានទទួលកិត្តិនាមថាជា ញ៉ា ដែលមកពីពាក្យកាត់ យ៉ា ។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍នោះ គឺ យ៉ា កន ជាឪពុករបស់ អូសាកាញ់ ធម្មទេវាដែលជាសមាជិកការិយាល័យនយោបាយបក្សប្រជាជនបដិវត្តន៍ឡាវ ។ នៅដើមទសវត្សរ៍៥០ ខណៈពេលដែលជនជាតិភាគតិចឡាវនិងខ្មែរលើមកពីរតនគិរី ដូចជា ថុងដាម ចាន់ថាផុន ត្រូវបានបញ្ជូនទៅរៀនវគ្គបណ្តុះបណ្តាលយោធា ឪពុករបស់ អូសាកាញ់ បានបញ្ជូនគាត់ទៅចូលរួមវគ្គបណ្តុះបណ្តាលនយោបាយនៅវៀតណាមខាងជើងដែរ ។ អូសាកាញ់ ចូលរួមជាមួយប៉ាថេតឡាវ

បន្ទាប់មករៀបការជាមួយនារីម្នាក់មកពីសាំនឿ ហើយក្លាយទៅជាកម្មាភិបាលយោធាដ៏សំខាន់នៅឡាវភាគខាងជើង ។ ថុងដាំ ដែលជាជនជាតិវ៉ឺនសៃបានចូលរួមជាមួយប៉ាថេតឡាវ ហើយនៅក្រោយឆ្នាំ១៩៧៥ គាត់ក្លាយទៅជាអភិបាលខេត្តអាត់តាពើ ។ នៅឆ្នាំ១៩៧៩ នៅពេលដែលគាត់មកទស្សនាភ្នំពេញ អូសាកាញ់ បានជួបជុំជាមួយម្ដាយរបស់គាត់និងបងប្អូនបង្កើតដែលនៅរស់ (បងប្រុសនិងស្រីម្នាក់ស្លាប់នៅរបបកម្ពុជាប្រជាធិបតេយ្យ) ។

ចាន់ដេង (ហៅ ថុងស៊ី) គឺជាកម្មាភិបាលម្នាក់ដែលធ្វើអន្តោប្រវេសន៍ពីប្រទេសឡាវទៅដីរំសេសាននៃប៉ាក់កាឡាន នៅសម័យអាណានិគម ។ នៅក្នុងការសិក្សារបស់លោក ហ្វីលីប ស្ទូត ទាក់ទងនឹងរបបខ្មែរក្រហម គាត់បានដកស្រង់សេចក្ដីបញ្ជាក់របស់ អៀង សារី ថា «ថុងស៊ី គឺជាបដិវត្តន៍ជើងចាស់ដ៏សំខាន់មកពីភូមិភាគឦសាន» ។ ចាន់ដេង បានទៅសិក្សានៅវៀតណាមខាងជើងក្រោយឆ្នាំ១៩៥៤ ហើយបន្ទាប់មកក្លាយទៅជាអ្នកបង្ហឹកខាងយោធានៅក្នុងសង្គ្រាមប្រឆាំងនឹង លន់ នល់ ។ ប្រពន្ធរបស់គាត់ឈ្មោះ ខាំឡៃ ហៅ បកែ និង បាកែវឡៃ នៅរស់ពីរបបប៉ុល ពត រស់នៅនៅខេត្តស្ទឹងត្រែង ។ ចាន់ នុកែវ (ហៅខាំហុត) គឺជាកម្មាភិបាលជនជាតិភាគតិចឡាវដែលចំណាយពេលវេលាភាគច្រើនរបស់គាត់នៅលំផាត់ ។ ចាន់ នុកែវ កើតនៅចម្ប៉ាសាក់ បន្ទាប់មកគាត់បានធ្វើដំណើរមកភ្នំពេញដើម្បីរៀននិងបួសជាព្រះសង្ឃនៅវត្តខណ្ឌលោម ។ នៅក្នុងទីក្រុងភ្នំពេញ គាត់ត្រូវបានជ្រើសតាំងដោយភ្នាក់ងារកុម្មុយនីស្តដែលធ្វើសកម្មភាពនៅក្នុងសន្ធរ ហើយបន្ទាប់មកគាត់ធ្វើដំណើរទៅភាគឦសានប្រទេសកម្ពុជានិងចាប់ផ្ដើមធ្វើជាអ្នកបដិវត្តន៍ ។ ចាន់ នុកែវ បានរៀបការបីដង លើកទីមួយជាមួយនារី ប៊ូណាង មកពីមណ្ឌលគិរី លើកទីពីរ នារីឡាវមកពីវ៉ឺនសៃ ដែលស្លាប់នៅវៀតណាម ហើយទីបញ្ចប់ជាមួយនារីទំពួនមកពីលំផាត់ខាងកើត ។ មិនមានមនុស្សច្រើនដែលស្គាល់សមាជិកចុងក្រោយនៃគណៈកម្មការមូលដ្ឋានទេ នោះគឺអ្នកស្រី ហួត ជាជនជាតិភាគតិចឡាវនៃស្រុកសៀមប៉ាងទទួលបន្ទុកកិច្ចការយុវជន ។ នៅទីបញ្ចប់ អ្នកស្រីនៅរស់ពីរបបខ្មែរក្រហម ។

ជនជាតិភាគតិចឡាវម្នាក់ទៀត ឈ្មោះ ប៊ួ ជួង ដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងចលនាបដិវត្តន៍នៅភាគឦសានប្រទេសកម្ពុជា ។ ប៊ួ ជួង កើតនៅគៀតង៉ុង នៅចម្ប៉ាសាក់ ដែលជាតំបន់ល្បីឈ្មោះខាងប្រមាញ់សត្វដំរី ។ បារាំងបានបញ្ចូលគាត់ទៅក្នុងកងកម្លាំងសន្តិសុខអាណានិគម បន្ទាប់មកគាត់ត្រូវបានបញ្ជូនពីភាគខាងត្បូងប្រទេសឡាវមកខេត្តស្ទឹងត្រែង ។ ក្នុងរយៈពេលដែលជប៉ុនកាន់កាប់ ប៊ួ ជួង បានចូលរួមជាមួយក្រុមអ្នកតស៊ូប្រដាប់អាវុធប្រឆាំងនឹងជប៉ុន នៅបរិវេណបរកែវ បន្ទាប់មកគាត់ចូលរួមជាមួយកងទ័ពឥស្សរៈជាកម្លាំងជាតិនិយមដែលចងសម្ព័ន្ធភាពជាមួយវៀតមិញ ។ យោងទៅតាមការបណ្ដុះបណ្ដាលយោធានិងបទពិសោធន៍ ប៊ួ ជួង បានក្លាយទៅជាប្រធាននៃកងឯកភាពកុម្មុយនីស្តកម្ពុជានៅភាគឦសានប្រទេសកម្ពុជា ។

ខ្ញុំបានសម្ភាសជាមួយជនជាតិភាគតិចឡាវ, ប្រូវ, កាវេត, គ្រឹង, ចារាយ, ទំពួន និងជនជាតិខ្មែរមកពីស្ទឹងត្រែងនិងរតនគិរី ពួកគេបានផ្ដល់សាច់រឿងផ្សេងៗគ្នាអំពី ឱម សេដា ។ ភាគច្រើននៃអ្នកទាំងអស់នោះអះអាងថា សេដា បានចូលរួមធ្វើសកម្មភាពនៅសៀមប៉ាងនិងវ៉ឺនសៃ ហើយបានធ្វើដំណើរទៅតំបន់ផ្សេងទៀតនៃភូមិភាគឦសាន ។ ចំណុចដ៏គួរឲ្យចាប់អារម្មណ៍គឺថា បារាំងបានកេណ្ឌប្រជាជនឲ្យធ្វើផ្លូវក្ដាប់ពីសៀមប៉ាងទៅវ៉ឺនសៃដែលធ្វើឲ្យប្រជាជនទាំងនេះមានការអន់ចិត្តចំពោះការខំប្រឹងប្រែងធ្វើផ្លូវនេះ ព្រោះរដូវវស្សានឹងឆាប់ចូលមកដល់ ដូច្នេះដីនឹងហូរទៅតាមទឹក ។ លើសពីនេះ បារាំងបាននាំគូលីវៀតណាមមកជួយកិច្ចការសាធារណៈថែមទៀត ។ ភ្នាក់ងារនិងអ្នកគាំទ្របក្សកុម្មុយនីស្តឥណ្ឌូចិនដែលទទួលបន្ទុកកិច្ចការសាធារណៈបានកេណ្ឌអ្នកស្រុកដែលកំពុងតែធ្វើការសាងសង់ផ្លូវគមនាគមន៍និងគម្រោងកំណត់ព្រំដែន ។ ដូច្នេះហើយបានជាបក្សកុម្មុយនីស្តឥណ្ឌូចិនជ្រើសរើសជនជាតិឡាវក្នុងខេត្តសុវណ្ណខេត្រនិងខាមមួននៅឡាវភាគកណ្ដាលឲ្យចូលរួមការតស៊ូបដិវត្តន៍ ។

នៅពេលចលនាកុម្មុយនីស្តកម្ពុជាទើបតែចាប់ផ្ដើម អ្នកបដិវត្តន៍នៅភូមិភាគឦសានគឺមានលក្ខណៈដូចគ្នានឹងវៀតមិញនៅខ្ពង់រាបភាគកណ្ដាល (នៅតំបន់លៀនយូរី) និងប៉ាថេតឡាវភាគខាងត្បូងប្រទេសឡាវ (មានមូលដ្ឋាននៅបានហ៊ិនឡាត ស្រុកសាណាមសៃ ខេត្តអាត់តាពើ) ច្រើនជាងអ្នកដឹកនាំនៅភ្នំពេញនិងភាគខាងកើតប្រទេសកម្ពុជា ។ ទំនាក់ទំនងជាមួយប៉ាថេតឡាវតាម

រយៈសៀមប៉ាង វៀតមិញតាមរយៈបរកែវ និងបក្សប្រជាជនបដិវត្តន៍ខ្មែរតាមរយៈភ្នាក់ងារតែមួយដែលមានមូលដ្ឋាននៅក្រចេះនិងជាអ្នកទាក់ទងសាខានៅភ្នំពេញនិងភាគខាងកើតខេត្តកំពង់ចាមនៅតែរក្សាដដែល ។

ខ្មែរលើមួយចំនួនដែលមកពីតាវេង បច្ចុប្បន្នរតនគិរីបានធ្វើដំណើរទៅតំបន់បូឡូវេនជាតំបន់ខ្ពង់រាបនៅឡាវភាគខាងត្បូងនៅអំឡុងទសវត្សរ៍៤០ ដើម្បីរកការងារធ្វើនៅចម្ការកាហ្វេដែលបង្កើតឡើងដោយបារាំងនិងសហគ្រិនក្នុងស្រុក ។ ជនអន្តោប្រវេសន៍កម្ពុជាដែលធ្វើការដោយកម្លាំង ត្រូវបានវៀតមិញនិងប៉ាថេតឡាវជ្រើសរើសនិងបណ្តុះបណ្តាលនៅចុងទសវត្សរ៍៤០ ។ ពួកគេបានចូលរួមជាមួយប៉ាថេតឡាវក្នុងប្រតិបត្តិការយោធានៅចម្ប៉ាសាក់ អាត់តាពើ និង សារ៉ាវ៉ាន់ ព្រមទាំងទទួលវគ្គបណ្តុះបណ្តាលមនោគមន៍វិជ្ជានៅដាក់ជឿង បច្ចុប្បន្នតំបន់សៀងខួង ។

នៅដើមឆ្នាំ១៩៥១ កងទ័ពឥណ្ឌូចិនត្រូវបានបង្កើតឡើងដោយរួមបញ្ចូលទាំងជនកុម្មុយនីស្តកម្ពុជា វៀតមិញ និង ប៉ាថេតឡាវ ។ ពេលនោះ សឺង ង៉ុកមិញ, ស៊ីវ ហេង និង ទូ សាមុត តំណាងឲ្យប្រជាជនកម្ពុជា និងព្រះអង្គម្ចាស់ សូផានុវង្ស, នូហាក់ ភូមិសាវណ្ណ, ភូមី វង្សវិចិត្រ, ខាំតៃ ស៊ីផាន់ដន, ស៊ីសាណា ស៊ីសាន និង ស៊ីងកាប៉ូ ស៊ីខតជូនឡាម៉ានី តំណាងឲ្យប៉ាថេតឡាវ ។ ខាំតៃ ស៊ីផាន់ដន គឺជាសមាជិកម្នាក់នៃក្រុមបដិវត្តន៍ដែលទៅតាំងទីលំនៅនៅព្រំដែនឡាវ-កម្ពុជា ។ ដូច្នេះ ទំនាក់ទំនងជាន់ខ្ពស់រវាងជនកុម្មុយនីស្តឡាវនិងខ្មែរខុសប្លែកពីទំនាក់ទំនងជាមួយវៀតណាម ។

នៅឆ្នាំ១៩៥១ កងទ័ពឡាវវៀតមិញដែលមកពីឡាវភាគខាងត្បូងបានចូលរួមជាមួយជនបដិវត្តន៍កម្ពុជានៅភាគឦសានដែលបង្កើតទៅជាមូលដ្ឋានតូចមួយនៅជិតសៀមប៉ាង, វ៉ឺនសៃ និងតាវេង ។ កងឥណ្ឌូចិនដែលលាយឡំគ្នាបានវាយដណ្តើមទីបញ្ជាការរបស់រដ្ឋាភិបាលដែលនៅតំបន់ដាច់ស្រយាលដោយជោគជ័យ ។ ប៉ុន្តែនៅពេលកងជំនួយដែលទទួលបានការបណ្តុះបណ្តាលនិងបំពាក់អាវុធមកពីភ្នំពេញត្រូវបានបញ្ជូនឲ្យមករក្សាស្ថិរភាពនៅតំបន់នេះ ពួកគេត្រូវបានបង្ខំឲ្យត្រឡប់ទៅទឹកដីឡាវវិញ ។ ខណៈដែលមានការនិរទេសនៅប្រទេសឡាវភាគខាងត្បូង អ្នកបដិវត្តន៍បានទទួលវគ្គបណ្តុះបណ្តាលនយោបាយវប្បធម៌ និងយោធាដើម្បីឲ្យក្លាយទៅជាកងប្រយុទ្ធដ៏មានសមត្ថភាពនិងអាចទទួលជោគជ័យក្នុងការឃោសនាទៅកាន់ប្រជាជនក្នុងស្រុក ។

នៅដើមឆ្នាំ១៩៥៤ កងទ័ពបដិវត្តន៍ឥណ្ឌូចិនបានបើកប្រតិបត្តិការយោធាធំជាងមុនដើម្បីរក្សាសន្តិសុខក្នុងតំបន់រំដោះដែលស្ថិតនៅឡាវភាគខាងត្បូងនិងភាគឦសានប្រទេសកម្ពុជា ។ ប្រតិបត្តិការនេះបានទទួលជោគជ័យលើកងទ័ពបារាំង ហើយបានបោះទីតាំងនៅអាត់តាពើ, សៀមប៉ាង, វ៉ឺនសៃ, បូកែវ និង លំផាត់ ព្រមទាំងបានគំរាមកំហែងដល់ខេត្តស្ទឹងត្រែងនិងក្រចេះដែលនៅតាមបណ្តោយទន្លេមេគង្គ ។ គោលបំណងនៃយុទ្ធនាការនេះគឺដើម្បីបង្កើតតំបន់មួយនៅប្រទេសកម្ពុជាដែលស្រដៀងគ្នាទៅនឹងតំបន់ដែលបង្កើតដោយប៉ាថេតឡាវនៅឡាវភាគខាងជើង និងវៀតមិញនៅវៀតណាមខាងជើងនិងខ្ពង់រាបភាគកណ្តាលដែលអាចបម្រើជាទីបញ្ជាការសម្រាប់ជនកុម្មុយនីស្តកម្ពុជា ។ យ៉ាងណាមិញ ការចូលរួមរបស់ឡាវជាច្រើននៅក្នុងការវាយប្រហាររបស់វៀតមិញលើភាគឦសានប្រទេសកម្ពុជា គឺដើម្បីបញ្ចូលតំបន់ឡាវភាគខាងត្បូងឲ្យដូចដើម ដូចនៅពេលដែលពួកបារាំងមិនចូលមកដល់ ។ អាស្រ័យហេតុនេះ វាមានរឿងទាស់ទែងគ្នាពីរគឺបដិវត្តន៍ដែលបង្កដោយបក្សកុម្មុយនីស្តឥណ្ឌូចិននិងការប្រគល់ទឹកដីឲ្យប្រទេសឡាវដែលបង្កើតទៅជាអតីតរាជាណាចក្រឡាវនៃខេត្តចម្ប៉ាសាក់ ។

កិច្ចព្រមព្រៀងនៃសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ បានធ្វើឲ្យទំនាក់ទំនងបដិវត្តន៍នៅតាមបណ្តោយព្រំដែនឡាវ-កម្ពុជាចុះខ្សោយ ។ នេះព្រោះតែកងទ័ពប៉ាថេតឡាវភាគច្រើនត្រូវបានប្រមូលផ្តុំឡើងវិញទៅខេត្តហួរផាននិងផុងសាឡីនៅឡាវភាគខាងជើង ។ កម្មាភិបាលភ្នាក់ងារសម្ងាត់មួយចំនួនដែលនៅសេសសល់បានសម្រេចចិត្តទៅរស់នៅទីបញ្ជាការឡាវង៉ាមរបស់ប៉ាថេតឡាវដែលនៅឆ្ងាយពីខ្ពង់រាបបូឡូវេន ជាងរយគីឡូម៉ែត្រពីភាគខាងជើង ។ កម្មាភិបាលប៉ាថេតឡាវដែលបានបម្រើការងារនៅភាគឦសានប្រទេសកម្ពុជាដូចជា ស៊ីម ម៉ាណូវៀង, ចំនៀបបួនឡុត, ស៊ុមឡាត ចន្ទាម៉ាត, សាវៃ សៃយ៉ាំសណា, សាម៉ាន វីឡៃយ៉ាខេត, ប៊ួន ដួម៉ាហាសៃសា, ភួន ស៊ីប្រ៉ាសឺត, ភូម៉ា ដួងម៉ាឡា, កែវ លួង

សីណា និង ថាវ៉ុន ចាឡឺនស៊ីក បច្ចុប្បន្ននៅបន្តការងាររបស់ពួកគេនៅសមរភូមិនៅឡាវដដែល ។

បន្ទាប់ពីកិច្ចព្រមព្រៀងសន្និសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៥៤ នៃ សារ៉ាន់ បានចូលរួមនៅក្នុងឆាកនយោបាយកម្ពុជា ក្នុងតួនាទីជាចលនាបដិវត្តន៍ ហើយក្រោយមកធ្វើជាបេក្ខជននៅក្នុងការបោះឆ្នោតជាតិសម្រាប់ខេត្តរបស់គាត់ ។ នៅពេលដដែលនេះ នៃ សារ៉ាន់ បានធ្វើជាគ្រូបង្រៀន និងអ្នករដ្ឋបាលផ្នែកអប់រំឲ្យសាលាឯកជនមួយនៅក្នុងទីក្រុងភ្នំពេញ ។ នៅដើមសម័យសង្គមរាស្ត្រនិយម នៃ សារ៉ាន់ គឺជាអ្នកគ្រប់គ្រងរបស់ សាឡុត ស ហើយក៏ជាអ្នកដើរតួនាទីសំខាន់ក្នុងការកេណ្ឌព្រះសង្ឃ និង សិស្ស និស្សិតឲ្យចូលរួមក្នុងចលនាកុម្មុយនីស្តដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនបានដឹងថាតើគាត់ធ្វើសកម្មភាពយ៉ាងណាខ្លះទេនៅខាងក្រៅទីក្រុងក្នុងអំឡុងឆ្នាំ១៩៥៥-១៩៦៣ ។ នៅចុងទសវត្សរ៍ ៥០ កម្មាភិបាលដឹកនាំខ្លះនៅភាគឦសានប្រទេសកម្ពុជា គឺ វេង ឃួន (តាវេង-ប្រូវ) ខាំដៃ (វ៉ុនសៃ-ឡាវ) ថងបៃ វ៉ុនសៃ (ឡាវ-ទំពួន) ចាន់តូ (វ៉ុនសៃ-ឡាវ) ទីដេង (សៀមប៉ាង-ឡាវ) ហ្គាវៀម (អូរជុំ-គ្រឹង) និង ចាន់ នុកែវ (លំផាត់-ឡាវ) ។

នៅឆ្នាំ១៩៥៧ គឺជាឆ្នាំសំខាន់សម្រាប់ការអភិវឌ្ឍចលនាបដិវត្តន៍ឥណ្ឌូចិននៅភូមិភាគឦសានប្រទេសកម្ពុជា ពីព្រោះទីប្រឹក្សាជនជាតិវៀតណាមនៅប្រទេសកម្ពុជាត្រូវបានដកចេញពីសមរភូមិទាំងស្រុង ។ ជាងនេះទៅទៀត អតីតលេខាបក្សកុម្មុយនីស្តប្រជាជនបដិវត្តន៍ខ្មែរ ស៊ីវ ហេង ចាប់ផ្តើមធ្វើការចរចាជាមួយរដ្ឋាភិបាលកម្ពុជាចំពោះការចាកចេញពីបក្សរបស់គាត់ ។ ស៊ីវ ហេង ដែលទទួលខុសត្រូវបណ្តាញបក្សប្រជាជនបដិវត្តន៍ខ្មែរនៅតាមជនបទបានប្រាប់ព័ត៌មានអំពីអតីតអ្នកដែលធ្លាប់តស៊ូជាមួយគាត់ទៅកាន់កងកម្លាំងសន្តិសុខរបស់សម្តេច សីហនុ ដែលបន្ទាប់មកគ្រប់គ្រងដោយ គូ រុន និង លន់ នល់ ។ វាហាក់ដូចជាថាអ្នកបន្តវេនបក្សកុម្មុយនីស្តឥណ្ឌូចិនឬបក្សប្រជាជនខ្មែរបដិវត្តន៍ខ្មែររបស់ជនកម្មុយនីស្តកម្ពុជាដែលដឹកនាំដោយខ្មែរក្រហមបានទទួលជ័យជម្នះនៅដើមទសវត្សរ៍៦០ ខណៈពេលដែល ឱម សេដា និង យ៉ាកន ត្រូវបានកម្ទេចចោលដោយទាហានរបស់សម្តេច សីហនុ តាមរយៈការចុះចូលរបស់ ស៊ីវ ហេង ។ មានការយល់ឃើញផ្សេងគ្នាថា យ៉ា កន ត្រូវបានសម្លាប់ដោយកងកម្លាំងរដ្ឋាភិបាលនៅខេត្តក្រចេះក្នុងឆ្នាំ១៩៥៦ ឬក៏នៅលំផាត់ក្នុងអំឡុងឆ្នាំ១៩៥៧ ។ ការស្លាប់របស់ ទូ សាមុត នៅឆ្នាំ១៩៦២ ធ្វើឲ្យមានការបញ្ចប់ទំនាក់ទំនងរបស់អ្នកជំនាន់ក្រោយនៃបក្សកុម្មុយនីស្តឥណ្ឌូចិននៅក្នុងចលនាកុម្មុយនីស្តនៅកម្ពុជា ។ កែវ មាស ជាជនកុម្មុយនីស្តកម្ពុជាម្នាក់ដែលមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយការដឹកនាំរបស់ប៉ាថេតឡាវ ។ អំឡុងពេលនោះ កែវ មាស បានចំណាយពេលជាច្រើននៅក្នុងដំរំលាក់ខ្លួននៅតាមបណ្តោយព្រំដែនវៀតណាម-កម្ពុជា ។ នៅទសវត្សរ៍៦០ កម្មាភិបាលមួយចំនួនដែលនៅភូមិភាគឦសានឈ្មោះថា ខាំ ឡែន (តាវេង-ប្រូវ) សៀងណយ (តាវេង-ប្រូវ) ថុងបៃ ខាំឡៃ (វ៉ុនសៃ-ឡាវ) ថុងស៊ីង (វ៉ុនសៃ-ឡាវ) និង គង់ ដើង (អូរជុំ-ទំពួន) ។

ដោយសារការចាកចេញរបស់ សាឡុត ស ពីភ្នំពេញទៅព្រំដែនវៀតណាម-កម្ពុជានៅដើមទសវត្សរ៍៦០ នៃ សារ៉ាន់ ត្រូវបានចាត់ឲ្យទៅធ្វើការនៅខេត្តមណ្ឌលគិរីម្តងទៀត ។ ចំពោះទំនាក់ទំនងឡាវ-កម្ពុជា ជំហានសំខាន់គឺខណៈពេលដែល នៃ សារ៉ាន់ រៀបការជាមួយនារីជនជាតិភាគតិចឡាវម្នាក់ ដែលមានឈ្មោះថា វ៉ុន ហើយពេលនោះ សារ៉ាន់ បានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រជាជនក្នុងស្រុក ដូចជាជនជាតិភាគតិចទំពួន ប៊ូណុង ចារាយ ឬក៏ឡាវ ។ បងប្អូនសាច់ថ្លៃជនជាតិឡាវរបស់ នៃ សារ៉ាន់ ត្រូវបានខេ្មសនាមឲ្យធ្វើជាក្រុមសិល្បៈរបស់ខ្មែរក្រហមនិងជាអ្នកដឹកនាំសមាជិកអង្គការលើ ។ ក្មួយស្រីរបស់គាយ៉ា ត្រូវបានរៀបចំឲ្យរៀបការជាមួយក្មួយប្រុសរបស់ អៀង ធីរិទ្ធ ។ បងធំដទៃទៀតនៃចលនាបដិវត្តន៍កម្ពុជាដែលបានចូលរួមជាមួយ នៃ សារ៉ាន់ នៅភូមិភាគឦសានក្នុងពាក់កណ្តាលទសវត្សរ៍ ៦០ គឺ សុន សេន អ៊ុំណេង និង នីកន ។ បន្ទាប់មក អ្នកទាំងនេះចូលរួមជាមួយ អៀង សារី, សាឡុត ស, ចាន់ សារ៉េត ហៅ (តាវ៉ា) កុយ ធួន, យ៉ែម, ទីវ អុល និង នួន ជា ។ សាឡុត ស បានដកអង្គរក្សរបស់ខ្លួនជាច្រើននាក់ដែលមកពីតំបន់ទំពួននៅតាមប្រាំងទន្លេស្រែពក ខណៈពេលដែល អៀង សារី បានដកអង្គរក្សរបស់ខ្លួនជាជនជាតិចារាយនៅអណ្តូងមាស ហើយ សុន សេន បានដកពីកាវេត ដែលនៅចន្លោះសៀមប៉ាងនិងវ៉ុនសៃ ។ ប៊ូ ផាត់

គឺជាជនជាតិភាគតិចខ្មែរម្នាក់ទៀតដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយឡាវនិងខ្មែរលើភាគឦសានប្រទេសកម្ពុជា ។ ប៊ូ ផាត់ ដែលមានដើមកំណើតនៅខេត្តតាកែវ បានធ្វើដំណើរទៅភាគឦសានឃឹតជាង តាយ៉ា ហើយបានទៅរស់នៅជិតសេសានដែលស្ថិតនៅចន្លោះតាវេងនិងវឺនសៃ ។ មុនពេលត្រឡប់មកដល់ភាគឦសាន ប៊ូ ផាត់ គឺជាអ្នកសារព័ត៌មានជាមួយ ខៀវ សំផន ។ អ៊ឹ ណេង ជាជនជាតិភាគតិចខ្មែរម្នាក់ដែលធ្លាប់ធ្វើជាអ្នកសារព័ត៌មាននៅក្នុងទីក្រុងភ្នំពេញដែរ មុនពេលចូលទៅព្រៃម៉ាគី ។ នៅរតនគិរី អ៊ឹ ណេង ត្រូវបានហៅថា វី បន្ទាប់មកនៅពេលដែលគាត់ឈរជើងនៅសៀមប៉ាង គេហៅគាត់ថា វង់ ។ ប្រពន្ធរបស់ អ៊ឹ ណេង ត្រូវបានគេហៅថា ស៊ិន នៅរតនគិរី ហើយកូនស្រីរបស់គាត់ត្រូវបានហៅថា ផាត នៅសៀមប៉ាង ។

ជនជាតិភាគតិចឡាវនៅមណ្ឌលគិរី ស្រុកកោះញែក មានបណ្តាញសំខាន់ជាមួយឡាវនៅស្ទឹងត្រែង, លំផាត់, វឺនសៃ, សៀមប៉ាង, និងឡាវ ។ នៃ សាវ៉ាន់, គាកាត និង មេដឹកនាំផ្សេងទៀតដែលមកពីទីក្រុងអាចចូលរួមជាមួយបណ្តាញទាំងនេះ ហើយក៏អាចអភិវឌ្ឍចលនាបដិវត្តន៍នៅភាគឦសានដែរ ។ នេះដោយសារតែជនជាតិភាគតិចឡាវធ្លាប់មានប្រវត្តិសាស្ត្រជាបណ្តាញដ៏មានប្រសិទ្ធភាពនៅក្នុងតំបន់ ហើយធ្លាប់ធ្វើពាណិជ្ជកម្មនៅក្នុងព្រៃព្រមទាំងបានធ្វើសកម្មភាពអប់រំតាមព្រះពុទ្ធសាសនាទៀតផង ។ អាស្រ័យហេតុនេះទើបអ្នកទាំងនេះអាចចូលរួមយ៉ាងជោគជ័យជាមួយប្រជាជនក្នុងស្រុក ហើយធ្វើឲ្យប្រជាជនមានការជឿទុកចិត្តមិនដូចជាជនជាតិភាគតិចខ្មែរក្រោម (ខ្មែរកណ្តាល) ដែលបានតែងតាំងជាសេវាកម្មសាធារណៈរបស់រដ្ឋាភិបាលកម្ពុជានិងជាកងកម្លាំងប្រដាប់អាវុធទេ ។ តាំងពីដើមទសវត្សរ៍៦០ ទំនាក់ទំនងរវាងខ្មែរលើនិងខ្មែរក្រោមមានភាពអន់ថយពីព្រោះតែការរឹបអូសដីធ្លីដើម្បីដាំកៅស៊ូនិងការជួលពលកម្មដោយឲ្យតម្លៃថោក ។

នៅអំឡុងចុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ នៃ សាវ៉ាន់ បានធ្វើដំណើរជុំវិញខេត្តព្រះវិហារនិងភាគឦសានប្រទេសកម្ពុជា ដើម្បីប្រមូលប្រជាជនឲ្យចូលរួមជាមួយខ្មែរក្រហម ។ ជាងនេះទៅទៀត នៃ សាវ៉ាន់ ក៏ដើរតួនាទីសំខាន់ក្នុងការធ្វើជាអ្នកនាំព័ត៌មានរវាងវៀតណាមនិងឡាវនៅពេលដែលទទួលសព្វាវុធយោធាតាមផ្លូវលំស៊ីហនុ នេះសំដៅទៅលើផ្លូវតពីសាខាបក្សនៅភាគខាងជើងដែលឆ្លងកាត់ផ្លូវលំហូជីមិញនៅភាគខាងជើងខេត្តអាត់តាពើទៅជ្រលងទន្លេសេកុងដែលហូរកាត់ខេត្តស្ទឹងត្រែង ។ ខ្មែរលើនិងជនជាតិភាគតិចឡាវដែលមកពីភាគឦសានផ្តល់អត្ថាធិប្បាយថា ការដឹកនាំរបស់ នៃ សាវ៉ាន់ នៅក្នុងស្រុកមានភាពយុត្តធម៌និងអាចទុកចិត្តបាន ទោះបីជាគាត់មានគោលបំណងផ្តួលរំលំរបប លន់ នល់ក៏ដោយ ។

បូ ខាវ (ហៅកែ) គឺជាយុទ្ធជនជនជាតិភាគតិចកាវែតដឹកនាំឃុំកុកឡាកភាគខាងជើងវឺនសៃ ។ នៅឆ្នាំ១៩៧០ យុទ្ធជនរបស់គាត់បានជួយផ្តល់ទីលំនៅសម្រាប់ខ្មែរហាណូយដែលរួចជីវិតបន្ទាប់ពីធ្វើដំណើរដ៏សែនលំបាកតាមផ្លូវលំហូជីមិញក្នុងគោលបំណងមកចូលរួមជាមួយខ្មែរក្រហមដើម្បីប្រឆាំងនឹងរបប លន់ នល់ ។ ខ្មែរហាណូយគឺជាសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរដែលបានធ្វើការនិងទទួលវគ្គបណ្តុះបណ្តាលនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅអំឡុងឆ្នាំ១៩៥៤-១៩៧០ ខណៈដែលពួកគេត្រូវបានបដិសេធចោលពេលដែលមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលជាកន្លែងដ៏មានសុវត្ថិភាពរបស់កម្ពុជា ។ អ្នកដែលសំខាន់នៅក្នុងក្រុមនេះមាន ឬ ជួង, ចិន រឿន, ពួយ នុចាន់, ប៉ែន សុវណ្ណ, ប៊ូ ថង និង ស៊ឹម កែវ ។ ឌី ផេង ជាយុទ្ធជនឡាវមកពីលំផាត់ ហើយដែលទៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅឆ្នាំ១៩៥៤ ។

នៅឆ្នាំ១៩៧០ កងកម្លាំងដ៏ធំពីរក្រុមរបស់ខ្មែរក្រហមដែលមកពីភាគឦសានបានអមដំណើរដោយកម្មាភិបាលជាន់ខ្ពស់ទៅកាន់មូលដ្ឋានថ្មីដែលស្ថិតនៅភាគខាងលិចទន្លេមេគង្គ ។ ក្រុមទី១រួមមាន ចាន់ សារ៉េត (ហៅ តាវ៉ា) ប៊ូ ផាត់ (ហៅ តាពាង) តាហៃ (ហៅ ស៊ឺយ) និង តាផាន បានបង្កើតទីបញ្ជាការបដិវត្តន៍នៅខេត្តព្រះវិហារដែលហៅថាតំបន់១០៣ ។ តាហៃ គឺជាជនជាតិភាគតិចខ្មែរមកពីព្រំដែនខេត្តស្វាយរៀងនិងតាយនិញ គាត់ធ្លាប់បានទទួលការបណ្តុះបណ្តាលនៅវៀតណាមមុនពេលមកដល់ភាគឦសាន ។ តាហៃ ធ្លាប់ជាអង្គរក្សរបស់ ខៀវ ប៊ុណ្ណារី និង អៀង សារី ។ តា ផាន គឺជាជនជាតិភាគតិចឡាវមកពីឃុំព្រះរំកិលជាប់ព្រំដែនឡាវ-កម្ពុជាជិតទន្លេមេគង្គ ។ ក្រុមដែលបានបញ្ជូន

ទៅព្រះវិហារមានបីកងរួមជាមួយទាហានវៀតណាមដែលជាទ័ពស្រួច ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅព្រះវិហារមានទាហានការពារសន្តិសុខជាង១០០នាក់ ដែលទាហានទាំងនេះភាគច្រើនជាជនជាតិភាគតិចឡាវនិងខ្មែរលើ ដូចជា ប៊ុន ចាន់ បងប្អូនប្រុសរបស់ (ខាំ ទៀង) គេវ សុត, តាតាន់, តាសុង (ទំពួន) កាត យ៉ៃ (គ្រឹង) អយខឿន (ចារាយ) និង បាតែម (ចារាយ) ។ មុនពេលដែលមកដល់ស្ទឹងត្រែង ទ័ពនៅភាគឦសានប្រដាប់ដោយស្នានិងគ្រាប់បែកដៃ ។ ប៉ុន្តែនៅពេលដែលក្រុមនេះមកដល់ ពួកគេប្រដាប់ដោយកាំភ្លើងអាកា៤៧និងកាំភ្លើងវែង ។ ទាហានស្ទើរតែទាំងអស់នេះបានរៀបការជាមួយនារីជនជាតិភាគតិចឡាវក្នុងស្រុកនៅពេលដែលគេបោះទីតាំងនៅព្រះវិហារ ។

ទីបញ្ជាការនៅព្រះវិហារដំបូងឡើយមានទីតាំងនៅអន្លង់ស្វាយ ស្រុករវៀង ហើយបន្ទាប់មកទៀតនៅភាគខាងជើងភូមិទំលាប់ដែលមានទំនប់ទឹកនិងដីរំដាមួយនឹងមន្ទីរពេទ្យស្ថានីយវិទ្យុនិងលំនៅរបស់កងទ័ព ។ ពេលបោះទីតាំងនៅព្រះវិហារដំបូងកម្មាភិបាលជាន់ខ្ពស់បានកែឈ្មោះឲ្យខ្លួនឯង ចាន់ សារ៉េត ទៅជាតាម៉ាន់ ប្រពន្ធរបស់គាត់ឈ្មោះ ភាព ប្រែទៅជា សុន, ប៊ូផាត់ទៅជា តាហង់, តាហៃ ទៅជា តាប៉ុង និង តាផាន ទៅជា តាប៉ាវ ។ តាហង់ និង តាផាន មានមូលដ្ឋាននៅភូមិទំលាប់ តាម៉ាន់ និង តាប៉ុង ឈរជើងនៅកន្លែងផ្សេងគ្នានៅស្រុកជ័យសែន ។ តាផានជាប្រធានផ្នែកសេដ្ឋកិច្ចនៅព្រះវិហារ តាហង់ មានតួនាទីខាងយោធានិងនយោបាយ ។ តាម៉ាន់ ជាស្នងការនយោបាយនៅតំបន់១០៣ ហើយ តាប៉ុង គឺជាប្រធានសន្តិសុខ ។ ប្រជាជនក្នុងស្រុកព្រះវិហារ សុទ្ធតែស្គាល់ តាយ៉ា និង តាហង់ ប្រជាជនខ្លះត្រូវបានអ្នកទាំងពីរបញ្ជាឲ្យសម្លាប់ ។ តាហង់ រៀបការនៅព្រះវិហារជាមួយនារីម្នាក់ឈ្មោះ ពិន ហើយយកក្មេងក្នុងស្រុកទៅបណ្តុះបណ្តាលក្នុងកងកុមារពិសេស ។ ជំនួយការរបស់ តាហង់ ឈ្មោះ យ៉ា ប៉ុន្តែគេគឺជាជនជាតិភាគតិចខ្មែរក្នុងស្រុកដែលមកពីរវៀង ប្រពន្ធរបស់គាត់ឈ្មោះ សូ (ហើយនៅរស់រហូតដល់សព្វថ្ងៃ) ។ តា យួន ជនជាតិភាគតិចខ្មែរជាមេបញ្ជាការយោធានៅតាមព្រំដែនក្បែរប្រាសាទព្រះវិហារ ។ តាមាក ជាមេដឹកនាំខ្មែរក្រហមនៅត្បែងមានជ័យ ។ ប៊ុន ចាន់ ក្លាយទៅជាប្រធានស្រុកជាំក្សាន្ត ។ តាមី ដែលជាជនជាតិភាគតិចទំពួន និងប្រពន្ធរបស់គាត់ ឈ្មោះ ស៊ី ខ្មែរលើ គឺជាមេបញ្ជាការយោធាស្រុក ។

ក្រុមទីពីរនៃមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលរួមមាន សាឡុត ស, កុយ ធួន និង ទីវ អុល រួមជាមួយនឹង កែ ពក, នួន ជា, ខៀវ សំផន, ហ៊ូ នឹម, និង ហ៊ូ យន់ នៅទីបញ្ជាការបក្សថ្មីនៅភាគខាងជើងខេត្តកំពង់ចាម ។ ពួកគេត្រូវបានអមដំណើរដោយទាហានខ្មែរលើដែលមានចំនួនទ័ពស្រដៀងគ្នានឹងកម្មាភិបាល វីថែម (ចារាយ) ។ នៅពេលដែល «បងធំ» នៃបក្សកុម្មុយនីស្តកម្ពុជាបានបោះមូលដ្ឋានដោយមានសុវត្ថិភាពនៅកម្ពុជាភាគកណ្តាល អ្នកទាំងនេះចាប់ផ្តើមប្រើមនោគមន៍វិជ្ជាមកពីវៀតណាមដែលគេបានសិក្សាដោយមានវិន័យតឹងរ៉ឹង ។

នៅឆ្នាំ១៩៧២ កម្មាភិបាលនៅភាគឦសានចាប់ផ្តើមភ័យខ្លាចចំពោះការរស់នៅរបស់ខ្លួន ពីព្រោះមេដឹកនាំខ្មែរក្រហមបានអនុម័តនូវគោលនយោបាយដ៏ឃោរឃៅប្រឆាំងនឹងជនជាតិវៀតណាមនិងអតីតអ្នកដែលនៅក្នុងការខុបត្ថម្ភរបស់គេ ។ នេះរួមបញ្ចូលទាំងអ្នកស្មោះត្រង់នឹងសម្តេច សីហនុ ដែលបានប្រមូលផ្តុំគ្នាក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ។ ខ្មែរក្រហមបានធ្វើការបោសសម្អាតទៅលើយុទ្ធជនភាគតិចឡាវនិងខ្មែរលើដូចជា ខាំដៃ, ខាំដេង, តាគៀង (គ្រឹង) ខាំផាន (វ៉ឺនសៃ-ឡាវ) បូនជ័រ (វ៉ឺនសៃ-ឡាវ) បូន កុង (កោះពី-ចារាយ) ចាន់ដេង និង ទីដេង ព្រមទាំងបំផ្លិចបំផ្លាញបេតិកភណ្ឌក្នុងស្រុកដូចជា ចេតិយដែលកសាងឡើងដើម្បីចៅយ៉ាថាមនៅវ៉ឺនសៃ ។ ហេតុដ៏អាក្រក់នៅក្នុងចំណោមប្រជាជនមូលដ្ឋាននិងអ្នកបដិវត្តន៍ដែលបានចាប់ផ្តើមធ្វើទំនាក់ទំនងជាសម្ងាត់ជាមួយឡាវនិងវៀតណាម គឺក្នុងគោលបំណងស្វែងរកជំនួយជួយដល់ខ្មែរក្រហម ។ ខាំវៀង និង កម្មាភិបាលជនជាតិភាគតិចទំពួនដែលមកពីភាគឦសាននៃស្រុកលំផាត់ចាប់ផ្តើមមានឈ្មោះល្បីល្បាញនៅភាគឦសានប្រទេសកម្ពុជា ព្រោះគាត់ជាប្រធានសន្តិសុខតំបន់ ។ គាត់បានរៀបការជាមួយនារីជនជាតិភាគតិចឡាវឈ្មោះ ស៊ីដម មកពីបាដឹមភាគខាងកើតទីរួមខេត្តស្ទឹងត្រែង ។ ខាំវៀង អាចនិយាយភាសាឡាវយ៉ាងស្ទាត់ជំនាញហើយគាត់គ្រប់គ្រងការសម្លាប់នៅភូមិភាគឦសាន ។ អ្នកស្រុកជាច្រើនបានរំឭកពីការមកដល់នៃកងទ័ពរបស់ខាំវៀងដែលអមទៅ

ដោយទន់ជាតិពណ៌ក្រហមជាប្រផ្នូលនៃការស្លាប់ ។ បន្ទាប់ពីវៀតណាមចូលមកដល់នៅឆ្នាំ១៩៧៩ ប្រជាជនក្នុងស្រុកបានសម្លាប់ ខាំវៀង។ ប្រពន្ធរបស់ ខាំវៀង នៅមានជីវិត ហើយសព្វថ្ងៃរស់នៅភាគឦសានខេត្តរតនគិរី ។

មានជនជាតិភាគតិចឡាវនិងកម្មាភិបាលទំពួនមួយចំនួនធ្វើជាកម្មាភិបាលខ្មែរក្រហមនៅលំផាត់ ដូចជា តាកេង និង តាពឹម ។ តាទុំ ជាជនជាតិគ្រឹង មានតួនាទីជាភូឈ្លួយរបស់ តាកេង ។ តាប៉ុន ជាជនជាតិភាគតិចឡាវ មិនមែនមកពីលំផាត់ជាប្រធានស្រុកទេ ។ គាត់បានរៀបការជាមួយនារីជនជាតិភាគតិចខ្មែរដែលមកពីស្វាយរៀង ឈ្មោះ ហួង ។ ហួង នៅរស់មានជីវិត ហើយសព្វថ្ងៃនាងជាអ្នកស្រុកលំផាត់ ។ តានីយ៉ន់ ជនជាតិភាគតិចឡាវម្នាក់ទៀតបានទទួលតំណែងជាប្រធានស្រុកបន្ទាប់ពី តាប៉ុង នៅពេលរបបកម្ពុជាប្រជាធិបតេយ្យផុតរលត់ទៅ ។ គាត់បានចូលរួមនឹងវៀតណាម ហើយស្លាប់នៅភូមិបានម៉ៃនៅឆ្នាំ១៩៨៤ ។ តាប៉េង ជាជនជាតិភាគតិចឡាវនិងជាអតីតព្រះសង្ឃដែលធ្លាប់សិក្សានៅស៊ឹងត្រែងមានតួនាទីជាឈ្លប ។ ការងាររបស់គាត់ គឺកោះហៅប្រជាជនក្នុងស្រុកឲ្យទៅរៀនសូត្រ ហើយសង្កេតមើលការសម្លាប់ខ្មាំងនៅក្នុងព្រៃ ។ ស៊ីថាត យុទ្ធជនខ្មែរហាណូយ ជាមេដឹកនាំម្នាក់ ហើយត្រូវបានបោសសម្អាតនៅលំផាត់ ។ ជនជាតិភាគតិចឡាវម្នាក់ទៀតដែលជាអ្នកមានអំណាចនៅភូមិភាគឦសានគឺ ថាវ៉ុន ។ នៅក្នុងការិយាល័យបក្សនៅស្គាមឃួយហៅមន្ទីរក-២១ តាសីឡាមកពីបានហង់យូ និង ខាំ គាត មកពីប៉ាក់កាឡាន ត្រូវបានបោសសម្អាតនៅវ៉ឺនសៃ ។

នៅឆ្នាំ១៩៧៣ នៃ សារ៉ាន់ បានទទួលស្វាគមន៍គណៈប្រតិភូរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្ករណសិរ្សរួបរួមជាតិកម្ពុជារបស់សម្តេច សីហនុ នៅឯព្រំដែនកម្ពុជា-ឡាវ នៅបរិវេណតាង៉ូ (ភាគខាងជើងសៀមប៉ាង) ជាមួយ ខៀវសំផន និង ហ៊ូ នឹម បន្ទាប់ពីព្រះអង្គម្ចាស់យាងមកតាមផ្លូវលំហូជីមិញ ។ នៃ សារ៉ាន់ និង តាហង់ បានអមដំណើរសម្តេច សីហនុ និងអ្នកមកជាមួយទ្រង់ទៅកាន់ទន្លេសេកុងនៅភូមិផាបាំងដែលនៅជិតភាគខាងជើងសៀមប៉ាង ។ បន្ទាប់មក គេទាំងអស់នោះបានបន្តដំណើរទៅវ៉ឺនខាំព្រំដែនប្រទេសឡាវនាភាគខាងកើតប្រាំងទន្លេមេគង្គខាងត្បូងខេត្តចម្ប៉ាសាក់ (កន្លែងដែលមានដើមល្ហុងធំមួយ) បន្ទាប់មកទៅភ្នំគូលែន (ខេត្តសៀមរាប) ហើយទើបញ្ចប់ត្រឡប់មកវិញ ។

នៅឆ្នាំ១៩៧៤ តាម៉ាន់ ដែលជាគណៈខេត្តព្រះវិហារត្រូវបានសម្លាប់ដោយអង្គរក្សជាជនជាតិភាគតិចកួយនៅឯមូលដ្ឋានរបស់គាត់ដែលនៅជ័យសែន ។ ដោយហេតុនេះ តាហង់ ក្លាយទៅជាប្រធានតំបន់១០៣ ។ តាហង់ មានមូលដ្ឋាននៅភូមិទំលាប់ ហើយគាត់តែងតែធ្វើដំណើរមកកាន់វៀងជានិច្ច ។ កូនចៅរបស់គាត់មានទីតាំងនៅជ័យសែននិងឆែប ។ ប្រពន្ធ តាម៉ាន់ ឈ្មោះ ព្រំសុន ក៏នៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដែរ ទោះបីជា ប៊ូ ផាត់ បាននិយាយអំពីនាងនៅក្នុងចម្លើយសារភាពរបស់ខ្លួនគេនៅមន្ទីរស-២១ក៏ដោយ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ ខ្មែរក្រហមចាប់ផ្តើមទំនាក់ទំនងម្តងទៀតជាមួយមេដឹកនាំប៉ាថេតឡាវដោយបានបញ្ជូនគណៈប្រតិភូដែលដឹកនាំដោយ ខៀវ សំផន និង អៀង សារី ទៅកាន់ទីបញ្ជាការប៉ាថេតឡាវនៅសាំនឿ ។ នៅពេលនោះ ជនសំខាន់របស់ប៉ាថេតឡាវដែលទទួលបន្ទុកទំនាក់ទំនងឡាវ-ថៃគឺ ខាំផៃ ប៊ូផា ។ យុទ្ធជនដែលមកពីឡាវភាគត្បូងដូចជា ស៊ីថុន កុមម៉ាដាម និងម៉ាហា កូ សុវណ្ណាមែធី ក៏ជួបជាមួយជនកុម្មុយនីស្តកម្ពុជា ។ ខាំផៃ ប៊ូផា បានចងសម្ព័ន្ធភាពដ៏សំខាន់ជាមួយអ្នកតំណាងរណសិរ្សរួបរួមជាតិកម្ពុជាដែលមានមូលដ្ឋាននៅប៉េកាំងនិងហាណូយជាជាងដោះស្រាយដោយផ្ទាល់ជាមួយខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ។ អាស្រ័យហេតុនេះ មេដឹកនាំប៉ាថេតឡាវត្រឹមតែដឹងពីដំណើរការរបស់បក្សកុម្មុយនីស្តកម្ពុជាដោយស្រពេចស្រពិលទេ ហើយយល់ខុសថា ព្រះអង្គម្ចាស់សីហនុគឺជាអ្នកមានតួនាទីសំខាន់នៅក្នុងចលនាបដិវត្តន៍កម្ពុជា ។

មុនពេលបរាជ័យនៅទីក្រុងភ្នំពេញ នៃ សារ៉ាន់ ត្រូវបានផ្លាស់ប្តូរពីភាគឦសានមកទីបញ្ជាការបក្សកុម្មុយនីស្តកម្ពុជានៅភាគកណ្តាលប្រទេសកម្ពុជាដោយទទួលបន្ទុកដឹកនាំភស្តុភារយោធាមុនពេលមានការវាយបែកទីក្រុង ។ បន្ទាប់ពីថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ នៃ សារ៉ាន់ បម្រើការងារនៅភ្នំពេញ ហើយចូលរួមជាមួយគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យក្នុងការស្វែងរកជំនួយខបត្ថម្ភជាសម្ភារៈពីប្រទេសចិន ។ ការផ្លាស់ប្តូររបស់ នៃ សារ៉ាន់ ពីភាគ

ឦសានប្រទេសកម្ពុជានៅឆ្នាំ១៩៧៣-៧៤ ធ្វើឲ្យខ្មែរក្រហមបាត់បង់ជំនួយខបត្តម្ភក្នុងស្រុកខណៈពេលដែលកម្មាភិបាលកម្ពុជាក្រោម អ៊ុំណេង និង នីកន ដែលជាបងប្អូនរបស់ សុន សេន ប្រកាន់ខ្ជាប់គោលនយោបាយបក្សប្រជាជនបដិវត្តន៍កម្ពុជាតឹងរ៉ឹងជាងមុននៅក្នុងសហគមន៍ក្នុងស្រុក ហើយបានរិះគន់ជនជាតិវៀតណាមថាជាបញ្ញើក្អែកដ៏អាក្រក់ ។

នេះបានផ្តល់លទ្ធផលដល់ខ្មែរលើនិងជនជាតិភាគតិចឡាវដែលនឹងនាំដោយ ប៊ូ ថង (ទំពួន) ស៊ើយ កែវ (កាចក់) ខាំ ឡេន (ប្រូវ) សៀង ណយ (ប្រូវ) វេង យួន (ប្រូវ) ឌី ដេង (ឡាវ) ខាំ ឡឿង (ប្រូវ) ប៊ុន មី (ប្រូវ) ឌី ភឹម (សៀមប៉ាង-ឡាវ) ចិន រឿន (តាវេង-ប្រូវ) បួ ជួង (ឡាវ) ខាំភិន (ទំពួន) ខាំចាញ់ (ប្រូវ) ពុយ នុចាន់ (ឡាវ) និង នូ បេង (ឡាវ) បាន ភៀសខ្លួនទៅប្រទេសវៀតណាមនិងឡាវ ។ អ្នកភៀសខ្លួនបានរត់គេចពីភូមិភាគឦសានប្រទេសកម្ពុជាទៅឡាវតាមរយៈផ្លូវបី គឺផ្លូវគោកពីសៀមប៉ាងទៅបានឃីណាក់ បន្ទាប់មកពីប្រាំងនៃជ្រោះភ្នំទៅកាន់ព្រំដែននិងទីបញ្ចប់ឆ្លងកាត់តាមណាហ្គាដែលនៅឆ្ងាយពីភាគឦសាន ។ បន្ទាប់មក ពួកគេក៏បានក្លាយជាមេដឹកនាំថ្មីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាពីព្រោះពួកគេទទួលបានការចូលចិត្តពីសំណាក់វៀតណាមនៅពេលដែលពួកគេបានសិក្សានៅអំឡុងពេលនិរទេសខ្លួន ។ ប៊ូ ថង បានក្លាយជារដ្ឋមន្ត្រីក្រសួងការពារជាតិនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមាន ស៊ើយ កែវ ជាជំនួយការ ។ នូ បេង បានក្លាយជារដ្ឋមន្ត្រីក្រសួងសុខាភិបាលរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ប៉ុន្តែគាត់បានបាត់បង់ប្រជាប្រិយភាពបន្ទាប់ពីត្រូវចាប់ខ្លួនពីបទរត់ពន្ធអាភៀន ។ ប៊ុន មី ក៏ត្រូវបានជ្រើសរើសឲ្យកាន់តំណែងខ្ពស់នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ ប៉ុន្តែគាត់មានជំងឺរ៉ាំរ៉ៃនិងឆ្កួតបន្ទាប់ពីសន្លប់នៅពេលគាត់ទទួលការវះកាត់យកគ្រាប់កាំភ្លើងចេញពីស្មារបស់គាត់ ។ បួ ជួង ក្លាយទៅជាអភិបាលខេត្តរតនគិរីនិងជាមេបញ្ជាការជាន់ខ្ពស់នៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់បក្សប្រជាជនកម្ពុជា ។ ពុយ នុចាន់ ក្លាយទៅជាមន្ត្រីយោធាជាន់ខ្ពស់ទទួលខុសត្រូវអាវុធយុទ្ធភណ្ឌ ។ ចាន់ នុកែវ ក្លាយទៅជាប្រធានតុលាការខេត្តរតនគិរី ។ នៅពេលដែលមិនទាន់មានការត្រួតពិនិត្យកិច្ចការងារច្បាប់នៅក្នុងខេត្ត ចាន់ នុកែវ បានជំរុញឲ្យមានការការពារប្រពៃណីនិងចម្រៀងឡាវ ។

បន្ទាប់ពីរំដោះបានភ្នំពេញនៅឆ្នាំ១៩៧៥ សូ សារឿន (ខ្មែរ-តាកែវ) និង ឌីធីន (ទំពួន) គឺជាកម្មាភិបាលខ្មែរក្រហមដ៏សំខាន់ដែលមានតួនាទីជាអ្នករដ្ឋបាលនៅភូមិភាគឦសានទទួលខុសត្រូវលើទាហានកងពលធំលេខ៨០១ ។ ឌី ធីន បានរៀបការជាមួយនារីជនជាតិភាគតិចខ្មែរមកពីកំពង់ស្ពឺឈ្មោះ រ៉ាន ។ កងនេះមានទាហានប្រមាណ៣០០០នាក់ទទួលបន្ទុកការពារសន្តិសុខនៅព្រំដែនភាគខាងជើងដែលនៅជាប់ប្រទេសឡាវនិងវៀតណាម ។ កងពលធំលេខ៨០២ គឺជាកងយោធាដែលទទួលបន្ទុកការពារសន្តិសុខនៅតាមបណ្តោយព្រំដែនឡាវ-កម្ពុជាភាគខាងលិច ។ កងពលធំលេខ៨០២ មានកងទ័ពជាជនជាតិកួយ ទំពួន ចារាយ និង ការវេត ។ កែវ សារឿន ជាប្រធានកងពលធំលេខ៨០២ ប៉ុន្តែគាត់ត្រូវបានតាជុន ធ្វើការបោសសម្អាតនិងផ្លាស់ប្តូរ ។ តាជុន មានដើមកំណើតមកពីខេត្តកំពង់ធំ ហើយគាត់គឺជាបងថ្លៃរបស់ សុន សេន ។ ទីបញ្ជាការរបស់គាត់ស្ថិតនៅត្រពាំងគល់ជិតក្បាលទន្លេរពៅ ។ បន្ទាប់ពីមានការគ្រប់គ្រងរបស់វៀតណាម គាត់បានរត់ទៅភ្នំដងរែក ហើយនៅឆ្នាំ១៩៨៤ គាត់បានចូលរួមជាមួយសុន សេន នៅប៉ៃលិន ក្រោយមកគាត់ស្លាប់នៅទីនោះ ប្រពន្ធរបស់ តាជុន មកពីខេត្តកំពង់ស្ពឺ ។ ស៊ុម ដែលជាជនជាតិភាគតិចទំពួនមានមូលដ្ឋាននៅឆែប ហើយក៏ជាមេដឹកនាំសំខាន់ម្នាក់ទៀតនៅកងពលធំលេខ៨០២ដែរ ។ កងពលធំលេខ៩២០ គឺជាកងកម្លាំងមួយទៀតដែលត្រួតពិនិត្យលើសន្តិសុខនៅខេត្តមណ្ឌលគិរីដែលនៅជាប់ព្រំដែននឹងវៀតណាម ។ កងពលនេះត្រូវបានដឹកនាំដោយឈ្មោះ ឈិន ជនជាតិភាគតិចខ្មែរមកពីស្វាយរៀង ហើយសយ ដែលជាបងប្អូនរបស់ កុយ ធួន គឺជាជំនួយការរបស់មេដឹកនាំម្នាក់នេះ ។

មុនឆ្នាំ១៩៧៦អង្គការលើបានចាត់តាំង នៃ សារ៉ាន់ ទៅភាគឦសានដើម្បីរក្សាសណ្តាប់ធ្នាប់នៅក្នុងតំបន់នោះ ។ បន្ថែមពីលើនេះ នៃ សារ៉ាន់ បានត្រួតត្រាទឹកដីមួយចំនួនធំដែលគ្របដណ្តប់លើខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ។ បញ្ហារបស់ជនភៀសខ្លួនខ្មែរលើមានភាពលំបាកយោងទៅតាម

ភាពតានតឹងរវាងប្រទេសវៀតណាមនិងប្រទេសកម្ពុជាដែលបានកើតឡើងតាំងពីឆ្នាំ១៩៦៨ ។ ភាពខឹងសម្បាររបស់ខ្មែរក្រហមទៅលើវៀតណាមកើតឡើងនៅពេលដែលវៀតណាមបដិសេធមិនផ្តល់សព្វាវុធឲ្យធ្វើឲ្យកងទ័ពទាំងពីរ ជួបប្រទះនឹងការខ្វះខាតអាហារ ។ នៅដើមឆ្នាំ១៩៧៥ កងទ័ពខ្មែរនិងវៀតណាមដណ្តើមទឹកដីគ្នាព្រមទាំងមានការទាស់ទែងគ្នាក្នុងការដណ្តើមធនធានសមុទ្រ ។ ក្នុងនាមជាបងធំបក្សនិងជាអ្នកមានឥទ្ធិពលលើជនជាតិវៀតណាម នៃ សារ៉ាន់ ត្រូវបានតែងតាំងជាអ្នកចរចាជាន់ខ្ពស់សម្រាប់ចរចាជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមអំពីបញ្ហាព្រំដែនដែលលាតសន្ធឹងដល់ខ្ពង់រាបស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ។ នៅដើមឆ្នាំ១៩៧៦ ខណៈពេលដែលអ្នកដឹកនាំបក្សត្រូវបានគំរាមកំហែងដោយគូប្រជែងដែលលាក់ខ្លួន អង្គការលើបានចាប់ផ្តើមមានមន្ទិលសង្ស័យ បន្ទាប់មក នៃ សារ៉ាន់ ដែលស្គាល់ជាតា យ៉ា បានក្លាយជាទិសដៅនៃការស៊ើបអង្កេត ។ អង្គការលើបានរុករកសត្រូវរបស់បក្សដែលប្រឆាំងនឹងលទ្ធិម៉ៅនិងបក្សកុម្មុយនីស្តចិន ។ នៃ សារ៉ាន់ អាចត្រូវប្រៀបប្រដូចនឹង ជូ អេនឡាយ ដែលស្លាប់នៅដើមឆ្នាំ១៩៧៦ ដោយអ្នកទាំងពីរសុទ្ធតែប្រកាន់តាមទស្សនៈសាច់ការនិយមដែលដោះស្រាយបញ្ហាដោយប្រើការអនុវត្តខណៈពេលដែលថ្នាក់លើរបស់ខ្លួនតែងតែស្វែងរកគោលដៅដែលមិនអាចធ្វើទៅរួច ។

មានគេដឹងថា តាយ៉ា ធ្លាប់មានគំនិតអំពីការគ្រប់គ្រងសេដ្ឋកិច្ចខុសប្លែកគ្នាពីប៉ុល ពតជាយូរណាស់មកហើយ ប៉ុន្តែយើងមិនដឹងច្បាស់ថា តាយ៉ា បានរួមគំនិតក្បត់ប្រឆាំងនឹងប៉ុល ពតដែរឬក៏អត់ទេ ។ ជាការពិតណាស់ តាយ៉ា បានគាំទ្របក្សកុម្មុយនីស្តកម្ពុជាដូចជា កុយ ធួន អតីតមេដឹកនាំខ្មែរក្រហមនៅភូមិភាគឧត្តរ (បន្ទាប់មកគឺជាមន្ត្រីសេដ្ឋកិច្ចនិងពាណិជ្ជកម្ម) និង ហ៊ូ យន់ ដែលបានផ្លាស់ប្តូរទៅកងអនុសេនាធំដែលរងគ្រោះថ្នាក់នៅពេលដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាកំពុងរៀបរាប់ពីបទពិសោធន៍មហាលោតផ្លោះនិងបដិវត្តន៍វប្បធម៌នៅប្រទេសចិន ។ ខណៈពេលដែល នៃ សារ៉ាន់ ធ្វើចំណាប់អារម្មណ៍របស់បក្សនៅក្នុងកិច្ចចរចានៅព្រំដែនធ្វើឲ្យយើងដឹងច្បាស់ថាគាត់ជាអ្នកស្មោះត្រង់នឹងបក្ស ។ នៅចុងឆ្នាំ១៩៧៦ អង្គការលើបានសម្រេចថា តាយ៉ា គឺជាជនក្បត់ដោយគាត់ធ្លាប់មានសម្ព័ន្ធភាពជាមួយជនជាតិវៀតណាមនិង «អ្នកសេរីនិយម» របស់បក្សដទៃ ហើយគាត់ក៏ត្រូវបានចោទប្រកាន់ថាមានគំនិតក្បត់ដើម្បីផ្តួលរំលំរបបបច្ចុប្បន្ន ។ នេះជាហេតុបណ្តាលឲ្យគាត់ត្រូវបានចាប់ខ្លួននៅខែកញ្ញានិងដាក់គុកនៅមន្ទីរសន្តិសុខទួលស្លែងដែលជាកន្លែងសួរចម្លើយនិងធ្វើទារុណកម្មយ៉ាងសាហាវ ។ ក្រោយមក កម្មាភិបាលមួយចំនួនធំមកពីភាគឦសាននិងកន្លែងដទៃទៀតក៏ត្រូវបានកម្ចាត់ចោលដែរដោយសារពួកគេ ធ្លាប់ជាសមាជិកនៃ «គម្រោងការឡាវ» របស់តាយ៉ា ។

ការសួរចម្លើយ តាយ៉ា បង្កឲ្យមានការបោសសម្អាតអ្នកមានមុខតំណែងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ កម្មាភិបាលខ្លះដែលមានជាប់ពាក់ព័ន្ធនឹងបណ្តាញក្បត់របស់ តាយ៉ា មានដូចជា តាសុត (ប្រធានខេត្តសៀមរាប) ឈិន (ប្រធានកងពលធំលេខ ៩២០) បូខាវ និងតាឡាវ ជាជនជាតិភាគតិចចារាយម្នាក់មកពីអណ្តូងមាសនិងអ្នកនៅក្រោមបង្គាប់របស់ តាយ៉ា ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺបងប្អូនរបស់តាឡាវ ឈ្មោះ វីជាម និង តាវើង នៅរស់ពីរបបខ្មែរក្រហម ។ ជាងនេះទៅទៀត រ៉ូម៉ម យុន និង ហ្គាឡាន់វេត ដែលជាកម្មាភិបាលជាន់ខ្ពស់ពីរនាក់របស់ជនជាតិភាគតិចកាចក់ មកពីអណ្តូងមាសត្រូវបានបញ្ជូនទៅភូមិភាគឦសានវិញ បន្ទាប់ពីត្រូវបានចាប់ខ្លួនទៅឃុំឃាំងនៅមន្ទីរស-២១ ។ ញ៉ែម សាន ជាជនជាតិភាគតិចខ្មែរមកពីខេត្តក្រចេះក្លាយទៅជាប្រធានកងពលធំលេខ៩២០ថ្មី ។ ប្រពន្ធរបស់ ញ៉ែម សាន ដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យ បច្ចុប្បន្នរស់នៅភាគខាងលិចប្រទេសកម្ពុជា ។

ការកើតមានឡើងដ៏គួរឲ្យចាប់អារម្មណ៍នៅក្នុងស៊េរីព្រឹត្តិការណ៍នៃសោកនាដកម្មនេះគឺបងប្អូនសាច់ញាតិរបស់ តាយ៉ា នៅមណ្ឌលគិរីនៅរស់រានមានជីវិតពីការរឹតបន្តឹងរបស់បក្ស ហើយគាត់នៅតែមានភាពស្មោះត្រង់ចំពោះអង្គការថ្នាក់លើរហូតដល់ទសវត្សរ៍៩០ ។ បងប្អូនសាច់ថ្លៃរបស់ តាយ៉ា ដែលជាជនជាតិភាគតិចឡាវ តាឡាំង (លេខាបក្សនៅខេត្តមណ្ឌលគិរី) និង ខាំភូន (អនុលេខា) ដែលទទួលខុសត្រូវតំបន់១០៥នៅទសវត្សរ៍ទី៧០ សុខចិត្តស្លាប់ដោយសម្លាប់គ្នាទៅវិញទៅមកជាជាងស្លាប់នៅ

ក្រោមដៃអ្នកយាមគុកទួលស្លែង (ការសិក្សាលម្អិតអំពីសកម្មភាពដែលរៀបចំឡើងដោយ សារ៉ា ខូម និង ស៊ឹម សុរិយា បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលឆាប់ៗនេះ) ។ អ្នកតំណាងពីរនាក់របស់ តាឡាំង គឺ សុភា ជនជាតិភាគតិចខ្មែរចារាយ និង រ៉ា ជនជាតិភាគតិចឡាវ ត្រូវបានអង្គការបោសសម្អាត ។ សៅ សារ៉ូន ជនជាតិភាគតិចព្នង និងជាបងប្អូនរបស់ តាឡាំង ក្លាយទៅជាប្រធានតំបន់១០៥ បន្ទាប់ពី តាឡាំង ស្លាប់ ។ ទិត យ៉ា ជាជនជាតិភាគតិចឡាវមកពីស្រុកកោះញែកគឺជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ដែរ ។ បងប្អូនរបស់ តាឡាំង, តាឡោក និង តាអុងស៊ី បានចូលរួមជាមួយគណៈកម្មការរដ្ឋបាលតំបន់១០៥ នៅឆ្នាំ១៩៧៨ ហើយនៅឆ្នាំ១៩៨៦ គាត់បានដឹកនាំអ្នកដើរតាមខ្មែរក្រហមរាប់រយនាក់ដែលមកពីភូមិភាគឦសានទៅកាន់ភ្នំដងរែក ដើម្បីចូលរួមជាមួយ តាម៉ុក, សុន សេន និង កែពក ។

អុងស៊ី ដែលធ្វើការជាមួយ ញ៉ែម សាន អតីតប្រធានកងពលធំលេខ៩២០ និងជាពេជ្ឈឃាតរបស់ សុន សេន បច្ចុប្បន្នរស់នៅអន្លង់វែងនៅជិតផ្ទះកូនរបស់ កែ ពក និង អ្នកថតរូបនៅមន្ទីរស-២១ ញ៉ែម អេន ។ អុងស៊ី ជាអ្នកធ្វើចម្ការ ដូចជាយុទ្ធជនខ្មែរក្រហមដទៃជាច្រើននាក់ដែរ ហើយគាត់ក៏ជាទីប្រឹក្សាយោធានៃកងទ័ពក្នុងតំបន់ដែលមានមូលដ្ឋាននៅអន្លង់វែងខាងត្បូងដែរ ។ តាអុងស៊ី រៀបការជាមួយនារីជនជាតិភាគតិចឡាវម្នាក់មកពីស្ទឹងត្រែង ។ នៅពេលដែលគាត់ជាយុវជន គាត់បានសិក្សានៅស្ទឹងត្រែង ហើយពេលដែលគាត់បួសជាព្រះសង្ឃ គាត់បានទៅធ្វើទស្សនកិច្ចនៅប្រទេសឡាវ ។ នៅពេលនោះ តាអុងស៊ី បានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះសង្ឃឡាវដែលមកប្រទេសកម្ពុជាដើម្បីឧបត្ថម្ភការកសាងព្រះវិហារ សាសនានៅតាមជ្រលងទន្លេស្រែពក ។ លោកស្រី បួ ចាន់ណា ក្មួយស្រីរបស់ប្រពន្ធ នៃ សារ៉ាន់ បច្ចុប្បន្នជាមន្ត្រីកិច្ចការនារីនៅភូមិ១០៥ជាភូមិដែលខ្មែរលើជាច្រើននាក់ធ្លាប់ធ្វើទំនាក់ទំនងជាមួយមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។ ថ្មីៗនេះ លោកស្រីត្រូវបានតែងតាំងជាអនុប្រធានឃុំ ។ ប្តីរបស់លោកស្រី កួយ ទាន់ (អតីតជំនួយការផ្ទាល់ខ្លួនរបស់ សូ សារឿន ជននៅក្រោមការឧបត្ថម្ភរបស់ ប៉ុល ពត និងជាពេជ្ឈឃាតរបស់ សុន សេន) គឺជាមន្ត្រីឃុំ ។

យុទ្ធជនទាំងអស់នេះតាំងទីលំនៅនៅឧត្តរមានជ័យហើយនៅប្រកាន់ខ្ជាប់វប្បធម៌ឡាវនិងខ្មែរលើ ។ ថ្មីៗនេះពួកគេបានជួបជុំជាមួយគ្រួសារនិងមិត្តភក្តិដែលមកពីមណ្ឌលគិរីនិងឡាវ ហើយបានចូលរួមសាងសង់ព្រះវិហារព្រះពុទ្ធសាសនានៅពាមជីមៀតដែលនៅតាមច្រាំងទន្លេស្រែពក ។ ភូមិ១០៥មានមូលដ្ឋាននៅតាមចំណោតភ្នំដងរែកក្រោមត្រង់សេដែល ប៉ុល ពត បានបោះបង់ចោលនិងភាគខាងលិចនៃអតីតមូលដ្ឋានរបស់ សូ សារឿន នៅភូមិអូរស្វាយ ។ វាគឺជាភូមិមួយដែលមានសណ្តាប់ធ្នាប់ប្លែកនិងគួរឲ្យចាប់អារម្មណ៍នៅក្នុងកន្លែងដែលគួរឲ្យទាក់ទាញ ពីព្រោះភូមិនេះបានទទួលការឧបត្ថម្ភពីសំណាក់អង្គការក្រៅរដ្ឋាភិបាល ។ ការរៀបចំនេះមានភាពផុយស្រឡះពីកន្លែងដែលសម្បូរដោយដីនៅមុំផ្ទះរបស់ ប៉ុល ពត និង តាម៉ុក ដែលស្ថិតនៅភាគខាងឦសាននៃភូមិ១០៥ ។ ៥-១០ គីឡូម៉ែត្រ ពីផ្លូវធំដែលភ្ជាប់ពីអន្លង់វែងទៅចុងសាង៉ាម គឺភូមិ១០៥ ជាកន្លែងដែលមានភាពសុខដុមរមនាផុយពីមុនដែលធ្លាប់ជាកន្លែងមានតែសង្គ្រាម ។

តាហង់ ត្រូវបានចោទប្រកាន់ពីបទប្រឆាំងអង្គការលើ ដូចជា តាយ៉ា ដែរ ប៉ុន្តែគាត់មិនត្រូវបានចាប់ខ្លួនទេរហូតដល់ដើមឆ្នាំ១៩៧៨ ខណៈពេលដែលគាត់ត្រូវបានសម្គាល់ថាជនជនក្បត់បក្សកុម្មុយនីស្តកម្ពុជា ។ នេះដោយសារតែគាត់ធ្លាប់មានទំនាក់ទំនងជាមួយ នៃ សារ៉ាន់ និងមានគំរូរដ្ឋបាលដែលអាចបន្ទរបន្ថយបាន ។ ដោយហេតុនេះ គាត់និងអ្នកក្រោមបង្គាប់របស់គាត់ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលខ្មែរក្រហមហើយបញ្ជូនទៅភាគនិរតី ។ កូនរបស់ តាហង់ ឈ្មោះ មួន នៅរស់ហើយនៅឆ្នាំ១៩៨១ ត្រូវបាន ជា ស៊ីម យកទៅបីបាច់ថែរក្សា ។ បងប្រុសរបស់ តាហង់ ឈ្មោះ ប៊ួទិត បានរត់ទៅវៀតណាម ហើយប្អូនស្រីរបស់គាត់នៅរស់ ។ ឡូត (ខ្មែរ-កំពង់ស្រឡៅ) មុត (ព្នង) និង កាន (កួយ) ដែលជាអ្នកធ្វើការនៅគុកអន្លង់ស្វាយក៏ត្រូវបានចាប់ខ្លួនដែរ ។ ខ្មែរក្រហមបានចាប់ផ្តើមប្រតិបត្តិការគុកនៅឆែប អន្លង់ស្វាយ និងរវៀង ។ បន្ថែមពីលើនេះទៀតមានវាលពិឃាតជាច្រើនស្ថិតនៅជិតភូមិទំលាប់ដែលជាកន្លែងមូលដ្ឋានរបស់ខ្មែរក្រហម ។ ម៉ិត្រី ជាជនជាតិភាគតិចខ្មែរមកពីភូមិភាគនិរតីបានមកកាន់តំណែងជាប្រធានស្រុកជាំក្សាន្តជំនួស ប៊ុនចាន់ ។ ប្រាសាទថ្មបុរាណត្រូវបាន

បំផ្លិចបំផ្លាញនៅក្រោមបញ្ជារបស់នាង ។ ម៉ិត្រី ហៅ រី បានរៀបការជាមួយ សឿន កម្មាភិបាលខ្មែរក្រហមមកពីខេត្តតាកែវដែលធ្វើការនៅអន្លង់វែង ។ ប៊ុនចាន់ ត្រូវបានបញ្ជូនទៅសៀមរាបបន្ទាប់មកទៅមន្ទីរស-២១នៅតាកែវ ។ គាត់មានជីវិតដោយសារការចូលមកដល់របស់កងទ័ពវៀតណាមនៅឆ្នាំ១៩៧៩ ។ ដោយ តាហង់ ត្រូវបានចាប់ខ្លួន រដ្ឋបាលនៅតំបន់១០៣ (ត្រូវបានគ្រប់គ្រងដោយ ចាន់ សម ហៅ សែ) និង ខឹម បន្ទាប់មកពួកគេត្រូវបានអង្គការធ្វើការបោសសម្អាត ។ ខឹម ដែលទទួលខុសត្រូវតំបន់១០៣ត្រូវបានជំនួសដោយ ម៉ុក ដែលជាជនជាតិភាគតិចខ្មែរ ។ ម៉ុក បានគេចខ្លួនទៅព្រំដែនថៃនៅឆ្នាំ១៩៧៩ ។ អតីតអង្គរក្សរបស់ តាប៉ុង ឈ្មោះ អ៊ីឈាន នៅរស់បន្ទាប់ពីការបោសសម្អាតនៅព្រះវិហារ បន្ទាប់មកបានក្លាយទៅជាអង្គរក្សរបស់អៀង សារី ។

ការស្លាប់នៅព្រះវិហារមានចំនួនតិចដោយសារតែកត្តាមួយចំនួន ។ ព្រះវិហារមិនសូវមានកងទ័ពវៀតមិញ ដូចជាកន្លែងខ្លះនៃប្រទេសកម្ពុជាទេ ។ នៅពេលមានសង្គ្រាមឥណ្ឌូចិនលើកទីមួយ កងទ័ពបដិវត្តន៍វៀតណាមបានត្រឹមតែឆ្លងកាត់ព្រះវិហារប៉ុណ្ណោះ ប៉ុន្តែមិនអាចបង្កើតសាខាបក្សប្រជាជនបដិវត្តន៍ខ្មែរនៅទីនោះបានទេ ។ នៅក្នុងទស្សនៈរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ព្រះវិហារគឺជាកន្លែងបរិសុទ្ធនិងជាមែកធាងនៃប្រពៃណីទំនៀមទម្លាប់របស់ប្រវត្តិសាស្ត្រកម្ពុជា ពីព្រោះប្រាសាទនេះស្ថិតនៅតែឯង ហើយបានទទួលការអភិវឌ្ឍតិច ។ ទំនាក់ទំនងរបស់មន្ត្រីជាន់ខ្ពស់ជាមួយប្រជាជនក្នុងស្រុកក៏មានភាពខុសប្លែកគ្នាដែរ ។ ជាឧទាហរណ៍ទៀត សំផន បានរៀបការជាមួយនារីក្នុងស្រុកជាជនជាតិភាគតិចខ្មែរឈ្មោះ រឿន មកពីរវៀង ។ ប្រជាជនតិចតួចនៅព្រះវិហារក៏បានជួយមិនឲ្យមានការសម្លាប់យ៉ាងច្រើនដែរ ពីព្រោះខ្មែរក្រហមត្រូវការអ្នកយាមនៅតាមព្រំដែនឡាវនិងថៃដើម្បីការពារការវាយឆ្មក់ ។

អ្នកតំណាងរបស់ តាយ៉ា ឈ្មោះ អ៊ុំណោង ត្រូវបានចាត់តាំងជាថ្មីឲ្យធ្វើជាប្រធាននៅភូមិភាគឦសានបន្ទាប់ពី តាយ៉ា ត្រូវបានចាប់ខ្លួន ។ អ៊ុំណោង និងគ្រួសាររបស់គាត់ដែលសុទ្ធតែជាជនជាតិភាគតិចខ្មែរមានទំនាក់ទំនងល្អជាមួយប្រជាជនក្នុងស្រុក ។ កូនស្រីរបស់គាត់ត្រូវបានបណ្តុះបណ្តាលជាគិលានុបដ្ឋាយិកា ។ នៅទីបញ្ចប់ អ៊ុំណោង ក្លាយទៅជាជនសង្ស័យក្នុងការបោសសម្អាតបណ្តាញរបស់ នៃ សារ៉ាន់ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ។ គាត់ត្រូវបានកោះហៅមកភ្នំពេញ ប៉ុន្តែគាត់បានធ្វើអត្តឃាតមុនពេលត្រូវចាប់ទៅមន្ទីរស-២១ ។ បន្ទាប់ពីគាត់ស្លាប់ ក្រុមគ្រួសាររបស់គាត់មិនបានទទួលការធ្វើបាបអ្វីទេ ។ តាប៊ុត កម្មាភិបាលនៅស្ទឹងត្រែង និងប្រពន្ធរបស់គាត់ ស៊ីផា ដែលជាកូនខ្មែរកាត់ចិនត្រូវបានសម្លាប់នៅចុងឆ្នាំ១៩៧៨ ។ បងប្អូនរបស់ តាប៊ុត ឈ្មោះ តាកាត ក៏ត្រូវបានចាប់ខ្លួនដែរ ។ ស្ត្រីមេម៉ាយដែលជាប្រពន្ធរបស់ អ៊ុំណោង និងតាកាត បានក្លាយទៅជាមិត្តជិតស្និទ្ធនឹងគ្នាបន្ទាប់ពីប្តីរបស់គេទាំងពីរបាត់ខ្លួន ។ អ្នកទាំងពីរបានចូលរួមនឹងសុន សេន បន្ទាប់ពីការកាន់អំណាចរបស់វៀតណាមនៅឆ្នាំ១៩៧៩ ។ កូនស្រីច្បងរបស់ អ៊ុំណោង ឈ្មោះ ប័ត បានបែកពីម្តាយរបស់នាង ហើយទៅរស់នៅបានលុង ព្រមទាំងធ្វើការជាបុគ្គលិកសុខាភិបាល ។ ប័ត រស់នៅក្នុងភូមិជាមួយនឹងនិរសារជាជនជាតិភាគតិចគ្រឹងរបស់ តាយ៉ា ឈ្មោះ ខាំផុង ។

ការរំដោះរបស់វៀតណាមនៅឆ្នាំ១៩៧៩ បានធ្វើឲ្យទំនាក់ទំនងឡាវ-កម្ពុជានៅតាមព្រំដែនឈានដល់ទីបញ្ចប់ ដោយពីរបបដែលមានការគាំទ្រពីវៀតណាមនៅក្នុងប្រទេសឡាវ ។ ប្រទេសកម្ពុជាបានស្វែងរកការឧបត្ថម្ភនៅក្នុងជំរំនៅភ្នំដងរែក ។ សមាជិកគ្រួសាររាជវង្សចម្ប៉ាសាក់នៅប្រទេសឡាវក្លាយទៅជាមានតួនាទីសំខាន់នៅក្នុង (ចលនាតស៊ូប្រឆាំងកុម្មុយនីស្តឡាវ) ដែលមានមូលដ្ឋាននៅជិតតំបន់ដែលជាប់ព្រំដែនប្រទេសបី គឺនៅតាមបរិវេណ អ៊ូប៊ុន ព្រះវិហារ និងចម្ប៉ាសាក់ ។ ជនភៀសខ្លួនខ្មែរក្រហមមកពីភាគឦសានបានសហការជាមួយនឹងចលនាតស៊ូប្រឆាំងកុម្មុយនីស្តឡាវដើម្បីបង្កើតទំនាក់ទំនងខាងក្រៅនិងបង្កើតប្រាក់ចំណូលតាមរយៈការលក់ត្បូង វត្ថុបុរាណ និងឈើ ។ ដើម្បីជាការតបស្នង ចលនាតស៊ូប្រឆាំងកុម្មុយនីស្តក៏ទទួលបានសព្វាវុធជាថ្នូរមកវិញ ។ មហិច្ឆតាចង់បានដីដែលបាត់បង់មកវិញនៅតែបន្ត ប៉ុន្តែវាក្លាយទៅជាធូរស្រាលវិញយ៉ាងលឿនដោយសារមានជម្លោះបក្ស ។

**រីធី ម៉ារធីន**

# ការពិតរបស់ខ្ញុំ

នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមបានវាយចូលដល់ទីក្រុងភ្នំពេញ ប្រជាជនទាំងអស់បានស្រែកជយោៗ រួចទះដៃអបអរសាទរ ប៉ុន្តែភាពរីករាយនេះបានស្ងប់ស្ងាត់ទៅវិញភ្លាមដែរបន្ទាប់ពីយោធាខ្មែរក្រហមឃោសនាឲ្យយើងចាកចេញពីផ្ទះសម្បែងមួយរយៈ ក្រោយពីកម្ទេចខ្មាំងអស់ទើបឲ្យត្រឡប់វិញ ។ យើងត្រូវបានគេហៅថាពួក១៧មេសា ឬប្រជាជនថ្មី ការនិយាយស្តីត្រូវអង្គការបង្រៀនឲ្យហៅថាសមមិត្តទាំងអស់ ។

ខ្មែរក្រហមបានដេញប្រជាជនឲ្យចាកចេញពីទីក្រុងទៅកាន់ទីជនបទ ។ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំបានធ្វើដំណើរទៅដល់វត្តព្រែកស្តី រួចសម្រាកនៅទីនោះនិងទទួលបានបាយមួយកញ្ចប់ម្នាក់ដើម្បីរង់ចាំកាណូតជិះទៅឃុំឈើខ្មៅ ។ ពេលនោះ មានពូមីងខ្លះឆ្ងល់ហើយសួរថា សមមិត្តតើថ្ងៃណាពួកខ្ញុំទាំងអស់គ្នាអាចវិលត្រឡប់ទៅផ្ទះវិញ?

ស្នូរកាំភ្លើងស្រាប់តែផ្ទុះឡើង ព្រមជាមួយសំឡេងស្រែកគំរាមរបស់យោធាខ្មែរក្រហមថា «កុំសួរនាំ អង្គការមិនទាន់កម្ទេចខ្មាំងអស់ទេ កម្ទេចអស់ពេលណាអង្គការនឹងឲ្យត្រឡប់ទៅថ្ងៃហ្នឹងហើយ» ។ មិត្តឯងជាខ្មាំងឬបានជាហ៊ានសួរអង្គការ? នេះជាសម្តីយោធាខ្មែរក្រហមដែលប្រើមកលើអ្នក១៧មេសា មុនឡើងកាណូតឆ្លងទៅឃុំឈើខ្មៅ ។ ក្តីរន្ធត់មួយបានមកដល់និងសម្លឹងមើលទៅគួរតក់ស្លុត ដោយខ្មែរក្រហមប្រើល្បិចពន្លិចកាណូតបណ្តាលឲ្យអ្នកពុំចេះហែលទឹកស្លាប់មួយចំនួន ។ ខ្មែរក្រហមបញ្ចេញចរិតស្អប់ខ្ពើមអ្នកថ្មី ដោយនិយាយមើលងាយថា អ្នកមូលធនមិនចេះជិះកាណូតសមតែលិចស្លាប់អីចឹងហើយ ។ ខ្មែរក្រហមនិយាយប្រៀបប្រដូចជីវិតអ្នកស្លូតត្រង់ទៅនឹងសំរាមដែលគេដុតចោល ។

ក្រុមខ្ញុំដែលត្រូវជម្លៀសទៅមានចំនួន១២គ្រួសារ (សមាជិក៣៥នាក់) រាប់ទាំងចាស់ ទាំងក្មេងបានឆ្លងរួចផុត ហើយត្រូវបញ្ជូនទៅដល់ភូមិកោះតូច ឃុំឈើខ្មៅ ស្រុកកោះធំ ។ នៅទីនេះគ្រួសារខ្ញុំទទួលបានរបបម្សៅជ្រៃមួយកូនកែវកូហូបជំនួសបាយ ។ ការហូបបែបនេះ ធ្វើឲ្យប្រជាជន១៧មេសាធ្លាក់ខ្លួនឈឺនិងបាក់កម្លាំងជាបន្តបន្ទាប់ ជាក់ស្តែង បងថ្លៃស្រីរបស់ខ្ញុំក្រោយពីគាត់សម្រាលកូនហើយ កូននោះក៏ស្លាប់ទៅវិញព្រោះគាត់គ្មានទឹកដោះឲ្យកូនបៅ ។ ខ្មែរក្រហមមិនឲ្យយកកូននោះទៅកប់ទេ ដោយឲ្យយកទៅបណ្តែតទឹកចោលវិញ ។ ដូច្នេះ យើងមិនហ៊ានជំទាស់នឹងបញ្ជារបស់ខ្មែរក្រហមទេព្រោះខ្លាចស្លាប់ ។ បីខែក្រោយមក


ការជម្លៀសប្រជាជនចេញពីទីក្រុង

យោធាខ្មែរក្រហមចុះស្រង់ប្រវត្តិរូបនិងនិយាយកុហកថា «អង្គការស្រាវជ្រាវរកអ្នកធ្វើការ អ្នកណាធ្លាប់ធ្វើអ្វីពីមុនឲ្យត្រឡប់ទៅកន្លែងនោះវិញ» ។ ពួដូច្នេះម្នាក់ៗចូលទៅធ្វើប្រវត្តិរូបស្ទើរតែគ្រប់គ្នា ព្រោះគិតថាបានត្រឡប់ទៅផ្ទះវិញ ។ ឪពុកខ្ញុំបានដឹងថានេះជាផែនការរបស់ខ្មែរក្រហម ដូច្នេះគាត់ក៏នាំសមាជិកគ្រួសារចេញទៅកាច់ពោតធ្វើដូចជាពុំដឹង ។ ម៉ោងមួយរំលងអធ្រាត្រក្រោយមក អ្នកដែលបានធ្វើប្រវត្តិរូបទាំងប៉ុន្មានត្រូវយោធាខ្មែរក្រហមប្រមូលទាំងគ្រួសារចេញទៅអស់ ក្នុងនោះមានលោក

មកព្រៃផងដែរ ដោយបាត់ដំណឹងរហូតដល់បច្ចុប្បន្ននេះ ។ ថ្ងៃបន្ត ខ្មែរក្រហមបានមកចាប់បងប្រុសទីពររបស់ខ្ញុំឈ្មោះ ពេជ្រ ដារ៉ា និងប្អូនប្រុសជីដូនមួយឈ្មោះ ស្វាយ បូរ៉ា យកទៅដាក់គុកវត្តដើង ឯក ។ ដោយទ្រាំទ្រនឹងទារុណកម្មពុំបាន បងប្រុសខ្ញុំដាច់ចិត្តលោត ទឹកសម្លាប់ខ្លួនទាំងដៃនៅជាប់ខ្នោះ ។ ដំណឹងនេះធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំអស់ក្ដីសង្ឃឹមជាខ្លាំង ។ បងប្រុសខ្ញុំត្រូវស្លាប់ ប្អូនប្រុសជាប់គុក ចំណែកខ្ញុំត្រូវអនុភូមិឈ្មោះ ចក់ ប៉ុនប៉ងសម្លាប់ ព្រោះតែស៊ើបដឹងថា គ្រួសារខ្ញុំជាអ្នករាជការ ឪពុកខ្ញុំធ្វើពេទ្យផ្នែកវិកលចរិក ។ ចក់ មានបំណងសម្លាប់ខ្ញុំមួយលើក ជាពីរលើកតែពុំបានសម្រេច ។ លើកទីមួយពន្លិចទូកឲ្យខ្ញុំលង់ស្លាប់ ប៉ុន្ដែមិនស្លាប់ព្រោះបានសមមិត្ត ដើង ជួយទាន់ ។ ក្រោយមក គ្រប់កលល្បិចរបស់ ចក់ ដែលប៉ងសម្លាប់ខ្ញុំ ត្រូវមេភូមិដឹងទាំងអស់ រួចក៏បានផ្លាស់ខ្ញុំឲ្យមកដកសណ្ដែកដីជាមួយយាយៗវិញ ។ ពេលដើរជួប ចក់ ម្ដងៗ គាត់តែងនិយាយថា «សំណាងល្អណាស់មិត្តឯង កុំអីអញលេងឲ្យចាស់ដៃ» ។

នៅឆ្នាំ១៩៧៦ អ្នក១៧មេសាត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅស្រុកមោងឫស្សី ។ ធ្វើដំណើរដោយរទេះភ្លើងរយៈពេលជាច្រើនម៉ោង វេលាម៉ោង៩យប់ គ្រួសារខ្ញុំក៏ត្រូវអង្គការចុចឈ្មោះឲ្យរស់នៅតំបន់១ ។ តែដូនពេលនោះ សំណាងល្អ គ្រួសារខ្ញុំបែរជាប្រឡំមកឡើងរទេះគោទៅតំបន់២វិញ ។

ជីវិតអ្នកនៅក្នុងតំបន់១ ជាមុខសញ្ញាត្រូវកម្ទេចចោលទាំងអស់ ដោយប្រុសៗត្រូវអង្គការស្នើទៅកាប់ព្រៃនៅភ្នំធិបតី ឬភ្នំផ្ដេរ ពុំឃើញត្រឡប់មកវិញទេ ។ ចំណែកជីវិតអ្នកនៅតំបន់២ ខ្មែរក្រហមប្រើវិធីសម្លាប់ជាជំហានៗ ដោយដំបូងអង្គការចែកគ្រាប់ពោត៨គ្រាប់ម្នាក់ រួចនិយាយថា ជួយសន្សំសំចៃអង្គការ ហូបតិចៗបានហើយ ព្រោះមិនបានបញ្ចេញកម្លាំងពលកម្មទេ ។ ពួកខ្ញុំអ្នក១៧មេសាមានចំនួន៦០៥គ្រួសារត្រូវបានអង្គការបញ្ជូនមករស់នៅក្នុងភូមិត្រស់ ឃុំអូរតាគី ស្រុកបាត់ដំបង ដោយចែកខ្ទមតូចឲ្យនៅរួមពីរគ្រួសារ ។ ខ្ទមនេះមានបិទជញ្ជាំងពាក់កណ្ដាលខណ្ឌគ្នានិងមានប្អូនដូរសង់ទល់មុខគ្នា ។ ក្រោយពីរៀបចំហើយ មេក្រុម មេកងបានបញ្ជាប្រជាជនឲ្យទៅជំរំធ្វើការ ដែលធ្វើឲ្យឪពុកព្រាត់កូន ជីដូនព្រាត់ចៅ ប្រពន្ធព្រាត់ប្ដី ។ កុមារតូចៗបានក្លាយទៅជាកូនអង្គការផ្ដាច់មនោសញ្ចេតនាពីឪពុកម្ដាយ និងសាច់ញាតិ រួចឲ្យកុមាររៀនច្រៀងបទដែលមានឈ្មោះថា «យើងខ្ញុំកុមារ ស្រឡាញ់អង្គការឥតមានព្រំដែន» ។

ខ្ញុំខុសពីកុមារដទៃ ព្រោះខ្ញុំតូចល្អិត សុខភាពពុំរឹងមាំ អង្គការដកឲ្យទៅចូលក្នុងកងចល័តពិសេសរបស់ក្រុមមិត្តនារីពេញកម្លាំងមានតួនាទីលើកទំនប់១៧មេសា ។ ចំណែកការហូបចុកវិញ គឺខ្ញុំទទួលបានបាយមួយចានចង្កឹះជាមួយសម្លចន្ទាបុស្សីកប្រេស ។ នៅពេលដែលខ្ញុំហូបបាយ ខ្ញុំតែងតែឃើញកងទ័ពខ្មែរក្រហមតាមឃ្លាំមើលមិនដាក់ភ្នែក ។ ខ្ញុំឆ្ងល់ក៏សួរថា សមមិត្តចាំមើលអី? ខ្មែរក្រហមនោះក៏ឆ្លើយថា ចាំចាប់ខ្មាំងក្រែងវាងើបប្រឆាំងនឹងអង្គការ ។ ខ្ញុំឈប់សួរ រួចឈរសម្លឹងមើលទៅមុខ និងគិតថាអ្វីទៅជាខ្មាំងរបស់អង្គការ ពួកអ្នករែកដីនេះជាខ្មាំងឬក៏មានអ្នកផ្សេង? ការគិតរបស់ខ្ញុំនឹកពុំឃើញទេ ក្រោយពីរែកដីរួច ខ្ញុំក៏ត្រឡប់មកជំរំវិញ ។

ពេលវេលាមួយភ្លែតសោះ នៅក្នុងជំរំមានមនុស្សស្លាប់ជាបន្តបន្ទាប់ដោយសារពស់ចឹកឬធ្វើអំពើខុសនឹងសីលធម៌ ដូចជាការលួចស្រឡាញ់គ្នារវាងយុវជននិងយុវនារី ។

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៧ ជាថ្ងៃធ្វើពិធីខួបរំលឹកខួបជ័យជម្នះ ខ្មែរក្រហមក៏បានឲ្យអ្នកសមរភូមិមុខវិលមកលេងក្រុមគ្រួសាររយៈពេលបីថ្ងៃ ។ ពេលនោះ ខ្ញុំសប្បាយរីករាយណាស់ ខ្ញុំលែងគិតពីការនឿយហត់ ដើរផង រត់ផង និងស្រែកច្រៀងផង ។ ពេលមកដល់ ខ្ញុំដឹងថាអ្នកសមរភូមិក្រោយចាប់ផ្ដើមហូបបបររួម និងត្រូវប្រមូលសម្ភារៈដាក់រួមនៅក្នុងសហករណ៍ទាំងអស់ ។ ដូច្នេះ ដោយសារតែហូបមិនគ្រប់គ្រាន់ និងឃ្លានខ្លាំង ធ្វើឲ្យអ្នកខ្លះដាច់ចិត្តលួចដំឡូងឬសម្លាប់សត្វឆ្មាធ្វើជាអាហារ ។ ខ្លះទៀតត្រូវកងឈ្លបចាប់បានយកទៅធ្វើទារុណកម្មដល់ស្លាប់ ។ អ្នក១៧មេសា ធ្វើការធ្ងន់បាក់កម្លាំង រហូតដល់មានក្បាលជង្គង់ធំជាងក្បាល ។ លើសពីនេះ ពេលឈឺមិនហ៊ានសុំច្បាប់ឈប់សម្រាកទេ ព្រោះខ្មែរក្រហមតែងតែនិយាយពាក្យមួយឃ្លាថា «គ្រុនញាក់ គ្រុនញ័រ គ្រុនគ្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនត្បូងចប» ។ ដូច្នេះហើយ គ្មានអ្នកណាម្នាក់ហ៊ានឈប់ឡើយ តស៊ូបូរផ្ដាច់ធ្វើការទាល់តែដើរលែងរួច ។

ក្រោយមក ខ្ញុំត្រូវបានចាត់តាំងឲ្យទៅរើសដីវិញ ។ ពេល

នោះ ខ្ញុំអាចលួចទៅតាមឪពុកខ្ញុំទៅភ្ជួរស្រែ និងដើរពីក្រោយគាត់រើសខ្យងបាន ។ ថ្ងៃមួយ នង្គ័លដែលឪពុកខ្ញុំភ្ជួរតែងតែរបូតដាលស្រាប់តែកងឈ្លបដើរយាមនៅទីនោះលើកកាំភ្លើងបាញ់តម្រង់ទៅរកឪពុកខ្ញុំលាន់ផ្ទុងបែកខ្ទាយ ខ្ញុំគិតថាឪពុកខ្ញុំស្លាប់ហើយ ។ បន្ទាប់មក គាត់ក៏យកកូនពូថៅទៅគោះដាលនង្គ័លទាំងញ័រដៃ រួចចាប់ផ្តើមភ្ជួរ ដាក់គោឲ្យស៊ីស្មៅនិងផឹកទឹក ។ ល្ងាចវិលមកសហករណ៍វិញ យើងទាំងអស់គ្នាហូបបបរជុំគ្នាដោយស្ងៀមស្ងាត់ ។ ម៉ែ ខ្ញុំ ប្អូនខ្ញុំ រួមទាំងគ្រួសារម្នាក់ៗសម្តែងនូវការសួរសុខទុក្ខឪពុកខ្ញុំតែតាមរយៈទឹកមុខនិងក្រសែភ្នែកប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៨ ពេលប្រជាជន១៧មេសាធ្លាក់ខ្លួនឈឺ ខ្មែរក្រហមឆ្លៀតឱកាសនោះបានយកថ្នាំគីនីនមកឲ្យលេប ដោយប្រាប់ថា លេបពីរគ្រាប់ព្រឹក ពីរគ្រាប់ល្ងាច ។ ភាពសោកសង្រេងមិនអាចភ្លេចបាន តែមួយយប់សោះសហករណ៍ខ្ញុំដែលមានគ្នាជាង៣០០គ្រួសារ ព្រឹកឡើងស្ងាត់ជ្រងំ ម្នាក់ៗត្រូវពុលថ្នាំគីនីនធ្វើឲ្យវង្វេងស្មារតីនិងវិលមុខដើរលែងរួចរហូតដាច់ខ្យល់ស្លាប់ ។ វិនាសកម្មនេះបានធ្វើឲ្យអ្នកនៅសមរភូមិក្រោយស្លាប់ស្ទើរតែទាំងអស់នៅសល់តែ៣៧គ្រួសាររួមទាំងគ្រួសារខ្ញុំផង ។ គ្រួសារខ្ញុំអាចចៀសផុតពីគ្រោះថ្នាក់នេះ គឺដោយសារឪពុកខ្ញុំជាពេទ្យអាចដឹងថាបើលេបថ្នាំនេះទៅមានតែស្លាប់ប៉ុណ្ណោះ ព្រោះយើងគ្មានអ្វីហូប ។ អ្នកដែលនៅរស់ទាំងប៉ុន្មាន ខ្លះទៅកាប់រណ្តៅ ខ្លះទៅសែងខ្មោចយកទៅកប់ក្នុងរណ្តៅរួមតែមួយ ។

មួយរយៈក្រោយមក ប្អូនស្រីខ្ញុំ ឈ្មោះ ស្វាយ វ៉ាន់ថា ក៏បានស្លាប់ដោយសារពុលវល្លិត្រដិត ។ ថ្ងៃមួយជីដូនខ្ញុំដែលឈឺដើរពុំរួចបានស្នើសុំខ្ញុំឲ្យយកបបរមកជូនគាត់ ។ ដោយសារតែអាណិតគាត់ខ្លាំងពេក ខ្ញុំក៏ព្យាយាមធ្វើការក្រៅម៉ោងដើម្បីបានអង្ករបន្ថែមលើបបររាវមួយចានដែលអង្គការចែកឲ្យ ។ មិនយូរប៉ុន្មានខ្ញុំសន្សំអង្ករបានមួយកំប៉ុងយកទៅដូរយកទឹកត្នោតជូនយាយ ។ ប៉ុន្តែ ខ្ញុំមិនបានជួបអ្នកឡើងត្នោតទេ បែរជាខ្ញុំត្រូវកងឈ្លបឈ្មោះដន ចាប់យកអង្ករវិញ និងព្រមានថា «ថ្ងៃក្រោយបើតាមទាន់ទៀត មិត្តឯងត្រូវធ្វើទោសតាមច្បាប់អង្គការគឺស្លាប់ហើយ» ។ ខ្ញុំមានការតក់ស្លុតចំពោះសម្តីនេះណាស់ ហើយក៏ដើរត្រឡប់មកខ្ទមវិញទាំងអស់សង្ឃឹម ។ ក្រោយពីខ្ញុំជម្រាបគាត់តាមដំណើរ ជីដូនខ្ញុំក៏បានយកគ្រឿងអលង្ការពីប្រអប់ឲ្យខ្ញុំយកទៅដូរអង្ករអ្នកមូលដ្ឋានចាស់មកដាំបាយជូនគាត់ហូបព្រោះគាត់ឃ្លានបាយណាស់ ។ ខ្ញុំក៏ប្រញាប់ទៅផ្ទះសមមិត្ត សាញ់ ដែលនៅមិនឆ្ងាយពីខ្ទមរបស់ខ្ញុំ រួចខ្ញុំលើកដៃសំពះគាត់និយាយថា «ខ្ញុំសុំដូរអង្ករចំនួន៥កំប៉ុង នេះរបស់ជីដូនខ្ញុំជូនអ៊ំជាថ្នូរដូរនឹងអង្ករ សូមអ៊ំពិនិត្យមើល ។ សមមិត្ត សាញ់ មិនឆ្លើយតបទេ រួចបោះរបស់ទាំងអស់មកឲ្យខ្ញុំវិញ ដោយស្តីបន្ទោសថា «ស្អី មាស ពេជ្រ ហ្នឹងស៊ីកើតឬអី យកទៅវិញទៅ កុំថាឡើយពីរប្រអប់ ទោះបីជាមានមាសមួយហឹបយកមកឲ្យក៏មិនព្រមដែរព្រោះស៊ីអត់កើត» ។

ខ្ញុំដើរបណ្តើរគិតបណ្តើរអាណិតដល់ជីដូនខ្ញុំដែលកំពុងរង់ចាំដូវខ្ញុំ ។ បន្ទាប់មក ខ្ញុំក៏ដើរតម្រង់ទៅដៃស្ទឹងមោងឈរពាក់កណ្តាលស្ពានលើកប្រអប់ទាំងពីរមើល និងគិតថាគ្មានតម្លៃទេពេលនេះ ទុកអ្នកក៏គ្មានប្រយោជន៍ដែរ រួចក៏បើកប្រអប់ទាំងពីរចាក់របស់ទាំងនោះទៅក្នុងស្ទឹងដោយពុំស្តាយស្រណោះឡើយ ។

ដើម្បីបំបាត់ការស្រេកឃ្លាន ខ្ញុំតែងតែទៅរាវក្តាមខ្យងមកស្ងោរហូបជំនួសបបររាវៗដែលសហករណ៍ចែកឲ្យ ។ ថ្ងៃមួយដោយសារការធ្វេសប្រហែសភ្លេចយកសំបកខ្យងទៅចោល ជីដូនខ្ញុំក៏បានយកកញ្ច្រែងទុកសំបកខ្យងនោះទៅទំពាហូបគ្មានសល់ លុះខ្ញុំត្រឡប់មកវិញ ស្រាប់តែឃើញគាត់កំពុងបម្រះនទៀលពេញកូនខ្ទម ។ មិនយូរប៉ុន្មាន ជីដូនរបស់ខ្ញុំក៏បានស្លាប់នៅវេលាម៉ោង៩ព្រឹក ដោយបន្សល់នូវសម្តីចុងក្រោយថា «វ៉ាន់ថង យាយឃ្លានបាយណាស់ មុននឹងស្លាប់យាយបានបាយមួយពុំទូតហូប ស្លាប់ទៅអស់ចិត្តហើយ» ។

នេះជារឿងដែលខ្ញុំមិនអាចបំភ្លេចបានទេនៅក្នុងជីវិត ។ រយៈពេល៤ថ្ងៃក្រោយមក ទើបមានអ្នកសែងយកសពរបស់គាត់ទៅកប់ក្នុងរណ្តៅរួម ។ ចាប់តាំងពីនោះមក ខ្ញុំត្រូវរស់នៅតែម្នាក់ឯង ។

នៅចុងឆ្នាំ១៩៧៨ សភាពការណ៍ចាប់ផ្តើមច្របូកច្របល់ដោយយោធាខ្មែរក្រហមជាមួយនឹងអ្នកមូលដ្ឋានចាស់ពុំទុកចិត្តគ្នា ទម្លាក់កំហុសដាក់គ្នាថាក្បត់នឹងអង្គការ ឬចោទថាជាមេខ្លោងក្បត់ ។ ហេតុការណ៍នេះធ្វើឲ្យមានការចាប់ចងសម្លាប់ជារៀងរាល់ថ្ងៃនិងធ្វើឲ្យអ្នក១៧មេសាមានអារម្មណ៍កាន់តែបាក់ស្បាត ។

ពួកពាយ័ព្យស្រាវជ្រាវរកពួកបូព៌ាទៅសម្លាប់ ក្រោយមកពួកនិរតីចាប់ពួកពាយ័ព្យយកទៅសម្លាប់វិញ ដែលវាបានកើតឡើងនៅចម្ងាយប្រហែលជា៥០០ម៉ែត្រប៉ុណ្ណោះពីរោងដាំបាយរបស់សហករណ៍ ហៅថាសាលាសម្ងាត់ ។

ខ្មែរក្រហមបានយកគ្រួសារគណៈតំបន់ឈ្មោះ ឈឿប ប្រពន្ធឈ្មោះ ង៉ែត កូនស្រីឈ្មោះ ឈឿត និងប្តី និងអ្នកផ្សេងទៀតដែលខ្ញុំចាំមិនអស់ទេ យកទៅសម្លាប់នៅសាលាសម្ងាត់នេះ ។ កូនប្រសារប្រុសគណៈតំបន់ត្រូវឆ្លូតនឹងសំបកដបឲ្យឆ្លើយសារភាពថាជាកាហ្សេបេឬសេអ៊ីអារបស់ចក្រពត្តិអាមេរិក ឯសមមិត្តនារីឈ្មោះ ញាញ់ មានតួនាទីធ្វើពេទ្យត្រូវពួកយោធានិរតីចាប់ក្បាលសំយ៉ុងទៅក្នុងរណ្តៅ រួចលប់ដីកប់ទាំងរស់នៅសល់ត្រឹមជង្គង់ ។ ខ្ញុំឈរមើលដើងមិត្ត ញាញ់ កន្រ្តាក់យ៉ាងយូរទើបឈប់ ។ វិធីមួយទៀត គឺជញ្ជូនស្រូវយកទៅកប់នៅចាមរអា ដោយអ្នកដែលទៅពុំមានវត្តមានមកវិញឡើយ ។

ថ្ងៃមួយ គណៈយោធាឈ្មោះ យ៉ាត មានប្រពន្ធឈ្មោះ គុយ ដែលកំពុងមានផ្ទៃពោះជិតគ្រប់ខែបានហៅខ្ញុំឲ្យទៅប្របាច់ជើងនិងបង្កេះគាត់ ។ ពេលនោះ ខ្ញុំឃើញ គុយ យករបាយការណ៍កម្មុចខ្មាំងពីនិរសារម្នាក់ពាក់ឯកសណ្ឋានឈុតខ្មៅ ឆ្នូតក្បាលកន្សែងក្រហមជិះសេះមកពីសហករណ៍វត្តចាស់ តាលាស់ ដូនទ្រី ក្អែកខ្ញុំ សាលាក្រៅ អូរគាមាវ មកធ្វើការបូកសរុបដើម្បីរាយការណ៍ទៅថ្នាក់លើ ។ ក្នុងនោះមាន ◆ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៨ នៅវត្តចាស់ កម្មុច១៥នាក់ ◆ ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៨ នៃក្អែកខ្ញុំ កម្មុច៣២នាក់ (ល្អណាស់) ◆ សរុប កម្មុច ៤៧នាក់ ។

អ្នកដែលកម្មុចខ្មាំងបានតិចត្រូវអង្គការប្រជុំទិទៀនថានៅមានអារម្មណ៍ស្ទាក់ស្ទើរ ស្នើបង្កើនការកម្មុចខ្មាំងបន្ថែមមួយកម្រិតទៀតទើបអង្គការមានកម្លាំងឈ្នះពួកចក្រពត្តិ ។

ខ្ញុំអាចឃើញរបាយការណ៍ទាំងនេះបាន គឺដោយសារ គុយ ឲ្យខ្ញុំសម្រាកក្រោមផ្ទះរបស់គាត់នៅពេលយប់ និងពេលថ្ងៃឲ្យខ្ញុំបោសសម្អាតនៅលើផ្ទះ ។ នៅពេលបានដឹង ខ្ញុំខ្លាចណាស់ ខ្ញុំបានសុំ គុយ ត្រឡប់ទៅនៅកងកុមាររើសដីវិញ ។ គុយ និង យ៉ាត ក៏ពុំថាអ្វីដែរ គ្រាន់តែផ្តាំថា ថ្ងៃណាមកលេងក៏បាន បើចង់មក ។

មិនយូរប៉ុន្មាន ពួកយោធាខ្មែរក្រហមដែលបាក់ទ័ពក៏នាំគ្នារត់គេចខ្លួន ។ ពេលនោះ ពូ ចំរើន ជាអតីតយោធាគិតថា យើងល្មមរកឱកាសគេចខ្លួនហើយ កុំបន្តដំណើរជាមួយពួកវាទៀត ប្រយ័ត្នវាសម្លាប់អស់ ភ្នំពេញ សៀមរាប បានសប្បាយអស់ហើយ យើងបកក្រោយវិញ ។

ក្រោយពីការគិតចប់ យើងទាំង១៣នាក់ក៏លើកដៃបួងសួងដល់ទេវតារក្សាភ្នំជួយបំបាំងពួកយើងឲ្យឆ្លងផុតពីការស្លាប់ និងការដេញតាមរបស់ខ្មែរក្រហម ។ ពិតជាព្រះតាមជួយ យើងបានធ្វើដំណើរទាំងភ័យខ្លាចរហូតដល់បានជួបមីងម្នាក់ឈ្មោះ គង់ ធ្លាប់រស់នៅក្នុងសហករណ៍ជាមួយខ្ញុំដែរ បានបក់ដៃឲ្យពួកយើងចូលពួន ។ យើងទាំងអស់គ្នាសំណាងណាស់ ព្រោះមិនបានជួបកងទ័ពខ្មែរក្រហម ។

យើងធ្វើដំណើរដល់ថ្នល់ជាតិ រួចបន្តដំណើររហូតដល់ស្វាយអាត់ មិនយូរប៉ុន្មានក៏បានមកដល់ក្រុងភ្នំពេញនៅវេលាម៉ោង៩កន្លះព្រឹក ។ បន្ទាប់មក យើងទាំងអស់គ្នាក៏បំបែកគ្នាត្រឡប់ទៅកាន់ស្រុកកំណើតវិញ ។ ខ្ញុំធ្វើដំណើរបណ្តើរគិតបណ្តើរថា ថ្ងៃ១៧ មេសា ពេលជម្លៀសចេញទៅមានគ្នា៣៥នាក់ ចុះថ្ងៃ៧ មករា ហេតុអ្វីរូបខ្ញុំត្រឡប់មកវិញតែម្នាក់ឯង? ។

ដើរតាមផ្លូវ កងទ័ពវៀតណាមឃើញខ្ញុំក៏អាណិតខ្ញុំ និងបានឲ្យបាយនិងកន្ទេលសម្រាកសមរម្យ ។ វៀតណាមនោះនិយាយខ្មែរមិនច្បាស់ទេ ដោយបានស្នើឲ្យខ្ញុំនៅជួយចែកថ្នាំដល់ប្រជាជនដែលមានជំងឺពុំរីដល់យោធាខ្មែរក្រហម ។ ប៉ុន្តែ ខ្ញុំបានបដិសេធសុំលាទៅតាខ្មៅវិញ ។ មកដល់ភូមិកំពង់សំណាញ់ ស្រាប់តែខ្ញុំរន្ធត់ផង ព្រោះផ្ទះខ្ញុំត្រូវខ្មែរក្រហមរុះរើក្លាយទៅជារណ្តៅកប់ខ្មោច ព្រមទាំងនៅមានក្លិនស្អុយនៅឡើយ ។ ខ្ញុំក៏ដើរប្រមូលវត្ថុសេសសល់មួយចំនួនទុក ដូចជាការបូបរបស់ប៉ា ស្បែកជើងម៉ែ និងរូបថតដែលនៅសេសដល់លើដីមួយចំនួន ។ ខ្ញុំអង្គុយឱបវត្ថុទាំងនោះពុំនិយាយអ្វីទាំងអស់ ។

ចុងក្រោយ ខ្ញុំសំណូមពរឲ្យសាលាក្តីខ្មែរក្រហមបន្តការកាត់ក្តីតទៅទៀត ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ក៏ដូចជាអ្នកដែលស្លាប់យ៉ាងអយុត្តិធម៌ ព្រមទាំងទុកជាប្រវត្តិសាស្រ្តដើម្បីកុំឲ្យរបបនេះកើតឡើងសាជាថ្មីម្តងទៀត ។

**ស្វាយ ខ៉ាន់ថន**

# សេចក្តីប្រកាសរកបងប្រុសឈ្មោះ មាស ពន្លក

*នាងខ្ញុំឈ្មោះ ស្វាយ វ៉ាន់ថង រស់នៅស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ស្វាយ សារិន (ស្លាប់) ធ្វើពេទ្យ ម្តាយឈ្មោះ ឌី យ៉ាត (ស្លាប់) ស្រុកកំណើតនៅក្នុងភូមិកំពង់សំណាញ់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សូមសួររកបងប្រុសឈ្មោះ មាស ពន្លក ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៥ ។ មុនពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ពន្លក ធ្វើជាទាហានលន់ នល់ ឈរជើងនៅក្នុងខេត្តពោធិ៍សាត់ ។*

*ប្រសិនបើបងបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងមកខ្ញុំតាមរយៈទូរសព្ទលេខ ០៩២ ៦៩៩ ០៣៨ ។*

# សេចក្តីប្រកាសរកក្មួយស្រី

*ខ្ញុំបាទឈ្មោះ ដេង យិុន រស់នៅភូមិរំលេច ឃុំរលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ សូមសួររកក្មួយស្រីឈ្មោះ ដេង យ៉ានីណា មានឪពុកឈ្មោះ ដេង យ៉ាន និងម្តាយឈ្មោះ ឡាយ អ៊ិន ។ មុនឆ្នាំ១៩៧៥ គ្រួសារ យ៉ាន ធ្វើការនៅ IRCC ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម នៅគីឡូម៉ែត្រលេខ២ ក្បែរព្រលានយន្តហោះ ក្រោយមក គាត់បានផ្លាស់ទីលំនៅមកនៅខាងជើងស្ពានចាស់ ។*

*ក្រោយពីខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ ខ្ញុំឮដំណឹងថា យ៉ានីណា រស់នៅខេត្តតាកែវ តែក្រោយមកមិនដឹងទៅរស់នៅទីកន្លែងណាទៀត ។ នៅឆ្នាំ១៩៨០ មានគេមកប្រាប់ថាក្មួយរបស់ខ្ញុំឈ្មោះ យ៉ានីណា រស់នៅពាមជីកង ។*

*សព្វថ្ងៃប្រសិនបើក្មួយស្រី ឬបងប្អូនណាបានឮ ឬបានស្គាល់ សូមទំនាក់ទំនងខ្ញុំឈ្មោះ ដេង យិុន រស់នៅភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ តាមរយៈទូរស័ព្ទលេខ ០១២ ៩៣១ ៩៨៥ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមអរគុណ ។*

# ដំណឹងសួររកសមាជិកគ្រួសារ

*នាងខ្ញុំឈ្មោះ គុំ ស៊ីសុផុន សព្វថ្ងៃរស់នៅបរទេស សូមសួររកសមាជិកគ្រួសារដែលបានបាត់ខ្លួនកាលពីរបបប៉ុល ពត ១)ឪពុកឈ្មោះ គុំ ឈុន ២)ម្តាយ ប៉ែន ស៊ុក ៣)បងស្រី គុំ សារឿន ៤)បងស្រី គុំ សាលី និង៥)ក្មួយប្រុស ឈុន ខេមរិន ។ ដំបូង អ្នកទាំងអស់នេះរស់នៅទីក្រុងភ្នំពេញ ក្រោយមកក៏ត្រូវកងទ័ពខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅជនបទ ។ នៅចុងឆ្នាំ១៩៨៩ មិត្តភក្តិរបស់ខ្ញុំដែលបានមកជួបខ្ញុំបានប្រាប់ខ្ញុំថា នៅក្នុងរបបខ្មែរក្រហម ឪពុកម្តាយនិងបងស្រីទាំងពីររបស់ខ្ញុំរស់នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ ចំណែកបងប្រុសឈ្មោះ គុំ សុខាយ ប្រពន្ធ ឃួន សុខខែម និងក្មួយប្រុស ឈុន ខេមរិន ត្រូវបានជម្លៀសទៅរស់នៅឃុំអូរដំបងមួយ ស្រុកសង្កែ ខេត្តបាត់ដំបង ក្រោយមកអ្នកទាំងពីរត្រូវខ្មែរក្រហមយកទៅសម្លាប់បាត់ ។ ចំណែក ខេមរិន ខ្ញុំបានឮដំណឹងពីអ្នកដែលបានឃើញផ្ទាល់ភ្នែកថា ខេមរិន ត្រូវបានអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលប្រតិបត្តិការនៅជំរំជនភៀសខ្លួនគោកធ្លូងជួយសង្គ្រោះ ។ ក្រោយមកបាត់ដំណឹងនេះរហូត ។*

*បើសិនបងប្អូនបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងមកនាងខ្ញុំតាមរយៈទូរសព្ទលេខ ០២៣ ៥៣០ ៣៨៤ ឬ អ៊ីម៉ែលៈ ptborey@gmail.com*






ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 104, August 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.